
Love Series
Publishing
18+
www.srolanhkhmer.com
មន្តអាគម
ល្បិចស្នេហ៍
អ្វីដែលមេក្រុមកំលោះចង់បានពីនាងជាងព្រហ្មចារី គឺសេចក្តីស្រឡាញ់
ដែលមិនមែនជាមន្តមារ។



## ...១...

## អំណាចមន្តស្រា

កែវភ្នែកមួយគូដ៏ស្រស់ស្អាត ដែលពោរពេញដោយភាពភ័យខ្លាច កំពុងសម្លឹងមើលទៅកាន់ផ្ទៃមេឃនាពេលរាត្រីព្រះច័ន្ទពេញវង់។ ដោយសារតែពន្លឺនៃព្រះច័ន្ទនោះបានបង្ហាញឲ្យឃើញថា កែវភ្នែកនោះមាន ពណ៌ក្រហមដ៏គួរឲ្យខ្លាច។ សំឡេងឆ្កែព្រៃព្រុស វូសៗ បន្តកន្ទុយគ្នា។ បាតជើងទាំងពីររបស់នារីម្នាក់នេះឈានដើរទៅក្នុងព្រៃស្ងាត់នោះ ដើម្បីរកផ្លូវចេញ ទាំងអារម្មណ៍ភិតភ័យជាខ្លាំងចំពោះភាពងងឹតស្ងប់ស្ងាត់នាពេលនោះ។

«នេះវាស្អីគេទៀត ហេតុអីក៏គួរឲ្យខ្លាចយ៉ាងនេះ!»

នាងដើរផងរត់ផងព្រមទាំងងាកក្រោយមើលឆ្វេងមើលស្តាំ រំពេចនោះកែវភ្នែកមួយគូនោះ បានក្រឡេកទៅឃើញមានសេតវិមានមួយខ្នងយ៉ាងធំមហិមាដែលតាំងនៅចំពោះមុខនាង។ នាងឈានជើងដើរចូលទៅកាន់សេតវិមានដ៏ធំដែលតាំងនៅចំពោះមុខនោះភ្លាម ហើយរូបភាពនោះក៏បានច្បាស់ទៅៗជាងមុនក្នុងកែវភ្នែករបស់នាង ព្រមជាមួយគ្នានោះទ្វារផ្ទះក៏របើកចេញមក។

**គ្រែគគគគគ**!!!

ពេលនោះភ្នែកនាងបានឃើញទ្វារនោះបើកចេញមក រាងស្តើងតូចនោះក៏ដើរចូលទៅយ៉ាងយឺតៗ នាងដើរទៅតាមផ្លូវទ្វារដែលបើកចេញព្រមទាំងមានកម្រាលព្រំពណ៌ក្រហមយ៉ាងវែងអន្លាយ ជើងទាំងទ្វេរបស់នាងដើរត្រឹកៗតាមព្រំនោះ រហូតទៅកាន់បន្ទប់ធំមួយដោយមិនដឹងខ្លួន សំឡេងទ្រហឹងអឺងកងក៏លាន់ឮឡើងក្នុងប្រសាទរបស់នាង។

**"រាងកាយរូបវិញ្ញាណរបស់នាងជារបស់យើង ហាស ហាស ហាស..."**

នារីនោះស្លុតចិត្តសាជាថ្មីនៅពេលដែលមានមនុស្សប្រុសម្នាក់ បានលូកដៃរបស់គេមកកៀកដៃរបស់នាងហើយបណ្តើរនាងទៅ។ នាងក៏ងើបមុខឡើងមើលម្ចាស់ដៃដែលចូលមកកៀកនោះភ្លាម។ នាងកើតមានអារម្មណ៍ប្រហោងពោះចំពោះផ្ទៃមុខមនុស្សដែលលូកដៃចូលមកនោះ។

រំពេចនោះបបូរមាត់របស់គេបានប្រថាប់មកលើបបូរមាត់របស់នាង នាងមើលទៅកាន់ផ្ទៃមុខរបស់គេដែលបានបញ្ចេញស្នាមញញឹម និងមន្តស្នេហ៍បញ្ជាក់យ៉ាងច្បាស់តែម្តង។ នាងបានបិទភ្នែកត្រឹមៗនៅពេលដែលបានទទួលរសជាតិនៃបបូរមាត់គេនោះ។

«កុំ...កុំ...ទេ...ទេ...»

«បង យ៉ុនហ៊ី! បង យ៉ុនហ៊ី!"

សំឡេងស្រែកហៅ ព្រមទាំងអង្រួនប្រាណយ៉ាងញ័រទទ្រើក ដោយអារម្មណ៍ភ័យស្លន់ស្លោរបស់ប្អូនស្រីឈ្មោះ យ៉ុនអា។ ប្អូនស្រីរបស់នាងធ្វើខ្លួនពាក់កណ្តាលប្រុសពាក់កណ្តាលស្រីគេងនៅក្បែរនោះ លូកដៃទៅចុចបើកភ្លើងនៅក្បាលដំណេកឲ្យភ្លឺ មុននឹងបែរមកមើលបងស្រីរបស់នាងដែលកំពុងតែបែក

ញើសពេញខ្លួន។

«យ៉ុនអា ទេ ?»

«គឺខ្ញុំហ្នឹងហើយ ចុះបងគិតថា ជាអ្នកណាគេដែរទៅ ហើយបងកើតអីបានជាបែកញើសជោកខ្លួនបែបហ្នឹង ?»

យ៉ុនអា សម្លឹងមើលមុខបងស្រីដែលពេលនេះហាក់បីដូចជាទើបតែរត់គេចគ្រាប់កាំភ្លើងមកពីទីណាអីចឹងក្រសែភ្នែកកំពុងតែគិតនិងរំឭកហេតុការណ៍ទាំងឡាយដែលនាងយល់សប្តិនោះ ទោះបីជាបងស្រីនាងមិនទាន់បានប្រាប់ថា មានអីកើតឡើងក៏ដោយចុះ ក៏នាងអាចយល់បានដែរថា គាត់យល់សប្តិពីអីនោះ។

«បង យ៉ុនហ៊ី គេងយល់សប្តិអាក្រក់ទៀតហើយមែនទេ បានជាស្រែកយ៉ាងស្លុតអារម្មណ៍បែបនេះនោះបង!»

«មែនហើយ បងយល់សប្តិប្លែកៗទៀតហើយណា»

«ហេ!!! បងញ៉ាំអីច្រើនពេកមុនគេងទេដឹង ?»

«បងគិតថា វាមិនមានអីពាក់ព័ន្ធនឹងការញ៉ាំតិច ឬច្រើននោះទេណា បងបានគេងយល់សប្តិបែបនេះជាច្រើនដងហើយណា» នាងព្រមទាំងបាននិយាយរៀបរាប់ប្រាប់ដល់ប្អូនស្រីបណ្ដើរផងដែរ។

«អឺ!!! វាជាការចម្លែកដែរហ្នឹងណាបង»

«អឺមមម!! នេះបងខំមកគេងជាមួយឯងហើយណា តែអាយល់សប្តិនោះនៅតែមកតាមរកបងទៀត»

យ៉ុនហ៊ី បាននឹកគិតដល់ហេតុការណ៍ព្រមទាំងបរិយាកាសដែលដូចេះបិទក្នុងសុបិនរបស់នាង តើវាជាលើកទីប៉ុន្មានហើយទៀកដែលនាងបានយល់សប្តិបែបនេះ! មនុស្សស្រីដែលនិយាយជាមួយនោះជាអ្នកណាគេដែរទៅ? ណា មួយអាបុរសម្នាក់ ដែលបានព្យាយាមប្រគល់រសជាតិស្នេហាមកឲ្យនាងនោះទៀត តើពួកគេជាអ្នកណាដែរទៅហ្ន!!

«បើអីចឹងបងគួរណាតែទៅឲ្យគ្រូមើលល្អជាងណាបង»



«រកគ្រូដែលព្យាបាលយល់សប្តិនេះនោះឬ ?»

«វាមិនមែនដូចបងនិយាយនោះទេណា គឺពេទ្យចិត្តសាស្ត្រនោះណា»

«នែ!! យ៉ុនអា ឯងថា បងឆ្កួតមែនដែរទេហ្នឹង ?»

«មិនមែនទេ មិនមែនទេបង ចេះតែនិយាយហ្នឹង!! អ្នកណាៗក៏គេនាំគ្នាទៅមើលពេទ្យចិត្តសាស្ត្រដែរណាបង សម័យនេះទៅហើយណា មិនចាំបាច់តែឆ្កួតចាំទៅនោះទេណាបង»

«បងថា ឯងហ្នឹងហើយដែលគួរតែទៅរកពេទ្យចិត្តសាស្ត្រនោះណាអាខ្វើយ!!»

«យើស!!! ដូចខ្ញុំនេះ ធ្វើជាខ្វើយវាប្រសើរហើយណាបង មិនចេះឈឺក្បាលរឿងប្រុសៗផងដែរ គេងវិញល្អជាង!!! អំ!!! មិនចាំបាច់គិតអីច្រើនពេកនោះទេណាបង ប្រយ័ត្នឆ្កួតមែនទែនទៅ!!!»

ឬក៏ពិតដូចដែលប្អូនស្រីនាងនិយាយពិតមែនទេដឹង យ៉ុនហ៊ី គិត នាងអាចមានអ្វីដែលខុសប្រក្រតីចំពោះសរសៃប្រសាទក៏អាចថាបានដែរ។ នាងបានជៀងភ្នែកមើលទៅកាន់ប្អូនស្រីដែលដាក់ខ្លួនគេងលក់យ៉ាងងាយនោះ ព្រមទាំងគិតថា តើមានរឿងអីកើតឡើងចំពោះនាងដែរទៅក្នុងកំឡុងប៉ុន្មានខែមកនេះ នាងបានយល់សប្តិបែបនេះដដែលៗ ប្រៀបបីដូចឃើញពិតៗអីចឹងឯងណា ?។

ថ្ងៃថ្មីបានឈានចូលមកដល់ គ្រប់យ៉ាងក៏ត្រូវដំណើរការដូចសព្វដងអីចឹងដែរ តែថ្ងៃនេះជាថ្ងៃដែលប្រញាប់ប្រញាល់បំផុតសម្រាប់ យ៉ុនហ៊ី យកតែមែនទែនហើយ ព្រោះថា នាងមានម៉ោងរៀននៅពេលព្រឹក តែនាងបែរជាក្រោកយឺតតែម្តង។ រូបរាងស្ដើងនោះដើរកាត់តុញ៉ាំបាយដែលមានប្អូនស្រីនៅអង្គុយចាំទីនោះ តែនាងបែរជាមិនចាប់អារម្មណ៍លើប្អូនស្រីព្រមជាមួយនឹងអាហារដ៏គួរឲ្យចង់ញ៉ាំនៅលើតុនោះទាល់តែសោះឡើយ។

«បង យ៉ុនហ៊ី មិនញ៉ាំអីសិនទេអីបង ?»

«អត់ទេ បងប្រញាប់ទៅណាស់!!!»

«មិនចាំបាច់ប្រញាប់ទេបង ទោះបីជាប្រញាប់យ៉ាងណាក៏នៅតែយឺតដដែលនោះណាបង»

«អាក!! ឯងនេះ គិតតែពីនាំនិយាយមិនឈប់បែបនេះ កាន់តែយឺតហ្នឹងឯង និយាយពីឯងវិញ ថ្ងៃនេះព្រែងទៅកុយវិញមិនអីចឹងអី?»

«ត្រូវហើយ អីចឹងបានជាខ្ញុំនៅចាំបងឯងនោះណា»

«ចាំបងធ្វើអីទៅ បងមិនបានទៅវិញជាមួយឯងទេណាអូន!!»

«ហើយចុះបងនឹងទៅវិញថ្ងៃណាដែរទៅ បើសិនជាអ្នកម៉ាក់សួរអាងប្រាប់គាត់ត្រូវនោះណាបង!!»

មែនហ្នឹងណា មហាវិទ្យាល័យជិតដល់ថ្ងៃវិស្សមកាលធំហើយនោះណា ហើយនាងក៏រៀនចប់ក្នុងវគ្គនេះផងដែរ បន្ទាប់មកប្រហែលជាត្រូវត្រឡប់ទៅសម្រាកកាយនៅកុយវិញសិន មុននឹងចាប់ផ្តើមធ្វើអ្វីដែលស្រឡាញ់ គឺការស្វែងរកបុរាណប្រវត្តិនោះណា តែអ្វីដែលសំខាន់សម្រាប់នាងនៅពេលនេះគឺ ត្រូវតែចុះស្រាវជ្រាវនៅចុងវគ្គសិក្សានេះឲ្យបានចប់ជាស្ថាពរសិន។

«អូនឯងប្រាប់ទៅអ្នកម៉ាក់ទៅថា បងត្រូវនៅចាំធ្វើការនៅវគ្គចុងក្រោយឲ្យចប់សព្វគ្រប់ជូនសាលាសិនណា ត្រូវទៅពេលណាចាំបងទូរស័ព្ទប្រាប់គាត់មុនណាអូន!!»

«គ្រាន់តែប៉ុណ្ណឹងទេដែលខ្ញុំចង់ដឹង បងទៅចុះបង!»

យ៉ុនហ៊ឺ មានអារម្មណ៍ថា ទាស់ចិត្តចំពោះប្អូនស្រីដែលមានចរិតឫកពាជាប្រុសៗនេះដល់ហើយ និយាយស្តីក៏កំបុតៗ តែងខ្លួនវិញប្លែកៗ មុខមាត់ក៏ស្អាតបាតដែរតែហេតុអីក៏ចូលចិត្តធ្វើជាប្រុសបែបនេះទៅវិញហ្ន!! បងស្រីដូចជានាងត្រូវតែនិយាយរណបដដែល។

«ឯងមិនអាណិតអ្នកម៉ាក់ខ្លះទេអី តែងខ្លួនធ្វើបាបចិត្តគាត់បែបហ្នឹងនោះអូន!»

«នែបង!! គ្រាន់តែតែងខ្លួនបែបហ្នឹង តែចិត្តមិនមែនអីចឹងឯណា»



«តែងក៏តែង បណ្តើរកៀកកិតតែមិត្តភក្តិស្រីៗទៀតនោះណា បងក៏ធ្លាប់ឃើញដែរ»

«អាក!!! ឬក៏បងចង់ឲ្យខ្ញុំបណ្តើរមនុស្សប្រុសវិញ?»

ពិតដូចដែលប្អូនស្រីនាងនិយាយពិតមែនដែរ តែទោះជាយ៉ាងណាក៏ដោយ ក៏នាងមិនចូលចិត្តចរិតឫកពារបស់ប្អូនស្រីនាងដដែលនោះណា នាងគិតហើយក៏ប្រញាប់ទៅមហាវិទ្យាល័យឲ្យបានលឿនជាទីបំផុត តាមដែលអាចធ្វើទៅបានកែវភ្នែកមួយគូដ៏ស្រស់ត្រកាលនោះ ងើយមើលទៅកាន់អាគារដែលមានច្រើនជាន់ក្នុងទីក្រុង ខេ។ ពេលនេះមានសិស្សសាលាដើរទៅមកយ៉ាងខ្វាត់ខ្វែងពេញបរិវេណសាលារៀន យ៉ុនហ៊ឺ ប្រញាប់ប្រញាល់ឱបសៀវភៅនៅនឹងដើមទ្រូងរបស់នាងយ៉ាងណែន។ នាងដើរបណ្តើររត់បណ្តើរព្រមទាំងលើកដៃមើលម៉ោង ហើយក៏មិនភ្លេចឧទានចេញមកនោះដែរ។

«អូ! ស្លាប់ហើយ!!! នេះខ្ញុំមកយឺតជាងកន្លះម៉ោងហើយតើ!»

មិនមានអីត្រូវគិតច្រើនទៀតនោះឡើយ ក្មេងរៀនសូត្រដូចជានាងប្រញាប់រត់ឲ្យលឿនបំផុតសំដៅទៅកាន់បន្ទប់រៀន គឺមកពីការយល់សប្តិនោះឯងបានធ្វើឲ្យនាងក្រោកទាំងកណ្តាលយប់ ហើយក្រោកយឺតនៅពេលព្រឹកទៅវិញ ធ្វើឲ្យនាងមកយឺតដូចពេលនេះ។ សំឡេងដ៏ស្រួយស្រែសក៏និយាយឡើងនៅពេលបានស្វែងរកថ្នាក់រៀនឃើញ។

«សុំទោសលោកសាស្ត្រាចារ្យ!»

គ្រប់ក្រសែភ្នែកនៃពួកសិស្សសាលាជាច្រើន ដែលនៅក្នុងថ្នាក់រៀនបានសម្លឹងមកកាន់នាងតែម្នាក់គត់ រួមជាមួយនឹងលោកគ្រូ ហារីហាស់ ដែលកំពុងតែបង្រៀនមុខវិជ្ជាបុរាណប្រវត្តិនោះផងដែរ គាត់សម្លឹងទៅកាន់សិស្សស្រីដែលកំពុងតែរត់យ៉ាងត្រហេបត្រហបមកនោះ ទោះបីជាមិនពេញចិត្ត តែលោកក៏ដឹងច្បាស់ណាស់ថា សិស្សស្រីមួយរូបនេះពិតជាស្វះស្វែងរៀនសូត្រណាស់ប្រហែលជាមិនមានចេតនាមកយឺតនោះទេ។ គ្រូដ៏ល្អដូចជាគាត់ក៏ជ្រើសរើសបន្តការបង្រៀនទៀត ហើយក៏ប្រហែលជាត្រូវប្រាប់រឿងសំខាន់ដល់និស្សិតដូចជានាង

បានដឹង។

«ប្រហែលជានៅសល់តែប្អូនម្នាក់ហើយទេដឹង យ៉ុនហ៊ី ដែលនៅមិនទាន់បានជ្រើសរើសប្រធានបទ»

វាត្រូវតែបែបនេះហើយ ព្រោះដោយនាងមកយឺតដល់ថ្នាក់ហ្នឹង នៅមានអ្នកណាផ្សេងទៀតឬ? នាងក្រឡេកភ្នែកមើលទៅកាន់មិត្តរួមថ្នាក់ផ្សេងៗ ដើម្បីបញ្ជាក់ពីការគិតរបស់នាងសាជាថ្មី។

«ប្រធានបទលើកនេះឬលោកសាស្ត្រាចារ្យ!»

«ត្រូវហើយ! ហើយក៏នៅសល់តែប្រធានបទតែមួយនោះផងដែរ»

ហើយថា!! ប្រធានបទតែមួយសម្រាប់នាងវាសក្តិសមហើយ នាងបានចាប់អារម្មណ៍ចំពោះប្រធានបទដែលនាងនឹងត្រូវសរសេរសារណា ហើយតាំងចិត្តស្វ័យសិក្សាដូចសិស្សដទៃដែលខំប្រឹងប្រែងរៀនសូត្រដូចជានាងនេះដែរ។

លោកសាស្ត្រាចារ្យ បង្ហាញការសិក្សាទាំងឡាយនៅលើក្តារខៀនជាបន្តបន្ទាប់ដែលជាវត្ថុបុរាណ មានទាំងខ្សែកបុរាណដែលមានលក្ខណៈជាបន្តោងគ្រីស្តាល់ កងដៃ គ្រឿងប្រដាប់សម្រាប់ពាក់នៅលើក្បាល គ្រឿងប្រដាប់ដៃពាក់នៅត្រង់ដើមដៃ។ តែអ្វីដែល យ៉ុនហ៊ី ចាប់អារម្មណ៍បំផុតនោះគឺ បន្តោងខ្សែកដែលមានរូបសត្វត្រដាងស្លាបមានភាពកោងជារូបបេះដូង វាដូចនឹងបន្តោងដែលនាងកំពុងតែពាក់នៅនឹងករបស់នាងនោះណា!

រំពេចនោះសំឡេងរដាក់រដុបក៏លាន់ឮឡើងចេញពីមាត់របស់នាង

«លោកសាស្ត្រាចារ្យ បន់... បន្តោង នោះមានតែមួយទេ មែនទេលោកសាស្ត្រាចារ្យ?»

«អ្វីដែលប្អូនបានឃើញក្នុងការដាក់បង្ហាញនោះ គឺតែមួយឈុតទេណា ជាគ្រឿងប្រដាប់របស់ព្រះនាង ទេមីន ហើយប្អូនត្រូវតែស្វែងរកសេចក្តីលម្អិតសរុបមកសរសេរជាសារណាឲ្យខ្ញុំ រួចត្រូវអធិប្បាយប្តូរចំណេះដឹងផ្សេងៗទៀតជាមួយនឹងមិត្តភក្តិរួមថ្នាក់ផងដែរណា យ៉ុនហ៊ី!!!»

«យ៉ាងណាដែរទៅលោកសាស្ត្រាចារ្យ?»



«បើសិនជាប្អូនចង់ដឹង ត្រូវតែទៅនិយាយគ្នាជាមួយលោកគ្រូបន្ថែមទៀត តែពេលនេះជាពេលសម្រាប់សិស្សផ្សេងៗរៀនសូត្របន្តណា»

នាងត្រូវអង្គុយស្តាប់លោកគ្រូបង្ហាត់បង្រៀនបន្ត ព្រោះនាងមកយឺតដោយខ្លួនឯង នេះជារឿងធម្មតាទេ ហើយនាងគិតថា នេះជាខែដន្យមួយហើយដែលមានរូបបន្តោងខ្សែកដែលមានភាពដូចគ្នានឹងបណ្តោងខ្សែករបស់នាង ឬក៏គេធ្វើម៉ូតតាមក៏ថាបាន ព្រោះថាគ្រឿងប្រដាប់ទាំងឡាយនោះជាគ្រឿងប្រដាប់របស់ព្រះនាង ទេមីន ដែលជាព្រះរាជវង្ស តើម៉េចហ្នឹងអាចមកនៅជាមួយនាងបានដែរទៅ! រំពេចនោះសំឡេងរបស់មិត្តភក្តិប្រុសដែលអង្គុយក្បែរនោះក៏និយាយលួងចិត្តនាងឡើងនៅពេលឃើញមុខនាងដូចជាសញ្ជឹងគិតអ្វីម្យ៉ាងនោះ។

«យ៉ុនហ៊ី ប្រធានបទរបស់ខ្ញុំនេះវាសាហាវជាងប្រធានបទរបស់នាងទៀតឯណោះណា»

«តើជាប្រធានបទអីដែរទៅ ចាម!!»

«គឺខ្ញុំបានប៉ះប្រធានបទដែលទាក់ទងជាមួយនឹងព្រះរាជមឈូសមាសរបស់ព្រះអង្គម្ចាស់ ហ្សាំ នោះណា»

មែនហ្នឹងណា! យ៉ុនហ៊ី គិត ព្រោះនាងជាមនុស្សដែលខ្លាចខ្មោចជាទីបំផុតនោះណា បានធ្វើប្រធានបទដែលទាក់ទងជាមួយនឹងគ្រឿងប្រដាប់របស់ព្រះនាង ទេមីន នោះជាការប្រសើរបំផុតហើយ ប្រសើរជាងទៅធ្វើប្រធានបទដែលទាក់ទងនឹងព្រះរាជមឈូសស្តេចទៅទៀតណា។

យ៉ុនហ៊ី បាននឹកដល់ដើមកំណើតនៃសត្វស្លាបដែលទទះស្លាបមានរាងជារូបបេះដូងពីមនុស្សស្រីតែលតោលម្នាក់នោះភ្លាម។ មានម្តងនោះលោកប៉ានាងឲ្យនាងជួយនាំភ្ញៀវក្នុងក្រុមហ៊ុនទេសចរណ៍របស់គាត់ដែលធ្វើដំណើរទៅទស្សនកិច្ចនៅរមណីយដ្ឋាន ហ្សូរ កាលពីពីរឆ្នាំមុននោះ។ នៅពេលដែលភ្ញៀវទេសចរណ៍កំពុងតែសម្រាកញ៉ាំអាហារដែលខាងក្រុមហ៊ុនបានរៀបចំនោះ ទើបនាងបានដើរលេងៗក្នុងបរិវេណដែលនាងធ្លាប់ស្គាល់ច្បាស់ តែនៅថ្ងៃនោះនាងបែរជាវង្វេងផ្លូវទៅវិញ ពេលនោះហើយដែលធ្វើឲ្យនាងបានទៅជួបមនុស្សស្រី

ជនជាតិអ៊ីស្លាមម្នាក់។

«នៅទីបំផុតខ្ញុំក៏បានជួបនាង យ៉ុនហ៊ី!!!»

«ស្គាល់ខ្ញុំដែរ?»

មនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះ បានសើចយ៉ាងក្អាកក្អាយជំនួសការឆ្លើយតបរបស់នាង។ ទោះបីជានាងហាក់បីដូចជាមានអារម្មណ៍ថា ចម្លែកៗចំពោះពាក្យសម្ដីរបស់នារីនោះក៏ដោយចុះ តែនាងគិតថា គាត់ស្គាល់នាងព្រោះតែនាងឧស្សាហ៍នាំភ្ញៀវ មកទស្សនាក្នុងរមណីយដ្ឋានមួយនេះហើយមើលទៅនោះ ហើយឈ្មោះរបស់ក្រុមហ៊ុនលោកប៉ានាងដែលដាក់ឈ្មោះនោះ គឺដាក់ថា យ៉ុនហ៊ី ទៀតផង។

«ដល់ពេលហើយមែនទេ?»

«ដល់ពេលអីដែរទៅ?»

«ពេលដែលត្រូវលាងបាបនោះអី ហា ហា...»

«ស្រីម្នាក់នេះប្រហែលជាមិនស្មាគ្រប់ទឹកទេដឹង យ៉ុនហ៊ី គិត ព្រមទាំងក្រឡេកភ្នែកចេញពីមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះភ្លាម ហើយរកមើលភ្ញៀវទេសចរណ៍របស់នាងវិញម្ដង។ មិនគួរឲ្យជឿថា នាងវង្វេង ដែលការពិតទៅនាងធ្លាប់ស្គាល់ទីតាំងទីនេះច្បាស់ណាស់តែពេលនោះសំឡេងរបស់មនុស្សស្រីជនជាតិអ៊ីស្លាមនោះបានលាន់ឮឡើង។

«យករបស់មួយនេះតាមខ្លួនចុះណា យ៉ុនហ៊ី»

«ស្អីគេទៀតហើយ កុំមករំខានសមាធិខ្ញុំបានដែរទេ ខ្ញុំកំពុងតែរកមើលផ្លូវចេញពីទីនេះណា»

«ចាំខ្ញុំនាំនាងចេញទៅណា ហក!!! យកខ្សែកនេះទៅពាក់សិនទៅ»

ស្រីស្រស់ក្រឡេកភ្នែកទៅមើលខ្សែក ដែលមានបន្ដោងពេជ្រដ៏មានតម្លៃព្រមទាំងមានរូបសត្វត្រដាងស្លាបជារាងបេះដូងហើយក៏មានអារម្មណ៍ស្រឡាញ់ចាប់ចិត្តតែម្ដង ដែលការពិតទៅនាងជាមនុស្សមិនចូលចិត្តគ្រឿង ប្រដាប់បែបនេះទាល់តែសោះ នាងមើលទៅកាន់ខ្សែកព្រមទាំងបន្ដោងនោះសាជាថ្មីដោយ



អារម្មណ៍ថា ដូចជាធ្លាប់ឃើញនៅទីណាពីមុនមក នាងគិតថា វាជារបស់មានតម្លៃទើបនាងមិនគិតចង់ទទួលយកវានោះណា។

យ៉ុនហ៊ី គិតក្នុងចិត្តថា មនុស្សស្រីជនជាតិអ៊ីស្លាមនោះប្រហែលជាត្រូវការលុយទេដឹង បានជាយករបស់មានតម្លៃបែបនេះមកលក់ ទោះបីជានាងមានអារម្មណ៍ថា ស្រឡាញ់ចាប់ចិត្តយ៉ាងណាក៏ដោយចុះក៏នាងមិនមានសមត្ថភាពឯណាដែលត្រូវរកប្រាក់មកទិញរបស់បែបនេះក្នុងពេលនេះទេ។

«យកខ្សែកនេះមកឲ្យខ្ញុំធ្វើអីដែរទៅ នាងទុកខ្លួនឯងទៅណា ខ្ញុំមិនមានលុយឯណាមកទិញនោះទេ»

«តែវាជារបស់នាងណា យ៉ុនហ៊ី»

មនុស្សស្រីជនជាតិអ៊ីស្លាមនោះ បានលើកដៃមកចាប់ដៃរបស់នាង ហើយដាក់ខ្សែកនោះមកលើដៃ។ យ៉ុនហ៊ី មើលទៅកាន់ខ្សែកនោះ ហើយព្យាយាមធ្វើការអធិប្បាយដល់មនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះថា នាងមិនមានសមត្ថភាពឯណាក្នុងការយកប្រាក់មកទិញរបស់មានតម្លៃបែបនេះនោះទេ។

«នាងត្រូវការប្រាក់មែនដែរទេ ខ្ញុំប្រហែលជាអាចមានលុយខ្លះសម្រាប់នាងដែរណា តែខ្សែកនោះខ្ញុំមិនយកនោះទេ ខ្ញុំមិនមានលុយទិញវាទេ វាពិតជាថ្លៃណាស់សម្រាប់ខ្ញុំ»

យ៉ុនហ៊ី លូកដៃចូលទៅក្នុងហោប៉ៅដើម្បីយកប្រាក់មួយចំនួនមកឲ្យមនុស្សស្រីជនជាតិអ៊ីស្លាមនោះ ដោយមិនត្រូវការខ្សែកដ៏មានតម្លៃមួយខ្សែនោះឡើយ ចរិតឬកពាររបស់នាងមិនមែនជាមនុស្សដែលឆ្លក់ឱកាសទេ នាងត្រូវដកកែវភ្នែកចេញពីមនុស្សស្រីជនជាតិអ៊ីស្លាមនោះភ្លាម នៅពេលឮសំឡេងអ្នកនាំភ្ញៀវរបស់ក្រុមហ៊ុនប៉ានាង។

«កញ្ញា យ៉ុនហ៊ី!!! កញ្ញា យ៉ុនហ៊ី!!!»

«ខាងនេះណា ខ្ញុំនៅខាងនេះ»

នាងតបទៅគេវិញហើយបែរទៅហុចលុយឲ្យមនុស្សស្រីជនជាតិអ៊ីស្លាមនោះ តែពេលនោះមនុស្សស្រីជនជាតិអ៊ីស្លាមនោះក៏បានបាត់ខ្លួនពីទីនេះទៅ

នាងបានរកមើលគាត់ព្រមទាំងឧទានតែម្នាក់ឯង។

«យីស!! គេទៅណាបាត់ទៅហើយនៀក ហើយចុះខ្សែកនេះមិនយកទៅវិញទេអី?»

«និយាយជាមួយអ្នកណាគេដែរទៅ យ៉ុនហ៊ី នោះគៀវកំពុងតែនៅចាំគ្រប់គ្នាណា»

«អ៎! មែនហ្នឹងណា ពេលបងមកទីនេះមានឃើញមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់ដើរជ្រួសផ្លូវបងដែរទេ?»

«អ្នកណាដែរទៅ ខ្ញុំមិនឃើញមនុស្សស្រីម្នាក់នោះទេណា»

«យល់ព្រម យល់ព្រម តោះយើងនាំគ្នាទៅណា!»

នឹកឃើញដល់មនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះ ប្រហែលជានាងមានសតិមិនគ្រប់ហើយមើលទៅនោះ ស្រីស្រស់បានឱនមុខទៅមើលខ្សែកមួយខ្សែនោះដែលនៅក្នុងដៃសាជាថ្មីម្តងទៀត នៅពេលជួបមនុស្សស្រីនោះម្តងទៀតចាំឲ្យគេវិញទៅចុះ។ តែចាប់ពីថ្ងៃនោះមក នាងមិនបានជួបមនុស្សស្រីនោះទៀតទាល់តែសោះឡើយ។

«យ៉ុនហ៊ី យ៉ុនហ៊ី!!!»

យ៉ុនហ៊ី ក្រោកចេញពីការស្រមៃនោះភ្លាមនៅពេលឮសំឡេងមិត្តប្រុសរួមថ្នាក់របស់នាងបន្លឺឡើង។

«ស្អីគេហ្នឹង ហៅឮៗម្លេះនៀក ចាម»

«បើហៅច្រើនដងហើយ ឯងមិនឮនោះណា នេះអស់ម៉ោងរៀនហើយ តោះយើងនាំគ្នាទៅ»

«អ៎!! អីចឹងឯងទៅមុនទៅណា ខ្ញុំប្រហែលជាត្រូវទៅនិយាយជាមួយសាស្ត្រាចារ្យ ហារីហាស់ សិនណា»

«ធ្វើបែបនេះក៏បាន»

«អឺ!! ទៅចុះណា»

ស្រីស្រស់ត្រូវតែប្រញាប់ដើរទៅកាន់បន្ទប់របស់លោកគ្រូម្នាក់នោះភ្លាម



ដើម្បីដឹងពីសេចក្តីលម្អិត ដែលទាក់ទងនឹងការធ្វើសារណាបញ្ចប់ការសិក្សារបស់នាង នេះជាការកិច្ចចុងក្រោយដែលនាងត្រូវតែធ្វើដើម្បីបញ្ចប់ការសិក្សារៀនសូត្រផ្នែកបុរាណវិទ្យារបស់នាង ក្មេងរៀនដូចជានាងត្រូវតែតាំងចិត្តធ្វើយ៉ាងណាឲ្យលទ្ធផលការសិក្សាចេញមកល្អ...ចំណែកឯលោកគ្រូ ហារីហាស់ ទោះបីជាគាត់ចិត្តល្អយ៉ាងណាក៏ដោយ តែចំពោះពិន្ទុវិញគាត់ត្រូវតែធ្វើឲ្យសុក្រិត បើសិនជាសារណានោះមិនស្ថិតក្នុងលក្ខខណ្ឌមួយដ៏សមស្រប គាត់ក៏មិនព្រមឲ្យចប់ងាយៗដែរណា។

«សុំការអនុញ្ញាតណាលោកសាស្ត្រាចារ្យ»

«យ៉ុនហ៊ី ឬ? យ៉ាងម៉េចដែរយើងហ្នឹង មករកគ្រូរឿងសារណាហើយមើលទៅនោះ»

«ចាស លោកគ្រូ»

«ចូលមកណា គ្រូនឹងនិយាយត្រួសៗចំពោះការបង្កើតគ្រោងនៃការធ្វើសារណានោះឲ្យស្តាប់ដើម្បីយល់ខ្លះៗណា»

យ៉ុនហ៊ី ព្យាយាមតាំងចិត្តស្តាប់ និងមើលទៅកាន់លោកគ្រូចំណាស់ម្នាក់នោះធ្វើការអធិប្បាយសេចក្តីលម្អិតព្រមទាំងស្តាប់នូវអត្ថន័យដែលត្រូវធ្វើការស្វែងរក ព្រមទាំងរូបភាពមកភ្ជាប់ជាមួយនៃសាច់រឿងដែលនាងត្រូវធ្វើតាមភាពជាក់ស្តែង។ គ្រាន់តែប៉ុណ្ណោះនាងក៏វិលមុខបាត់ទៅហើយ ការធ្វើសារណាទាក់ទងជាមួយនឹងគ្រឿងប្រដាប់របស់ភេរវកម្មមិនមែនជារឿងងាយៗសម្រាប់មនុស្សសាមញ្ញដូចជានាងទាល់តែសោះឡើយ។

«ប្អូនបានយល់ពីការងារដែលត្រូវធ្វើហើយមែនទេ យ៉ុនហ៊ី?»

«ចាស លោកគ្រូ»

យល់ពីទ្រឹស្តីនោះវាចេះតែយល់ហើយ តែការអនុវត្តនោះ វាមិនងាយនោះទេ ចំពោះការធ្វើព្រមជាមួយនឹងការស្វែងរករូបភាពភ្ជាប់តាមភាពជាក់ស្តែងនោះ។ កំពុងតែពិបាកចិត្ត រំពេចនោះសំឡេងរបស់លោកសាស្ត្រាចារ្យក៏លាន់ឮឡើង។

«រូបភាពគ្រឿងប្រដាប់មួយឈុតនេះជារបស់ព្រះនាងម្ចាស់ ទេមិន បុគ្គលដែលបានស្នងត្រកូល និងគ្រប់គ្រង គឺត្រកូល **ពជវង្សអ៊ីមក៉ម បាហាម** ហើយសព្វថ្ងៃនេះក៏នៅសេសសល់តែព្រះអង្គម្ចាស់ **ឈិតខាមែន** ដែលជាអ្នកមើលថែរក្សាទ្រព្យសម្បត្តិរបស់ព្រះនាង **ទេមិន** តែម្នាក់គត់»

«**ឈិតខាមែន** ឬលោកគ្រូ?»

សាស្ត្រាចារ្យសម្លឹងមុខនិស្សិតស្រីរបស់គាត់ ដែលកំពុងតែមានកង្វល់ ហើយគាត់ក៏អត់ទ្រាំមិនអស់សំណើចមិនបាន ចំពោះភាពសង្ស័យរបស់នាងនោះជា ហេតុអីនាងធ្វើមុខគួរឲ្យចង់សើចបែបនេះ គឺភ្លេចខ្លួនអង្គុយចំហមាត់កំពុងនឹករកវិធីសាស្ត្រក្នុងការធ្វើសារណារបស់នាងតែប៉ុណ្ណោះ។

«មែនហើយ ឈិតខាមែន តែប្អូនប្រហែលជាពិបាកក្នុងការចូលទៅជិតខ្លួនគេណាស់ តែអាចរកទិន្នន័យពីមនុស្សដែលនៅក្បែរខ្លួនរបស់ ឈិតខាមែន បាន»

ក្មេងរៀនដូចជានាងនេះឬ ដែលមិនអាចមានសមត្ថភាពចូលទៅជិតព្រះអង្គម្ចាស់ **ឈិតខាមែន** នោះ គ្រាន់តែចូលទៅរក ចូលទៅតាមគាត់ទៅវាអស់រឿងហើយគ្មានអ្វីអស្ចារ្យនោះទេ ស្គាល់និស្សិតដែលឆ្លាតវៃដូចជានាងតិចពេកហើយ។ ផ្ទៃមុខរបស់នាងបញ្ចេញស្នាមញញឹមនៅពេលដែលនាងបាននឹកឃើញដល់មនុស្សដែលអាចធ្វើឲ្យនាងសម្រេចការងារនោះបាន។

"ហាន់ណា មិត្តសម្លាញ់ ឈិត ប្រាកដជាអាចជួយដល់នាងបានជាក់ជាមិនខានឡើយ"

**នៅឯសេតវិមានដ៏ធំស្កឹមស្កៃរបស់ ឈិត ដែលលាតសន្ធឹងយ៉ាង** ធំមហិមា ពោរពេញទៅដោយក្តីស្រឡាញ់របស់គូស្វាមីភរិយាថ្មីថ្មោងវ័យក្មេងទាំងពីរនាក់ នោះគឺ ហាន់ណា ជាមួយនឹង ឈិត ដែលតែងតែយល់ចិត្តយល់ថ្លើមគ្នាយ៉ាងល្អកល្អិន។ ពួកគេទាំងពីរនាក់អត់ទ្រាំមិននិយាយរំឭករឿងរ៉ាវទាំងឡាយដែលធ្វើឲ្យកើតមានស្នេហារវាងពួកគេមិនបានឡើយ សំឡេង



ស្រស់ស្រាយរបស់អតីតតារាស្រីល្បីឈ្មោះម្នាក់នោះបានលាន់ឮឡើងភ្លាម។

«មិនគួរឲ្យជឿទាល់តែសោះថា អូនបានរួចជីវិតពីអាពួកជួញដូរមនុស្សឆ្លងដែនខុសច្បាប់នោះមកបានទាល់តែសោះ»

«បងឯណោះវិញទេ មិនគួរណារួចជីវិតមកបែបនេះសោះ»

ឈិត នឹកដល់ថ្ងៃដំបូងដែលគេបានចូលទៅជួយភរិយារបស់គេពីអាពួកជួញដូរមនុស្សឆ្លងដែនខុសច្បាប់នោះ តែនាងបែរជាសម្តែងឫទ្ធិយ៉ាងអស្ចារ្យតែម្តងរហូតទាល់តែគេ បានលះបង់ជីវិតចូលទៅជួយនាងចេញមកស្ទើរតែយកជីវិតចេញមកវិញមិនបាន

«អូនមិនជឿទាល់តែសោះថា ក្នុងថ្ងៃដំបូងអូនបែរជាមើលទៅបងថាជាជនអន្តរាយលទៅវិញ»

ពេលនោះមានតែភ្នែកតែគ្មានប្រស្រី ចុះបើប្តីនាងរូបរាងសង្ហាឡូយឆាយដល់ថ្នាក់ហ្នឹងទៅហើយ នាងនៅមើលឃើញថា ជាជនអន្តរាយលបានទៀត។

«វាគ្មានអីប្លែកនោះទេ ព្រោះថា ចរិតឬកពារបស់អូនរឹងទទឹង មានភាពជឿជាក់លើខ្លួនឯងខ្ពស់ មិនព្រមស្តាប់អ្នកណាទាំងអស់ គិតតែខ្លួនឯងថាតែខ្លួនឯង...»

«នែបង!! កុំមកថាឲ្យខ្ញុំណា ក្រែងបងទេតើសដែលជាអ្នកសម្តែងល្ខោនបោកប្រាស់ខ្ញុំរហូតដល់ខ្ញុំជឿថា បងជាជនអន្តរាយលនោះ»

ពិតមែននោះណា នៅពេលដែលនឹកឃើញដល់អតីតកាលដ៏សែនផ្អែមល្ហែមជាមួយគ្នា ស្រីស្រស់បានធ្វើឲ្យជីវិតរបស់ពួកគេមានភាពស្រស់ស្រាយជាងមុន ទម្រាំតែបានចិត្តបានកាយរបស់នាងមកវាពិបាកសែនពិបាក តែក្តីស្រឡាញ់ដែលគេបានពីនាងមកនោះវាមានតម្លៃមិនអាចកាត់ថ្លៃបានឡើយ។

«ចុះបើអូនពូកែនឹ ធ្វើដូចខ្លួនឯងខ្លាំងណាស់អីចឹង ត្រូវតែប្រដៅខ្លះហ្នឹងឯង»

«នែ!! បងថាខ្ញុំនី!!»

«អត់ទេ អត់ទេ បងគ្រាន់តែនិយាយពីភាពគួរឲ្យស្រឡាញ់របស់អូនទេ

តើស»

«ហ្នឹងហើយ បងថាឲ្យខ្ញុំនោះ»

ដៃទាំងសងខាងដ៏រឹងមាំរបស់គេ ក៏បានស្រាវឱបប្រពន្ធរួចក៏ថើបម្ដងទៀត ហើយសំឡេងគ្រលរនោះក៏បាននិយាយលួងចិត្តភរិយារបស់គេ ព្រោះនាងចាប់ផ្ដើមងក់ងរទៀតហើយ។

«អត់ទេ បងកំពុងតែរៀបនិយាយថា ដោយសារតែចរិតឫកពាបែបនេះហើយដែលធ្វើឲ្យបងស្រឡាញ់អូននោះណា ហើយអូនក៏បានលង់ស្រឡាញ់មនុស្សអន្ធពាលនេះងប់ងុលដែរតើមិនពិតឬ?»

«ហឹស!!! មិនដឹងជាមនុស្សប្រុសអីទេ ពូកែអាខាងល្បិចកល មនុស្សស្រីដូចជាខ្ញុំនេះតាមបងលែងទាន់ហើយ!!»

«តែវាក៏សក្ដិសមដែរណាដែលបងធ្វើបែបហ្នឹងនោះ»

«បោកប្រាស់ខ្ញុំបែបនេះឬ ដែលបងនិយាយថាសក្ដិសមនោះ!»

«ចុះបើបងបានទទួលរបស់ដែលមានតម្លៃឥតគណនា ព្រមទាំងទឹកចិត្តបរិសុទ្ធពីអូនដែរនោះអី»

ឈិត លើកមុខភរិយារបស់គេឡើងដែលពេលនេះធ្វើមុខក្រញ៉ូវ បបូរមាត់ដ៏ស្រស់ស្អាតរបស់គេថើបបបូរមាត់ដ៏គួរឲ្យចង់ប៊ិតរបស់ភរិយា គេយ៉ាងផ្អែមល្ហែមដូចដែលគេតែងតែធ្លាប់ថើបនោះ ព្រោះភរិយារបស់គេទាំងស្អាតទាំងសិចស៊ី ណាមួយអាឿងលើគ្រែនាងក៏ជំនាញតែម្ដង។ ឈិត ចាប់ផ្ដើមទម្រេតខ្លួនភរិយាគេងនៅលើគ្រែ ដៃរបស់គេក៏ចាប់ផ្ដើមរាវលូកចូលទៅក្នុងប្រឡោះអាវរបស់នាងយ៉ាងរឹមរាម ដៃនោះច្របាច់ត្រង់ដើមទ្រូងនាងហើយមកឈប់ទ្រឹងនៅចំចុងសុដន់នាងទាំងទ្វេ រំពេចនោះអារម្មណ៍ស្រេកឃ្លានតណ្ហាក៏បានផុសឡើងភ្លាម។ អាវក្រៅ និងក្នុងត្រូវបានសម្រាតចេញពីរាងកាយ បង្ហាញឲ្យឃើញនូវសុដន់ដ៏ធំក្បុំក្បោះ ព្រមទាំងចុងសុដន់របស់នាងពណ៌ផ្កាឈូកគួរឲ្យចង់ប៊ិតជញ្ជក់។ មាត់របស់គេថើបនៅត្រង់មុខ ម៉ាត់ ដើមក ព្រមទាំងរាលដាលទៅដល់ភូមិឋានដែលមានភ្នំធំៗពីរនៅទន្ទឹមគ្នាយ៉ាងធំទ្រលុកទ្រលន់នោះ តើ



គេម៉េចនឹងអាចទប់អារម្មណ៍បានទៅ ចំពោះរាងកាយដ៏សែនសិចស៊ីរោលរាលក្ដៅសាច់របស់ភរិយាគេនៅពេលនេះទៅ គ្រាន់តែប៉ុណ្ណឹងអារម្មណ៍លើខ្លួនប្រាណគេក៏បានពុះកញ្ជ្រោលឡើងគ្រប់ច្រកល្ហក។ ពេលនោះអាអូនតូចរបស់គេក៏បានងើបឡើង ការប្រតិបត្តិការក៏កាន់តែក្ដៅរោលរាលទៅៗដូចគ្នាដែរ រំពេចនោះសំឡេងគោះទ្វារព្រមជាមួយនឹងសំឡេងស្រែកហៅក៏បានលាន់ឮឡើង។

**«អ្នកនាង ហាន់ណា អ្នកនាង ហាន់ណា»**

«អ្នកណាហ្នឹង! ចង់តែដេញចេញទៅឲ្យឆ្ងាយទៅទៀត» ឈិត រអ៊ូរទាំយ៉ាងក្ដៅចិត្តតែម្ដង ព្រោះគេត្រូវបញ្ឈប់ចំណង់តណ្ហារបស់គេទាំងកណ្ដាលផ្លូវបែបនេះ។

«គឺ រីន ទេ អ្នកនាង ហាន់ណា! អ្នកនាង យ៉ុនហ៊ី មកជួបអ្នកនាង»

«ចាំស អូន រីន បងកំពុងតែចេញទៅឥឡូវនេះហើយណា»

«ចាំបន្តិចទៀតចាំចេញទៅក៏បានដែរណាអូន»

ឈិត អត់ទ្រាំមិនខឹងមិនបាន នៅពេលដែលគេឃើញភរិយារបស់គេក្រោកហើយរៀបចំស្លៀកសម្លៀកបំពាក់ឲ្យរៀបរយវិញនោះ ហើយចេញទៅដោយមិនខ្វល់ពីអារម្មណ៍ស្វាមីទាល់តែសោះ ស្រីស្រស់សម្លឹងមើលស្វាមីនាងហើយអត់ទ្រាំមិនអស់សំណើចមិនបាន។

«អូនសើចស្អីទៅ!»

«គឺសើចអាអូនតូចរបស់បងហ្នឹងណាមើលទៅវាចុះឡើងបះហើយរឹង»

«ហើយចុះអូនចង់ទៅ ហើយទុកបងចោលបែបនេះឬ?»

«មានទៅចោលឯណា តែ យ៉ុនហ៊ី ប្រហែលជាមានការអីប្រញាប់ហើយបានជាមកនោះ»

«មិត្តភក្ដិអូនមិនដឹងពេលដឹងវេលាសោះហើយទៀត»

«នែ!! អ្នកណាឲ្យប្រាកដទៅដែលមិនដឹងពេលដឹងវេលានោះ បងឯងហ្នឹង មើលចុះកណ្ដាលថ្ងៃថែសសោះ បងនៅ...»

ហាន់ណា ជ្រើសរើសក្នុងការមិននិយាយបន្ត ព្រោះស្វាមីរូបសង្ហារបស់

នាងពូកែណាស់ក្នុងការធ្វើសកម្មភាពលើគ្រែនោះ ម៉្យាងមិត្តភក្តិមករកនាងយូរៗម្តង នាងត្រូវតែចុះទៅទទួលហើយ ប្តីទុកមួយឡែកសិនទៅ ចាំចប់កិច្ចការចាំទៅបន្តសកម្មភាពនោះជាមួយប្តីទៀត។

«បានហើយ បានហើយ អូនប្រញាប់ទៅរក យ៉ុនហ៊ី វិញប្រសើរជាង»

«យ៉ុនហ៊ី នោះចាំមួយភ្លែតទៅវាមិនអីនោះទេ» ឈីត អ៊ើរទាំ។

«បងប្រាកដចិត្តហើយឬថា ចង់ឲ្យនាងចាំភ្លែតនោះ»

ហឺមមម! នាងមិនចង់និយាយឲ្យវែងឆ្ងាយនោះទេ ព្រោះស្វាមីជាទីស្រឡាញ់របស់នាងលេងល្បែងស្នេហាលើគ្រែម្តងៗរាប់ម៉ោងនោះណា ណាមួយគេធ្វើម្តងមិនដែលឆ្អែតទេ ចង់តែមួយហើយមួយទៀតតែរហូតហ្នឹង ហើយនៅមានមុខមកនិយាយថា ឲ្យមិត្តភក្តិចាំតិចតួចទៀតនោះណា។

«បើអីចឹងបងចាំខ្ញុំភ្លែតនៅទីនេះចុះណាប្តីសម្លាញ់ ខ្ញុំទៅរកនាងបន្តិចសិន ចាំរួចការងារហើយខ្ញុំនឹងប្រញាប់ចូលមករកប្តីសម្លាញ់ឯងភ្លាមណា»

ទោះជាគេទាស់ចិត្តចំពោះហេតុការណ៍ ដែលរំខានក្តីសុខយ៉ាងណាក៏ដោយចុះ តែបើនាងនៅតែរឹងរូសថា មិត្តភក្តិសំខាន់ជាងអំណាចចំណង់តណ្ហារបស់គេនៅពេលនេះ ប្តីដ៏ល្អដូចជាគេប្រហែលត្រូវតែតាមចិត្តភរិយាគេហើយទើបបាន ព្រមទាំងគិតក្នុងចិត្តថា អត់បាយញ៉ាំបង្អែមក៏បាន ហើយពេលនោះគេក៏ប្រញាប់ដើរចុះទៅតាមភរិយារបស់គេទៅក្រោមដែរ។

«អីចឹងក៏បានដែរ អីចឹងក៏បានដែរ ចាំបងមួយភ្លែតណា»

កែវភ្នែកមួយគូដ៏សែនស្រស់សោភាកំពុងតែសញ្ជឹងគិតព្រមទាំងសម្លឹងមើលទៅកាន់ពពួកមេអំបៅ ដែលហោះហើរចុះឡើងនៅក្នុងលំហជុំវិញដើមផ្កាជាច្រើនប្រភេទនោះ ព្រមទាំងនឹកគិតដល់ជីវិតអតីតកាលរបស់មិត្តភក្តិស្រីនាងដែលធ្វើជាតារាសុខៗ ក៏បានរសាត់អណ្តែតមកធ្វើជាប្រពន្ធមហាសេដ្ឋីបែបនេះទៅវិញ។

នាងបានកាត់ចិត្តគេចពីភាពរញ៉េរញ៉ៃនៃពិភពសិល្បៈ ដើម្បីបន្តការ



សិក្សាតាមដែលចិត្តប៉ងប្រាថ្នា តែបែរជាត្រូវគេចាប់ជីវិតខ្លួនមកទៀត ប្រហែលជាជោគជតានាំឲ្យនាងបានមកជួបជាមួយ ឈីត ដែលជាមហាសេដ្ឋីហើយ។

រំពេចនោះនាងក៏ភ្ញាក់ចេញពីការស្រមៃនោះ ព្រោះមានសំឡេងដ៏ស្រួយស្រែសរបស់មិត្តភក្តិនាងបានលាន់ឮឡើង។

«យ៉ុនហ៊ី នោះឯងទេឬ?»

«ត្រូវហើយ ឯងមានក្តីសុខហើយភ្លេចមិត្តភក្តិអីចឹងឬ!»

ទោះបីជានាងនិយាយលេងសើចជាមួយមិត្តភក្តិនាងយ៉ាងណាក៏ដោយក៏នាងបានដាក់ភ្នែកចេញពីមិត្តភក្តិហើយក្រឡេកមើលទៅកាន់ស្វាមីរបស់មិត្តដែលកំពុងតែកៀកគ្នាមកជាមួយដែរនោះ ហាក់បីដូចជាខ្លាចគេមិនដឹងថាជាគូស្វាមីភរិយាគ្នាយ៉ាងអីចឹង។

«សួស្តីណា ឈីត»

«សួស្តី យ៉ុនហ៊ី ម៉េចក៏មិនព្រមឡើងទៅខាងលើទៅ?»

«នៅទីនេះត្រជាក់ល្អ ហើយមានអាងហែលទឹកព្រមទាំងមានផ្កាស្អាតៗទៀតផង»

«បើអីចឹងយើងនាំគ្នាញ៉ាំអាហារថ្ងៃត្រង់នៅទីនេះល្អដែរទេ?» ឈីត ភ្ញាក់មាត់សួរយោបល់នារីទាំងពីរដែលនៅចំពោះមុខគេនោះ។

«នេះអ្នកទាំងពីរនៅមិនទាន់ញ៉ាំអាហារថ្ងៃត្រង់នៅឡើយទេ? ម៉ោងជិតបីល្ងាចហើយណា»

ហាន់ណា ស្តាប់មិត្តភក្តិស្រីនាងសួរព្រមទាំងមោស់មាត់ជីបៗ ចង់តែបរិយាយសកម្មភាពអាក្រក់ៗរបស់ស្វាមីនាងយកតែមែនទែនតែម្តង ថារឿងបាយម្ហូបនោះឬដែលសំខាន់ជាងសកម្មភាពលើគ្រែរបស់គេនោះ។

«ខ្ញុំជាប់រវល់ការងារហ្នឹងណា»

ស្រីស្រស់សម្លឹងមើលមុខស្វាមីដែលគេបានគុហកមិត្តភក្តិនាង ចុះបើគេពូកែខាងល្បែងបោកប្រាស់នោះស្រាប់ហើយ នាងគិតបន្ត ជាប់រវល់ការងារកាមតណ្ហានោះទេដឹង នាងអត់ទ្រាំមិននិយាយទាំងមុលាចំពោះស្វាមីរបស់នា

ងដែលកុហកមុខរាបស្មើ ធ្វើដូចមិនមានរឿងអីកើតឡើងនោះមិនបានទាល់តែសោះឡើយ ហើយបែរទៅឲ្យសញ្ញាទៅកាន់មេផ្ទះឲ្យលើកអាហារមកកាន់តុដែលនៅនឹងកន្លែងអាងហែលទឹក។

«យ៉ុនហ៊ី ហេតុអីក៏ឯងមើលទៅដូចជាប្លែកខុសពីមុនម្ល៉េះ?»

«ប្លូ!!! អីមែនហ្នឹងណា ចុះបើយើងមិនបានពាក់វ៉ែនតានោះណា»

«អឺ!! មែនតើសវើយ ហើយនេះឯងភ្លេចវ៉ែនតាឬ? ហើយឯងមើលឃើញដែរ?»

«ភ្លេចវ៉ែនតាឯណាទៅ យើងបានទៅវះកាត់ភ្នែកហើយហើយណា»

«អំ!!! មែនក៏អី ពេទ្យគេពូកែណាស់ហ្ន៎!! វះកាត់ឯងឡើងស្អាតតែម្ដង»

«ហោយ!! គ្រាន់តែកែភ្នែកតើស តែសម្រស់របស់យើងនោះស្អាតស្រាប់តើសវើយ»

«អឺ!!! ឯងមិនសូវជាលង់ខ្លួនឯងប៉ុន្មាននោះទេណា»

ហាន់ណា សម្លឹងមើលទៅកាន់មិត្តនាងដែលជាកូនកាត់បីសាសន៍អាមេរិចកាំង-អារ៉ាប់-កូរ៉េ។ ដោយសារតែបិតារបស់នាងជាកូនកាត់ពីរសាសន៍អាមេរិច-អារ៉ាប់ ចំណែកម្ដាយរបស់នាងជាជនជាតិកូរ៉េ។ ហាន់ណា ទើបតែសង្កេតមិត្តភក្តិស្រីរបស់នាង នៅពេលដែលមិនពាក់វ៉ែនតា ផ្ទៃមុខនាងស្រស់ស្រាយខុសប្លែកពីធម្មតា ចំណែកឯរូបរាងកាយនោះ នាងស្អាតស្រាប់ហើយ។

«យ៉ុនហ៊ី យើងថាឯងគួរណាទៅប្រកួតបវរកញ្ញាបានណា»

«អូ!!! យើងមិនដើរតាមផ្លូវឯងធ្លាប់ដើរនោះទេ យើងមិនមានទេពកោសល្យខាងហ្នឹងដូចឯងនោះទេ ហើយពិសេសយើងមិនស្អាតដូចឯងដែរនោះណា ពិតមែនដែរទេ ឈីត?»

យ៉ុនហ៊ី សម្លឹងមើល ឈីត ដែលមើលកិរិយារបស់គេក្នុងកែវភ្នែកមានមន្តស្នេហ៍ជំនួសចម្លើយ ព្រមទាំងឱនមើលកិរិយារបស់គេដោយមិនខ្វល់ថាមានមិត្តនាងនៅទីនេះដែរ។ តើនាងជាថ្លឹងទទឹងកញ្ចក់គេដែរទេទៀត? យ៉ុនហ៊ី គិតនាងប្រហែលជាត្រូវប្រញាប់និយាយពីធុរៈរបស់នាងហើយទើបបាន ព្រោះ



សកម្មភាពរបស់ពួកគេទាំងពីរនៅចំពោះមុខនាង ហាក់បីដូចជាចង់ធ្វើអ្វីផ្សេងក្រៅពីនេះជាក់ជាមិនខាន រំពេចនោះសំឡេងស្រួយស្រែសក៏បន្លឺឡើងភ្លាម។

«ខ្ញុំមកនេះគឺចង់ពិភាក្សាជាមួយ **ឈីត** ក្នុងរឿង **ឈីតខាមែន**»

«ហា!! **ឈីតខាមែន** !!!»

ឈីត សម្លឹងមើលមុខមិត្តភក្តិរបស់ភរិយាគេ ដោយទឹកមុខងឿងឆ្ងល់ ហើយចង់ដឹងថា វាមានន័យយ៉ាងណាដែរទៅ តើមកពិភាក្សាអីជាមួយនឹង **ឈីតខាមែន** ព្រោះថា មនុស្សស្រីច្រើននាក់ណាស់ដែលចូលក្បែរគេពេលណាត្រូវតែមានគ្រោះថ្នាក់គ្រប់គ្នានោះណា។

«ចាស គឺរឿងរបស់ **ឈីតខាមែន** នោះណា **ឈីត**»

«តើមានអីចាំបាច់ខ្លាំងឬ យ៉ុនហ៊ី ទើបបានជាចង់ជួប **ឈីតខាមែន** នោះ?»

«គឺវាទាក់ទងជាមួយនឹងសារណា ដែលសរសេរអំពីគ្រឿងប្រដាប់របស់ព្រះនាងម្ចាស់ **ទេមីន** នោះ»

«នែ!!! កុំប្រាប់ខ្ញុំឲ្យសោះថា រឿងប៉ុណ្ណឹងត្រូវតែចូលទៅជួបផ្ទាល់ជាមួយនឹង **ឈីតខាមែន** ដែរនោះ»

ទឹកដមសំឡេងភ្ញាក់ផ្អើលរបស់ ឈីត បានធ្វើឲ្យ ហាន់ណា មានភាពចម្លែកចិត្តជាខ្លាំង។ គ្រាន់តែណែនាំឲ្យមិត្តភក្តិនាងបានទៅជួបជាមួយនឹង ឈីតខាមែន តែប៉ុណ្ណោះសោះ មិនមានអីធំដុំឯណា ព្រោះ យ៉ុនហ៊ី បានជួយដល់នាង និងស្វាមីច្រើន ហើយគ្រាន់តែរឿងប៉ុណ្ណឹងរឿងអីដែលជួយមិត្តភក្តិនាងមិនបានដែរទៅ។

«ម៉េចអីចឹង ឈីត គ្រាន់តែចូលទៅសម្ភាសន៍ហើយថតរូបភ្ជាប់ជាមួយប៉ុណ្ណោះនោះណា»

«មែនហើយ គឺដូចដែល **ហាន់ណា** និយាយនោះឯងណា **ឈីត** ព្រោះថា **ឈីតខាមែន** ជាអ្នកថែរក្សាទ្រព្យសម្បត្តិរបស់ព្រះនាងម្ចាស់ **ទេមីន** នោះអី»

ទោះបីជាគេស្គាល់ ឈីតខាមែន យ៉ាងច្បាស់យ៉ាងណាក៏ដោយ តែគេក៏

បានដឹងយ៉ាងច្បាស់ថា មួយរយៈក្រោយមកនេះ ឈីតខាមែន មិនត្រូវការឲ្យអ្នកណាចូលទៅជួបគេបានងាយៗនោះទេ ជាពិសេសមនុស្សស្រី ហើយដោយចរិតឫកពារល្អរបស់គេ គេក៏ត្រូវតែគោរពការសម្រេចចិត្តរបស់ ឈីតខាមែន ដូចគ្នាដែរ។ ម្យ៉ាងទៀត គេក៏មានអារម្មណ៍អាណិតដល់មនុស្សស្រីនៅចំពោះមុខគេម្នាក់នេះណាស់ គេពិតជាមិនចង់ឲ្យនាងមានគ្រោះថ្នាក់ដូចមនុស្សស្រីដទៃទៀតដែលបានចូលជិត ឈីតខាមែន នោះឡើយ។

ឈីត សម្លឹងមើលមនុស្សស្រីពីរនាក់ដែលនៅចំពោះមុខគេនោះមិនព្រិចភ្នែក ដើម្បីត្រូវការចម្លើយ វាពិតជាធ្វើឲ្យគេពិបាកចិត្តណាស់ បើសិនជាគេបាននិយាយការពិតប្រាប់ដល់ពួកនាង តើពួកនាងពីរនាក់ជឿគេឬក៏អត់ទេហ្ន៎!! ចំពោះរឿងរ៉ាវអាថ៌កំបាំងនេះ។

រំពេចនោះភាពស្លុតចិត្តក៏កើតឡើង នៅសុខៗ មេឃដែលភ្លឺចែសបែរជាងងឹត ព្រមទាំងមានខ្យល់ព្យុះបក់បោកយ៉ាងចម្លែកតែម្ដង។ គ្រប់ក្រសែភ្នែកមើលទៅកាន់សមុទ្រខ្សាច់ ដ៏ធំល្វឹងល្វើយមើលទៅដាច់កន្ទុយភ្នែកនោះឃើញផ្ទៃមេឃស្រអាប់មើលអីមិនឃើញទាល់តែសោះ។

**«នោះ!! មើលនោះចុះណា ឈីត តើមានអីកើតឡើងហ្នឹង!!!»** ហាន់ណាហើបមាត់សួរយ៉ាងស្លុតចិត្ត។

«ព្យុះសមុទ្រខ្សាច់នោះណា តោះយើងនាំគ្នាចូលទៅខាងក្នុងទៅ»

ទោះបីជាគេស៊ាំនៅឯសមុទ្រខ្សាច់នេះ តែព្យុះដែលគេឃើញនោះវាចម្លែកជាងរាល់ដងដែលធ្លាប់ជួប។ ពពួកខ្សាច់បានរួមបញ្ចូលគ្នាជាដុំខ្យល់ព្យុះ បោកមកពីចម្ងាយ ហើយប្រហែលជាបានសម្លាប់មនុស្សមិនតិចនាក់នោះទេ នេះជាព្យុះខ្សាច់ ស៊ូណាមិ ទៀតនៀក។

**«ឆ្កួតមែន វាកើតស៊ីហ្នឹង!!!»**

«ហើយចុះយើងគួរតែធ្វើយ៉ាងណាដែរទៅ ឈីត ?»

«មិនបាច់បារម្ភទេ ចាំខ្ញុំនាំពួកនាងទៅកាន់បន្ទប់សុវត្ថិភាពណា»

ឈីត និយាយ ព្រមទាំងនាំមនុស្សស្រីទាំងពីរនាក់នោះចូលទៅក្នុង



បន្ទប់មានសុវត្ថិភាពនៅក្នុងសេតវិមានដ៏ធំស្កឹមស្កៃនោះ រួចចេញមកខាងក្រៅសាលាថ្មីដើម្បីឲ្យសញ្ញាដល់ពួកកូនចៅគេ គេចពីគ្រោះថ្នាក់ដូចគ្នាដែរ ហើយអ្វីដែលនាំឲ្យគេត្រូវស្លុតចិត្តជាលើកទីពីរនោះ ដែលធ្វើឲ្យគេញ៉ីភ្នែកចុះឡើងៗចំពោះការដែលបានឃើញមនុស្សប្រុសដែលមករកគេ។

**«ឈីតខាមែន!! លោកមកទីនេះបានដោយរបៀបណាដែរទៅ?»**

«ព្រោះតែព្យុះសមុទ្របក់បោកនោះហើយណា ទើបបានជាយន្តហោះផ្ទាល់ខ្លួនរបស់យើងត្រូវឈប់ចុះចតនៅត្រង់សេតវិមានរបស់ឯង ប្រហែលជាត្រូវគេចព្យុះនៅទីនេះសិនហើយណា ឈីត ចាំពេលឈប់មានព្យុះពេលណាចាំខ្ញុំចាប់ផ្ដើមធ្វើដំណើរចាកចេញពីទីនេះបន្តទៀត»

«អ៎!!! ដោយក្ដីរីករាយ អ៊ីចឹងអញ្ជើញលោកចូលទៅខាងក្នុងសិនចុះណា ឈីតខាមែន»

ទោះបីជានិយាយគួរសមតាមរបៀបម្ចាស់ផ្ទះក៏ដោយ តែអារម្មណ៍របស់គេក៏គិតដែរថា តើមានអីកើតឡើងដែរទៅ? យូររាប់ឆ្នាំខែហើយណាដែលឈីតខាមែនមិនបង្ហាញខ្លួន។ ដោយសារតែព្យុះចម្លែកនេះឬដែលបណ្ដាលឲ្យគេបានបង្ហាញខ្លួននៅទីនេះ ភាពចម្លែកក្នុងចិត្តបានកើតឡើងភ្លាម។

**ទោះបីជា យ៉ុនហ៊ី ជាមនុស្សស្រីដែលរឹងមាំយ៉ាងណាក៏ដោយ តែនាង**បានឱបមិត្តភក្ដិនាងយ៉ាងណែនដូចគ្នាដែរ ហើយមើលទៅមិត្តភក្ដិនាងក៏កើតមានអារម្មណ៍ដូចគ្នាដែរ។ មើលទៅពួកគេឱបគ្នាជាប់ដូចកូនភ្លោះខ្លួនជាប់គ្នាអ៊ីចឹង

«គួរឲ្យខ្លាចណាស់ ហាន់ណា តើសេតវិមាននេះរលំដែរទេហ្ន៎!!»

«មិនអីនោះទេ ទីនេះសាងសង់ឡើងសម្រាប់ការពារខ្យល់ព្យុះ ភ្លៀងហើយប្រហែលជាខូចខាតតែនៅខាងក្នុងទេណា ឯងនៅជាមួយយើងឯងមិនបាច់ភ័យនោះទេណា»

«ហើយចុះឯងមិនខ្លាចទេអី ហាន់ណា!!»

«អ្នកណាថា យើងមិនខ្លាចទៅ!!!»

«យីស!! យើងនេះចង់ឆៃមុខនឹងឯងដល់ហើយនៀក»

នៅពេលទ្វារធំនៃសេតវិមាននោះបើកចេញមក ក្រសែភ្នែករបស់នាងទាំងពីរបានសម្លឹងមើលទៅកាន់មនុស្សប្រុស ដែលមានមាឌធំរាងស្ដើងខ្ពស់កំពុងតែដើរតាមពីក្រោយម្ចាស់ផ្ទះមក ធ្វើឲ្យកែវភ្នែកមួយគូដ៏ស្រស់ត្រកាលរបស់ យ៉ុនហ៊ី បើកធំវត្លាមតែម្ដង។

«នោះ!! នោះ!! កែវភ្នែកមួយនោះ!!!»

«ស្លុតចិត្តអីទៀតហើយហ្នឹង យ៉ុនហ៊ី នេះឯងគិតភ័យរហូតដល់ថ្នាក់ចង់ឆ្កួតទៅហើយនៀក»

យ៉ុនហ៊ី មិនចាប់អារម្មណ៍លើពាក្យសម្ដីរបស់មិត្តនាងឡើយ កែវភ្នែករបស់នាងនៅតែសម្លឹងចាប់ចង ទៅកាន់បុរសមុខមាំម្នាក់ដែលឈរនៅចំពោះមុខនាង ព្រមទាំងគិតថា នោះហើយជាកែវភ្នែកមួយគូនៅក្នុងក្ដីសុបិនរបស់នាង ដែលគេនោះតែងតែប្រាថ្នាចង់ប្រគល់ស្នេហាដល់នាងគ្រប់ពេល។ នាងចងចាំក្នុងខួរក្បាលបានល្អតែម្ដង រំពេចនោះសតិស្មារតីរបស់នាងក៏បានត្រឡប់ចូលមកកាន់រាងកាយសាជាថ្មីនៅពេលដែលមិត្តស្រីរបស់នាងបានអង្រួន និងហៅឈ្មោះនាង។

«យ៉ុនហ៊ី!! យ៉ុនហ៊ី!! តើឯងកើតអីហ្នឹង!!!»

«ហាន់ណា...យើង...យើង...យើង»

«មើលចុះមុខឡើងស្លេកស្លាំងតែម្ដងហើយនៀក ឯងខ្លាចព្យុះនោះខ្លាំងបែបនេះ!»

តើនាងនឹងប្រាប់មិត្តនាងដោយរបៀបណាទៅ ទោះបីជានាងនិយាយការពិតចេញទៅ តើគេអាចជឿលើនាងបានដែរទេ? រំពេចនោះសំឡេងគ្រលររបស់ម្ចាស់សេតវិមានក៏បានលាន់ឮឡើង។

«នេះជា ហាន់ណា ភរិយារបស់យើង ចំណែកឯនោះ យ៉ុនហ៊ី ជាមិត្តភក្ដិរបស់ ហាន់ណា»



«ហាន់ណា យ៉ុនហ៊ី នេះគឺជា ឈឹតខាមែន!!!»

«ឈឹតខាមែន!!!»

ពួកគេពីរនាក់នោះ ភ្ញាត់សំឡេងដូចគ្នាក្នុងពេលតែមួយនោះយ៉ាងចម្លែកចិត្ត ដែលនៅសុខៗមនុស្សដែលនិយាយថា ពិបាកក្នុងការចូលជួបបំផុតបែរជាអាចមកបង្ហាញខ្លួនយ៉ាងងាយៗបែបនេះទៅវិញ។ ទោះបីជា យ៉ុនហ៊ី មានអារម្មណ៍ចម្លែកចិត្តព្រមទាំងវិលវល់យ៉ាងណាក៏ដោយចុះ តែនាងក៏មិនភ្លេចធ្វើការរាក់ទាក់តាមមារយាទនោះដែរ។ នាងគិតដល់ពិន្ទុពេញនៃមុខវិជ្ជាដែលនាងត្រូវធ្វើសារណាបញ្ចប់ការសិក្សារបស់នាងនោះណា។

«ចាស រីករាយដែលបានស្គាល់លោក ឈឹតខាមែន»

ពិតជារីករាយមែនទែនតែម្ដង! នាងគិត តែកែវភ្នែករបស់គេមួយគូនោះឯងដែលនាងមិនហ៊ានមើលទៅទាល់តែសោះ តើវាមិចនឹងអាចដូចកែវភ្នែកមួយគូដែលនាងយល់សប្ដិនោះដោយរបៀបណាដែរទៅ?

«រីករាយដែលបានស្គាល់នាងដូចគ្នាដែរ ហាន់ណា យ៉ុនហ៊ី»

យ៉ុនហ៊ី អត់ទ្រាំមិនមើលទៅកាន់ ឈឹតខាមែន មិនបានឡើយនៅពេលដែលគេម្នាក់នោះបាននិយាយមកកាន់នាង។ កែវភ្នែកដែលមើលមកនេះហើយជាកែវភ្នែកក្នុងក្ដីសុបិន ហើយគេសម្លឹងស៊ើដែលនៅនឹងករបស់នាងដែរទៅ នាងសម្លឹងទៅកាន់បុរសដែលនៅចំពោះមុខ ការដែលគេមើលមកនាងហើយជ្រួញចិញ្ចើមនោះដោយគេឃើញខ្សែករបស់នាង ហើយធ្វើឲ្យនាងលើកដៃទៅអង្អែលកខ្លួនឯងដោយមិនដឹងខ្លួន។ គេប្រហែលជាមិនមែនខ្មោចឆៅដែលបិតឈាមមនុស្សទាំងរស់នោះទេណា ណាមួយគេមានប្រវត្តិលាក់ខ្លួនតែក្នុងផ្ទះមិនចេញមកឃើញសភាពខាងក្រៅទៀតនោះ។ រំពេចនោះសំឡេងគ្រលរក៏បានលាន់ឮឡើង។

«បន្ទោងខ្សែកដែលមានរូបសត្វត្រដាងស្លាប ជារូបបេះដូងមួយនោះនៅនឹងករបស់នាង តើបានវាមកពីណា យ៉ុនហ៊ី?»

ដៃទាំងពីររបស់នាងលើកទៅស្រវាយកបន្ទោងនោះមកកាន់មើល អំ!!!

ការពិតទៅគេចាប់អារម្មណ៍ចំពោះខ្សែកដែលមានបន្តោងរូបសត្វក្រដាងស្លាបជារាងបេះដូងនោះទេតើស ខណៈពេលជាមួយគ្នានោះក៏បាននឹកឃើញនូវអ្វី ម្យ៉ាងរហូតដល់នាងបានស្លុតចិត្តនិយាយចេញមកថា៖

«អូ!!! ស្លាប់ហើយស្រីជនជាតិអ៊ីស្លាមមិនគ្រប់ទឹកនោះបានទៅលួចខ្សែកមួយខ្សែនេះរបស់ ឈីតខាមែន មកឬ?»

«ឯងនិយាយពីស្អីទៅ យ៉ុនហ៊ី តើឯងទៅលួចខ្សែកនេះពីណាមក?»

មើលមិត្តភក្តិនាងនិយាយចុះ មាត់មិនមានគម្រូបទាល់តែសោះ ចង់តែហែកមាត់វាឲ្យរហែក យ៉ុនហ៊ី មើលទៅកាន់កែវភ្នែកមួយគូដ៏មុតមាំនោះព្រមទាំងធ្វើការអធិប្បាយបន្ត។

«គឺមានមនុស្សស្រីជនជាតិអ៊ីស្លាមតែលតោលម្នាក់បានឲ្យខ្ញុំ»

«មនុស្សស្រីជនជាតិអ៊ីស្លាម?»

«ខ្ញុំហ៊ានស្បថណា ថាខ្ញុំមិនបានទៅលួចរបស់អ្នកណានោះទេ មនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះបានឲ្យខ្ញុំមែន តែពេលនេះខ្ញុំមិនដឹងថា នាងទៅណាបាត់ហើយនោះទេ!!»

យ៉ុនហ៊ី ស្តាប់សំឡេងស្រួយស្រែសរបស់ ហាន់ណា ដែលនិយាយកាត់មុខនាង ដោយមិនចាំបាច់គិតទាល់តែសោះថា៖

«នេះជាខ្សែករបស់ ឈីតខាមែន ដែលមានគេលួចទៅឬ?»

ទៀតហើយមិត្តភក្តិខ្ញុំនិយាយចេញមកមាត់គ្មានគម្រូបទៀតហើយ ការដែលមិត្តរបស់នាងមានប្តីតាំងពីអាយុក្មេងៗបែបនេះ គឺមកពីនាងមិនសូវចេះគិតនេះឯងឬ? នេះនាងមកនិយាយបើកផ្លូវថា នាងជាចោរលួចទៀតឬ មិនចេះនិយាយការពារមិត្តភក្តិទាល់តែសោះហើយមិត្តខ្ញុំ។ រំពេចនោះសំឡេងរបស់ ឈីតខាមែន ក៏និយាយឲ្យនាងសប្បាយចិត្ត លែងសូវខឹងមិត្តភក្តិ។

«មិនមានអីនោះទេណា ខ្ញុំគ្រាន់តែឃើញវាស្អាតទើបសួរសាកមើលនោះណា»

«គឺ យ៉ុនហ៊ី ចង់ពិភាក្សាទាក់ទងជាមួយនឹងគ្រឿងប្រដាប់របស់ព្រះនាង



ម្ចាស់ ទេមិន នោះណា ឈីតខាមែន»

រំពេចនោះរឿងដែលគិតថា ពិបាកប្រែក្លាយទៅជាស្រួលវិញគ្រាន់តែមួយប៉ព្រិចភ្នែកដោយសារតែ ឈីត និយាយចេញទៅយ៉ាងប្រាកដប្រជាដែរនោះណា។

«នាងចង់ចូលទៅសិក្សាបេតិកភណ្ឌនៅខាងក្នុងរាជវាំងឬ?»

«ចាស...ចាស...ត្រូវហើយ ហើយខ្ញុំក៏ចង់ធ្វើការសម្ភាសន៍បុគ្គលដែលដឹងច្រើនដូចលោក ឈីតខាមែន នោះផងដែរ»

«នាងរៀនទាក់ទងនឹងផ្នែកបុរាណវិទ្យាមែនដែរទេ?»

«ត្រូវហើយ ខ្ញុំរៀនទាក់ទងនឹងបុរាណវិទ្យា នៅសល់តែមួយមុខវិជ្ជាដែលកំពុងតែធ្វើសារណានេះឯងនឹងចប់ហើយ»

«បើអីចឹង នាងប្រាកដជាមានចំណេះដឹងទាក់ទងនឹងការថែរក្សាការពារព្រមទាំងកែច្នៃប្រដាប់ប្រដាវត្ថុបុរាណហើយមែនដែរទេ យ៉ុនហ៊ី?»

«ចាសត្រូវហើយណា នោះហើយគឺជាគោលដៅចម្បងនៃការសិក្សាផ្នែកបុរាណវិទ្យានោះអី ហើយខ្ញុំក៏មិនអន់ដែរនោះណា រៀនបាននិទ្ទេសអេ រាល់ឆ្នាំដែរ មិនអួតនោះទេ»

ដោយសារតែភាពពូកែនិយាយ និងអំពើល្អៗរបស់ខ្លួនបែបនេះហើយ តើមិនឲ្យនាងអួតបានដោយរបៀបណាទៅ រហូតដល់ថ្នាក់មិត្តស្រីរបស់នាងកេះមិនឲ្យនិយាយច្រើនពេកនោះណា។

«នែ៎ យ៉ុនហ៊ី!!! អួតតិចៗបានហើយណា យើងខ្មាសគេណាស់ដែលមានមិត្តភក្តិពូកែខាងអួតដូចជាឯងនោះ»

«ហេយ!!! យើងមិនមែនអួតទេណា វាជាការពិត»

យ៉ុនហ៊ី បែរទៅខ្សឹបប្រាប់មិត្តភក្តិនាងតិចៗវិញ នាងហាក់បីដូចជាមានអារម្មណ៍ទាស់ចិត្តមែនទែនតែម្តង នៅពេលដែលមិត្តនាងតែងតែនិយាយកាត់សម្តីនៅពេលដែលនាងកំពុងតែរក់នឹងការនិយាយនោះ ហើយរំពេចនោះសំឡេងគួសន្ទនាក៏បានលាន់ឮឡើងភ្លាម។

«ខ្ញុំកំពុងតែរកអ្នកដែលមានចំណេះដឹងខាងផ្នែកហ្នឹងផង ដើម្បីយកទៅថែរក្សាជួសជុលវត្ថុបុរាណ តើនាងអាចទទួលយកការងារនេះបានដែរទេ ?»

«ពិតមែន ? ឈឹតខាមែន ខ្ញុំរីករាយនឹងទទួលការងារនេះតែម្តង»

យ៉េស !!! អ្នកណាទៅភ្លើមិនទទួលដែរទៅ បានទាំងលុយ យ៉ុនហ៊ី គិតរំពេចនោះសំឡេង ហាន់ណា ដែលរៀនផ្នែកបុរាណវិទ្យាមិនចប់ ព្រោះមានស្វាមីមុននោះ ក៏បានខ្សឹបដាក់ត្រចៀកនាងភ្លាម។

«យ៉ុនហ៊ី ឯងមិនគិតសិនទេអី !»

«យើងគិតហើយហើយ»

«គិតពេលណាទៅ ? បើយើងឃើញឯងទទួលពាក្យនោះភ្លាមសោះ»

«អឺ ! ណ្ហើយចុះណា យើងជាមនុស្សដែលគិតលឿននោះណា»

«ហើយចុះឯងទៅនៅជាមួយគេនោះ ?»

«យើងទៅនៅហើយ មិនមានអីត្រូវពិបាកគិតផង»

ពួកនាងទាំងពីរយកដៃបាំងមាត់ខ្សឹបខ្សៀវគ្នា ពេលនោះសំឡេងរបស់ ឈឹតខាមែន ក៏បានលាន់ឮឡើងជាការសរុបសេចក្តី។

«សរុបមក ខ្ញុំអនុញ្ញាតឲ្យនាងចូលធ្វើសារណាបញ្ចប់ការសិក្សារបស់នាងនិងឲ្យចូលទៅក្នុងរាជវាំងខ្ញុំបាន តែនាងបានយល់ព្រមទទួលការងាររបស់ខ្ញុំហើយណា បើអីចឹងស្អែកនេះខ្ញុំនឹងឲ្យកូនចៅមកទទួលនាងទៅស្នាក់នៅឯសេតវិមានរបស់ខ្ញុំ វាងាយស្រួលក្នុងការធ្វើការងារជាង»

ឈឹតខាមែន សម្លឹងមើលមុខមនុស្សស្រីដែលឈរនៅចំពីមុខគេនោះ ពេលនេះនាងសើចញញឹមដោយអារម្មណ៍សប្បាយចិត្តជាពន់ពេក។ ផ្ទៃមុខដែលមុតមាំនោះបានបញ្ចេញស្នាមញញឹមសាជាថ្មីម្តងទៀត គេគិតថា ប្រហែលជាសមបំណងទៅតាមអំណាចមន្តស្រាហើយមើលទៅនោះ គេគិតក្នុងចិត្តចប់រួចក៏លាអ្នកទាំងអស់គ្នាចេញទៅ។

«មានអារម្មណ៍ថា ខ្យល់ព្យុះនោះបានស្ងាត់ហើយ ខ្ញុំប្រហែលជាត្រូវលាអ្នកទាំងអស់គ្នាត្រឹមនេះទៅចុះណា»



បុរសមាឌធំខ្ពស់នោះក្រោកឈរឡើង នាំឲ្យអ្នកទាំងអស់គ្នាក៏នាំគ្នាក្រោកតាម មួយភ្លែតក្រោយមកម្ចាស់សេតវិមានក៏បាននាំមុខគេដើរចេញទៅខាងក្រៅ ធ្វើឲ្យ យ៉ុនហ៊ី ដែលសមតាមបំណងនោះលោតកញ្ឆេងប្រាណដោយភាពសប្បាយចិត្តជាខ្លាំងនៅក្រោយខ្នង ឈឹតខាមែន។

«យេ !! ហេតុអីក៏មានលាភពីរជង់បែបនេះទៀត ហាន់ណា»

«អឺ !!! យើងជួយរីករាយជាមួយឯងផងណា ហើយឯងក៏កុំទៅលោតកញ្ឆេងរហូតដល់ធ្វើឲ្យរបស់របរបស់គេខូចខាតអស់ណា អំ !!! ហើយម្យ៉ាងទៀតឯងក៏កុំគិតចង់លួចរបស់របរគេឲ្យសោះណា យ៉ុនហ៊ី !!!»

ហាន់ណា និយាយណែនាំមិត្តមិនទាន់ទាំងចប់សេចក្តីផង នាងហាក់បីដូចជាមានអារម្មណ៍ថា មានអ្វីរឹងមកគោះក្បាលនាង។

«នេះនែ !! ឯងមាត់គ្មានគម្របទាល់តែសោះ»

«អូយ !!! នេះឯងខោកក្បាលយើង ?»

«ខួរក្បាលឯងរវល់តែគិតរឿងលើគ្រែឬ បានជាគិតថា យើងចង់ទៅលួចរបស់របរបស់គេនោះ»

«ហើយចុះឯងមិនអីចឹងទេ ?»

«នៅមកនិយាយទៀត »

យ៉ុនហ៊ីអត់ទ្រាំមិនលើកដៃទៅខោកក្បាលមិត្តទៀតមិនបានសោះឡើយ តែក៏ត្រូវដកដង្ហើមធំ ព្រោះនាងគិតថា នេះគឺជាបំណងល្អរបស់មិត្តភក្តិនោះណា ទោះបីជាមានអាការអាឡូកអាឡឺតតិចតួចក៏ដោយចុះ។

«យើងគ្រាន់តែនិយាយលេងតើស ចុះបើយើងបារម្ភពីឯងនោះអី»

«អីចឹងល្អហើយណា តែឯងកុំប្រមាថឲ្យសោះណា ឮទៅទាំងមនុស្សទាំងខ្មោចណា»

«នែ !! ឯងហ៊ានភ្នាល់ជាមួយយើងដែរទេ ថាពិន្ទុសារណារបស់យើងប្រាកដជាលើសគេជាក់ជាមិនខានទេណា ហើយលោកគ្រូប្រាកដជាចម្លែកចិត្តខ្លាំងដែរណាចាំមើលទៅ»

ហាន់ណា ត្រូវអង្គុយស្តាប់ទាំងតឹងទ្រូងនៅពេលដែលមិត្តនាងនិយាយរៀបរាប់ដូចសត្វសារិកាកែវ ហើយនាងក៏សប្បាយចិត្តជួសមិត្តដែរដែលមានសំណាងបែបនេះ។ ភាពអស្ចារ្យមួយគឺបានឃើញ ឈើតខាមែន បង្ហាញខ្លួន តែនៅពេល ឈើតខាមែន ធ្វើដំណើរចេញពីទីនេះផ្ទៃមេឃក៏ប្រែជាភ្លឺស្រឡះវិញតែម្តង។

ក្រោយពីនាងបានជូនមិត្តភក្តិត្រឡប់ទៅវិញហើយ ហាន់ណា ក៏មានអារម្មណ៍ថា ចម្លែកចំពោះសកម្មភាពរបស់ស្វាមីនាងដែលប្រែទៅជាស្ងាត់មាត់មិនសូវនិយាយស្តីអីទាល់តែសោះ ឬក៏គេទើបតែនឹកឃើញខឹងនាងភ្លាមក្នុងការដែលនាងទាស់ចិត្តមិនព្រមបន្តស្នេហាលើគ្រែជាមួយគេនោះទេដឹង រំពេចនោះសំឡេងដ៏ស្រួយស្រែសនៃការស្រឡាញ់ស្វាមី ស្មើជីវិតរបស់នាងក៏បានបន្លឺឡើង។

«ឈើត តោះយើងឡើងទៅងូតទឹកសម្រាកនៅខាងលើតោះ!!!»

ទោះបីជាពាក្យសម្តីដែលឲ្យដៃស្វាមីរបស់នាងក៏ដោយចុះ តែសកម្មភាពរបស់ស្វាមីនៅតែស្ងាត់ស្រងំដដែល ប្រហែលជាគេខឹងនាងហើយមើលទៅ ដែលនាងទុកឲ្យគេតាំងអារម្មណ៍កណ្តាលផ្លូវបែបនេះនោះ តែសំឡេងគ្រលរក៏បានបន្លឺឡើង។

«បងមិនដឹងថាត្រូវធ្វើយ៉ាងណាឲ្យល្អនោះទេ ហាន់ណា»

ភរិយាដូចជានាងកំពុងតែរៀបនិយាយថា ចាំនាងជាអ្នកធ្វើក៏បានដែរជាការសុំខមាទោសដែលបានធ្វើឲ្យគេខកអារម្មណ៍នោះណា តែមិនទាន់ទាំងនាងហើបមាត់និយាយផងស្វាមីរបស់នាងក៏និយាយកាត់មុនទៅហើយ។

«តើ យ៉ុនហ៊ី មិនដឹងត្រូវជួបបញ្ហាអ្វីខ្លះដែរទៅហ្ន៎!!!»

«ឈើត នេះបងកំពុងតែគិតរឿង យ៉ុនហ៊ី ទេ ខ្ញុំស្មានតែបងគិតពីរឿង... អ៎...រឿងដែលខ្ញុំមិនតាមចិត្តបងនោះហើយតើស»

បិះបាក់មុខហើយតើសខ្ញុំ! នាងសម្លឹងមើលមុខស្វាមីដែលមើលទៅហាក់បីដូចជាមានរឿងអីពិបាកចិត្ត។ នាងខំនិយាយបង្អើបគេប៉ុណ្ណឹងហើយតែគេនៅមិនដឹងរឿងទៀត នេះវាខុសស្រឡះពីចរិតពិតគេណាស់។



«អូនដឹងដែរទេថា ឈើតខាមែន ជាមនុស្សប្រុសដែលមិនចូលចិត្តឲ្យអ្នកណាចូលទៅជិតគេបាននោះឡើយ បងដូចជាចាប់ផ្តើមបារម្ភពី យ៉ុនហ៊ី ហើយ»

«ជាមនុស្សប្រុសដែលហាមឃាត់ឬ? ម៉េចបានជាគេហាម ហើយអ្នកណាគេជាអ្នកហាមដែរទៅ?»

ហាន់ណា កើតមានអារម្មណ៍សង្ស័យឡើងនៅពេលដែលស្វាមីប្រាប់បែបហ្នឹង។

«វាហាក់បីដូចជារឿងស្រពិចស្រពិលនោះណាអូន តែវាក៏បានកើតឡើងពិតៗហើយដែរ»

«បងមានន័យថាម៉េចដែរទៅ អធិប្បាយឲ្យច្បាស់ៗជាងនេះបន្តិចមើសឈើត»

ស្វាមីគេគិតថា ប្រពន្ធគេខួរក្បាលបែបហ្នឹងឬ ទើបបានជានិយាយមិនយល់ន័យ។

«គឺបែបនេះណា មនុស្សស្រីដែលចូលទៅជិត ឬក៏មានទំនាក់ទំនងជាមួយនឹង ឈើតខាមែន គ្រប់រូបតែងតែបញ្ចប់ជីវិតគ្រប់គ្នាទាំងអស់ណា»

«ហា!!! ហេតុអីក៏បងមិនព្រមប្រាប់ខ្ញុំ!! មិនប្រាប់ យ៉ុនហ៊ី មុនសិនដែរទៅ»

ឈើត កំពុងតែសម្លឹងមើលភរិយាដែលពេលនេះមានទឹកមុខពិបាកចិត្តថែមទាំងមានកង្វល់ជាខ្លាំង គេមើលឃើញយ៉ាងច្បាស់តែម្តង មុននឹងធ្វើការអធិប្បាយបន្តទៀត។

«ពីដំបូងបងគិតថា យ៉ុនហ៊ី គ្រាន់តែធ្វើការសម្ភាសទាក់ទងនឹងសារណាតែប៉ុណ្ណោះ ពេលធ្វើសារណារួចឲ្យរួចគ្នាតែម្តងនោះណា មិននឹកស្មានថាត្រូវចូលទៅមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលក្នុងការងារជាមួយគេថែមទៀតនោះណា វាលឿនពេក លឿនជាងការដែលបងគិតដល់ទៅទៀតណា»

“អូយស្លាប់ហើយ មិនកើតទេ មិនកើតទេ...ខ្ញុំនឹងទូរស័ព្ទទៅប្រាប់យ៉ុនហ៊ីឥឡូវនេះណា»

ដៃដ៏ទន់ភ្លន់របស់កិរិយាស្អាតរបស់គេ បានលើកទូរស័ព្ទចុចទៅកាន់មិត្តនាងយ៉ាងញាប់ដៃ យឺសសស... ដោយសារតែព្យុះស៊ុណាមិហ្នឹងទេដឹងបានជាទាក់ទងមិនបានសោះ។



www.srolanhkhmer.com



## ...២...

## សេតវិមានចម្លែក

ឡានបើកឆ្លងកាត់សមុទ្រខ្សាច់ ដែលមានកម្តៅថ្ងៃក្តៅខ្លាំង ចាំងពន្លឺព្រាកៗ មុននឹងឆ្លងកាត់ទៅដល់ព្រៃស្ងាត់ដ៏ធំល្វឹងល្វើយ ស្រីស្រស់សម្លឹង មើលទៅកាន់ ផ្លូវព្រៃដែលនាងហាក់ដូចជាធ្លាប់ឃើញ។ នាងសម្លឹងមើល ទៅខាងមុខឡានដែលកំពុងតែបើកយ៉ាងលឿន មើលឃើញដើមត្នោតច្រើនតម្រៀបជួរគ្នាមិនដាច់កន្ទុយភ្នែក ហើយគ្រាន់តែមួយប៉ប្រិចភ្នែកសោះ ឡានមួយគ្រឿងនោះក៏បានមកឈប់ចតនៅខាងមុខនៃសេតវិមានមួយដ៏ធំស្កឹមស្កៃ។

យ៉ុនហ៊ី ក្រឡេកភ្នែកមើលទៅកាន់បរិវេណជុំវិញនោះសាជាថ្មីម្តងទៀត នាងនៅតែមានអារម្មណ៍ថា ដូចជាធ្លាប់ឃើញដដែលចំពោះអ្វីដែលនាងបានឃើញ សូម្បីតែសេតវិមានមួយនេះ ស្រីស្រស់ក៏ចាប់ផ្តើមឈានជើងដើរចូលទៅ

យ៉ាងយឺតៗទៅក្នុង ព្រមទាំងអារម្មណ៍មួយនឹកឃើញភ្លាម ធ្វើឲ្យនាងភ្ញាក់ខ្លួនឲ្យព្រើត ព្រឺសម្បុរខ្លាក។

«នេះ! នេះជាសេតវិមាននៅក្នុងក្ដីសុបិនតើស តើវាម៉េចនឹងអាចទៅរួចដែរទៅ?»

**គ្រែតតតតត...**

ទ្វារនៃសេតវិមាននោះរបើកចេញព្រមជាមួយនឹងសំឡេងយ៉ាងឮៗ នៅពេលនោះនាងយល់ថា ហេតុអីបានជាសាំងតែមួយដំណក់សោះ មិនព្រមយកមកដាក់កុំឲ្យវាឮទៅ មានហានៈដល់ទៅមហាសេដ្ឋីចេះកំណាញ់ទៅកើត រួចនាងក៏ភ្ញាក់ខ្លួនឲ្យព្រើតនៅពេលដែលមានសំឡេងអញ្ជើញពីស្រីបម្រើក្នុងសេតវិមានម្នាក់បានលាន់ឮឡើង។

«អញ្ជើញខាងក្នុងចាស!!»

«យីស!! មកតាំងពីអង្កាល់ ភ័យសឹងអី»

«ឈឹតខាមែន នៅចាំនាងនៅខាងក្នុងចាស»

យ៉ុនហ៊ី សម្លឹងមើលមនុស្សស្រីអ្នកបម្រើដែលមិនព្រមតបសំណួរនាងទាល់តែសោះ គិតខ្លួនឯងទៅចុះថា ស្រីបម្រើនោះប្រហែលជាចូលមករកនាងនៅពេលនាងវង្វេងតែកាំងភ្លឹកចំពោះអ្វីៗ ដែលស្រដៀងទៅនឹងការយល់សប្តិរបស់នាងនោះហើយ រួចនាងក៏ដើរតាមស្រីបម្រើនោះទៅ តែនាងក៏ចម្លែកចិត្តសាជាថ្មីម្ដងទៀត នៅពេលបានឃើញកម្រាលព្រំពណ៌ក្រហមដែលក្រាលនៅតាមផ្លូវដើរ។ ទៀតហើយឬ! នេះជាទីកន្លែងក្នុងសុបិនរបស់នាងទៀតហើយ នាងគិតព្រមទាំងនិយាយឡើង។

«តើនេះជាស្អីទៅ!!!»

«ចាស!! អីគេដែរ នាងនិយាយអី!!!»

«មានតើស!!»

នាងចង់និយាយថា មានរឿងអីដែរទៅហ្នំ! ចុះបើនាងនិយាយរៀបរាប់ពីការយល់សប្តិចេញទៅហើយមិនមានអ្នកណាជឿនោះ នាងនឹងក្លាយទៅជា



មនុស្សឆ្កួតក្នុងកែវភ្នែករបស់មនុស្សគ្រប់គ្នា។ រួចនាងក៏នឹកឃើញភ្លាមពីគោលបំណងដែលនាងត្រូវមកកាន់ទីនេះ គឺដើម្បីស្វែងរកព័ត៌មានធ្វើសារណា។ ភ្លាមនោះនាងក៏ភ្ញាក់ពីការស្រមៃនោះដោយសារសំឡេងសួរដែលៗរបស់ស្រីបម្រើព្រមទាំងប្រើទឹកមុខសង្ស័យៗទៀតផង។

«តើមានបញ្ហាអីដែរចាស!!»

«អត់ អត់មានអីទេ»

យ៉ុនហ៊ី សម្រេចចិត្តក្រឡាស់ពាក្យសម្ដី ហើយសម្លឹងមើលមុខស្រីបម្រើដែលដើរនាំមុខនាងទៅ ជើងទាំងពីររបស់នាងដើរមួយៗយឺតៗមិនឮសំឡេងសោះនៅលើកម្រាលព្រំសំដៅទៅកាន់ខាងលើនៃតួសេតវិមាន ហើយឈានជើងទៅកាន់បន្ទប់មួយដោយមិនដឹងខ្លួនដោយមានសំឡេងក្រលួចៗ លាន់ឮក្នុងប្រព័ន្ធប្រសាទរបស់នាងផងដែរ។

**"រាងកាយព្រមទាំងវិញ្ញាណរបស់នាងជារបស់យើង ហា..ហា..ហាស់"**

«អ្វី.....អ្វីទៅ នាងនិយាយពីស្អី !!!»

«ចាស អីគេអ្នកនាង ខ្ញុំមិនបាននិយាយអីឯណាអ្នកនាង»

យ៉ុនហ៊ី សួរទៅកាន់ស្រីបម្រើដែលនាំផ្លូវនាងនោះ តែស្រីបម្រើម្នាក់នោះបែរជាមកមើលនាងដោយងឿងឆ្ងល់ជាពន់ពេក ព្រមទាំងលើកដៃឡើងអេះក្បាល នាងក៏ពិតជាចង់លើកដៃអេះក្បាលដូចគ្នាដែរ នៅពេលក្ដីសុបិនរបស់នាងប្រែក្លាយមកជាការពិតបែបនេះនោះ ហើយតើនាងត្រូវជួបប្រទះនូវអ្វីខ្លះទៀតដែរទៅហ្នំ!!! មិនទាន់ទាំងបាននិយាយស្អីឲ្យចប់ផង សំឡេងគ្រលរមួយក៏បានលាន់ឮឡើង។

«មកដល់ហើយ យ៉ុនហ៊ី!»

យ៉ុនហ៊ី សម្លឹងមើលមុខម្ចាស់សំឡេងនោះដែលហៅឈ្មោះពិតរបស់នាងយ៉ាងពេញៗមាត់ កែវភ្នែករបស់នាងសម្លឹងទៅប៉ះជាមួយកែវភ្នែកមួយគូដ៏មានមន្តស្នេហ៍ដែលកំពុងតែអង្គុយនៅលើកៅអីនៅតុធ្វើការរបស់គេ។ នាងមើលទៅកាន់កែវភ្នែកដែលនាងធ្លាប់ឃើញនោះ ទោះបីជាធ្លាប់ស្គាល់តែម្ដងហើយក៏នាង

នៅតែរៀបពាក្យសម្ដីបែបសុភាពដើម្បីបញ្ចប់ការសរសេរសារណាឲ្យបានពិរោះដែរ។

«ចាស មកដល់ហើយ ហើយក៏ត្រៀមខ្លួនរួចជាស្រេចក្នុងការប្រតិបត្តិការងារដែរ»

«នាងចង់សម្រាកយកកម្លាំងសិនក៏បានដែរណា»

«មិ...មិនសម្រាកល្អជាង»

តើឲ្យខ្ញុំសម្រាករបៀបណាទៅ? យ៉ុនហ៊ី គិត ចុះបើសំណួរជាច្រើនបានកើតឡើងក្នុងប្រព័ន្ធប្រសាទរបស់នាងនោះណា។ ដំបូងគឺនាងត្រូវទម្លាយអាថ៌កំបាំងក្នុងយល់សប្តិសិន ប្រហែលជាមានតែម្ចាស់សេតវិមាននេះម្នាក់ទេមើលទៅដែលអាចទម្លាយអាថ៌កំបាំងទាំងនេះបានថា គេនៅតែក្នុងសេតវិមានតែសោះ ហេតុអីក៏ចូលទៅរញ៉េរញ៉ៃលូកលាន់ក្នុងការស្រមៃរបស់នាងបាន។

«ហើយតើត្រូវចាប់ផ្ដើមដោយរបៀបណាដែរទៅ!!»

សំឡេងរអ៊ូរទាំចេញពីមាត់របស់ស្រីស្រស់ ព្រមទាំងលើកដៃអេះក្បាល រំពេចនោះសំឡេងគ្រលររបស់ម្ចាស់ផ្ទះបានលាន់ឮឡើង។

«មានអារម្មណ៍ថា នាងដូចជាមានអីមែនទេ?»

«ត្រូវហើយ ត្រូវហើយ គឺ...គឺ ...»

ហេតុអីក៏ចាប់ផ្ដើមពិបាកបែបនេះទៅហើយ ព្រមទាំងគិតថា ពេលនាងនិយាយចេញទៅ គេមិនជឿទៀតហ្នឹងណា មិនត្រឹមតែប៉ុណ្ណោះគេអាចថានាងជាមនុស្សសរសៃប្រសាទទៀតផង។ អ្វីដែលអាក្រក់ជាងនេះទៅទៀតនោះ គេប្រាកដជាគិតថា នាងជាមនុស្សឆ្កួតតែម្ដងក៏ថាបានដែរ ហើយវាប្រហែលជាការប្រថុយគ្រោះថ្នាក់ ពេលត្រូវបានគេដេញចេញពីសេតវិមាននោះណា បើមិនដូច្នោះទេ ត្រូវគេបញ្ជូនទៅកាន់មន្ទីរពេទ្យឆ្កួតទៀតនោះ តើធ្វើម៉េចទៅ? អូយ!! ឈឺខួរណាស់។ នាងអត់ទ្រាំមិនលើកដៃទៅខ្ទប់ក្បាលមិនបាន។

«នាងនិយាយមកចុះណា ខ្ញុំយល់ពីនាង!!!»

«ហា!!! លោកយល់ពីខ្ញុំ? ខ្ញុំមិនទាន់បាននិយាយអីផងហ្នឹង!»



ឈើតខាមែន សម្លឹងមុខស្រីស្រស់ គេដឹងជាងស្អីទៅទៀតថា នាងបានជួបប្រទះនូវអ្វីខ្លះក្នុងកំឡុងប៉ុន្មានខែមកនេះ យ៉ាងណាក៏ដោយចុះ ក៏គេត្រូវតែចាំតាមសង្កេតមើលសកម្មភាពរបស់នាងសិនដែរ ហើយរំពេចនោះសំឡេងដែលសម្ដែងអារម្មណ៍សប្បាយចិត្តក៏បានលាន់ឮឡើង។

«សូម្បីតែរឿងការយល់សប្តិឬ?»

«ត្រូវហើយ សូម្បីតែក្នុងក្ដីសុបិនរបស់នាងទៀតផង យ៉ុនហ៊ី»

ស្រីស្រស់ញញឹមព្រមទាំងទាញកៅអីខិតជិតគេខ្លាំងបន្តិចដើម្បីភាពជឿជាក់ នាងប្រហែលជាមិនត្រូវបានគេដេញចេញពីសេតវិមាននេះដោយសារតែគិតអីឆ្កួតៗនោះទេ ហើយរំពេចនោះរឿងរ៉ាវទាំងឡាយក្នុងក្ដីសុបិនរបស់នាងក៏បានអធិប្បាយយ៉ាងវែងឆ្ងាយចេញពីមាត់របស់នាងភ្លាម។

«មិនគួរឲ្យជឿទាល់តែសោះថា សកម្មភាពនៃក្ដីសុបិនទាំងឡាយរបស់ខ្ញុំអាចយកមកប្រើក្នុងសេតវិមាននេះបាននោះទេ»

«នាងនិយាយមកនេះចប់ហើយឬ?»

«នៅទេ!! អូ ចប់ហើយៗៗៗ»

ឆ្កួតទេអី! អ្នកណាទៅភ្លើនិយាយរៀបរាប់ពេលដែលត្រូវបានគេថើបដែរទៅ ជាពិសេសនៅចំពោះបុគ្គលក្នុងក្ដីសុបិនរបស់នាងនោះគឺ ឈើតខាមែន ដែលកំពុងតែអង្គុយនៅចំពីមុខនាងដែរនោះណា ហើយរំពេចនោះផ្ទៃមុខសង្ហាក៏បានប្រែទៅជាក្រហមព្រឿងៗមួយរំពេច។

«សរុបមក តើចប់ឬក៏មិនចប់ដែរទៅ!»

ហើយគេសួរអីក៏សួរយ៉ាងនេះទេនៀក នាងខំបិទបាំងបំផុតហើយណា យ៉ុនហ៊ី សម្លឹងមើលទៅគាត់កែវភ្នែកមួយគូដ៏សែនមោះមុតនោះ ធ្វើឲ្យនាងហាក់ដូចជាអង្គុយគួទមិនជាប់និងកៅអីសោះឡើយ រំពេចនោះក៏មានសំឡេងអីមួយធ្វើឲ្យនាងភ្ញាក់ឲ្យព្រើត នាងក៏ហាក់ទៅឱបបុរសសង្ហាដែលនៅចំពោះមុខនាងភ្លាម។

«**ចាំងងងង**!!!»

«អូយយយ!!!»

មិនគួរឲ្យជឿទាល់តែសោះថា នាងអាចហក់ទៅបានឆ្ងាយដល់ថ្នាក់ហ្នឹង រូបរាងដ៏ធំនោះក៏បានលើកដៃទាំងពីរមកឱបនាងជាប់ដូចគ្នាដែរ ព្រមទាំងបិទភ្នែកត្រឹមៗ ខណៈពេលនោះនាងហាក់បីដូចជាមានអារម្មណ៍ថាមានអ្វីកក់ក្ដៅដែលឱបអង្អែលលួងអារម្មណ៍គិតភ័យលើខ្លួនរបស់នាង។

«យ៉ុនហ៊ី យ៉ុនហ៊ី នាងមិនអីទេមែនទេ!!»

«សំឡេងនោះ...ជាសំឡេងសេតវិមានរលំទេតើស»

«មិនមែនជាសំឡេងរលំសេតវិមានទេណា ជាសំឡេងរន្ទះបាញ់តើស នាងមិនបាច់ភ័យទេ»

«សំឡេងរន្ទះបាញ់ឬ? តើវាម៉េចនឹងអាចទៅរួចទៅ?»

«មើលទៅនាងដូចជាខ្លាចរន្ទះបាញ់ណាស់ហ្ន!!!»

«ខ្ញុំគ្រាន់តែ...គ្រាន់តែភ័យតើស»

នាងទៅភ័យធ្វើអីដែរទៅ បើនាងមិនដែលទៅស្បថជាមួយអ្នកណាផង មានតែម៉្យាងប៉ុណ្ណោះដែលនាងខ្លាចខ្លាំងបំផុតក្នុងជីវិតរបស់នាង នោះគឺខ្លាចខ្មោច។

«តើម៉េចនឹងអាចទៅរួចដែរទៅ បើពេលដែលខ្ញុំមកនៅខាងក្រៅនោះមេឃក្ដៅហួតហែងសឹងអី»

«ម៉េចមិនអាចទៅរួចដែរទៅ បើនៅខាងក្រៅនោះមេឃឡើងងងឹត ថែមទាំងមានព្យុះភ្លៀងខ្លាំងផងដែរ បើមិនជឿ ខ្ញុំបើកវាំងននឲ្យនាងមើលក៏បានដែរណា»

នាងនៅតែមិនស្ងប់ចំពោះពាក្យសម្ដីរបស់គេដដែល ព្រោះពេលដែលនាងមក មេឃនៅស្រឡះថែសសោះនោះណា ហើយវាអាចកើតមានខ្យល់ព្យុះនៅឯនាយសមុទ្រខ្សាច់នេះបានដោយរបៀបណាទៅ រំពេចនោះនាងក៏បានឮសំឡេងខ្សឹបតិចៗដាក់ត្រចៀករបស់នាង។

«ចាប់ពីពេលនេះតទៅនាងប្រហែលជាត្រូវជួប ត្រូវឃើញអ្វីប្លែកៗច្រើន



ជាងនេះទៀតណា យ៉ុនហ៊ី»

កែវភ្នែកមួយគូនោះសម្លឹងមើលបបូរមាត់ក្រហមរងាលដែលកំពុងតែធ្វើការអធិប្បាយជាបន្តបន្ទាប់ តែបបូរមាត់គេនោះនៅមិនសូវជាឆ្ងាយពីបបូរមាត់របស់នាងប៉ុន្មានដែរទេ កែវភ្នែកបញ្ចេញមន្តស្នេហ៍ដូចក្នុងសុបិនរបស់នាងទៀត អ្វីដែលសំខាន់គឺបបូរមាត់របស់គេ គឺកំពុងតែឱនមកថើបបបូរមាត់នាងទៀតផង។

«ទេ...ទេ...មិនមែនបែបហ្នឹងទេ មែនទេ ហេតុអីក៏ដូចក្នុងសុបិនរបស់ខ្ញុំម្ល៉េះ?»

យ៉ុនហ៊ី ព្យាយាមតាំងសតិស្មារតី រួចក៏រុញច្រានមនុស្សប្រុសរូបរាងខ្ពស់ធំនោះចេញពីនាង ហើយតើនាងឡើងមកអង្គុយលើភ្លៅគេតាំងពីពេលណាដែរទៅនៀក នេះនាងខ្លាចរន្ទះរហូតដល់ថ្នាក់ហក់ឡើងជិះលើភ្លៅគេឬ? គិតចប់ ស្រីស្រស់ក៏ប្រញាប់ចុះចេញពីភ្លៅរបស់ម្ចាស់សេតវិមាននោះភ្លាម អូយស្លាប់ហើយខ្ញុំ!! តើខ្ញុំធ្វើមុខបែបណាទៅនៀកដែលហក់ទៅជិះលើភ្លៅគេបែបហ្នឹងនោះ ខ្មាសគេណាស់មិនដឹងត្រូវយកមុខទៅទុកឯណានោះទេខ្ញុំអើយខ្ញុំ។

ឃើតខាមែន កែស្ថានការណ៍នៃការអៀនខ្មាសរបស់ភាគីស្រីដោយក្រោកទៅបើកវាំងននទៅបង្អួច ធ្វើឲ្យឃើញនូវដំណក់ភ្លៀង និងពន្លឺផ្លេកបន្ទោរព្រាកៗយ៉ាងខ្លាំងតែម្ដង ធ្វើមើលតែពិភពលោកនេះចង់រលំរលាយអីចឹង។

«មិនគួរឲ្យជឿទាល់តែសោះឡើយថា នៅសមុទ្រខ្សាច់ស្ងួតហួតហែងនេះមានព្យុះភ្លៀងធ្លាក់ខ្លាំងបានដល់ថ្នាក់នេះនោះ»

«ចុះខ្ញុំបានប្រាប់នាងហើយថា ចាប់ពីពេលនេះតទៅនាងនឹងបានជួបបានឃើញនូវអ្វីដែលប្លែកៗជាងនេះច្រើនទៀតណា»

កែវភ្នែកមួយគូនោះសម្លឹងមើលស្រីស្រស់ ដែលកំពុងតែមានអារម្មណ៍វិលវល់ បើជាជោគវាសនាទេវតាកំណត់មែន គឺមានតែគេ និងនាងហើយដែលអាចបំបែកវាសនាដែលទេវតាកំណត់នេះបាន។

«ថ្ងៃនេះប៉ុណ្ណឹងសិនចុះណា យ៉ុនហ៊ី»

«ចាស!! ប៉ុណ្ណឹងសិន»

ឈិតខាមែន អត់ទ្រាំមិនសើចញញឹមចំពោះការផ្ដល់ចម្លើយនេះមិនបាន ព្រោះទាំងអារម្មណ៍ទាំងវិញ្ញាណមិនបាននៅក្នុងខ្លួននាងឡើយ នាងប្រហែលជាកំពុងតែវិលវល់ចំពោះហេតុការណ៍ដែលបានជួបនោះហើយមើលទៅ។

«ត្រូវហើយប៉ុណ្ណឹងសិនចុះណា ខ្ញុំមើលទៅនាងហាក់ដូចជាហត់នឿយខ្លាំងហើយ ហើយអ្វីដែលសំខាន់នាងបាននិយាយរៀបរាប់រឿងរ៉ាវក្នុងក្ដីសុបិនរបស់នាងចប់ហើយដែរ»

យ៉ុនហ៊ី ចាប់ផ្ដើមមានសតិឡើងវិញ នាងបានប្រាប់ទៅគេអស់ហើយឬថា ក្នុងក្ដីសុបិនរបស់នាងមានឈុតឆាកស្នេហាឱបថើបដែរនោះ ហើយគេក៏ប្រហែលជាដឹងដែរហើយថា បុគ្គលដែលថើបនាងនោះជាអ្នកណា តែនេះនាងបិះនឹងបានថើបពិតៗផងដែរ ហើយអារម្មណ៍ប្លែកៗក៏បានកើតឡើង រហូតដល់ថ្នាក់នាងត្រូវតែរកផ្លូវដោះស្រាយវិញដោយខ្លួនឯងទើបបាន។

«ខ្ញុំ...ខ្ញុំទៅសម្រាកសិនក៏ល្អម្យ៉ាងដែរ ខ្ញុំអស់កម្លាំងពិតមែននោះណា»

ផ្ទៃមុខមុតមាំនោះបញ្ចេញស្នាមញញឹម រំពេចនោះសំឡេងទ្វារក៏បានបើកចេញ ថែមទាំងបានឃើញនូវរូបភាពរបស់អ្នកបម្រើម្នាក់ដែលដើរចូលមកដោយនាងមិនទាំងដឹងទាល់តែសោះថា ឈិតខាមែន បានឲ្យសញ្ញាទៅកាន់កូនចៅគេឲ្យចូលមកតាំងពីពេលណានោះទេ។

«ជូនី នាំ យ៉ុនហ៊ី ទៅកាន់បន្ទប់សម្រាក ហើយមើលថែនាងឲ្យបានល្អផងណា»

«ចាស លោក **ឈិត** អញ្ជើញអ្នកនាង យ៉ុនហ៊ី»

ចប់សម្ដីទទួលរបស់នារីបម្រើ យ៉ុនហ៊ី ក៏បានដើរតាមនាងទៅ។ ខាមែន ដកដង្ហើមធំចេញមក ក្រសែភ្នែកហាក់បីដូចជាកំពុងតែគិតអ្វីម្យ៉ាង។

គេអង្គុយលើកៅអីផ្អែកខ្លួនងើយមុខទៅខាងលើបន្តិច ហើយនឹកគិតដល់រូបភាពដែលបិតារបស់គេបានបន្សល់ទុកនូវវង្សត្រកូល ដែលត្រូវភ្ជាប់មកជាមួយនូវអំណាចមន្តត្រា ប្រៀបបីដូចជារង់ចាំពេលវេលាឲ្យគេមកដោះ មុន



ពេលបិតារបស់គេបានផុតជីវិតទៅមួយថ្ងៃ ក្រោយពេលគាត់រាយរ៉ាប់ប្រាប់នូវរឿងរ៉ាវទាំងឡាយនោះរួចរាល់។

(ឈិតខាមែន ឯងចូលមកជិតយើងមក!!)

(លោកប៉ា តើនោះជាស្អីគេដែរទៅ?)

ឈិតខាមែន សម្លឹងមើលទៅកាន់ស្បែកសត្វមួយប្រភេទ ដែលសរសេរជាភាសាអ៊ីស្លាមអាចដឹងបានខ្លះៗថា នោះគឺជាគម្ពីរវេទមន្តអ្វីម្យ៉ាង គ្រាន់តែគេក្រឡេកភ្នែកមើលក៏មានអារម្មណ៍ថា ក្រដាក់ដល់បេះដូងខាងក្នុងបាត់ទៅហើយ

(ឈិតខាមែន មានតែឯងម្នាក់ប៉ុណ្ណោះដែលអាចរំដោះអំណាចមន្តត្រានេះចេញបានណាកូន)

(អំណាចមន្តត្រាឬលោកប៉ា ហើយវាជាស្អីដែរទៅ?)

ឈិតខាមែន សម្លឹងមើលមុខជីសែនរាបស្មើរបស់បិតាគេភ្លាមពេលនោះ គាត់កំពុងតែនិយាយរៀបរាប់ពីដើមកំណើតដំបូងបង្អស់នៃត្រកូលរបស់ពួកគេ ទើបបានជាគេត្រូវតាំងចិត្តស្ដាប់ដូចគ្នាដែរ។

(វាជាស្នៀតសក់របស់ព្រះនាងម្ចាស់ ទេមីន បុត្រីរបស់ស្ដេចនៃ **ក្សត្រ វីអាប់ឌុនអ៊ីមក៏មចាហាម** ដែលមានឈ្មោះត្រកូលដើមគឺ **អ៊ីមក៏មចាក៏ម** របស់យើងនោះណា **ឈិតខាមែន**)

(ត្រកូលដើមឬ លោកប៉ា!)

(ត្រូវហើយ វាកើតឡើងរាប់ពាន់ឆ្នាំមកហើយណាកូន)

ឈិតខាមែន ដឹងបានខ្លះៗដែរថា ខ្លួនឯងគឺជាខ្សែស្រឡាយនៃរាជវង្ស តែសព្វថ្ងៃនេះគេគឺជាជនសាមញ្ញមួយរូបតែប៉ុណ្ណោះ។

(កាលពីដើមឡើយនោះគឺព្រះនាងម្ចាស់ទេមីន បានរៀបអភិសេកជាមួយនឹងគូដណ្ដឹងព្រះអង្គ ទាំងពីរព្រះអង្គទ្រង់ស្រឡាញ់គ្នាណាស់ ព្រះគូដណ្ដឹងរបស់ព្រះនាងចង់យកចិត្តយកថ្លើមព្រះនាង ទេមីន ព្រោះជាបុគ្គលដែលទ្រង់ស្រឡាញ់ ទើបព្រះអង្គធ្វើគ្រឿងប្រដាប់គ្រប់ឈុតដើម្បីប្រគល់ជូនព្រះនាងក្នុងថ្ងៃរៀបអភិសេក។ គ្រឿងប្រដាប់ដែលទ្រង់ធ្វើថ្វាយដល់ព្រះនាង ទេមីន ជារូបសត្វក្រដាង

ស្លាប ជារូបបេះដូង ដែលមានត្បូងទទឹមពណ៌ខៀវនៅចំកណ្ដាលបន្ទោងដ៏ស្រស់ស្អាតនោះតែម្ដង )

ឈើតខាមែន នឹកគិតដល់គ្រឿងប្រដាប់ដែលគេបានថែរក្សាទុក រួមមាន ខ្សែក ក្រវិល កងដៃ គ្រឿងប្រដាប់នៅលើព្រះកេស គ្រឿងប្រដាប់សម្រាប់ពាក់នៅត្រង់ដើមដៃ ហើយជាពិសេសបន្ទោងខ្សែកដែលបានបាត់ស្រមោលគ្មានដំណឹង ហើយគេក៏ទើបតែបានឃើញបន្ទោងខ្សែកនោះនៅជាមួយនឹងមនុស្សស្រីម្នាក់ដែលនាងកំពុងតែមកបន្តផតាកម្មអាថ៌កំបាំងជាមួយរូបគេដែរនេះ។

( គូដណ្ដឹងរបស់ព្រះនាង បានចេញដំណើរទៅស្វែងរកត្បូងទទឹមទាំងឡាយនៅទីឆ្ងាយៗ ក្នុងដែនដីសមុទ្រខ្សាច់ ព្រមទាំងតាមជ្រលងផងភ្នំទាំងឡាយ ដើម្បីយកមករចនាឲ្យក្លាយទៅជាគ្រឿងប្រដាប់គ្រប់ឈុត ដែលស្រស់ស្អាតគ្មានគូប្រៀប តែសំណាងអាក្រក់ព្រះអង្គទ្រង់ឆ្លងជំងឺមួយយ៉ាងធ្ងន់ធ្ងរ តែព្រះអង្គក៏នៅតែព្យាយាមជីកគាស់ត្បូងទាំងឡាយ ដែលកម្រនឹងរកបាននោះមកច្នៃជាគ្រឿងប្រដាប់ ខ្សែកព្រមទាំងបន្ទោង រហូតដល់ថ្ងៃកំណត់នៃការរៀបអភិសេក បន្ទោងរូបសត្វត្រដាងស្លាបជារូបបេះដូងនោះ ក៏បានសម្រេចជារូបរាងយ៉ាងស្រស់ត្រកាល។ ពលទាហានបានសែងព្រះអង្គដែលនៅសល់តែដង្ហើមចុងក្រោយត្រឡប់មកវិញក្នុងថ្ងៃរៀបអភិសេក )

ឈើតខាមែន នៅពេលនេះមានអារម្មណ៍សោកសៅជាទីបំផុត គេសោកសៅរហូតដល់ថ្លាក់ទឹកភ្នែកកូនប្រុសស្រក់ហូរដោយមិនដឹងខ្លួន ប្រៀបបីដូចជាការរៀបរាប់របស់បិតាគេគឺជារឿងពិតរបស់គេអីចឹង គេតាំងចិត្តស្ដាប់បិតាគេនិយាយរៀបរាប់បន្តដោយក្ដីក្រហល់ក្រហាយចិត្តជាពន់ពេក។

( គូដណ្ដឹងរបស់ព្រះនាង ខំប្រឹងទប់ចិត្តជាទីបំផុតរហូតទាល់តែកម្មវិធីរៀបអភិសេកនោះបានបញ្ចប់ នៅពេលគេបញ្ជូនព្រះអង្គចូលបន្ទប់ផ្សំដំណេក ទើបព្រះនាងទ្រង់ដឹងថា ព្រះស្វាមីជិតសុគតទៅហើយ ព្រះនាងខូចចិត្តជាខ្លាំង ហើយទ្រង់បានប្រាថ្នាថា នឹងតាមទៅរស់នៅជាមួយព្រះស្វាមីគ្រប់ៗជាតិណាៗទាំងអស់ )



( ក្រោយពីព្រះស្វាមីព្រះនាងបានសុគតទៅ ព្រះនាងបានយកគ្រឿងប្រដាប់នោះតម្កល់ទុក ហើយអង្វរអធិដ្ឋានរៀងរាល់ថ្ងៃចំពោះគ្រឿងប្រដាប់មួយឈុតនោះ ព្រមទាំងសរសេរពាក្យអធិដ្ឋាននៅលើស្បែកសត្វមួយប្រភេទជាភាសាអ៊ីស្លាមដែលមានអត្ថន័យជាវេទមន្តអ្វីម្យ៉ាង ហើយមិនយូរប៉ុន្មានព្រះនាងក៏ចូលទីវង្គតទៅតាមព្រះស្វាមីរបស់ព្រះនាងដែរទៅ )

ឈើតខាមែន គិតដល់គ្រឿងប្រដាប់ដែលបានគាស់រកឃើញក្នុងចេតិយរបស់ត្រកូលគេ ដែលបានរក្សាទុកក្នុងហិបបិដាន់ ក្នុងបន្ទប់រក្សាសាកសពដែលមានទាំងទ្រព្យសម្បត្តិផ្សេងៗជាច្រើនទៀត មានទាំងម៉ាស់បិទមុខ មកុដ ខ្សែកចិញ្ចៀន ក្រវិល ព្រមទាំងប្រដាប់ប្រដាផ្សេងៗទៀតជាច្រើន ដែលសុទ្ធតែជាមាសសុទ្ធ និងនៅល្អព្រោះបានកប់ទុក។

ឈើតខាមែន មានអារម្មណ៍ត្រជាក់ដៃត្រជាក់ជើងនៅពេលនឹកគិតដល់ពាក្យសម្ដីសំខាន់ៗរបស់ឪពុករបស់គេ គេមិននឹកស្មានថាសម័យនេះទៅហើយនៅមានរឿងរ៉ាវបែបនេះនៅសេសសល់លើលោកនេះទៀតទេ។ ហើយអ្វីដែលសំខាន់ រូបគេត្រូវមកពាក់ព័ន្ធនឹងរឿងបែបនេះដែរ ដែលត្រូវមកថែរក្សាទ្រព្យសម្បត្តិគេ។ ហើយក៏មានព្រះនាង ទេមីន ចាប់ជាតិថ្មីនោះម្នាក់ទៀត ព្រះនាងមិនអាចចាប់ជាតិមកជាមនុស្សក្នុងភពវិស្សបាន ដោយសារតែពាក្យសច្ចា និងអំណាចមន្តស្រា ដែលព្រះនាងសន្យាជាមួយគូដណ្ដឹងព្រះនាងកាលពីអតីតជាតិនោះឯង!!! រំពេចនោះកញ្ច្រែបស់ស្រីស្រស់ក៏បានផុសឡើង

«យ៉ុនហ៊ី តើនាងមានដឹងទេថា ចាប់ពីពេលនេះទៅ នាងនឹងជួបប្រទះនូវបញ្ហាអ្វីខ្លះ ?»

ព្រមជាមួយនឹងពាក្យសម្ដីរបស់បិតាគេ ក៏បានតាំងទ្រឹងក្នុងខួរក្បាលរបស់គេផងដែរ គេខ្លួនឯងក៏មិនគិតថា ជឿដែរ ហើយមនុស្សធម្មតាក៏មិនមានអ្នកណាជឿដូចតែគេនោះដែរ។

**( ឈើតខាមែន ឯងគឺជាគូដណ្ដឹងរបស់ព្រះនាង ទេមីន ដែលចាប់ជាតិថ្មី ហើយជឿជាក់ថា ព្រះនាងម្ចាស់ ទេមីន ក៏បានតាមមកចាប់ជាតិជាថ្មីដូចគ្នាដែរ**

ឯងត្រូវតែរង់ចាំមនុស្សស្រីម្នាក់នោះក្នុងនាមជាព្រះនាង ទេមិន )

( លោកប៉ា រឿងដែលលោកប៉ាបាននិយាយរៀបរាប់មកនោះប្រហែលជាពុតំណាលៗគ្នាមកណាលោកប៉ា លោកប៉ាមិនគួរគិតជារឿងដែលប្រាកដប្រជានោះទេណាលោកប៉ា )

( ឈីតខាមែន ឯង!!! កុំនិយាយបែបហ្នឹងជាដាច់ខាតណា!!!! )

កែវភ្នែកមោះមុតរបស់លោកប៉ាគេបែរជាម៉ឹងម៉ាត់ជាមុនទៀត ដៃទាំងទ្វេរបស់គាត់បានលូកមកចាប់ស្មាគេជាប់ ហើយសំឡេងមុតមាំក៏បន្លឺឡើងយ៉ាងម៉ត់ចត់ជា៖

( ក្នុងកំឡុងគ្រិស្តសករាជ ២០០០ នេះ នឹងអាចកើតមានហេតុការណ៍ខុសធម្មជាតិមួយ ដើម្បីឲ្យឯងបានជួបជាមួយគូព្រេងរបស់ឯង ឯងជាមនុស្សប្រុសដែលត្រូវបានគេហាមឃាត់ គឺតម្រូវឲ្យស្ថិតតែក្នុងបួងមន្តគ្រាតែប៉ុណ្ណោះ! ដូច្នេះហើយក្នុងកំឡុងគ្រិស្តសករាជនេះ ចូរឯងកុំបណ្តោយឲ្យមនុស្សស្រីណាដែលមិនមែនជាគូព្រេងរបស់ឯងមកមានទំនាក់ទំនងជាមួយឯងឲ្យសោះ )

ហើយវាក៏ពិតដូចដែលបិតារបស់គេផ្តែផ្តាំមែន កាលពីលើកមុនៗ គេមិនដែលមានបញ្ហាពាក់ព័ន្ធជាមួយមនុស្សស្រីតាមលក្ខណៈកំលោះនោះទេ តែក្នុងកំឡុងឆ្នាំ ២០០០ កន្លងមកនេះ មនុស្សស្រីដែលចូលមកពាក់ព័ន្ធជាមួយគេពួកនាងសុទ្ធតែបញ្ចប់ជីវិតគ្រប់គ្នា រហូតដល់ថ្នាក់គេឃាំងខ្លួននៅតែក្នុងសេតវិមានរបស់គេមិនចេញទៅខាងក្រៅអស់រយៈពេលជាយូរហើយ។

( ត្រូវហើយណា ការដែលកើតមានខ្យល់ព្យុះដ៏ធំនោះគឺដោយសារតែអំណាចនៃបួងមន្តគ្រា ដែលបណ្តាលឲ្យនាង និងខ្ញុំបានជួបគ្នាជាលើកដំបូងនោះណា យ៉ុនហ៊ី )

ឈីតខាមែន ក្រោកឡើងដើរទៅកាន់បង្អួច សម្លឹងមើលទៅកាន់ខាងក្រៅដែលមានគ្រាប់ភ្លៀងធ្លាក់យ៉ាងខ្លាំងដូចមេឃចង់រលំរលាយអីចឹង ដោយសារតែអំណាចមន្តគ្រាឬយ៉ាងណាដែរទៅ កែវភ្នែកគេហាក់បីដូចជាសញ្ជឹងគិតអ្វីម៉្យាងមុននឹងដើរសំដៅទៅកាន់បន្ទប់គេងភ្លាម។



យ៉ុនហ៊ី ប្រែខ្លួនចុះឡើងៗដោយសារតែនាងគេងមិនលក់ ទោះបីជាកាលៈទេសៈតម្រូវឲ្យនាងគេងលក់យ៉ាងណាក៏ដោយ តែក្នុងអារម្មណ៍របស់នាងបែរជារសាប់រសល់មិនដឹងមូលហេតុ។ បើនិយាយថា ប្លែកកន្លែងវាដូចជាមិនមែនទេ ព្រោះថា នាងជាមនុស្សទៅណាមកណាស្រួលគេងស្រួលដេក។ រំពេចនោះភ្លើងអំពូលគ្រប់ដួងនៅក្នុងបន្ទប់របស់នាងត្រូវបានបិទ រាងកាយនាងត្រូវបានឃ្លុំដោយភួយយ៉ាងជិត...ចុះនាងជាមនុស្សខ្លាចខ្មោចបំផុតនោះណា តើឲ្យនាងគេងក្នុងបន្ទប់ងងឹតបានដោយរបៀបណាទៅ។ សំឡេងខ្យល់បក់ផាយផាត់ព្រមទាំងសំឡេងផ្គរលាន់យ៉ាងទ្រហឹងអឹងកង រូបរាងស្តើងទន់ល្វតល្វន់នោះបានចុះពីលើគ្រែដោយមិនដឹងខ្លួនទាល់តែសោះឡើយ ហើយដើរតាមទ្វារដែលបានបើកស្រាប់ដោយអំណាចមន្តគ្រាអ្វីម៉្យាង ប្រាណដ៏ល្វតល្វន់នោះបានដើរឆ្លងកាត់ព្រំពណ៌ក្រហមទៅកាន់បន្ទប់មួយដោយមិនដឹងថាវិញ្ញាណរបស់នាងទៅណាអស់នោះទេ។

ឈីតខាមែន សម្លឹងមើលរាងកាយដែលដើរចូលមកដោយគ្មានវិញ្ញាណក្នុងខ្លួននោះភ្លាម ព្រមទាំងគិតថាគេប្រហែលជាត្រូវទទួលរ៉ាប់រងក្នុងស្ថានការណ៍ដែលកំពុងតែនឹងកើតឡើងនោះហើយមើលទៅ យ៉ាងណាក៏គេបានត្រៀមចិត្តត្រៀមកាយហើយដែរ ចំពោះអំណាចដែលនឹងមកគ្របដណ្តប់អារម្មណ៍ស្រីស្រស់ដែលនៅចំពោះមុខគេនេះ។

កែវភ្នែកមួយគូដ៏មុតមាំនោះបានសម្លឹងមើលស្រី ដែលមានរូបរាងស្តើងដែលឈរនៅមាត់ទ្វារកំពុងចាប់ផ្តើមដោះសម្លៀកបំពាក់ចេញម្តងមួយៗ នៅចំពោះមុខគេដោយគ្មានស្មារតីក្នុងខ្លួននោះឡើយ។

អូស្លាប់ហើយ! ដើមទ្រូងរបស់នាងធំទ្រលុកទ្រលន់ទាំងគូតែម្តង!!

គេអត់ទ្រាំមិនលេបទឹកមាត់ក្អឹកៗមិនបាន ណាមួយគេបានឃើញល្បែងក្រោមដែលស្រលនព្រមទាំងសាច់សខ្ចីថែមទៀតផងនោះអី វាបានធ្វើឲ្យចិត្តនិងអារម្មណ៍របស់គេញាប់ញ័រមិនឈប់ឈរ ចំពោះរូបរាងអាក្រាតកាយដ៏សែនសិចស៊ីនេះ តែគេក៏បានតាំងចិត្តថា នឹងមិនធ្លាក់ឱកាសជាដាច់ខាត ព្រោះគេ

បានប្រាកដចិត្តថា មនុស្សស្រីដែលនៅចំពោះមុខគេនោះមកទីនេះដោយអំណាចមន្តក្រាអ្វីម្យ៉ាង ដូចមនុស្សស្រីផ្សេងទៀតដែរ ហើយបន្ទាប់ពីនោះមកពួកនាងក៏ត្រូវបញ្ចប់ជីវិត ក្រោយពេលដែលមានទំនាក់ទំនងជាមួយគេរួចហើយ។

«យ៉ុនហ៊ី យ៉ុនហ៊ី!!»

ឈិតខាមែន ព្យាយាមដាស់នាងឲ្យដឹងខ្លួន ទោះបីជាគេដឹងថា នាងត្រូវបានគ្របដណ្ដប់ដោយអំណាចមន្តក្រាក៏ដោយចុះ កែវភ្នែកទាំងពីររបស់គេពេលនេះកំពុងតែមើលទៅកាន់នាង ដែលកំពុងធ្វើសកម្មភាពបញ្ចេញមនោសញ្ចេតនាស្នេហាក្រហល់ក្រហាយនៅចំពោះមុខគេ ស្រីស្រស់ដើរចូលមកកៀកកើយប្រាណគេ ដៃទាំងទ្វេរបស់នាងបពោសអង្អែលប្រាណ និងដើមទ្រូងរបស់គេយ៉ាងភ្លើតភ្លើន។ គេព្យាយាមប្រមូលសតិស្មារតីយ៉ាងមោះមុត មិនឲ្យលង់ក្នុងការបពោសអង្អែលនោះជាមួយនាងឡើយ ហើយបិទភ្នែកសូត្រមន្តគាថាក្នុងចិត្តដែលគេចាំជាប់ក្នុងចិត្តរហូតមក។ នៅពេលដែលព្យាយាមសូត្រមន្តគាថានោះដដែលៗរួចមក មានអារម្មណ៍ថា ការស្ទាបអង្អែលរបស់នាងមកលើរូបគេដូចជារាងស្ងើយឡើងវិញ តែត្រចៀករបស់គេក៏បានឮនូវសំឡេងស្រែក!

ឈិតខាមែន បើកភ្នែកឡើងភ្លាម កែវភ្នែកមុះមុតរបស់គេក្រឡេកទៅឃើញស្រមោលដើរចេញពីកាយនាង។

ចាចចចចច!!!

ឈិតខាមែន ហក់ទៅទ្ររាងកាយដែលដួលសន្លប់មិនមានសតិនោះជាប់ គេមិនមែនជាមនុស្សឆក់ឱកាសនោះទេ តែក៏មិនបានបដិសេធថាគេមិនមែនជាមនុស្សប្រុសសុទ្ធសាធដែរ ដែលតែងមានអារម្មណ៍ចង់ចំពោះរាងកាយដែលអាក្រាតសែនសិចស៊ីនៅចំពោះមុខគេពេញៗភ្នែកបែបនេះដែរ។

**យ៉ុនហ៊ី មានអារម្មណ៍ថា ដូចជាមានអ្វីខុសប្រក្រតី ទើបប្រញាប់បើកភ្នែកឡើងយឺតៗ ហើយក៏ភ្ញាក់ខ្លួនព្រើតនៅពេលបានឃើញស្រមោលបុរ**



មាត់ដ៏ក្រហមប្រាលដូចនៅក្នុងក្ដីសុបិនរបស់នាង បានដាក់មកលើបបូរមាត់របស់នាងនៅចំពោះមុខ។

«ទេ...ទេ ខ្ញុំយល់សប្ដិទៀតហើយឬ?»

«នាងមិនមែនសុបិនទេណា យ៉ុនហ៊ី»

រំពេចនោះនាងក៏បានឮសំឡេងយ៉ាងច្បាស់ៗចំពោះអ្វីដែលនាងគិតថាជាក្ដីសុបិន។

«យ៉ុនហ៊ី ដឹងខ្លួនវិញហើយមែនទេ!!!»

ដៃទាំងពីរដ៏សែនទន់ល្មើយនោះ លូកទៅស្ទាបផ្ទៃមុខមុតមាំ ដែលនៅមិនឆ្ងាយពីនាងប៉ុន្មាន ហេតុអ្វីក៏ដូចជាពិតៗម្ល៉េះទៀត ហើយតើពេលណាទៅបាននាងដឹងខ្លួនវិញ ដើម្បីទៅឲ្យផុតពីកែវភ្នែកដែលពោរពេញទៅដោយមន្តស្នេហ៍ និងសម្រែកតណ្ហានេះដែរទៅ!

បុរសសង្ហាអត់ទ្រាំមិនសើចមិនបានចំពោះសកម្មភាពស្ទាបអង្អែលមុនរបស់នាង នៅពេលនេះបបូរមាត់ស្ដើងរបស់នាងបានហើបមាត់ផ្ទុះសម្ដីយ៉ាងស្លូតចិត្ត ទើបគេក៏យកឱកាសនោះឱនទៅប្រថាប់លើមាត់របស់នាងដោយហាមចិត្តមិនបានតទៅទៀតឡើយ ចុះក្រែងគេបានប្រាប់ហើយតើសថា គេក៏ជាមនុស្សប្រុសម្នាក់ដែរ ហើយរំពេចនោះបបូរមាត់ដ៏ស្ទាត់ជំនាញរបស់គេក៏បានលូកចូលក្នុងជ្រៅទៅៗយ៉ាងគ្មានត្រាប្រណី ដោយសារតែភាពស្រស់ស្អាតព្រមទាំងភាពសិចស៊ីនៃដើមទ្រូងធំណែនរបស់នាងនោះដែលធ្វើឲ្យគេទប់អារម្មណ៍មិនបាន

មានអារម្មណ៍ថា រាងកាយអាក្រាតនោះនៅពីក្រោមប្រាណរបស់គេតើធ្វើម៉េចនឹងអាចទប់អារម្មណ៍បាន បើនាងបានដុតភ្លើងស្នេហ៍យ៉ាងពុះកញ្ជ្រោលដល់ថ្នាក់នេះនោះ ហើយដៃរបស់គេនោះក៏បានធ្វើតាមបំណងប្រាថ្នាចាប់ដើមទ្រូងដ៏សែនធំក្បុំក្បោះនោះយ៉ាងញាប់ដៃ។

ចំណែកឯមនុស្សស្រីនោះកំពុងតែគិតថា ខ្លួននាងកំពុងតែសុបិន នាងចាប់ផ្ដើមមិនប្រាកដចិត្តហើយថា វាជាក្ដីសុបិន ឬក៏ជាការពិតនោះឡើយ តែអ្វីដែលនាងដឹងច្បាស់ គឺនាងកំពុងតែបានទទួលការប៉ះស្ទាបអង្អែលយ៉ាងពេញចិត្ត

តែម្តងហើយ តែមុននឹងគិតថា វានឹងអាចកើតមានអ្វីដែលយ៉ាប់ជាងនេះបាន នាងក៏ច្រានព្រលឹងរបស់គេនោះចេញភ្លាមតែម្តង។

«នេះ!! នេះខ្ញុំមិនបានសុបិនទេ»

សំឡេងញ័រទទ្រើក ព្រមជាមួយនឹងសំឡេងដកដង្ហើមមិនដល់គ្នាបានលាន់ឮឡើង គឺនាងកំពុងតែរម្ងាប់អារម្មណ៍នោះណា ចុះបើនាងមកដេកឲ្យមនុស្សប្រុសបើបឱបលូកស្ទាបស្រួលៗនោះអី ហើយពេលនោះនាងក៏បានស្លុតចិត្តខ្លាំងជាលើកទីពីរនៅពេល ដែលនាងក្រឡេកភ្នែកទៅឃើញរូបកាយនាងអាក្រាត។

**«អូយយយយ!!! ស្លាប់ហើយ លោក...លោកដោះខោអាវខ្ញុំ...»**

ដៃដ៏ល្វតល្វន់របស់នាងទាំងពីរក៏យកមកបិទបាំងភ្នំដ៏ធំញ៉ាំញ៉ោះរបស់នាង ទោះបីជាបិទមិនជិតក៏ដោយចុះ ហើយរំពេចនោះសំឡេងស្រែកយ៉ាងស្រួយស្រេសក៏បានលាន់ឮឡើង។

**«ឈឺតខាមែន ហេតុអ្វីក៏លោកធ្វើបែបនេះ!»**

**«ខ្ញុំមិនបានធ្វើទេណា យ៉ុនហ៊ី!!»**

**«នៅមកនិយាយថា មិនបានធ្វើទៀត ឃើញច្បាស់នៅនឹងភ្នែកទាំងគូរបស់ខ្ញុំទៅហើយណា»**

ណាមួយអាការៈស្ទាបលូកលាន់នាងនោះទៀត ចាប់បាននឹងមុខហើយនៅហ៊ានមកបដិសេធទៀតឬ!

«ខ្ញុំទទួលស្គាល់ថា អ្វីដែលនាងឃើញនោះខ្ញុំពិតជាបានធ្វើពិតមែនតែពីមុនៗនោះ ខ្ញុំមិនបានធ្វើទេណា អឺ...»

យ៉ុនហ៊ី មិនព្រមស្តាប់ការរៀបរាប់ប្រាប់បន្តទៀតនោះឡើយ នាងមានអារម្មណ៍ថា គឺជាការដោះសាររបស់គេច្រើនជាង ព្រមទាំងគិតថា មនុស្សប្រុសអីចឹងតែទាំងអស់ហ្នឹងឯង ជឿជាក់មិនបានទាល់តែសោះ ហើយក៏គិតបន្តទៀតថា តើនាងព្រមឲ្យគេដោះសម្លៀកបំពាក់បានដោយរបៀបណាទៅ ហើយបន្ទប់មួយនេះក៏ជាបន្ទប់របស់គេផងដែរនោះណា។



«នេះខ្ញុំមិននឹកស្មានដល់ទាល់តែសោះថា លោកបានចាប់ខ្ញុំមកកាន់បន្ទប់របស់លោកបែបនេះនោះ មិនត្រឹមតែប៉ុណ្ណោះថែមទាំងដោះខោអាវរបស់ខ្ញុំទៀត»

នាងចង់ស្ទើឲ្យគេឈឺចិត្តម្តង មុខមាត់ស្អាតបាតប៉ុណ្ណឹងដែរ ហេតុអីក៏ជាមនុស្សរោគចិត្ត តណ្ហាក្រាស់បែបនេះនោះ មានរឿងធំទាល់តែបាន មើលទៅឈឺតខាមែន ប្រហែលជាត្រូវនិយាយរៀបរាប់រឿងរ៉ាវប្រាប់ពីការពិតដល់នាងហើយទើបបាន ទោះបីជាថ្ងៃនេះនាងជឿឬមិនជឿក៏ដោយចុះ តែទោះបីជាយ៉ាងណាក៏នាងត្រូវតែដឹងនូវ អ្វីដែលនាងគួរតែដឹងដែរ ហើយរំពេចនោះសំឡេងគ្រលរ នោះព្យាយាមយ៉ាងខ្លាំងក្នុងការអធិប្បាយ។

«នាងត្រូវបានខ្មោចនាំមកកាន់ទីនេះណា យ៉ុនហ៊ី»

គេមិនដឹងទេឬយ៉ាងណាហ្នឹងដែលថា មនុស្សស្រីដែលអង្គុយរកឿងគេនោះខ្លាចខ្មោចជាទីបំផុត ហើយមិនទាន់ទាំងបានអធិប្បាយបន្តផង នាងគ្រាន់តែឮថា ខ្មោចនាងក៏ហក់ទៅឱបកគេយ៉ាងណែនទៅហើយ រហូតដល់ថ្នាក់ភ្ញាត់មាត់ស្រែកចេញមករកតែស្លាប់មិនយល់។

«អូយយយ!! ខ្មោ...ខ្មោ...ខ្មោច...»

ដៃទាំងសងខាងដែលទំនេរនោះបានក្រសោបឱបនាងយ៉ាងណែនព្រមទាំងអង្អែលខ្នងជាការលួងចិត្តផងដែរ។

«ត្រូវហើយណា នាងត្រូវបានអំណាចមួយដ៏ចម្លែកនាំមកទីនេះ»

មិនត្រឹមតែនិយាយមាត់ទទេនោះទេ ច្រមុះរបស់គេបានខិនទៅក្រេបក្លិនក្រអូបដើមទ្រូងនួនលគករបស់នាងផងដែរ។

«អំណាចម៉្យាង!! ខ្ញុំ...ខ្ញុំមិនយល់នោះទេ»

«វាជាអំណាចអាថ៌កំបាំងមួយដែលនាងត្រូវតែជួបណា យ៉ុនហ៊ី»

«ហើយហេតុអីខ្ញុំត្រូវតែជួបវា លោកដឹងរឿងនេះបានដោយរបៀបណាដែរទៅ? ឬក៏លោកចិញ្ចឹមខ្មោច? ត្រូវហើយៗ លោកប្រាកដជាចិញ្ចឹមខ្មោចប្រាកដហើយ»

ចុះបើគេដឹងពីការគិតរបស់នាងតាំងពីបានជួបនាងដំបូង មិនថានាងចង់គិតអី ឬមានអ្វីក្នុងចិត្តក៏ដោយ ត្រូវហើយ! គេប្រាកដជាចិញ្ចឹមខ្មោចមែនទែនហើយ។

«លោកមានព្រាយខ្មៅ ឬក៏ចិញ្ចឹមម្រេញគង្វាលអីប្រាកដហើយ បើមិនអីចឹងទេប្រហែលជាចិញ្ចឹមខ្មោចអ្វីម្យ៉ាង!!»

«នាងនិយាយពីអ្វីហ្នឹង ខ្ញុំមិនយល់ពីនាងនិយាយនោះទេ»

«មិនដឹងទេ!! ដឹងតែខ្ញុំដឹងទាន់ជាន់កែងលោកទៅចុះ លោកទៅប្រាប់ពួកកូនចៅខ្មោចរបស់លោកទៅថា កុំចូលមកជិតខ្ញុំ!!»

កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះសម្លឹងមើលទៅជុំវិញបន្ទប់ ព្រមទាំងគិតក្នុងចិត្តថា មិនបានការទេ បើដូច្នោះសារណានាងពិតជាមិនបានសម្រេចលឿននោះឡើយ ត្រូវតែដាក់គម្រោងចាកចេញពីទីនេះឲ្យលឿនបំផុតជាការប្រសើរជាង អាកគក!!! ហើយហេតុអីក៏នៅអង្គុយឲ្យគេឱបទៅកើតដែរទៅ អួយយយ!! ខ្ញុំអើយខ្ញុំពិតជាឆ្កួតមែន។

«លែង...លែងខ្ញុំភ្លាមទៅ!!!»

និយាយបណ្ដើរដៃរបស់នាងក៏បានស្រវារកក្អួយមកគ្រប់ប្រាណ រំពេចនោះកែវភ្នែកក៏បានក្រឡេកទៅឃើញឈុតដេករបស់នាងដោះទម្លាក់ចោលនៅត្រង់មាត់ទ្វារបន្ទប់របស់គេ នេះមានន័យថា នាងបានដោះខោអាវតាំងពីមុខទ្វារចូល ហើយដើរទាំងប្រាណននលតកនោះមករកគេឬ! សំឡេងស្រែកទាំងតិចៗរបស់នាងក៏បានលាន់ឮឡើង។

«ឆ្កួត!! ឆ្កួតមែន!! លោកនេះពិតជាគ្រូខ្មោចសុទ្ធសាធតែម្ដងហើយ!»

«ហឺសស!!!កាន់តែយ៉ាប់ទៅៗហើយណា នាងត្រូវតែស្ដាប់ខ្ញុំនិយាយសិនណា យ៉ុនហ៊ី»

«ទេ ខ្ញុំមិនស្ដាប់ទេ ខ្លាចលោកព្រួសទឹកមន្តសណ្ដំស្នេហ៍អីដាក់ខ្ញុំទៀតនោះណា»

ឈើតខាមែន ពិតជាមិនយល់នូវពាក្យសម្ដីរបស់ស្រីស្រស់ទេ នាងបាន



ដើរក្ដួយធំមួយនោះទៅកាន់មាត់ទ្វារ ដែលមានឈុតដេកនាងនៅទីនោះ មុននឹងប្រញាប់ស្លៀកពាក់។ ទោះបីជានាងមិនយល់ក៏ដោយចុះក៏គេត្រូវតែធ្វើការអធិប្បាយការពិតដល់នាងចំពោះហេតុការណ៍ ដែលកើតឡើងចំពោះនាងឲ្យទាល់តែបានដែរ។ ក្នុងខណៈពេលនោះទ្វារដែលនាងកំពុងតែដើរទៅរកនោះក៏បានបិទឮសូរគ្រាំងយ៉ាងឮៗ។

«**គ្រែគគគគ**!!! **គាំងៗ**!!!»

«**អាយយយ**!!! **ខ្ម...ខ្មោច**!!!»

ធ្វើឲ្យរាងកាយដ៏ទន់ល្វតល្វន់នោះហក់ទៅរកបុរសមាឌធំជាថ្មីម្ដងទៀត ហើយភាពខ្លាចខ្មោចរបស់នាងធ្វើឲ្យនាងបិទភ្នែកជិតឱបគេយ៉ាងណែន ទោះបីជាទៅឱបគ្រូខ្មោចក៏ប្រសើរជាងនៅជិតខ្មោចមែនទែននោះដែរ ព្រមទាំងមានអារម្មណ៍ថា ដៃរបស់គ្រូខ្មោចនោះបានលូកលាន់លើខ្លួនប្រាណរបស់នាងជាលើកទីពីរ។

«លោកហៅខ្មោចមកបន្លាចខ្ញុំទៀតហើយមែនទេ!!!»

«ទេ មិនមែនទេណា ខ្ញុំមិនមែនជាគ្រូខ្មោចដូចដែលនាងគិតនោះទេណា»

«ហើយចុះនៅស្រាប់ៗទ្វារបើកចេញដោយរបៀបណា បើមិនមែនខ្មោចនោះ»

តាំងពីកើតមកខ្លាចខ្មោចស្រាប់ទៅហើយ តែនេះបានមកជួបជាមួយនឹងគ្រូខ្មោចពិតៗទៀត មិនដឹងជាមានខ្មោចប៉ុន្មានសិបនាក់នោះទេក្នុងសេតវិមានមួយនេះ ហើយនេះនាងត្រូវមកនៅក្នុងកន្លែងខ្មោចជាមួយនឹងគ្រូខ្មោចបែបនេះឬ? រំពេចនោះសំឡេងស្រែករបស់នាងក៏ស្រែកឡើងមួយទំហឹង។

«ហ៊ឺៗៗៗ!!! ខ្មោច!! សុទ្ធតែខ្មោច ខ្មោចមិនចេះតិច ទៅខាងណាក៏សុទ្ធតែខ្មោចដែរ ហ៊ឺៗៗៗ»

«វាមិនមែនដូចដែលនាងគិតនោះទេណា»

«មែន!!! មេចថាមិនមែនទៅ ហ៊ឺៗៗ សុទ្ធតែខ្មោច!!!»

ហើយខណៈពេលនោះ ខួរក្បាលរបស់នាងគិតតែខ្លួនឯង ព្រមទាំងនឹកស្រមើស្រមៃទៅដល់អ្វីៗ ដែលគួរឲ្យខ្លាចទាំងឡាយទាំងពួងមកប្រមូលផ្តុំគ្នាក្នុងខួរក្បាលពេញតែម្តង។

«ហើយតើមានប៉ុន្មានកន្លែងដែរទៅដែលលោកចិញ្ចឹមនោះ ហឹៗៗ ខ្ញុំមិនគួរណាមកទីនេះទាល់តែសោះ»

សំឡេងដកដង្ហើមរបស់បុគ្គលដែលត្រូវបានគេដាក់កំហុសថា ជាគ្រូខ្មោចនោះបានលាន់ឮឡើង ទោះបីជាគេនិយាយប្រាប់ពេញមួយយប់ក៏នាងនៅតែមិនស្តាប់គេដែរ ឈិតខាមែន មានអារម្មណ៍យល់ពីទឹកចិត្តនាងដែលត្រូវមកជួបប្រទះនូវរឿងរ៉ាវពិបាកនឹងទទួលបាននេះណាស់។

«ល្ហើយចុះ ល្ហើយចុះ!! នាងទៅគេងក្នុងបន្ទប់នាងដែរទេ ខ្ញុំជូននាងទៅណា!»

«ត្រឡប់ទៅគេងម្នាក់ឯងនោះឬ ទេ...ទេខ្ញុំមិនទៅទេ ខ្ញុំខ្លាចខ្មោច»

«បើសិនជានាងខ្លាច អីចឹងនាងត្រូវតែគេងនៅទីនេះហើយណា»

«គេងជាមួយលោកនោះ! ទេ...ទេ ខ្ញុំនៅតែខ្លាចដដែលហ្នឹងណា ហឹៗ»

អ្នកដែលល្ងង់ចិត្តនាងនោះចាប់ផ្តើមពិបាកចិត្តហើយ តើនាងគិតយ៉ាងម៉េចដែរទៅ តែអ្វីដែលគេដឹងនោះ គឺនាងនៅឱប/ប្រាណគេជាប់នៅឡើយនោះណា ប្រហែលជាត្រូវតែធ្វើតួនាទីរបស់គេដែលត្រូវឱបអង្អែលប្រាណនាងឲ្យនាងបាត់ខ្លាចហើយមើលទៅនោះ ចុះបើនាងឱបគេយ៉ាងណែនបែបនេះ មកថាគេផ្អក់ឱកាសមិនបានទេ។

«ខ្ញុំខ្លាចឡើងរឹងដៃរឹងជើងអស់ទៅហើយ លោកមិនឃើញទេអី លោកឲ្យខ្មោចរបស់លោកចេញទៅ កុំមកលងខ្ញុំទៀតអីណា ហឹៗ»

«លែងមានហើយអាខ្មោចអីនោះ ខ្ញុំធានា...ខ្ញុំធានា»

សំឡេងទន់ភ្លន់របស់ ឈិតខាមែន បាននិយាយលួងលោមខាងស្រីព្រោះថា នាងខ្លាចខ្មោចឡើងរឹងខ្លួនទៅហើយ ភ្លេចខ្លួនមកក្រសោបឱបគេទៀតផងហើយចុះបើសិនជាអាអូនរបស់គេឡើងរឹងដែរនោះ តើឲ្យគេរម្ងាប់អារម្មណ៍បាន



ដោយរបៀបណាទៅ គេប្រហែលជាទ្រាំខាំមាត់សង្កត់ចិត្តចំពោះរាងកាយដ៏សែនសិចស៊ីនេះទាល់តែតាំងបេះដូងហើយមើលទៅនោះ។ រំពេចនោះដៃដែលឱបគេជាប់ណែននោះបានលូកមកឱបផើមរបស់គេ។

«គេងយ៉ាងលង់លក់តែម្តងហ្ន៎!!! អ្នកខ្លាចខ្មោច!!!»

គេនិយាយខ្សឹបៗចេញមក ព្រមទាំងដាក់ខ្លួនគេងដោយស្រាវឱបស្រីស្រស់នោះមកនែបនិត្យជិតកាយគេផងដែរ ចំណែកឯភ្នែករបស់គេក៏ចង់តែបិទតាមនាងដូចគ្នាដែរ ទោះបីមានការពិបាកខ្លាំងយ៉ាងណាក៏ដោយចំពោះការដែលគេងជាមួយមនុស្សស្រីដែលមានរាងសិចស៊ី ព្រមទាំងអាក្រាតកាយនៅក្នុងរង្វង់ដៃរបស់គេបែបនេះនោះណា។

ចិញ្ចើមជ្រួញចូលគ្នារបស់ស្រីបម្រើម្នាក់ដែលត្រូវបាន យ៉ុនហ៊ី បង្ខំឲ្យនៅក្បែរនាងមិនឲ្យផុតពីក្រសែភ្នែក រង់ចាំឲ្យនាងញាត់សម្លៀកបំពាក់យ៉ាងប្រញាប់ប្រញាល់ រហូតដល់ស្រីបម្រើនោះទ្រាំលែងបានក៏សាកសួរថា៖

«អ្នកនាង យ៉ុនហ៊ី តើអ្នកនាងមិនពេញចិត្តអ្វីមែនទេបានជាអ្នកនាងប្រញាប់ត្រឡប់ទៅវិញបែបនេះនោះ អ្នកនាង!!»

ផ្ទៃមុខក្រញូវមិនតបសំណួរ ដែលស្រីបម្រើម្នាក់នោះសួរសោះឡើយ តើវាមានប្រយោជន៍អីទៅ បើស្រីបម្រើនោះក៏ត្រូវមន្តសន្ទំរបស់ ឈិតខាមែន គ្រូខ្មោចនោះដែរហើយ។

«លោក ឈិតខាមែន ចិត្តល្អសឹងអីហ្នឹងអ្នកនាង អ្នកនាងមិនសប្បាយចិត្តរឿងអីដែរទៅ?»

ណក!!! ឃើញទេ!! នាងប្រាកដជាត្រូវមន្តសណ្តំពិតមែនហើយ ទើបបានជាគិតថា ឈិតខាមែន ជាមនុស្សល្អនោះ ខ្ញុំដឹងទាន់ហើយ ក្រៅពីជាគ្រូខ្មោចហើយលោកជាមនុស្សដែលឆ្កួតនឹងកាមតណ្ហាទៀត។

«អ្នកនាង!!! ម៉េចក៏អ្នកនាងមិននិយាយអីចឹង!! អ្នកនាងមិនពេញចិត្តរឿងអីដែរទៅ ខ្ញុំនឹងទៅប្រាប់លោក ខាមែន ឲ្យអ្នកនាងណា»

មិនមានសំឡេងឆ្លើយតបអ្វីទាំងអស់ពីស្រីស្រស់ រហូតទាល់តែរៀបចំខោអាវរួចរាល់ ស្រីបម្រើដូចនាងបានត្រឹមតែឈរអេះក្បាលយ៉ាងងឿងឆ្ងល់តែប៉ុណ្ណោះឯង។

សំឡេងអូសកាបូបវ៉ាលីសចុះមកពីខាងលើយ៉ាងឮៗធ្វើឲ្យ ឈើតខាមែន ចេញពីបន្ទប់ធ្វើការរបស់គេមកខាងក្រៅដើម្បីមើលនាង ហើយក៏ដូចនូវអ្វីដែលគេគិតពិតមែន មនុស្សស្រីដែលបានមកស្នាក់នៅជាមួយគេនោះត្រូវបានមន្តសង្កត់រហូតទាល់តែរាងចាលតែម្ដង នាងប្រហែលជាចង់ចេញពីសេតវិមានមួយនេះទេដឹង!!!

«យ៉ុនហ៊ី នោះនាងចង់ទៅណាហ្នឹង!!»

«ខ្ញុំទៅផ្ទះខ្ញុំវិញនោះឯង!!»

«ហើយចុះនាងមិនធ្វើការងារសារណាទេអី!!»

ឈឺស!!! យកពាក្យការងារសារណាមកគំរាមឬ គេគិតចង់ធ្វើអីៗលើនាងនោះទេតើស ហ៊ុយយយ!! នេះសំណាងហើយដែលនាងរហ័សដែរ!! តែអេ!!! កាលពីយប់មិញនាងបានគេងជាមួយគេទេតើស មិនឃើញគេធ្វើអីនាងឯណា តែកុំភ្លេចឲ្យសោះថា គេបានប្រើខ្មោចឲ្យមកដោះខោអាវនាងចេញ គ្រាន់តែប៉ុណ្ណឹងគឺមិនអាចទទួលបានទៅហើយណា។

«ខ្ញុំសុខចិត្តប្រឡងធ្លាក់ប្រសើរជាងមកនៅជាមួយខ្មោច ក្នុងសេតវិមាននេះដែរណា!!!»

នាងមិនចង់និយាយរៀបរាប់អីច្រើនថា នាងនឹងនៅឲ្យពួកខ្មោចអស់នោះមកចាប់សម្រាតខោអាវទៀតធ្វើអី រំពេចនោះសំឡេងដែលនាងគិតថា គេគឺជាគ្រូខ្មោចនោះក៏បានឮឡើង។

«ធ្វើបែបនេះទៅចុះ ចាត់ទុកថា នាងព្យាយាមស្ដាប់ខ្ញុំអធិប្បាយរឿងពិតដល់នាងបន្តិចទៅបានទេ»

«រឿងសំខាន់!!! រឿងសំខាន់ដែលទាក់ទងជាមួយនឹងការងារសារណាខ្ញុំនោះឬ ខ្ញុំលែងធ្វើលែងអីហើយ!!!»



«វាមិនមែនរឿងនោះសុទ្ធសាធនោះទេណា»

នាងមានរឿងសំខាន់តែមួយរឿងប៉ុណ្ណោះនោះគឺការងារសារណា ហើយសម្រាប់រឿងដែលប្រញាប់បំផុតក្នុងពេលនេះនោះគឺ នាងត្រូវតែប្រញាប់ចេញពីសេតវិមាននេះឲ្យបានលឿនជាទីបំផុតតាមដែលអាចធ្វើទៅបាន។

«បើសិនជាលោកមេត្តា ខ្ញុំចង់សុំឲ្យអ្នកបើកឡានរបស់លោកបើកជូនខ្ញុំត្រឡប់ទៅវិញបន្តិចបានទេ»

«យ៉ាងណាក៏នាងមិនអាចត្រឡប់ទៅវិញបានដែរណា»

«ហេតុអីក៏ខ្ញុំទៅវិញពេលនេះមិនបាន លោកចង់ឃុំឃាំងធ្វើទារុណកម្មខ្ញុំឬ?»

«ខ្ញុំទៅឃុំឃាំងធ្វើទារុណកម្មនាងធ្វើអីដែរទៅ កាលពីយប់មិញនាងមិនឃើញទេអី»

នេះគេនៅមកនិយាយពីរឿងកាលពីយប់មិញទៀត ដោយសារតែនាងមិនដឹងហ្នឹងហើយបានជានាងមកឈរដោះខោអាវនៅពីមុខគេនោះ កុំប្រាប់ឲ្យសោះថា គេបានថតវីដេអូទុកដើម្បីជាលេសជាមួយនាងឲ្យនាងនៅទីនេះបន្តនោះ។

«នែលោក! កុំយករឿងកាលពីយប់មិញមកនិយាយបានទេ ស្អាយចិត្តណាស់ដែលខ្ញុំខំទុកចិត្តលោក ដែលលោកគឺជាមិត្តភក្តិរបស់ ឈើត នោះ»

«នាងនិយាយពីស្អីនាងហ្នឹង ខ្ញុំចង់និយាយរឿងយប់មិញនោះ គឺរឿងភ្លៀងខ្លាំងព្រមទាំងមានព្យុះទៀត ក្រែងនាងបានដឹងដែរតើមិនអីចឹងអី ហើយវាក៏បានធ្វើឲ្យផ្លូវថ្នល់ខូចខាតអស់ហើយដែរ»

ឈើតខាមែន ដើរចូលទៅរួចលូកដៃទៅទាញដៃវ៉ាលីសដាក់ខោអាវរបស់នាងចេញពីដៃ ព្រមទាំងដើរអូសវា និងនាងទៅកាន់បន្ទប់ធ្វើការរបស់គេ ធ្វើការអធិប្បាយនូវអ្វីដែលនាងគួរតែដឹងឲ្យបានច្បាស់លាស់ មិនមែននាងត្រូវគិតតែឯងថា តែខ្លួនឯងនោះទេ។

«ផ្លូវថ្នល់នៅឯសមុទ្រខ្សាច់នេះនោះណា មានខ្សាច់ក្រាលនៅខាងក្រោម

សុទ្ធសាធ នៅពេលមានភ្លៀងធ្លាក់មកយូរៗម្ដងបែបនេះវានាំឲ្យផ្លូវនោះខូច ហើយណាមួយភ្លៀងខ្លាំងដូចយប់មិញផងនោះ ធ្វើឲ្យមនុស្សម្នាមិនអាចធ្វើដំណើរទៅណាមកណាបានងាយៗនោះឡើយ»

«អូ!!! គួរឲ្យស្ដាយដែរ បើភ្លៀងខ្លាំងដូចមេឃចង់រលំបែបនោះទៅហើយណា»

ពាក្យសម្ដីដែលគេនិយាយដូចជាទំនងជាការពិតដែរ តែទោះបីជាយ៉ាងណាក៏ដោយចុះនាងត្រូវតែរកវិធីសាស្ត្រក្នុងការចាកចេញពីទីនេះឲ្យបាន មិនថានាងត្រូវដើរដោយជើងឬយ៉ាងណាក៏ដោយ គេចង់ឲ្យមនុស្សដែលខ្លាចខ្មោចបំផុត ត្រូវមករស់នៅក្នុងកន្លែងសុទ្ធតែខ្មោចបែបនេះបានដោយរបៀបណាដែរទៅ គេមិនឲ្យនាងទៅដោយសារតែហេតុផលផ្លូវដាច់អីចឹងឬ ចុះក្រែងនាងធ្លាប់ប្រាប់ហើយថា នាងមិនដែលខ្លាចអ្វីទេក្រៅពីខ្មោចនោះណា តែសំឡេងគ្រលរនោះនៅតែព្យាយាមនិយាយអធិប្បាយបន្ត។

«ក្រែងនាងក៏បានដឹងដែរតើសថា កាលពីប៉ុន្មានខែកន្លងមកនេះ វាមានរឿងកើតឡើងប្លែកៗឡើងចំពោះរូបនាងខ្លះនោះ!»

នាងគិតតាមសំឡេងមុតមាំដែលគេនិយាយចេញមកនោះ មែនហ្នឹង! ការដែលគេមើលឃើញយ៉ាងច្បាស់ៗនោះគឺ សុបិនដែលមានការបបោសអង្អែលយ៉ាងជក់ចិត្តជិតអារម្មណ៍ដោយគ្មានមូលហេតុនោះទៀត។

«ខ្ញុំអាចនិយាយរៀបរាប់ពីហេតុការណ៍ដែលកើតឡើងនោះបានណា»

ទោះបីជាសម្ដីរបស់ម្ចាស់សេតវិមាននោះនិយាយមក ធ្វើឲ្យនាងមានការចាប់អារម្មណ៍ស្ដាប់ចំពោះហេតុការណ៍ ដែលនាងជួបប្រទះយ៉ាងណាក៏ដោយចុះ តើនាងម៉េចនឹងអាចជឿទុកចិត្តលើគេបានដែរទៅ?។

«ចុះបើលោកគឺជាគ្រូខ្មោចនោះណា លោកប្រាកដជាដឹងហើយថា មានអីកើតឡើងពីអតីតកាលខ្លះនោះ»

«ទៀតហើយនៀក បើនាងនៅតែមិនស្ដាប់នូវអ្វីដែលខ្ញុំនិយាយផង តើនាងម៉េចនឹងអាចដឹងពីការពិតបានទៅ ដែលវាបានកើតឡើងកាលពីអតីតកាល



ព្រមទាំងនឹងអាចកើតឡើងទៅថ្ងៃអនាគតបានទៅ!»

«លោកនិយាយថា នឹងមានហេតុការណ៍ចម្លែកកើតឡើងចំពោះខ្ញុំឬ?»

យ៉ុនហ៊ី សម្លឹងមើលទៅកាន់ ឈិតខាមែន ដែលនៅចំពោះមុខនាង ពេលនេះគេបានងក់ក្បាលទទួល តើនាងគួរជឿនូវអ្វីដែលគេនិយាយចេញមកនោះឬក៏អត់ទេហ្ន!! តែវាក៏មិនមានអ្វីខុសខាតឯណា ហើយខ្មោចវាក៏មិនចេញមកក្នុងពេលថ្ងៃចែសបែបនេះនោះដែរ។

កែវភ្នែកដែលបញ្ចេញភាពងឿងឆ្ងល់ បានកើតឡើងក្នុងចិត្តរបស់នាង នាងប្រហែលជាត្រៀមខ្លួចជាស្រេចហើយមើលទៅ ក្នុងការទទួលស្ដាប់នូវហេតុការណ៍ចម្លែកដែលនឹងកើតឡើងចំពោះនាង។

«នាងស្ដាប់ខ្ញុំណា អ្វីៗគ្រប់យ៉ាងវាកើតឡើងចេញពីបួងមន្តត្រា»

«បួងមន្តត្រា? ខ្ញុំមិនយល់នោះទេ»

«នោះមានន័យថា នាងនិងខ្ញុំកំពុងតែស្ថិតក្នុងបួងមន្តត្រា វាគឺជាពាក្យបណ្ដាសា ដែលធ្វើឲ្យនាងនិងខ្ញុំមានដំណើរជីវិតទៅតាមពាក្យបណ្ដាសាមួយនោះ»

«បួងមន្តត្រា!! ពាក្យបណ្ដាសាស្អីគេដែរទៅ!! ខ្ញុំនៅតែមិនយល់ដដែលនោះណា»

កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះនៅតែមើលទៅកាន់បុគ្គល ដែលកំពុងតែធ្វើការអធិប្បាយមកកាន់នាង ទោះបីជានាងគិតថា ការដែលគេនិយាយចេញមកមានហេតុផលយ៉ាងណាក៏ដោយ ក៏នៅតែជារឿងដែលមករារាំងក្នុងអារម្មណ៍របស់នាងដដែល ដែលនាងមិនដែលជួបប្រទះក្នុងពិភពលោកពិតៗបែបនេះនោះឡើយ!

ឈិតខាមែន ព្យាយាមអធិប្បាយការពិតទាំងប៉ុន្មានដែលគេបានដឹងពីបិតារបស់គេដល់មនុស្សស្រីម្នាក់នេះស្ដាប់យ៉ាងតាំងចិត្តតាំងថ្លើម គ្រាន់តែមិនបានប្រាប់ចំពោះរឿងរ៉ាវរបស់មនុស្សស្រីទាំងប៉ុន្មាន ដែលបានបញ្ចប់ជីវិតជាច្រើននាក់ដោយសារតែអំណាចអាថ៌កំបាំងនេះឡើយ ព្រោះថាវាអាចមានផល

ប៉ះពាល់ទៅថ្ងៃអនាគតបាន។

«នាងយល់ហើយមែនទេ?»

«វាមានរឿងបែបនេះកើតឡើងក្នុងលោកនេះដែរ? មិនគួរឲ្យជឿទាល់តែសោះហើយនៀក»

«ពីដំបូងខ្ញុំក៏គិតដូចនាងដែរហ្នឹង តែខ្ញុំក៏ត្រូវទទួលយកការពិតចំពោះអំណាចអាថ៌កំបាំងនោះ»

«ខ្ញុំមិនចង់ជឿទាល់តែសោះ»

«តែនាងត្រូវតែជឿណា»

ហើយចុះវាគួរឲ្យជឿបានដោយរបៀបណាទៅ មនុស្សស្រីចិត្តរឹងដូចជានាងគិតក្នុងចិត្ត ឬក៏គេតែងរឿងមកបោកប្រាស់នាងទេដឹង! នៅចំពោះភាពស្ងប់ស្ងាត់នោះសំឡេងគ្រលររបស់បុរសដែលមានឈ្មោះថា ឈិតខាមែន បានលាន់ឮឡើងភ្លាម។

«ឬក៏នាងអាចធ្វើការអធិប្បាយចំពោះសុបិនប្លែកៗ ដែលកើតឡើងចំពោះនាងឲ្យខ្ញុំស្តាប់ក៏បានដែរណា»

មែននោះណា សុបិននោះហើយដែលនាងមិនអាចនិយាយចេញមកបាននោះ ថាវាកើតឡើងដោយរបៀបណា ឬក៏ការដែលគេនិយាយចេញមកនោះជាការពិតដែលនាង និងគេកើតមកក្នុងជោគវាសនាក្នុងអំណាចមន្តគ្រាមួយដែលគេនិយាយពិតមែននោះ។

កែវភ្នែកមុះមុតនោះមើលទៅកាន់មនុស្សស្រី ដែលកំពុងតែប្រើការគិតគេរអត់ទ្រាំមិនផ្តល់កម្លាំងចិត្តចំពោះជោគជតាវាសនាជីវិត ដែលនាងត្រូវជួបប្រទះនេះមិនបាន ហើយអ្វីដែលសំខាន់គឺនាងជាគូគ្រងរបស់គេទៅថ្ងៃអនាគតដែលទេវតាកំណត់ ប្រហែលរឿងនេះហើយទេដឹងដែលបានធ្វើឲ្យគេពេញចិត្តពេញថ្លើមនាងតាំងពីថ្ងៃដែលគេជួបនាងគ្រាដំបូងម្ល៉េះ។

«នាងសាកគិតទៅមើលថា នៅស្រុកខ្ញុំកើតមានខ្យល់ព្យុះធំដោយរបៀបណាដែរទៅក្នុងភូមិភាគនៃសមុទ្រខ្សាច់នេះ»



«នេះលោកចង់និយាយថា នេះគឺជាអំណាចមន្តគ្រាអាថ៌កំបាំងដែលធ្វើឲ្យខ្ញុំ និងលោកមកជួបគ្នានោះឬ?»

«ចុះនាងគិតថា វាមែនអត់ចុះ?»

មិនជឿក៏ត្រូវតែជឿដែរ នាងគិត ណាមួយក្តីសុបិនរបស់នាងក្លាយជាការពិតនោះទៀត តែនាងក៏នៅតែមានគួនចិត្តមួយមិនអស់មិនហើយចំពោះអំណាចអាថ៌កំបាំងដែលគេនិយាយប្រាប់នាងនោះដដែល។

«តើខ្ញុំម៉េចនឹងអាចជាព្រះនាង ទេមីន ដែលមកចាប់ជាតិថ្មីដោយរបៀបណាទៅ»

«ហើយចុះនាងអាចរកហេតុផលមកលុបលាងបានដែរទេ?»

«គឺខ្ញុំសង្ស័យថាព្រះនាង ទេមីន មកកើតជារូបខ្ញុំយ៉ាងម៉េច ហើយវិញ្ញាណដែលនាំខ្ញុំទៅកាន់បន្ទប់របស់លោកនោះ តើនឹងអាចជាវិញ្ញាណរបស់ព្រះនាង ទេមីន បានដោយរបៀបណាដែរទៅ បើខ្ញុំនៅទីនេះហ្នឹង!»

គ្រាន់តែប៉ុណ្ណឹង នាងចាប់ផ្តើមវិលវល់ទៅហើយ ដែលការពិតទៅនាងជាអ្នកនិយាយតែឯងថាតែឯងនោះណា ហើយយយ!!! ហេតុអីក៏ជីវិតរបស់នាងត្រូវមកជួបនឹងហេតុការណ៍ដ៏សែនឈឺក្បាលបែបនេះនៀក ហើយពេលនោះសំឡេងគ្រលររបស់គេក៏បានធ្វើការអធិប្បាយបន្ត។

«នេះដោយសារតែការសន្យារបស់ព្រះនាង ទេមីន មុនពេលដែលព្រះនាងសុគតនោះណា»

«ការសន្យាមុនស្លាប់?»

ឈិតខាមែន លូកដៃទៅចាប់ដៃនាងដែលកំពុងគិតពិចារណាចំពោះហេតុការណ៍ទាំងឡាយដែលនាងបានជួបបានឃើញ។ ហើយគេក៏បានធ្វើការអធិប្បាយបែបចិត្តសាស្ត្រឲ្យនាងបានជឿខ្លាំងជាងមុនទៅទៀត

«គឺដូចតែពន្លឺ និងសំឡេងនោះអី ពេលដែលមានព្យុះរន្ទះវាតែងតែមានពន្លឺមុនចំណែកឯសំឡេងមកតាមក្រោយ»

«លោកចង់និយាយថា ចិត្តរបស់ព្រះនាង ទេមីន នៅមាន តែវិញ្ញាណ

របស់ព្រះនាងបានទៅចាប់ជាតិថ្មីហើយឬ?»

«គឺដូចដែលនាងយល់ហ្នឹងវាត្រឹមត្រូវហើយណា»

«ការពិតវាគួរតែមកព្រមគ្នា...» ស្រីស្រស់នៅតែឆ្ងល់ៗ។

«បើសិនជា គ្មានអំណាចដ៏កាចសាហាវនៃពាក្យសន្យាជាឧបសគ្គនោះ» ឈីតខាមែន អធិប្បាយបន្ត។

នាងក៏ដូចជាមានអារម្មណ៍ថា រឺលវល់ព្រមទាំងងឿងឆ្ងល់ចំពោះអ្វីទាំងឡាយដែលនាងបានដឹងនោះ ជាពិសេសមនុស្សប្រុសដែលនៅចំពោះមុខនាងគេបាននិយាយថា នាងគឺជាគូព្រេងរបស់គេនោះណា ចុះក្រែងព្រះនាង ទេមិនព្រះនាង បានស្រឡាញ់គូដណ្ដឹងព្រះនាងយ៉ាងខ្លាំងនោះទេតើស តែនាងមិនមានអារម្មណ៍បែបហ្នឹងសោះ។

យ៉ុនហ៊ី អត់ទ្រាំមិនគិតមិនបានទាល់តែសោះថា តាំងពីកើតមកនាងមិនដែលមានចិត្តស្រឡាញ់អ្នកណាផង រហូតដល់ថ្នាក់មិត្តភក្ដិទាំងអស់នាំគ្នាគិតថានាងជាខ្ទើយស្រឡាញ់ស្រីដូចគ្នាជាមួយ ហាន់ណា ដែលជាមិត្តភក្ដិជិតស្និទ្ធរបស់នាង តែឥឡូវ ហាន់ណា មានប្ដីបាត់ទៅហើយដូច្នេះហើយនាងបានរួចផុតពីការចោទប្រកាន់នោះមួយវគ្គ។ ទោះបីជា ឈីតខាមែន ជាមនុស្សប្រុសសង្ហាឥតខ្ចោះក៏ដោយ ក៏នាងមិនអាចបណ្ដោយចិត្តឲ្យស្រឡាញ់គេភ្លាមៗបានដែរ។

«ហើយចុះខ្ញុំគួរធ្វើយ៉ាងណាទើបល្អដែរទៅ»

«នាងត្រូវតែនៅទីនេះបន្តនោះឯងណា»

«នៅបន្តទីនេះ?»

ការដែលនាងត្រូវនៅបន្តទីនេះ គឺធ្វើឲ្យនាងពិបាកចិត្តព្រោះនាងខ្លាចខ្មោចបំផុតនោះអី ហើយនាងអាចត្រូវបានអំណាចមន្តគ្រាមកគ្រប់គ្រងអារម្មណ៍ ត្រូវមកដើរស្រាតខោអាវឲ្យមនុស្សប្រុសមើលទៀតឬ? គឺពីរចំណុចនេះហ្នឹងឯងដែលនាងមិនអាចទទួលយកបាននោះណា។

អំ!!! ហើយនៅមានចំណុចទីបីមួយទៀត គឺនាងពិតជាខ្លាចកំលោះ



ដែលនៅចំពោះមុខនាងដែលប្រគល់មន្តស្នេហាមកកាន់នាងទៀត នេះជាកម្មពៀរអីទៅនៀក ហឺៗៗ!!! សំឡេងដកដង្ហើមធំក៏បានលាន់ឮឡើង។

ឈីតខាមែន អាចយល់ពីអារម្មណ៍នោះបាន តើគេអាចនិយាយប្រាប់នាងបានដោយរបៀបណាទៅ ដើម្បីឲ្យរឿងរ៉ាវទាំងឡាយស្ងប់ស្ងាត់បាន បើសិនជានាងមានចិត្តស្រឡាញ់គេដូចដែលព្រះនាង ទេមីន មានចិត្តស្រឡាញ់គូដណ្ដឹងព្រះនាងនោះប្រសើរបាត់ទៅហើយ ដល់ពេលនោះនឹងអាចមានការលុបលាងអំណាចមន្តគ្រាដ៏អាថ៌កំបាំងមួយនោះបាន ប្រហែលជាតួនាទីរបស់គេហើយដែលត្រូវធ្វើឲ្យនាងស្រឡាញ់គេ ឲ្យនាងប្រគល់ទាំងកាយទាំងចិត្តមកឲ្យគេដោយភាពស្មោះស្ម័គ្រ និងពេញចិត្ត។

«ខ្ញុំគិតថា នាងបានទទួលព័ត៌មានខ្លះដែលអាចយកទៅធ្វើជារបាយការណ៍សារណាខ្លះហើយណា យ៉ុនហ៊ី»

«លោកចង់ឲ្យខ្ញុំសប្បាយចិត្តចំពោះការដែលបានធ្វើរបាយការណ៍ដែលត្រូវប្ដូរជាមួយនឹង...»

«ជាមួយស្អីដែរទៅ?»

«ជាមួយនឹងការដែលខ្ញុំ អស់ខ្លួននោះអី ចេះសួរទៅកើតដែរ»

ឈីតខាមែន ព្យាយាមទប់សំណើច តែអត់មិនបានចំពោះរូបរាងដ៏សែនទាក់ទាញ និងស៊ិចស៊ីរបស់នាងកាលពីយប់មិញនោះ គេទៅវិញទេដែលមិនដឹងថា សំណាងល្អ ឬសំណាងអាក្រក់នោះ ដែលបានឃើញមនុស្សស្រីដូចជានាងសម្រាតសម្លៀកបំពាក់អាក្រាតកាយនៅចំពោះមុខគេ អួសទាញឲ្យគេមានតណ្ហាផ្លូវភេទបាននោះ។ ហើយដោយសារតែគេខ្លាចអំណាចមន្តគ្រាត្រូវបញ្ចប់ជីវិតរបស់នាងដូចស្រីៗដទៃជួបប្រទះនៅពេលដែលរួចរាល់ក្នុងការរួមភេទជាមួយគេរួចនោះ កុំអីដល់ណាដល់ណីទៅហើយ។

«នេះលោកសើចស្អីគេទៅ ខ្ញុំមិនកំប្លែងជាមួយលោកនោះទេណា»

«កុំគិតច្រើនអីណា នេះដល់ម៉ោងញ៉ាំអាហារពេលព្រឹកហើយ យើងនាំគ្នាញ៉ាំអាហារពេលព្រឹកសិនទៅណា»

«ខ្ញុំមិនមែនខួរក្បាលបង្កងនោះទេណា ដែលអាចភ្លេចមិនគិតច្រើនចំពោះរឿងដែលខ្ញុំអាក្រាតកាយនៅចំពោះលោកបាននោះ»

«អីចឹងគិតក៏គិតទៅ តែកុំបារម្ភអីណា ព្រោះខ្ញុំជឿជាក់ថាគ្រប់បញ្ហាអាចដោះស្រាយបាន»

ប្រហែលជាត្រូវជឿបែបហ្នឹងដែរហើយមើលទៅនោះ ហើយចុះផ្លូវដោះស្រាយរបស់គេគឺជាអ្វីទៅ? ក្រសែភ្នែកនាងមើលទៅកាន់ដៃរបស់ ខាមែន ដែលហ៊ានបំពានកាន់ដៃរបស់នាងនោះ នេះគេប្រហែលជាគិតថា គេគឺជាគូដណ្ដឹងរបស់នាងហើយមើលទៅនោះ។

ឈឺស!!! នាងមិនទាន់ទាំងបាននិយាយថា ជឿលើពាក្យសម្ដីដែលគេនិយាយទាក់ទងនឹងអំណាចអាថ៌កំបាំងនោះផង យ៉ុនហ៊ី គិតថា វាប្រាកដជាមានផ្លូវដោះស្រាយក្រៅពីការនិយាយរបស់គេនោះ ចាំគិតបណ្ដើរៗតាមក្រោយទៅចុះ ទៅញ៉ាំអាហារទ្រាប់ពោះសិនទៅចុះ នាងសរុបសេចក្ដីមុននឹងព្រមដើរទៅកាន់តុអាហារ យ៉ាងហោចណាស់ក៏គេមិនមែនជាគ្រូខ្មោចដូចដែលនាងគិតនោះដែរ។

ក្រោយពីភ្លៀងធ្លាក់យ៉ាងជោគជាំដូចបាក់មេឃកាលពីយប់មិញនោះ ព្រឹកថ្ងៃស្អែកថ្មីក៏ក្ដៅហួតហែងស្ទើរតែ ៤០ ទៅ ៥០ អង្សាសេទៅហើយ រូបរាងស្ដើងរបស់នាងបានលើកទូរស័ព្ទ ព្រមទាំងលើកវាឡើងខ្ពស់ហួសក្បាលដើម្បីរកសេវា ព្រមទាំងដើរចុះដើរឡើងៗ តែក៏ត្រូវឈប់ឆ្អឹងនៅពេលមានសំឡេងមួយបានលាន់ឮឡើង។

«អ្នកនាង យ៉ុនហ៊ី នៅទីនេះមានសេវាពេញតែម្ដង»

«អ!!! មែននោះណា ខ្ញុំមិនបានមើលនៅលើអេក្រង់ទូរស័ព្ទនោះណានេះឯងដឹងបានដោយរបៀបណាដែរទៅ ជូនី?»

«ហឹមមម!!! ព្រោះលោក ឈើតខាមែន ដាក់សេវាផ្ទាល់ខ្លួនរបស់គាត់នោះណាអ្នកនាង»



មែននោះណា គេមានឋានៈដល់ទៅមហាសេដ្ឋីមានលុយច្រើនរាប់រយពាន់លាន ដើរស៊ីដេកស៊ីមួយជាតិក៏មិនអស់ដែរ គ្រាន់តែសេវាផ្ទាល់ខ្លួនជាកម្ទេចលុយរបស់គេប៉ុណ្ណោះមិនហួសពីសមត្ថភាពគេនោះទេ។ នាងក៏បានចុចទូរស័ព្ទទៅកាន់គោលដៅដែលនាងចង់ចុច ហើយប្រញាប់បញ្ចេញសំឡេងភ្លាម នៅពេលអ្នកទទួលលើក។

«ហាន់ណា!! គឺយើងណា»

[យ៉ុនហ៊ី!!! ឯង...ឯងនៅរស់ទេ?]

«គឺនៅរស់ហ្នឹងឯង យើងនៅមិនទាន់ងាប់ទេណា»

[មិនមែនទេណា យើងចង់មានន័យថា ឯងនៅក្នុងសេតវិមានរបស់ឈើតខាមែន ទៀត?]

«ត្រូវហើយណា!!!»

[ហេតុអីក៏ឯងមិនលើកទូរស័ព្ទ!!! នេះយើងចុចទៅឯងឡើងប៊ូតុងទូរស័ព្ទស្ទើរតែផ្លុះអស់ទៅហើយណា]

«កុំអាលរអ៊ូទៅមើល ចុះយើងចុចទៅរកឯងហើយនោះអី»

[ហើយចុះឯងជួបអីខ្លះដែរទេ!!!]

សំឡេងរសាប់រសល់ដែលសួរពីសកម្មភាពទាំងឡាយនោះធ្វើឲ្យ ស្រីស្រស់ដឹងតែម្ដងថា មិត្តភក្ដិជើងល្អរបស់នាងដឹងរឿងអីច្រើនទាក់ទងនឹងឈើតខាមែន ជាក់ជាមិនខានឡើយ។

[យ៉ុនហ៊ី យ៉ុនហ៊ី!!! ឯងស្ដាប់យើងឬអត់ទេ?]

«ស្ដាប់តើស ស្ដាប់ យើងកំពុងតែស្ដាប់ឯងណា វ៉ះ!! ហាន់ណា ឯងសាកសួរ ឈើត ទៅមើលថា ធ្វើយ៉ាងណាយើងអាចចេញពីទីនេះបានដែរទៅ»

[ថាម៉េច យ៉ុនហ៊ី!! ថាម៉េច!! ឯងនិយាយថាម៉េច?]

«ហាន់ណា!! យើងចង់ចាកចេញពីទីនេះ ឯងដឹងទេ អាក!!!! ដាច់បាត់»

យ៉ុនហ៊ី ចម្លែកចិត្តមែនទែនថា ហេតុអីនិយាយសុខៗក៏ដាច់ទៅ មានអី

ចូលមកជ្រែកតែម្ដង បានជាដាច់បែបនេះនោះ នាងពិនិត្យមើលនៅលើអក្រង់ទូរស័ព្ទឃើញមានសេវាពេញតែម្ដង ស្រីស្រស់ព្យាយាមចុចលេខទូរស័ព្ទមិត្តនាងជាថ្មីម្ដងទៀត តែមិនចូលសោះ។

«កុំប្រាប់ឲ្យសោះថា អស់ថ្មនោះ ហឺៗៗៗៗ !!!»

នាងរអ៊ូរទាំព្រមទាំងចុចទូរស័ព្ទបណ្ដើរក៏នឹកឃើញភ្លាមថា ចុះបើសិនជាមិនមែនទូរស័ព្ទមិត្តនាងអស់ថ្ម តើវាជាស្អីទៅ បើសេវាមានស្ទើរតែមួយរយភាគរយហើយ ឬអំណាចមន្តគ្រារបស់ព្រះនាង ទេមិន?

រំពេចនោះនាងហាក់បីដូចជា មានអារម្មណ៍ថា ខ្យល់បក់ផាយផាត់ព្រមទាំងធ្វើឲ្យនាងត្រជាក់ពេញប្រាណថែមទៀតផង ព្រមជាមួយនឹងសំឡេងគ្រលួចមកព្រមគ្នាជាមួយខ្យល់។

**"រាងកាយ ចិត្តវិញ្ញាណរបស់នាងជារបស់យើង ហា...ហា...ហាស់"**

សំឡេងគ្រលួចដែលនាងធ្លាប់ឮ បានឮទ្រហឹងនៅក្នុងសរសៃប្រសាទរបស់នាងសាជាថ្មីម្ដងទៀត បរិយាកាសប្រែប្រួលជាគួរឲ្យខ្លាចយ៉ាងចម្លែកម៉េចមិនដឹងទេ យ៉ុនហ៊ី ព្យាយាមរកប្រភពសំឡេងដែលនិយាយគ្រលួចនោះ ដើម្បីកាត់បន្ថយភាពភ័យខ្លាចរបស់នាង។

«ជូនី!! ឯងជាអ្នកនិយាយមែនទេ!! នោះគឺឯងមែនទេ ឯងនៅទីណាដែរហ្នឹង ជូនី!!!»

កែវភ្នែកភ័យខ្លាចនោះសម្លឹងទៅកាន់អេក្រង់ទូរស័ព្ទដែលពេលនេះបែរជាមានពន្លឺភ្លឺបភ្លែតៗ ព្រមទាំងមានកែវភ្នែកបើកធំៗមួយគូកំពុងតែបើកភ្នែកមើលមកកាន់នាង រំពេចនោះ យ៉ុនហ៊ី បានគ្រវែងទូរស័ព្ទនោះចេញឆ្ងាយពីនាងភ្លាម។

«អូយ!!! នេះ...នេះជាស្អីទៅ ជូនី!»

មាត់ដ៏តូចនោះហាមាត់ស្រែករកស្រីបម្រើដែលនៅសុខៗ ក៏បាត់ខ្លួនទៅកែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះ ក្រឡេកមើលទៅជុំវិញបរិវេណនោះដោយអារម្មណ៍ភ័យខ្លាច ទោះបីជាពេលថ្ងៃត្រង់ក៏ដោយចុះ ហើយទោះបីជាមិនមែន



សុបិន តែនោះវាគឺជាការពិត នេះនាងត្រូវបានខ្មោចលងឬ!!!

«ជូនី!! ជូនី!!! ឯងនៅឯណា!!!»

នៅពេលមិនមានសំឡេងទទួលឆ្លើយតបពីស្រីបម្រើ ទើបនាងប្រញាប់រត់ចូលទៅក្នុងសេតវិមាននោះយ៉ាងលឿន ទោះបីជាដួលអស់ដៃអស់ជើងយ៉ាងណាក៏ប្រសើរជាងត្រូវខ្មោចលងដែរ ព្រមទាំងមានអារម្មណ៍ថា បុកជាមួយនឹងរាងកាយនៃមនុស្សមាឌធំមួយទំហឹង។

«**អូយ**!!!»

«យ៉ុនហ៊ី!! យ៉ុនហ៊ី!!!»

«ឈឹតខាមែន!!!»

«មែនហើយគឺខ្ញុំ នាងជួបអីមែនទេ?»

«ខ្ញុំ...ខ្ញុំនៅទីនេះទៀតមិនបាននោះទេ ខ្ញុំចង់ចាកចេញពីទីនេះ ខ្ញុំចង់ចេញពីទីនេះ»

ដៃទាំងពីរដ៏សែនទន់ភ្លន់នោះអង្រួនប្រាណឈឹតខាមែនយ៉ាងញាប់ញ័រ ដើម្បីបញ្ជាក់ថា នាងពិតជាខ្លាចខ្លាំងណាស់ ខ្លាចរហូតស្ទើរក្លាយទៅជាមនុស្សឆ្កួតទៅហើយ។

**«ទេ ទេ!!! ខ្ញុំលែងនៅទីនេះហើយ ខ្ញុំមិននៅទេ»**

ឈឹតខាមែន ឱបក្រសោបប្រាណដែលទន់នោះយ៉ាងណែន ព្រមទាំងអង្អែលខ្នងលួងលោម ប្រុសសង្ហាគិតថា នាងប្រហែលជាជួបនឹងអំណាចមន្តគ្រាមួយនោះហើយមើលទៅ។

«លែងមានអីហើយណា លែងមានអីហើយ»

«មានតើស!!! ក្រែងលោកក៏ដឹងដែរថា មាននោះ លោកមិនបាច់មកលួងលោមខ្ញុំនោះទេ ខ្ញុំមិនជឿលោកទៀតឡើយ ខ្ញុំនឹងចេញពីទីនេះ...»

ឈឹតខាមែន មើលទៅកាន់មនុស្សស្រីដែលនៅក្នុងប្រអប់ដៃរបស់គេពេលនេះនាងយំសោកព្រមទាំងគ្រវីក្បាលចុះឡើងៗ ដោយមិនព្រមស្ដាប់ហេតុផលអ្វីទាំងអស់ ប្រហែលជាមានតែគេម្នាក់ហើយមើលទៅនោះ

ហៅសតិស្មារតីនាងត្រឡប់មកវិញបាននោះ។

«យ៉ុនហ៊ី ស្ដាប់ខ្ញុំណា ទោះបីជានាងនៅតែរឹងទទឹងក្នុងការចាកចេញពីទីនេះឲ្យបានយ៉ាងណា តែនាងមិនអាចគេចវេសពីបួងមន្តគ្រានោះបានឡើយ ព្រោះថា វាចងនាងជាប់នៅក្នុងអំណាចវិលវល់មួយនោះរហូតដល់ថ្ងៃស្លាប់»

«តែខ្ញុំខ្លាច!! លោកយល់ទេថា ខ្ញុំខ្លាច!!!»

«យល់ណាស់ ខ្ញុំពិតជាយល់ខ្លាំងមែនទែន! បើសិនជានាងចាកចេញពីទីនេះនឹងមិនមានអ្នកណាយល់ ពីអំណាចមន្តគ្រាដ៏អាថ៌កំបាំងនេះបានឡើយ តែបើនាងនៅទីនេះ នាងនៅមានខ្ញុំ នាងយល់ដែរទេថា នាងនៅមានខ្ញុំដែលយល់ពីនាង...»

គេសម្លឹងមើលទៅកាន់នាង ដែលពេលនេះស្ងាត់មាត់ មានតែសំឡេងដកដង្ហើមក្ដៅខណ្ដាៗនៅក្នុងប្រអប់ដៃលើដើមទ្រូងរបស់គេ ដៃធំរបស់គេលូកទៅអង្អែលខ្នងនាងយ៉ាងល្ងង់លោម។

«ហេតុអីក៏ជាខ្ញុំ ហេតុអីក៏ជារូបខ្ញុំអីចឹង!!!»

«ព្រោះតែនាងមានក្រសែចិត្តនោះអី ចិត្តដែលអ្នកដទៃមិនមាន!!»

«ក្រសែចិត្ត!!!»

«ត្រូវហើយ!!! គ្រប់យ៉ាងត្រូវបានកំណត់មកបែបហ្នឹងស្រាប់ទៅហើយ ហើយនាងក៏មានក្រសែចិត្តដែលអំណាចមន្តគ្រានោះអាចទំនាក់ទំនងជាមួយនាងបានថែមទៀតផង»

ឈីតខាមែន ចាប់ស្មាទាំងសងខាងរបស់ស្រីស្រស់ កែវភ្នែកមួយគូដែលមោះមុតនោះសម្លឹងមើលមុខនាងដែលពោរពេញទៅដោយទឹកភ្នែក សំឡេងគ្រលរនៅតែនិយាយបន្ត។

«បើសិនជាតាមលក្ខណៈវិទ្យាសាស្ត្រ នាងសាកគិតទៅមើលថា ហេតុអីក៏មានមនុស្សមួយចំនួនត្រូវរន្ទះបាញ់ ហើយមួយចំនួនទៀតមិនត្រូវរន្ទះបាញ់ ដែលការពិតទៅពួកគេនៅក្រោមភ្លៀងធ្លាក់ដូចគ្នា»

«នេះលោកចង់និយាយថា មនុស្សដែលត្រូវរន្ទះបាញ់នោះមានក្រសែ-



ចិត្តដែលអាចឲ្យរន្ទះបាញ់បានឬ?»

«ត្រូវហើយណា ដូចដែលនាងយល់ហ្នឹងឯង ដូចដែលនាង និងខ្ញុំដែលត្រូវបានមន្តសង្កត់មិនអាចជៀសផុតបាន»

«តែ...តែខ្ញុំ...»

«មិនមានតែទេ នាងត្រូវតែទទួលវាឲ្យបាន ហើយរកផ្លូវដោះស្រាយរួមគ្នា»

ដៃធំនោះកាន់តែឱបនាងជាប់ព្រមទាំងអង្អែលល្ងង់លោម នាងហាក់បីដូចជាតាំងស្មារតីបានព្រោះបានទទួលការប៉ះស្ទាបដ៏កក់ក្ដៅ តែនាងក៏ច្រានគេចេញ ព្រមទាំងមានអារម្មណ៍ខឹងចិត្តខ្លួនឯងមែនទែនដែលព្រមអនុញ្ញាតឲ្យគេឱបបានយ៉ាងយូរសែនយូរ។

«នាងកុំមានគំនិតចាកចេញពីទីនេះអីណា ព្រោះថាវាក៏ាង នឹងគោលបំណងរបស់ព្រះនាង ទេមីន»

ឈឹស!!! គេចេះតែនិយាយហើយ ព្រោះគេមិនមែនជាអ្នកជួបរឿងរ៉ាវនោះផ្ទាល់ ហើយម្យ៉ាងទៀតគេមិនមែនជាអ្នកស្រាតខោអាវឯណា ថែមទាំងគេជាមនុស្សប្រុសដែល ឃើញនាងអាក្រាតកាយផងដែរ ហើយសំឡេងគ្រលួចនោះក៏បន្លឺឡើង។

«នាងសន្យាជាមួយខ្ញុំមកណាថា នាងនឹងនៅទីនេះដើម្បីដោះស្រាយបញ្ហាជាមួយខ្ញុំណា»

សំឡេងដកដង្ហើមធំក៏បានងកចេញមកយ៉ាងនឿយណាយចិត្តមែនទែន កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះ សម្លឹងមើលទៅកាន់កែវភ្នែកមោះមុតរបស់គេដែលពេលនេះកំពុងតែបញ្ចេញមន្តស្នេហ៍ នេះនាងត្រូវជួបទាំងខ្មោចទាំងស្នេហាឬ! ទើបនាងប្រញាប់ទទួលពាក្យគេភ្លាមដើម្បីបញ្ចប់កែវភ្នែកស្នេហា ដែលគេបានបញ្ចេញមកកាន់នាងនោះ។

«ហ៊ឹម!!! អីចឹងក៏បានដែរ អីចឹងក៏បានដែរ!!!»

«អីចឹងក៏បាននោះមានន័យថាម៉េចទៅ!!»

«អាក!!! គឺនៅទីនេះនោះអី ចុះក្រែងលោកចង់ឲ្យខ្ញុំនៅទីនេះឬ?»

ចប់សំឡេងនិយាយនោះ នាងក៏ដើរចេញទៅព្រមទាំងស្រែកហៅស្រីបម្រើនៅក្នុងសេតវិមាន នាងប្រហែលជាយក ជូនី ទៅនៅក្បែរនាងរហូតហើយមើលទៅនោះ។

«ជូនី!! ជូនី!! ឯងនៅណាហ្នឹង!!!»

«ចាស នៅទីនេះអ្នកនាង!!»

«ចាប់ពីពេលនេះតទៅហាមនៅឆ្ងាយខ្ញុំឲ្យសោះណា យល់ដែរទេ!!!»

«ហេតុអីដែរទៅ អ្នកនាង!!»

«ចុះបើខ្ញុំខ្លាចខ្មោចនោះណា ចេះសួរទៅកើត?»

«ខ្មោចស្អីគេដែរទៅ ខ្ញុំមកនៅតាំងពីយូរហើយ មិនដែលឃើញមានខ្មោចអីនោះផង»

«ចុះបើឯងមិនមានក្រសែបិត្តអាចមើលឃើញដូចខ្ញុំនោះណា»

«ក្រសែចិត្ត!! ក្រសែបិត្តអីគេដែរទៅ អ្នកនាង!»

«មិនចាំបាច់សួរទេណា ជូនី ចាំទុកថានាងត្រូវតែនៅជាមួយខ្ញុំគ្រប់ពេលវេលា យល់ទេ!»

«ចាស!! ចាស!! យល់ហើយចាស!!»

ឈឺតខាមែន សម្លឹងមើលរូបរាងតូចប្រឡូងដែលពេលនេះបានដើរទៅកាន់បន្ទប់សម្រាករបស់នាងទៅ គេអត់ទ្រាំមិនសើចចំពោះស្រីស្រស់ដែលជឿជាក់លើខ្លួនឯង ហើយត្រូវមកជួបនឹងអំណាចអាថ៌កំបាំងមួយ គឺដូចរូបគេកាលពីដំបូងដែរ កាលនោះគេក៏ធ្លាប់មិនជឿ និងបានសាកល្បងរឹងទទឹងចំពោះអំណាចអាថ៌កំបាំងនោះដែរ ដោយសារតែគេជាបុគ្គលជំនាន់ថ្មី មានការគិតទាន់សម័យ មិនព្រមជឿនូវអ្វីដែលបិតាគេប្រាប់ពីដើមកំណើតនៃវង្សត្រកូល ទើបបណ្ដាលឲ្យកើតមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះមនុស្សដែលនៅជុំវិញខ្លួនគេ។

ឈឺតខាមែន ត្រឡប់ទៅគិតចំពោះហេតុការណ៍កាលពីអតីតដែលគេ



បានបំពានទៅលើអំណាចមន្តគ្រាជ័រអាថ៌កំបាំងមួយនោះ មិនជឿនូវអ្វីដែលបិតាគេនិយាយ ហាមមិនឲ្យនៅជិត ឬក្បែរមនុស្សស្រីណាឡើយ ព្រោះថាគេគឺជាមនុស្សប្រុសដែលហាមឃាត់។ នៅពេលនោះគេក៏បានទឹកអស់សំណើចចំពោះពាក្យសម្ដីនោះដែរ រួចក៏បានប្រើជីវិតរស់នៅដូចប្រុសដទៃ ដែលចេញចូលសង្គមបានតាមចិត្ត ចេញទៅកម្មវិធីជប់លៀងផ្សេងៗទៀត។

«នោះនោះអី ឈឺតខាមែន ណា នែននី ឯងចង់ស្គាល់គេមិនអីចឹងឬ?»

«អូ!!! ព្រះជាម្ចាស់!!! រូបពិតហេតុអីក៏សង្ហាជាងក្នុងរូបថតបែបនេះទៅវិញ សង្ហាមានមន្តស្នេហ៍គួរឲ្យទាក់ទាញមែន»

«នែ!! នែ!! ឯងឈប់ស្រមើស្រមៃទៀតទៅណា មកនេះមក យើងណែនាំគេឲ្យស្គាល់ឯងណា នែននី»

ស្រីស្អាតលំដាប់បវរកញ្ញា និងតារាស្រីស្អាតល្បី ឬក៏ស្រីលំដាប់ខ្ពស់អីផ្សេងៗ ចង់មានទំនាក់ទំនងជាមួយគេមិនខ្វះនោះទេ ព្រោះគេជាមនុស្សប្រុសដែលអស្ចារ្យគ្រប់យ៉ាងគ្មានខ្វះចន្លោះត្រង់ណាឡើយ។

«ឈឺតខាមែន អញ្ជើញខាងនេះចាស»

«អ!! ព្រីម គឺនាងទេ មានការអីដែរទៅ?»

«ខ្ញុំចង់ណែនាំលោកឲ្យស្គាល់ នែននី មិត្តភក្តិរបស់ខ្ញុំនោះណា នាងគឺជាអ្នកចេញម៉ូតគ្រឿងពេជ្រ អាចថ្ងៃមុខលោកអាចបានរួមការងារជាមួយនាងនោះអី»

«បាទរីករាយដែលបានស្គាល់ណា នែននី»

«រីករាយដែលបានស្គាល់លោកដូចគ្នាដែរ ឈឺតខាមែន»

ការស្គាល់គ្នាតាមរយៈមិត្តភក្តិណែនាំ យូរៗទៅក្លាយជាមានទំនាក់ទំនងគ្នាយ៉ាងជ្រាលជ្រៅ តែពួកនាងតែងតែបានបញ្ចប់ជីវិតតាមៗគ្នាទៅ ម្នាក់ ពីរនាក់ បីនាក់ និងកាន់តែបន្ថែមកើនឡើងជាបៀយៗ។ នៅពេលណាដែលគេមានទំនាក់ទំនងស្និទ្ធស្នាលជាមួយពួកនាង ពួកនាងដូចមិនមែនជាពួកនាងអីចឹង ហើយអ្វីដែលប្លែកគួរឲ្យកត់សម្គាល់គឺពួកនាងបានបញ្ចប់ជីវិតដូចៗគ្នា គឺការសម្លាប់ខ្លួន

ដោយមិនមានបញ្ហាអីធំដុំទេ។

នោះគឺជាហេតុផល ដែលនាំឲ្យគេជឿពាក្យសម្ដីដែលបិតារបស់គេនិយាយប្រាប់ ហើយក៏ព្រមប្រតិបត្តិតាម។ តែសម្រាប់មនុស្សស្រីដែលគេស្រឡាញ់គេពិតជាមិនចង់ឲ្យនាងតបតជាមួយគេវិញដោយអំណាចបួងមន្តគ្រានេះឡើយ។

កែវភ្នែកមុតមាំនោះគិតថា មនុស្សស្រីម្នាក់នេះត្រូវដើរទៅតាមកូនអុកនៃអំណាចបួងមន្តគ្រា ហើយត្រូវតែរួមដៃគ្នារកវិធីដោះស្រាយ ឲ្យរួចផុតពីបួងមន្តគ្រានោះព្រមគ្នា នោះគឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់នាងផងដែរ។

នៅពេលរាត្រីបានមកដល់សាជាថ្មី ស្រីស្រស់ក៏កើតមានអាការខ្វល់-ខ្វាយក្រហល់ក្រហាយចិត្តជាថ្មី ជូនី ស្រីបម្រើកំពុងតែងឿងឆ្ងល់ចំពោះនាងដែលគ្រាន់តែគេងយប់សោះនាងពាក់ខោអាវអីក៏ច្រើនជាន់ម្ល៉េះ? រហូតដល់ថ្នាក់នាងភ័យតែម្ដង មុខមាត់ដូចជាស្អាតបាតទេ ហេតុអីក៏ចូលចិត្តធ្វើខ្លួនចម្លែកៗបែបនេះទៅវិញនៀក នាងពិតជាមិនយល់ទាល់តែសោះហើយ នាងគិតរួចក៏អត់ទ្រាំមិនសួរដោយក្ដីសង្ស័យមិនបាន។

«អ្នកនាង យ៉ុនហ៊ី ហេតុអីក៏ស្លៀកពាក់សម្លៀកបំពាក់ច្រើនជាន់ម្ល៉េះ?»

កែវភ្នែកមួយគូស្រស់ស្អាតនោះមើលទៅកាន់អ្នកសួរ ចុះបើវាជាវិធី-សាស្ត្រការពារខ្លួនលំដាប់ទីមួយនោះណា ដើម្បីឲ្យខ្មោចពិបាកដោះខោអាវនាងចេញនោះអី ហើយតើនាងនឹងនិយាយប្រាប់ដល់ស្រីបម្រើនោះថាយ៉ាងណាដែរទៅ។

«អ!!! ខ្ញុំមានអារម្មណ៍ថា រងាហ្នឹងណា ជូនី មិនអីទេ តោះគេងទៅ!!»

«រងា? អីចឹងបន្ថយម៉ាស៊ីនត្រជាក់បន្តិចទៅក៏បានដែរ»

«មិនចាំបាច់បន្ថយម៉ាស៊ីនត្រជាក់ទេ ខ្ញុំអត់អីទេ ឯងគេងចុះណា អ!!! ហើយតួនាទីរបស់ឯងគឺត្រូវតែប្រុងប្រយ័ត្នមើលខ្ញុំឲ្យជិតដល់មែនទែនណា កុំឲ្យខ្ញុំដើរចេញទៅក្រៅបន្ទប់នេះឲ្យសោះ យល់ដែរទេ!»

«ចាស យល់ហើយណាអ្នកនាង!!»



យ៉ុនហ៊ី និយាយបញ្ជាក់ម្ដងហើយម្ដងទៀតជាមួយក្មេងស្រីបម្រើម្នាក់នោះដែលកំពុងតែអេះក្បាល!!! ព្រមទាំងលើកខ្នើយឱបទៅដាក់នៅឆ្កួរជើរនៃមាត់ទ្វារចូលតាមបញ្ជារបស់នាង ទោះបីជាមិនសូវជាទុកចិត្តចំពោះអ្វីដែលនាងធ្វើយ៉ាងណាក៏ដោយចុះ តែក៏ប្រសើរជាងមិនបានធ្វើអ្វីសោះនោះដែរ។

យប់យន់ស្ងាត់ឈឹង មេឃឈើបក់បោកតាមកម្លាំងខ្យល់បក់រវិចៗ សំឡេងឆ្កែព្រៃនាំគ្នាលូយ៉ាងទ្រហឹងអឹងកង ស្រីស្រស់កំពុងតែគេងយ៉ាងលង់លក់ តែដោយសារតែអំណាចអាថ៌កំបាំងមួយបានធ្វើឲ្យនាងគេងបើចុះឡើងៗដៃរបស់នាងបានទាញខោអាវដែលពាក់ជាច្រើនជាន់នោះ ចេញអស់ពីខ្លួនញើសចេញជាគ្រាប់ធំៗនៅលើផ្ទៃមុខ ស្រីស្រស់ស្ទុះក្រោកឡើងដោយមិនដឹងខ្លួន ជើងដ៏សែនល្អតល្ងន់នោះ ឈានជើងចុះពីលើគ្រែគេង ដើរតម្រង់ទៅកាន់ទ្វារចេញដែលពេលនោះបើកចំហរួចជាស្រេចដោយអំណាចមន្តគ្រាអាថ៌កំបាំងមួយនោះ ហើយដើររំលងប្រាណស្រីបម្រើនោះទៅយ៉ាងងាយស្រួល។

ឈិតខាមែន ក្រោកដឹងខ្លួនឡើង មើលទៅកាន់ប្រាណរបស់ស្រីស្រស់ដែលកំពុងតែដើរសំដៅចូលមកក្នុងបន្ទប់របស់គេ នាងប្រហែលជាមកទីនេះដោយអំណាចមន្តគ្រាដូចកាលពីយប់មិញហើយមើលទៅ រូបគេផ្ទាល់ក៏បានត្រៀមខ្លួនរួចជាស្រេចហើយក្នុងការទទួល រំពេចនោះសំឡេងដែលគេតែងតែប្រើសម្រាប់បញ្ឈប់បញ្ហាបានលាន់ឮឡើង។

«ព្រះនាង ទេមីន ចូរព្រះនាងបញ្ឈប់ទង្វើបែបនេះភ្លាមទៅ»

ភ្នែករបស់ស្រីស្រស់ ដែលត្រូវបានគ្រប់គ្រងដោយអំណាចមន្តគ្រា បែរជាបើកធំៗ ហើយមានពណ៌ខៀវសម្លឹងមកកាន់ ឈិតខាមែន ដែលនៅតែព្យាយាមនិយាយហាមប្រាម។

«មនុស្សស្រីដែលព្រះនាងកំពុងតែគ្របដណ្ដប់ម្នាក់នេះ ជាផ្នែកមួយរបស់ព្រះនាង ដែលបានមកចាប់ជាតិជាថ្មីនោះណាព្រះនាង បើសិនជាព្រះនាងចង់បាននាង ដោយការយកប្រាណដែលចាប់ជាតិថ្មីមកលេងសើចបែប

នេះ នោះចិត្ត កាយ វិញ្ញាណរបស់ព្រះនាងមិនអាចស្ងប់ចិត្តបានឡើយ ខ្ញុំក្រែងថានឹងអាចធ្វើបាបមនុស្សស្រីម្នាក់នេះវិញទេណាព្រះនាង»

**«ទេ ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ ព្រះអង្គគឺជាព្រះស្វាមីរបស់ខ្ញុំម្ចាស់ព្រះអង្គបានចាកចោលខ្ញុំម្ចាស់មក តាំងពីថ្ងៃរៀបអភិសេកម្ល៉េះ ខ្ញុំម្ចាស់ទន្ទឹងរង់ចាំព្រះអង្គម្ចាស់មករាប់ពាន់ឆ្នាំហើយ ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ ខ្ញុំម្ចាស់ត្រូវការព្រះអង្គ»**

ឈឺតខាមែន សម្លឹងមើលរាងកាយដ៏ទន់ល្វតល្វន់នោះ ពេលនេះនាងកំពុងតែសម្រាតខោអាវទោះបីគេជាមនុស្សប្រុសដែលមានអារម្មណ៍រំជើបរំជួលចំពោះរូបរាងដ៏សែនសិចស៊ីយ៉ាងណាក៏ដោយ ក៏គេមិនមានអារម្មណ៍ចង់អីជាមួយនាងនៅពេលនេះនោះដែរ ព្រោះគេដឹងច្បាស់ថានោះគឺជាអំណាចអាថ៌កំបាំងតែប៉ុណ្ណោះ គេបានសូត្រមន្តគាថាដែលបិតាគេបានប្រាប់មុនពេលដែលលោកបានចែកឋានទៅ នៅចំពោះសំឡេងអឺងកងដែលជ្រែកចូលក្នុងអារម្មណ៍របស់គេ។

**«រាងកាយ ចិត្ត និងវិញ្ញាណរបស់នាងទាំងអស់ជាកម្មសិទ្ធិរបស់យើងហើយ នៅពេលនេះ យើងចង់មានសម្ពន្ធភាពជាមួយព្រះស្វាមីរបស់យើង ហាស់ ហាស់ ហាស់»**

ឈឺតខាមែន ហៀបជាមានអារម្មណ៍ចម្លែកចិត្តមែនទែនថាមន្តគាថាដែលគេតែងតែសូត្រកាលពីលើកមុនៗ ហេតុអីក៏លើកនេះហៀបជាមិនបានផលដូចសព្វដងអីចឹង គេសម្លឹងមើលរាងកាយអាក្រាតដែលត្រូវមន្តសណ្ដំនៃអំណាចមន្តគ្រាដ៏អាថ៌កំបាំងនោះ មើលទៅសភាពរបស់នាងដូចជាតក់ក្រហល់នឹងចំណង់រួមភេទណាស់ ហើយនាងក៏កំពុងតែខិតចូលបន្តិចម្ដងៗមកលូកស្ទាបអង្អែលប្រាណរបស់គេ។ កែវភ្នែករបស់គេសម្លឹងឃើញបន្ទោងខ្សែកដែលពាក់នៅនឹងករបស់នាង ឈឺតខាមែន ប្រញាប់កន្ត្រាក់វាចេញពីករបស់នាង ហើយលើកយកមកក្ដាប់ជាប់នឹងដៃ ព្រមទាំងសូត្រមន្តគាថាដែលបិតាគេប្រាប់នោះភ្លាមរហូតដល់រាងកាយនន្ទលគកនោះខ្ទាតចេញពីគេ ហើយសម្រែកស្រែករបស់



នាងក៏បានបន្លឺឡើងភ្លាម។

អាយយយយយ!!!!

ឈឺតខាមែន បះពោមឆ្អឹតចំពោះសំឡេងស្រែកនោះ។ នាងប្រហែលជារួចផុតពីអំណាចគ្រប់គ្រងនោះហើយមើលទៅ ឈឺតខាមែន លើកយកភួយមកគ្របដណ្ដប់លើប្រាណនន្ទលគករបស់នាងដែលគេងសន្លប់ឥតឲ្យដឹងខ្លួន គេសម្លឹងមើលទៅកាន់នាង ដែលគេងលង់លក់នោះ រួចក៏ដាក់កាយចូលគេងនៅក្បែរនាង។

«ខ្ញុំនឹងមិនផ្ដល់ឱកាស ក្នុងពេលដែលនាងមិនមែនជារូបវិញ្ញាណនាងផ្ទាល់នោះទេ»

ឈឺតខាមែន និយាយរអ៊ូរ ហើយឱបក្រសោបនាងយ៉ាងណែនជាប់ដើមទ្រូង គេទៅវិញទេដែលត្រូវរងទុក្ខវេទនាដែលត្រូវមកគេងឱបមនុស្សស្រីដ៏សែនសិចស៊ីដូចជានាងនោះណា។

អាកាសធាតុចាប់ផ្ដើមត្រជាក់ទៅៗ នាងកម្រើកខ្លួនខិតចូលកាន់តែជិតគេ នាងហាក់បីដូចជាមានអារម្មណ៍ថាសែនកក់ក្ដៅដែលបាននៅក្នុងប្រអប់ទ្រូងរបស់គេបែបនេះណាស់ ហើយអារម្មណ៍នោះក៏ដឹងថា ដូចជាមានការលូកប៉ះស្ទាបលើរាងកាយរបស់នាងកាន់តែជ្រៅទៅៗ

នាងសុបិនទៀតហើយឬយ៉ាងណានៀក ដៃទាំងពីររបស់នាងចាប់កាន់ផែនទ្រូងដ៏ធំល្វឹងល្វើយនោះ ព្រមទាំងគិតថា តើស្អីទៀតហើយនៀក ហេតុអីក៏ដូចមែនទែនទៀតហើយហ្នឹង វាជាការពិត ឬក៏ហុកទៅនៀក ដែលនាងមកដេកឲ្យគេឱបស្រួលៗបែបនេះនោះ រំពេចនោះនាងចាប់ផ្ដើមដឹងខ្លួនមែនទែន ទើបដឹងថាវាជាការពិតមិនមែនជាក្ដីសុបិនល្អតរបស់នាងនោះឡើយ។

**«អាយយយ!! ឈឺតខាមែន!»**

ឈឺតខាមែន ភ្ញាក់ឲ្យព្រើតចំពោះសំឡេងស្រែកយ៉ាងស្លុតចិត្តនោះ ព្រមទាំងបើកភ្នែកធំៗ មើលទៅកាន់មនុស្សស្រីដែលក្រោកឈរឡើងទាំងនន្ទលគកដោយភ្លេចខ្លួននោះផងដែរ ក្រសែភ្នែករបស់នាងមើលមកកាន់គេដូចចង់ស៊ីសាច់

ហុតឈាមទាំងរស់អីចឹង។

«នែ៎ លោក!!! ឆ្កួតតណ្ហាក្រាស់ មិនគ្រប់ទឹក លោកឆក់ឱកាសលើខ្ញុំទៀតហើយណា!!!»

«យ៉ុនហ៊ី!! នាងកុំឡូឡាទៅមើស គេងតទៀតទៅណា ចាំស្អែកចាំនិយាយគ្នាទៀតណា...»

យ៉ុនហ៊ី មើលទៅកាន់រាងកាយដែលគេងស្ដូកស្ដឹងនោះ ហេតុអីក៏គេនិយាយបានស្រួលៗម្ល៉េះ ហេតុអីក៏ចាំដល់ស្អែកដែរទៅ ហើយចុះយប់នេះនោះគេចង់ឲ្យនាងគេងជាមួយគេទៀតឬ និយាយចេះតែនិយាយបានហ្នឹងហើយ ចុះបើគេជាមនុស្សប្រុសនោះអី តែរំពេចនោះនាងហាក់បីដូចជាមានអារម្មណ៍ថាល្ហល្ហេវលើប្រាណរបស់នាង ដៃទាំងទ្វេចាប់ស្ទាបទៅតាមដងខ្លួន ព្រមទាំងឱនមើលទៅកាន់ប្រាណទាំងមូល ពេលនេះគឺនទលគក រំពេចនោះសំឡេងស្រែកក៏បានលាន់ឮយ៉ាងស្អុតស្អូងម្ដងទៀត។

«អាយយយយ!! ឈិតខាមែន!!!»

«ហឺស!!! នាងហៅខ្ញុំទៀតហើយណា»

រំពេចនោះបុរសសង្ហា មិនដឹងជាសំណាងល្អឬក៏សំណាងអាក្រក់នោះទេ ពេលបើកភ្នែកឡើងបានឃើញរាងកាយនទលគករបស់នាងដែលនៅមិនឆ្ងាយពីកែវភ្នែកប៉ុន្មាននោះផងដែរ ទោះបីជានាងព្យាយាមបិទបាំងរបស់របរនាងក៏ដោយចុះ តែវាមិនបានបិទបាំងជិតឯណា នេះនាងមិនដឹងខ្លួននាងទេឬថា ពេលនេះនាងបានដុតភ្លើងតណ្ហាដល់គេស្ទើរតែទប់អារម្មណ៍មិនបានទៅហើយ។

«លោក!! លោកចង់ធ្វើអីហ្នឹង!!!»

«គឺខ្ញុំជួយនាងដូចកាលពីយប់នោះនោះអី ខ្ញុំមានទៅធ្វើអីក្រៅពីហ្នឹងបានដែរទៅ»

«ធ្វើដូចកាលពីយប់ តែខ្ញុំគេងជាមួយលោកណា...»

នាងមិនចង់និយាយថា នាងគេងនទលគកកៀកកើយគេនោះទេណា តើម៉េចនឹងអាចទៅរួចដែរទៅ។ ទោះបីជាសំឡេងនោះព្យាយាមធ្វើការបដិសេធ



តើនាងម៉េចហ្នឹងអាចជឿគេបានដែរទៅ។

«គឺហ្នឹងហើយ តែខ្ញុំមិនមែនជាអ្នកធ្វើនោះទេណា»

«នែ៎! នែ! លោកកុំមកអាងថាខ្មោចទៀតឲ្យសោះណា»

«ខ្ញុំមិនបានអាងនោះទេណា តែវាជាការពិត»

«ខ្ម...ខ្ម...ខ្មោចទៀតហើយឬ»

គេមិនបានសង្ឃឹមឲ្យរាងកាយដែលនទលគកនោះហក់មកឱបគេទៀតនោះឡើយ តែនាងបានហក់មកឱបគេដោយភ្លេចខ្លួន ចំណែកឯសុដន់ដ៏សែនធំក្បៀកក្បោះទ្រលុកទ្រលន់ទាំងពីររបស់នាង បានត្រវីត្រវាត់ទៅតាមកម្លាំងហក់របស់នាងដែរ ដៃទាំងសងខាងរបស់ ឈិត បុរសសង្ហាក៏បានលូកចាប់ព្រួចាប់រាដោយភ្លេចខ្លួនដូចគ្នា ចុះបើគេមិនមែនជាព្រះពុទ្ធឯណាដែលរបស់មកដល់កន្លែងហើយមិនស្រវាត្របាក់នោះណា។

«តែពេលនេះលែងមានខ្មោចហើយណា នាងកុំបារម្ភទៅណា»

សំឡេងគ្រលួចបានខ្សឹបដាក់ត្រចៀករបស់នាង នាងមើលទៅកាន់កែវភ្នែកមួយគូដែលបញ្ចេញមន្តស្នេហ៍ទាក់ទាញនោះ ពេលនេះគេបានប្រថាប់បបូរមាត់មកលើបបូរមាត់នាង តើនាងគួរតែខ្លាចមួយណាដែរទៅ ហេតុអីក៏ជីវិតនៅពេលនេះរបស់ស្រីឬកពារឹងរូសដូចជានាង ហាក់បីដូចជាមានអារម្មណ៍សោប់សល់ម្ល៉េះ!

ឈិតខាមែន ប្រើស្បៀតពិសេសធ្វើឲ្យនាងទទួលតបស្នងការថើបរបស់គេវិញបានយ៉ាងជក់ចិត្ត អណ្ដាតដ៏មានជំនាញរបស់គេលូកចូលទៅយ៉ាងជ្រៅដើម្បីទាក់ទាញអារម្មណ៍តណ្ហាឡើងដល់កំពូល។ គេបានផ្ដេកខ្លួននាងចុះសាជាថ្មី ទោះបីជាគ្រាដំបូងនាងហាក់ដូចជាមានការរាំង តែដល់ដំណាក់កាលចុងក្រោយ នាងក៏ស្លុងចិត្តចំពោះរសជាតិស្នេហ៍របស់គេនោះទាល់តែបាន។ នាងហាក់បីដូចជាមានអារម្មណ៍វិលវល់សាជាថ្មី មិនអាចបែងចែកបានឡើយថា នេះជាសុបិន ឬជាការពិតឡើយ តែអ្វីដែលនាងដឹងច្បាស់នោះគឺនាងពេញចិត្តចំពោះការស្ទាបលូកលាន់បីតជញ្ជក់បែបនេះណាស់ មាត់គេថើប

រាលដាលមកដល់កន្លៀតដើមកយ៉ាងសព្វសាច់ ថើបដោយត្រេកត្រអាលពុះកញ្ជ្រោល ដៃទាំងពីររបស់គេចាប់ច្របាច់ដើមទ្រូងដ៏ធំណែនក្បុំនោះយ៉ាងគ្មានត្រាប្រណី កែវភ្នែកបង្គួសទៅដល់ចុងនៃកំពូលភ្នំទាំងពីរដែលមានពណ៌ស៊ីជម្ពូ ហើយក៏ចាប់ផ្ដើមបឺតជញ្ជក់តាមចិត្តប្រាថ្នារបស់គេតែម្ដង ធ្វើឲ្យអារម្មណ៍របស់នាងពោរពេញទៅដោយសម្រែកតណ្ហាឡើងដល់កំពូល។ រសជាតិស្នេហានោះឡើងដល់ចំណុចកំពូល ទាំងអារម្មណ៍ខ្លាចអារម្មណ៍ចង់អារម្មណ៍ព្រឺព្រួច។ រំពេចនោះ សំឡេងស្រែកដង្ហោយចេញពីចំណង់តណ្ហាក៏លាន់ឮឡើងយ៉ាងខ្សាវៗ ដោយអារម្មណ៍ច្របូកច្របល់ទាំងខ្លាច ទាំងអៀនខ្មាស។ សំឡេងពួកគេទាំងពីរដែលត្រេកត្រអាលនោះ ក៏ពួតគ្នាស្រែកចេញមកយ៉ាងពុះកញ្ជ្រោលឡើង។

«ឈីតខាមែន!!»

សំឡេងស្រែករបស់នាងធ្វើឲ្យគេឈប់ ហើយមើលទៅមុខនាង ដែលកំពុងតែមានអារម្មណ៍ពុះកញ្ជ្រោល យកដៃទាំងពីរទ្រដើមទ្រូងដ៏ធំរបស់គេជាប់ពីក្រោមកាយគេ។

«ម៉េចដែរ?»

«ទេ...ទេខ្ញុំមិនដឹងទេ...»

សំឡេងគ្រលួចរបស់នាងព្យាយាមនិយាយចេញ នាងប្រហែលជាមិនទាន់ត្រៀមខ្លួនរួចជាស្រេចនោះទេ។ ដៃធំរបស់គេក៏ទាញប្រាណនាងមកអែបនឹងប្រាណរបស់គេ ហើយរំពេចនោះសំឡេងគេក៏លាន់ឮឡើង។

«អ៊ីចឹងក៏បានដែរ ខ្ញុំនឹងតាមចិត្តនាង»

តើនាងគួរតែខកចិត្តឬសប្បាយចិត្តឲ្យប្រាកដទៅដែលគេបញ្ឈប់សកម្មភាពរបស់គេទាំងកណ្ដាលផ្លូវបែបនេះនោះ។ រួចនាងក៏គេងស្ងៀមលើដើមទ្រូងរបស់គេដូចដើម ព្រោះនាងខ្លួនឯងទេដែលឡូឡា ហើយ ឈីតខាមែន ក៏ធ្វើតាមចិត្តនាងដែរទៅ នាងគិតយ៉ាងក្ដៅក្រហាយ ហើយក៏គេងបន្តក្នុងរង្វង់ដៃរបស់គេដោយមិនមានសំឡេងអឺមករំខានទៀតនោះឡើយ។





...៣...

**ស្នេហាពិរោធ**

រូបរាងស្តើងរបស់ស្រីស្រស់ដើរតាម ឈីតខាមែន កំលោះសង្ហាទៅកាន់សារមន្ទីរជាតិ ដែលបើកធ្វើការជាបណ្ដោះអាសន្នដើម្បីជួសជុលក្រោយពីមានភ្លៀងធ្លាក់យ៉ាងខ្លាំងធ្វើឲ្យមានការខូចខាតជាច្រើន។ ផ្លូវថ្នល់ដែលនឹងអាចធ្វើដំណើរទៅកាន់សារមន្ទីរនោះត្រូវដាច់ខូចខាតជាខ្លាំង។ យ៉ុនហ៊ី ក្រឡេកភ្នែកមើលទៅកាន់របស់របរព្រមទាំងគ្រឿងប្រដាប់ទាំងឡាយ ដែលដាក់តាំងនៅក្នុងសារមន្ទីរនោះ ជារបស់របររបស់ព្រះនាង ទេមីន សុទ្ធសាធ។

កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះ មើលទៅកាន់របស់របរទាំងឡាយដែលបានរៀបចំតាមផ្នែកៗ ហើយក៏ឈប់ឈរនៅត្រង់ប្រអប់ក្លងពណ៌មាសជាច្រើនដន្លាប់នោះយ៉ាងជក់ចិត្ត ស្រៀបដូចជាធ្លាប់បានប្រើវាពីមុនមកអ៊ីចឹង។

រំពេចនោះសំឡេងគ្រលរបស់គាត់ខាងប្រុស កំលាន់ឮឡើងនៅចំពោះភាពស្ងប់ស្ងាត់នោះ។

«នោះគឺជាគ្រឿងសម្អាងរបស់ព្រះនាង ទេមីន ណា យ៉ុនហ៊ី»

«គ្រឿងសម្អាង ?»

«មនុស្សស្រីសម័យបុរាណ ចេះប្រើប្រាស់គ្រឿងសម្អាងលម្អកាយមានតាំងពីប្រដាប់លាបលើភ្នែក ក្រោមភ្នែក រោមភ្នែក ព្រមទាំងមានក្រែមលាបបបូរមាត់ថែមទៀតផងណា»

«គឺដូចដែលព្រះនាង **លីអូជាត់ថាវ៉** នោះមែនទេ ?»

«ត្រូវហើយព្រះនាង ទេមីន ក៏ដូចគ្នាដែរ ក្រៅពីគោលបំណងក្នុងភាពស្រស់ស្អាតហើយនោះ គឺដើម្បីការពារពន្លឺចាំងចូលភ្នែករបស់ព្រះនាងថែមទៀតផង»

កំលោះសង្ហាឈរពីក្រោយប្រាណនាង ដែលកំពុងតែចាប់អារម្មណ៍លើប្រដាប់ប្រដា និងគ្រឿងសម្អាង ហើយអត់ទ្រាំមិនហិតក្លិនក្រអូបៗនៃគ្រឿងសម្អាងទាំងនោះមិនបានឡើយ រួចអធិប្បាយបន្ត៖

«ក្លងនេះពណ៌កាហ្វេណា នាងសាកយកវាទៅហិតសាកមើលទៅ»

ដៃដ៏ទន់ភ្លន់នោះទទួលយកក្លងនោះមកកាន់ ដូចពាក្យដែលគេប្រាប់មែនសាច់ម្សៅម៉ត់ប្រៀបដូចជាម្សៅដែលមានឃឹហោល្បីក្នុងផ្សារទំនើបអីចឹង។

«ស្អាតណាស់ គួរឲ្យចម្លែកមែនទែន»

«ម្សៅមួយក្លងនោះធ្វើពីថ្មបាយក្រៀមណា»

«មើលមួយក្លងនេះចុះ ពណ៌សចាំងតែម្តង»

«ចំណែកឯពណ៌ខៀវសុទ្ធនោះ ធ្វើមកពីអំបិលមាស»

ឈីតខាមែន អធិប្បាយឲ្យស្រីស្រស់ស្តាប់យ៉ាងជំនាញតែម្តង ប្រអប់ដៃដ៏ធំរឹងមាំរបស់គេ ឱបចង្កេះពីក្រោយនាងយ៉ាងស្អិត តែនាងមិនរារាំងអ្វីឡើយនាងបែរជារវល់តែចាប់អារម្មណ៍លើគ្រឿងសម្អាង ក្នុងប្រអប់ដៃរបស់នាងទៅវិញ។



«ប្រអប់ពណ៌ខៀវនេះ ប្រហែលជាធ្វើមកពីថ្មបាយក្រៀមទៀតហើយមើលទៅនោះ»

«ត្រូវហើយ! ជាថ្ម លីពីសឡាស៊ី នោះណា»

«ឈ្មោះប្លែកណាស់ ខ្ញុំមិនធ្លាប់ឮពីមុនមកទាល់តែសោះ តែអាចដឹងបានខ្លះថា ត្រូវលាបលើគ្របកភ្នែកមុន ហើយប្រើពណ៌ផ្ទៃមេឃលាបត្រង់កណ្តាល រួចលាបពណ៌ខៀវនៅជាន់ក្រោមបំផុត ហើយបបូរមាត់ប្រាកដជាលាបពណ៌ក្រហមហើយមើលទៅនោះ...»

ដៃដ៏ទន់ភ្លន់របស់នាងបានបើកដន្លាប់ពណ៌ក្រហមនោះមើលដោយទឹកមុខរីករាយ ឈីត សម្លឹងមើលកិរិយារបស់ស្រីស្រស់ គេអត់ទ្រាំមិនមានក្តីសុខជាមួយនាងមិនបាន ព្រមទាំងគិតថា របស់របរទាំងអស់នៅក្នុងសារមន្ទីរនេះជារបស់នាងពីអតីតជាតិទេតើស បានជានាងមានអារម្មណ៍ថា ដូចជាមានមនោសញ្ចេតនាជាមួយវាបែបនេះ រំពេចនោះសំឡេងស្រស់ស្រាយបានលាន់ឮឡើង

«នេះនែ!! ដន្លាប់ពណ៌ក្រហមនៅទីនេះទេ»

«ពណ៌ក្រហមនោះធ្វើមកពីដីច្រេះ យកមកចម្រាញ់សម្រាប់លាបមាត់និងថ្ពាល់»

«ខ្ញុំពិតជាចូលចិត្តរបស់អស់នេះណាស់»

«ខ្ញុំសប្បាយចិត្តណាស់ដែលនាងចូលចិត្តវា»

ឈីតខាមែន ឱបរាងកាយរបស់នាងទៅកាន់ទូដែលដាក់តាំងនូវគ្រឿងប្រដាប់គ្រប់ឈុត ហើយបានយករបស់នីមួយៗនោះមកដាក់នៅលើតុធំ នាងស្ទាបអង្អែលគ្រឿងប្រដាប់ទាំងនោះយ៉ាងសប្បាយចិត្ត

«ខ្ញុំសុំជូតសម្អាតគ្រឿងប្រដាប់ទាំងអស់នេះណាបានទេ ?»

«បានតើស ប្រពៃណាស់ បើយើងបានជូតសម្អាតវានោះវាប្រាកដជាស្អាតជាងនេះទៅទៀតណា»

យ៉ុនហ៊ី ដកក្រាសជុសសម្អាតចេញពីប្រអប់គ្រឿងប្រដាប់ដែលនាងត្រៀមយកមកជូតសម្អាតវត្ថុបុរាណ ដោយមានកំលោះសង្ហាអង្គុយនៅជិតនាង

នោះដែរមិនព្រមឃ្លាតឆ្ងាយទៅណាសោះ ចំណែកឯនាងវិញផ្ទុតផងបោសសម្អាតផងដោយសប្បាយចិត្តជាពន់ពេក។ ភ្លាមនោះនាងធុំក្លិនកាហ្វេចូលច្រមុះរបស់នាងភ្លាម។

«សុំការអនុញ្ញាតលោក ឈើតខាមែន នេះគឺជាអាហារសម្រន់ចាស»

ឈើតខាមែន ងក់ក្បាលហើយទទួលយកកាហ្វេនោះពីស្រីបម្រើ ដែលកាហ្វេនោះមិនមានជាតិស្ករនោះទេ។ ស្រីស្រស់ឆ្លាតវៃដូចជានាងបានរកនឹកឃើញនូវអ្វីម្យ៉ាង កែវភ្នែករបស់នាងមើលទៅកាន់កាហ្វេនៅនឹងដៃរបស់ឈើតខាមែន ដោយសញ្ជឹងគិត។

«នេះជារបស់អ្នកនាងចាស ជាទឹកក្រូចប្រចាំស្រស់»

«ចាស អរគុណហើយណា ជូនី»

«នាងត្រូវការកាហ្វេមែនទេ យ៉ុនហ៊ី ?»

ឈើតខាមែន សួរនាំនាងយ៉ាងយកចិត្តទុកដាក់នៅពេលគេឃើញកែវភ្នែករបស់នាងកំពុងតែចាប់អារម្មណ៍លើកាហ្វេដែលនៅនឹងដៃរបស់គេ។

«ចាសត្រូវហើយ តែខ្ញុំត្រូវការវាមុនគេងបានដែរទេ ?»

«នាងចង់ផឹកកាហ្វេមុនចូលគេង ? ហើយចុះម៉េចនឹងអាចគេងលក់បានទៅ»

«គឺព្រោះតែខ្ញុំមិនចង់គេងលក់នោះអី»

ឈើតខាមែន យល់ពីគោលបំណងរបស់ស្រីស្រស់ទើបសើចយ៉ាងក្អាកក្អាយចេញមកដោយមិនអាចទប់បាន នាងមិនព្រមគេងលក់ព្រោះតែខ្លាចអំណាចមន្តគ្រាគ្របសង្កត់នាងឲ្យដោះខោអាវទៀតឬ!

«នែលោក!! លោកសើចស្អីគេហ្នឹងហាស ?»

«គឺសើចពីវិធីក្នុងការការពារខ្លោចរបស់នាងហ្នឹងឯងណា»

«ហើយម៉េចចុះ!!! តើវាខុសត្រង់ណាដែរទៅដែលខ្ញុំចង់ធ្វើដើម្បីការពារខ្លួនមិនបានទេអី»

ហឺស!!! ស្អប់ណាស់!!! គេប្រហែលជាខ្លាចខានបានមើលរបស់ ហ្វ្រឹៗ



នោះទេដឹង គេបានមើលឃើញរបស់ដែលនាងហួងហែងខ្លាំងបំផុតក្នុងជីវិតដល់ទៅពីរដងឯណោះណា ហើយគេថែមទាំងបានចាប់វាយ៉ាងពេញៗដៃទៀត។ ហើយរំពេចនោះផ្ទៃមុខរបស់នាងប្រែជាក្រហម ព្រមទាំងបញ្ចេញសំឡេងម៉ាត់ៗចេញមក។

«ជូនី យប់នេះនាងត្រូវយកកាហ្វេទៅឲ្យខ្ញុំដាក់ឲ្យច្រើនហើយដាក់ឲ្យវាងចាស់បន្តិចទៅណា»

«អូយ!!! ស្លាប់ហើយអ្នកនាង អ្នកនាងមិនគេងទេអី»

«ហើយចុះអ្នកណាប្រាប់ថា ខ្ញុំគេងនោះ!!»

«ចាស! ចាស!!»

យ៉ុនហ៊ី មើលទៅកាន់ស្រីបម្រើដែលដើរចេញពីនាងទៅព្រមទាំងអេះក្បាលដោយងឿងឆ្ងល់ អត់ទ្រាំមិនគិតមិនបានទាល់តែសោះថា ស្រីបម្រើរបស់ឈើតខាមែន មានចៃនៅលើក្បាលច្រើនពេកទេដឹងបានជាអេះរហូតបែបនេះ ព្រោះថា តាំងពីនាងចូលមកក្នុងសេតវិមានធំមួយនេះនាងបានឃើញស្រីបម្រើនោះអេះក្បាលមិនឈប់។ រំពេចនោះសំឡេងគ្រលរក៏និយាយឡើងព្រមទាំងមានស្នាមញញឹមហាក់បីដូចជាញញឹមនឹងឯងផងដែរ។

«កុំញ៉ាំកាហ្វេមុនពេលគេងអីណា វាអាចនាំឲ្យនាងខូចសុខភាពនាង»

«ឈិស!!! យ៉ាងណាក៏ប្រសើរជាងខូចខ្លួនដែរ» យ៉ុនហ៊ី តបតក្នុងចិត្តរបស់នាង។

«ខ្ញុំហ៊ានធានាថា យប់នេះនាងនឹងមិនត្រូវបានអំណាចអាថ៌កំបាំងនោះរំខានទៀតឡើយ»

«កុំមកបោកប្រាស់ខ្ញុំ ដើម្បីចង់ឃើញខ្ញុំសម្រាតខោអាវឲ្យមើលឲ្យសោះ ខ្ញុំមិនជឿលោកនោះទេ ខ្ញុំដឹងទាន់ចរិតលោកហើយណា»

«ខ្ញុំនិយាយមែនទែនណា ព្រោះថា ក្រសែចិត្តក្នុងខ្លួនរបស់នាងនៅពេលនេះកំពុងតែទន់ខ្សោយបាត់ទៅហើយ»

«ក្រសែចិត្តទន់ខ្សោយអីចឹង ? ហើយចុះលោកដឹងបានដោយរបៀប

ណាដែរទេ!»

«ចុះបើបន្ទោងខ្សែករបស់នាងវាលែងនៅជាមួយនាងហើយនោះអី»

ដៃរបស់នាងលើកទៅស្ទាបត្រង់ករបស់នាង មែនហ្នឹងណា! តើខ្សែកខ្ញុំបាត់ទៅណាហើយហ្នឹង វាបាត់ទៅណាហើយ បាត់តាំងពីអង្កាល់ដែរទៅ!

«នោះមានន័យថា ខ្សែកព្រមទាំងបន្ទោងមួយនោះជារបស់ព្រះនាងទេមីន អីចឹងឬ?»

«ត្រូវហើយណា វាជាគ្រឿងប្រដាប់របស់ព្រះនាង ទេមីន ដែលនាងកំពុងតែបោសជូតសម្អាតនេះនោះអី»

«ហើយចុះហេតុអី...?»

ស្រីស្រស់កំពុងតែគិតថា ហេតុអីក៏ខ្សែកមួយខ្សែនោះបានទៅនៅក្នុងដៃមនុស្សស្រីតែលពោលម្នាក់នោះទៅវិញ ឬក៏ស្រីតែលពោលនោះបានលួចខ្សែកនេះពីសារមន្ទីរនេះទៅ ហើយតើនាងនឹងត្រូវបានគេចោទប្រកាន់ពីបទដែលទទួលយករបស់ពីចោរឬអត់ហ្ន!

«ខ្ញុំមិនដឹង មិនឮអីជាមួយនាងស្រីម្នាក់នោះទេណា ខ្ញុំគ្រាន់តែ...»

«នាងកុំនិយាយតែឯង ថាតែម្នាក់ឯងបែបហ្នឹងទៅមើល ខ្ញុំមិនបាននិយាយថាអីនាងឯណា អ្វីដែលកើតឡើងទាំងឡាយសុទ្ធតែជាគោលបំណងរបស់ព្រះនាង ទេមីន ទាំងអស់»

ដៃរឹងមាំរបស់គេទាញប្រាណនាងមកឱបនឹងដើមទ្រូង មានអារម្មណ៍ថានាងក៏អែនខ្លួនផ្អែកថ្ពាល់មកលើរូបគេ ដោយមិនមានប្រកែកអ្វីនោះឡើយ នាងប្រហែលជាស៊ាំហើយមើលទៅនោះ ចំពោះការប៉ះពាល់រាងកាយគ្នាទៅវិញទៅមករវាងនាង និងគេនោះណា។ រូបរាងស្តើងនៅក្នុងប្រអប់ដៃរបស់គេនោះនៅតែសញ្ជឹងគិត ទោះបីវាជាការពិតដូចដែលគេនិយាយក៏ដោយចុះ តែនាងត្រូវតែមិនប្រមាថបាននោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយក៏នាងមិនព្រមគេងនៅពេលយប់នោះដែរ នាងគេងនៅពេលថ្ងៃវាប្រសើរជាង។

ស្រីបម្រើអេះក្បាលសាជាថ្មីម្តងទៀត នៅពេលបានឃើញនាងកំពុងតែ



អង្គុយក្រេបកាហ្វេមុខឡើងជូរនៅលើគ្រែគេង មនុស្សស្រីស្អាតម្នាក់នេះធ្វើឫកប្លែកៗទៀតហើយ ចុងក្រោយនាងអត់ទ្រាំមិនសួរមិនបានសោះឡើយ។

«អ្នកនាង មិនឆ្ងាញ់ហើយអ្នកនាងខំប្រឹងញ៉ាំធ្វើអីដែរទៅ?»

«ខ្ញុំមិនបានញ៉ាំឲ្យវាឆ្ងាញ់ឯណា ជូនី!»

ស្រីបម្រើលើកដៃមកអេះក្បាលទៀតហើយ យ៉ុនហ៊ី ឆ្ងល់មែនទែនតែម្តងថា នាងពិតជាមានថៃដូចដែលគិតពិតមែនក៏អត់។

«ឯងឯងអុយគេងក៏ទៅគេងទៅចុះណា ខ្ញុំនៅអង្គុយបែបនេះហើយ»

យ៉ុនហ៊ី មើលទៅកាន់ស្រីបម្រើដែលកំពុងតែទម្រេតខ្លួនគេងយ៉ាងងាយស្រួលនោះ តែកែវភ្នែករបស់នាងនៅតែពោរពេញទៅដោយភាពសង្ស័យ ចិញ្ចើមនៅតែជ្រួញចូលគ្នាមិនព្រមលោទាល់តែសោះ ស្រីស្រស់ដូចជានាងមិនដឹងថាត្រូវធ្វើការអធិប្បាយយ៉ាងណាដើម្បីឲ្យស្រីបម្រើនោះយល់នោះឡើយ គឺបានត្រឹមតែបែរមកក្រេបកាហ្វេបន្តនោះឯង។

សំឡេងអី? នាងមានអារម្មណ៍ថា ដូចជាចម្លែកៗបានលាន់ឮឡើងនៅក្បែរតុដែលនាងអង្គុយកំពុងធ្វើរបាយការណ៍សារណានោះ នាងមានអារម្មណ៍ព្រឺស្លុងខ្លួង ហើយក៏ឈប់ធ្វើរបាយការណ៍នោះផងដែរ មានអារម្មណ៍ថាប្រព័ន្ធប្រសាទរបស់នាងដូចជាស្រ្តេសខ្លាំងមែនទែនតែម្តង ប្រហែលជាមកពីឥទ្ធិពលកាហ្វេហើយមើលទៅនោះបានជានាងបញ្ឈរភ្នែក ដែលការពិតទៅនាងងងុយគេងសឹងស្លាប់ទៅហើយនោះ តែនេះជាសេចក្តីត្រូវការរបស់នាងទេ!

រហូតដល់ទៀបភ្លឺ នាងឃើញក្រោមភ្នែករបស់ខ្លួនឡើងជាំខ្មៅ ព្យាយាមបំបាត់ដែរ តែហេតុអីក៏សែនវេទនាបែបនេះហ្ន!! រាងស្តើងនោះបានរអ៊ូ។

«អូយ!!! ស្លាប់ហើយអ្នកនាង!!ម៉េចហើយអត់អីទេអ្នកនាង!»

«ជូនី មែនទេ?»

«ចាំស គឺខ្ញុំអ្នកនាង ស្លាប់ហើយមើលភ្នែករបស់អ្នកនាងចុះស្លក់ហើយជាំខ្មៅមើលសឹងតែមិនស្គាល់ណាអ្នកនាង»

«ខ្ញុំមិនស្លាប់នោះទេណា ហើយក៏មិនអីដែរ»

«មិនអីម៉េចកើត! ភ្នែកដូចខ្លាឃ្មុំអីចឹងហើយអ្នកនាង»

«ចុះបើខ្ញុំងងុយគេងនោះណា ខ្ញុំទៅងូតទឹកសិនហើយណា នឹងបានគេង»

«ចាស! ចាស! អីចឹងញ៉ាំអាហារពេលព្រឹកសិនទៅណាអ្នកនាង»

នាងពិតជាងងុយគេងខ្លាំងហើយ ចង់តែគេងឲ្យលក់ដល់ល្ងាចតែម្តង រួចញ៉ាំកាហ្វេទៀតនៅពេលយប់។ ផ្ទៃមុខរបស់នាងញញឹមទាំងប្រឹងៗដែលកាលពីយប់មិញនោះអំណាចមន្តស្រាអាថ៌កំបាំងមិនបានមកគ្របដណ្តប់នាង។

តែរាងកាយដ៏ស្តើងនោះ ក៏ក្រហល់ក្រហាយយ៉ាងទារុណទារុណនៅលើគ្រែគេង។ ការពិតទៅនាងពិតជាងងុយសែនងងុយតែមិនអាចបិទភ្នែកឲ្យលក់បាន។

«ទាមួយក្បាល...ទាពីរក្បាល...ទាបីក្បាល...ទាមួយរយក្បាល...អូយ!!! មិនដឹងជារាប់ដល់ប៉ុន្មានហើយទេ»

ហេតុអីក៏ទារុណទារវេទនាយ៉ាងនេះទេនៀក យ៉ុនហ៊ី ប្តូរការគិតហើយក្រោកអង្គុយម្តង ដើម្បីធ្វើយ៉ាងណាឲ្យមានប្រយោជន៍វិញប្រសើរជាង។ រំពេចនោះនាងក៏លូកទៅទាញកាបូបចេញមក យកប្រដាប់ប្រដាសម្រាប់ជូតសម្អាតទៅជូតរបស់ដែលមាននៅក្នុងសារមន្ទីរវិញ។

ឈីតខាមែន កំពុងតែបើកទ្វារបន្ទប់ កែវភ្នែករបស់គេក៏បានក្រឡេកទៅប៉ះនឹងរាងតូចស្តើងរបស់នាងដែលដើរសំដៅចូលមកដោយគ្មានកម្លាំងកំហែងរង្វង់ភ្នែកស្លក់ជាំខ្មៅមើលឃើញដឹងពីចម្ងាយតែម្តង នេះនាងរឹងទទឹងញ៉ាំកាហ្វេមិនគេងមិនពួនបែបនេះឬ!

«យ៉ុនហ៊ី នាងទៅសារមន្ទីរឬ?»

«ចាស!! ខ្ញុំនឹងចូលទៅធ្វើការនៅក្នុងសារមន្ទីរនោះណា»,

«ហើយចុះនាងទៅរួចដែរ?»

«រួចតើស ខ្ញុំទៅរួចណា...»

សំឡេងដកដង្ហើមរបស់ម្ចាស់សេតវិមានលាន់ឮឡើង តើនាងទៅរួច



បានដោយរបៀបណាដែរទៅ គ្រាន់តែនាងនិយាយស្ទើរតែស្តាប់មិនបានថានាងនិយាយថាម៉េចផងនោះ រំពេចនោះគេក៏ស្ទុះទៅគ្រានាងភ្លាម។

«នាងទៅសម្រាកសិនទៅណា»

«អ្នកណាថា ខ្ញុំចង់សម្រាកនោះ...ខ្ញុំបានគេងរាប់សត្វទាអស់រាប់ពាន់ក្បាលហើយនៅមិនទាន់គេងលក់ផង»

«នេះនាងញ៉ាំកាហ្វេអស់ម៉ាប៉ាន់ធំតែម្តង?»

«អឺសហឹស!!!»

«សរសៃប្រសាទនាង ប្រហែលជារឹងដូចដែកហើយមើលទៅនោះ ប្រហែលជាត្រូវឲ្យជាតិកាហ្វេនោះអស់ឥទ្ធិពលសិនហើយទើបបាន»

«អឺសហឹស!!»

នេះនាងនិយាយមិនដឹងរឿងអ្វីទាំងអស់ កំលោះសង្ហានាំនាងទៅកាន់សារមន្ទីរដូចដែលនាងត្រូវការ ហើយព្យាយាមស្តាប់សំឡេងដែលនិយាយចេញមករបស់នាង។

«ខ្ញុំ...ងងុយគេងមែនទែនតែម្តងហើយ...»

«នាងគេងនៅលើគ្រែនេះសិនទៅណា»

ឈីតខាមែន ត្រកងកាយរបស់នាងទៅគេងនៅលើគ្រែរបស់ព្រះនាងទេមីន នៅក្នុងសារមន្ទីរនោះ ហើយឲ្យសញ្ញាទៅកាន់ស្រីបម្រើរបស់គេ មិនយូរប៉ុន្មានស្រីបម្រើក៏ដើរមកភ្លាម។

«ជូនី ឯងទៅឆុងទឹកក្រូចឆ្មាដែលជូរជ្រះមកឲ្យយើងមួយកែវមកណា»

«ចាស!! លោក»

កែវភ្នែកមួយគូនោះមើលរូបរាងស្តើងដែលគេងនៅលើគ្រែនោះ ទោះបីជាគេមានអារម្មណ៍ថា ទាស់ចិត្តចំពោះនាងក្នុងការដែលនាងរឹងទទឹងញ៉ាំកាហ្វេរហូតដល់ថ្នាក់គេងមិនលក់ក៏ដោយ នេះនាងប្រហែលជាគិតថា នេះជាវិធីក្នុងការរាំងអំណាចមន្តស្រាដែលតាមចងកម្មួចងៀនាងឬ!

«នាងញ៉ាំទឹកក្រូចឆ្មាបន្តិចទៅណា នឹងប្រសើរជាងមុន»

គេលើកកែវគ្រីស្តាល់មួយកែវនោះទៅឲ្យនាងញ៉ាំ ហើយនាងក៏ញ៉ាំដោយមិនតមាត់អីទាំងអស់ ប្រហែលជាវេទនាចំពោះអាការងងុយគេងហើយគេងមិនលក់ហើយមើលទៅនោះ គេគិត។ បុរសសង្ហាសម្លឹងមើលរាងកាយដ៏សែនស៊ិចស៊ីរហូតដល់ថ្នាក់គេស្រមើស្រមៃមើលឃើញដល់ដើមទ្រូងដ៏ធំក្បុំក្បោះទ្រលុកទ្រលន់នោះ ដែលគេក៏ធ្លាប់បានឃើញ និងប៉ះប្រចាំមកដែរនោះណា។

ឈិតខាមែន ដើរត្រួតត្រាក្នុងសារមន្ទីរនោះ ដើម្បីបង្វែរអារម្មណ៍តណ្ហារបស់គេ មួយសន្ទុះក្រោយមកគេក៏ដើរមករកគ្រែដែលនាងគេងសាជាថ្មី ផ្ទៃមុខនោះប្រែជាញញឹមនៅពេលឃើញនាងគេងលង់លក់ ព្រមទាំងទាញភួយមកដណ្តប់លើកាយនាងយ៉ាងថ្នាក់ថ្នម។

និយាយពី យ៉ុនហ៊ី ក្នុងជាតិជាព្រះនាង ទេមីន កំពុងតែសម្រាលកាយចូលទៅក្នុងអាងហែលទឹកពណ៌សខាប់ ព្រមទាំងមានអ្នកបម្រើនៅជុំវិញហើយសំឡេងចេចចាចក៏លាន់ឮឡើងក្នុងបន្ទប់នោះ។

«ព្រះនាងពិតជាស្រស់ស្អាតមែនទែនតែម្តង ព្រះនាង»

«អូ!! នៅត្រង់នោះយើងជាអ្នកសម្អាតជូនព្រះនាងក៏បានដែរណា»

«អូ!! មិនបានទេណាព្រះនាង ព្រះនាងនៅស្ងៀមៗទៅបានហើយណាព្រះនាង»

«ពួកឯងប៉ុណ្ណឹងបានសិនហើយ យើងឡើងគោកហើយណា»

«បន្តិចទៀតសិនទៅណាព្រះនាង»

«បានហើយណា គូដណ្តឹងរបស់យើងកំពុងតែនៅរង់ចាំយើងណា ក្រែងពួកឯងក៏ដឹងដែរតើសមិនអីចឹង ?»

«ក្រាបទូល! ក្រាបទូល! ព្រះនាង»

ព្រះនាង ទេមីន លើកព្រះកាយឡើងព្រមទាំងមានបរិវារពីរនាក់តាមមកពីក្រោយហែហមជាមួយព្រះនាង។ ព្រះនាងពិតជាមានក្លិនក្រអូបណាស់ ដោយសារតែព្រះនាង បានចុះត្រាំក្នុងទឹកដែលមានផ្កាជាច្រើនប្រភេទត្រាំក្នុងនោះ។ ស្រីបម្រើលើកយកកន្សែងមកដណ្តប់លើព្រះកាយរបស់ព្រះនាង ព្រះភក្ត្រ



ស្រស់ស្អាតបង្ហាញនៅក្នុងស្រមោលកញ្ចក់ ដៃទាំងទ្វេរបស់ព្រះនាងលើកទៅស្ទាបអង្អែលសក់ ហើយធ្វើការតុបតែងកាយដោយលាបលើភ្នែក ក្រោមភ្នែក រោមភ្នែក ចិញ្ចើម បបូរមាត់ និងអ្វីគ្រប់យ៉ាងដែលចាំបាច់ មើលទៅស្រស់ស្អាតលើសស្រីដទៃ។

«ពិតជាស្រស់ស្អាតណាស់ ព្រះនាង»

ព្រះភក្ត្រដ៏ស្រស់ស្អាតនោះ ញញឹមទទួលយកនូវការកោតសរសើរពីស្រីកំណាន់របស់ព្រះនាង ហើយក៏យាងទៅកាន់កន្លែងណាត់ជួបនោះគឺព្រះដំណាក់ទទួលភ្ញៀវក្នុងសួនច្បាររាជវាំង។

រូបរាងដ៏ធំក្រអាញនោះ ដើរសំដៅទៅកាន់ព្រះនាងដែលកំពុងតែដើរសំដៅទៅរកគេដូចគ្នាដែរនោះ ពួកគេទាំងពីរញញឹមដាក់គ្នាយ៉ាងផ្អែមល្ហែមតែម្តង មុននឹងគូដណ្តឹងព្រះនាងចូលទៅឱបព្រះនាងដោយអារម្មណ៍ស្នេហា។

«ព្រះនាងរបស់ខ្ញុំពិតជាស្រស់ស្អាតមែនទែន»

គូដណ្តឹងព្រះនាង ប្រថាប់ស្នាមថើបមួយខ្សឹតទៅលើព្រះភក្ត្រព្រះនាងភ្លាម។

«ខ្ញុំនឹកព្រះនាងណាស់»

«ខ្ញុំក៏នឹកព្រះអង្គដូចគ្នាដែរ»

ឈិតខាមែន ព្យាយាមស្តាប់ពាក្យសម្តីដែល យ៉ុនហ៊ី កំពុងនិយាយមមើនៅលើគ្រែនោះ ប្រហែលជាមកពីឥទ្ធិពលរបស់ជាតិកាហ្វេអ៊ីនហើយមើលទៅនោះ ដៃធំរបស់គេលូកទៅស្ទាបមុខរបស់នាងតែត្រូវនាងយកដៃចាប់កាន់ដៃគេទៅវិញ ទើបគេបណ្តោយតាមនាងទៅ ព្រមទាំងស្តាប់នូវការរជើរភេយបន្ទះ

«ខ្ញុំស្រឡាញ់ព្រះអង្គ ខ្ញុំនឹកព្រះអង្គ»

«នេះនាងកំពុងតែយល់សប្តិឬយ៉ាងណាហ្នឹង!»

ឈិតខាមែន ព្យាយាមមើលទៅកាន់កិរិយារបស់ស្រីស្រស់ គេដឹងភ្លាមតែម្តងថា នាងកំពុងតែស្រមៃដល់អតីតជាតិរបស់នាង គេពិតជាចង់ដឹងមែនទែនថា នាងកំពុងតែស្ថិតក្នុងបែបបទបែបណាក្នុងក្តីសុបិននោះ តែអ្វីដែល

សំខាន់នាងយកដៃគេទៅឱបផ្អិបនឹងដើមទ្រូង ពេលនេះនាងយកវាទៅលូកលាន់ប្រដាប់ទូលទ្រូងរបស់នាងយ៉ាងឆ្ងាញ់ដៃបាត់ទៅហើយនោះអី តើគេអាចទ្រាំបានយូរដល់ពេលណាដែរទៅទៀត។ គេព្យាយាមទាញដៃចេញខ្លាំងប៉ុណ្ណា នាងកាន់តែស្រវាដៃរបស់គេទៅឱបជាប់ណែនខ្លាំងជាងមុនទៅទៀត។ កែវភ្នែកមួយគូរបស់គេ សម្លឹងមើលទៅកាន់ផ្ទៃមុខរបស់ស្រីស្រស់ ពេលនេះហាក់បីដូចជាស្រស់ស្រាយជាងមុន ព្រោះនាងគេងលក់តាំងពីព្រឹករហូតដល់ល្ងាចនោះអី នេះនាងចង់គេងបន្តដល់ពេញមួយយប់ទៀតឬហ្នឹង!

រំពេចនោះ ផ្ទៃមុខដ៏ស្រស់សោភានោះក៏ពេញទៅដោយស្នាមញញឹមបបូរមាត់ស្តើងរបស់នាងហើបៗ ហាក់បីដូចជាកំពុងតែរង់ចាំរសជាតិនៃការថើបដ៏តក់ក្រហល់ តើគេទ្រាំបានទៀតដែរទេ! ឈើតខាមែន ក៏ប្រថាប់មាត់ថើបទៅលើបបូរមាត់ដែលហើបៗមករកគេនោះភ្លាម ប្លែកមែនទែនតែម្តង ការពិតទៅនាងកំពុងតែគេងលក់សោះ តែនាងបែរជាតបស្នងរសជាតិស្នេហានៃការថើបរបស់គេបានភ្លាមៗទាន់ចិត្តតែម្តង តើគេម៉េចនឹងមិនបន្តរសជាតិស្នេហ៍នោះជូននាងបានទៅ!

អណ្តាតដ៏មានជំនាញរបស់កំលោះសង្ហា លូកចូលយ៉ាងជ្រៅទៅក្នុងមាត់ដ៏មានរសជាតិផ្អែមរបស់នាង ដែលពេលនេះពោរពេញទៅដោយអារម្មណ៍ពុះកញ្ជ្រោល រូបរាងតូចច្រឡឹងដែលនៅក្រោមកាយរបស់គេនោះចាប់ផ្តើមកម្រើក នាងបានដឹងខ្លួនព្រមជាមួយនឹងអារម្មណ៍មួយដែលប្លែកថ្មី។ តើវាកើតឡើងបានដោយរបៀបណាដែរទៅ ព្រោះថា នាងកំពុងត្រូវបានគូដណ្តឹងនាងថើបទេតើស តែទ្រង់នោះមិនបានញាក់ញីប្រដាប់ដើមទ្រូងនាងឯណា! ហើយរំពេចនោះកាយរបស់នាងក៏សម្រេចចិត្តប្រានអ្វីដែលមានអារម្មណ៍ថា ទើសទាល់នោះចេញភ្លាម។

«យ៉ុនហ៊ី បានដឹងខ្លួនវិញហើយ?»

«ឈើតខាមែន លោកទេ?»

«គឺខ្ញុំហ្នឹងឯង ចុះនាងគិតថា ជាអ្នកណាដែរទៅ?»



ហេតុអ្វីក៏មុខរបស់ ឈើតខាមែន ដូចមុខរបស់គូដណ្តឹងព្រះនាងនៅក្នុងសុបិនម្ល៉េះ! យ៉ុនហ៊ី ព្យាយាមតាំងសតិអារម្មណ៍ ព្រមទាំងគិតថា មកពីនាងគិតច្រើនចំពោះគ្រឿងប្រដាប់របស់ព្រះនាង ទេមិន ពេកទេដឹងបានជាយល់សប្តិរឿងទាំងនោះបែបនេះ។ រំពេចនោះសំឡេងមួយក៏បានលាន់ឮឡើង។

«ទៀតហើយណា! ឈើតខាមែន! ហេតុអ្វីក៏លោកធ្វើបែបនេះទៀតអីចឹង!!»

«ខ្ញុំធ្វើអីគេទៅ?»

«គឺ...គឺលោកមកលូកលាន់ខ្ញុំនៅពេលដែលខ្ញុំគេងលក់នោះអី»

ឈើតខាមែន សើចយ៉ាងក្អាកក្អាយចេញមកដោយទប់សំណើចមិនបាន គឺនាងវិញទេដែលគេងលក់ហើយ នៅមានអារម្មណ៍ឲ្យដៃគេនោះណា គេជាមនុស្សប្រុសពេញលក្ខណៈណា មិនមែនជាស៊ីម៉ង់ត៍ដែលនៅស្ងៀមមិនចេះធ្វើអីទាល់តែសោះនោះទេ ភស្តុតាងនៅឃើញជាក់ស្តែងទៀតនោះណាដែលនាងនៅឱបដៃគេយ៉ាងណែនបេះមិនចេញនោះណា។

«នាងវិញទេដែលជាអ្នកចាប់ផ្តើមនោះ»

«នែ!! លោកនិយាយឲ្យស្រួលបួលណា ខ្ញុំជាអ្នកចាប់ផ្តើមស្អីគេទៅ!»

«ខ្ញុំនេះ? ពេលណាបាននាងលែងដៃខ្ញុំបានដែរទៅ ហាស់!!»

យ៉ុនហ៊ី មើលទៅកាន់ដៃធំដែលនាងកំពុងតែឱបនោះ នេះនាងមិនបានឱបជាមួយនឹងគូដណ្តឹងក្នុងសុបិនទេអី!នាងដកដង្ហើមធំដោយហួសចិត្តចំពោះក្តីសុបិនដែលដូចពិតៗនោះ ព្រមទាំងការថើបរបស់ ឈើតខាមែន ទៀត អូយ!! ខ្ញុំអើយខ្ញុំ!!!

«តែខ្ញុំគេងលក់ ខ្ញុំមិនមានសតិឯណាទៅធ្វើបែបនោះជាមួយលោកមុននោះទេ»

ឈើតខាមែន មិនបានចាប់អារម្មណ៍ការរកឿងរបស់ស្រីស្រស់នោះឡើយ យ៉ាងណាក៏ដោយនាងប្រាកដជាក្លាយជារបស់គេមិនថ្ងៃនេះក៏ថ្ងៃក្រោយដែរ។

«នាងមានអារម្មណ៍គ្រាន់បើជាងមុនដែរទេ?»

មើលចុះប្រញាប់ប្ដូររឿងនិយាយតែម្ដង ហើយសរុបមកតើមានរឿងអ្វីកើតឡើងចំពោះនាងដែរទៅ រឿងដែលនាងបានដុតអារម្មណ៍តណ្ហាគេនោះប្រាកដជាមិនមែននោះទេ ព្រោះថានាងបានស្លៀកខោយ៉ាងក្រាស់ផងដែរ ហើយចំពោះរឿងរសជាតិស្នេហានោះនាងជាអ្នកចាប់ផ្ដើមមុនពិតមែនឬ?

ឈើតខាមែន សម្លឹងមើលទៅកាន់ស្រីស្រស់ដែលកំពុងតែបារម្ភ មិនដឹងជានាងគិតច្រើនធ្វើអីទៀត បើគេបានឃើញរបស់នាងស្ទើរតែទាំងអស់ហើយនោះណា។

«ខ្ញុំគិតថា នាងហាក់បីដូចជាស្រស់ស្រាយជាងមុនខ្លះហើយណា»

«ម៉ោងប៉ុន្មានហើយហ្នឹង!»

«ដល់ម៉ោងញ៉ាំអាហារពេលល្ងាចហើយណា»

«នេះល្ងាចហើយ?»

នាងលើកដៃមើលនាឡិកា វាបានបញ្ជាក់ថា ម៉ោងប្រាំល្ងាចហើយ តើវាម៉េចនឹងអាចទៅរួចដែរទៅ នេះនាងគេងស្ទើរតែពេញមួយថ្ងៃទៅហើយ! រំពេចនោះសំឡេងគ្រលរក៏និយាយលើកទឹកចិត្តនាងភ្លាម។

«នាងឃ្លានដែរទេ?»

ពោះរបស់នាងក្ងរគ្រូកៗភ្លាមតែម្ដង នៅពេលបានឮសំណួរបែបហ្នឹង។ នាងឃ្លានព្រោះមិនបានញ៉ាំអីមកតាំងពីព្រឹកនោះអី ក្នុងសុបិនមានតែងូតទឹកហ្នឹង អូ!! នាងយល់សប្តិថា ងូតទឹកដោះគោផងដែរណា វាពិតដូចមែនទែនតែម្ដងរហូតដល់ថ្នាក់នាងលើកដៃនាងមកហិត

«នៀក!!! ក្លិនក្រអូបនៅជាប់ខ្លួនខ្ញុំនៅឡើយទេ»

«ក្លិនក្រអូបអីដែរទៅ យ៉ុនហ៊ី?»

ឈើតខាមែន ទាញដៃស្រីស្រស់ទៅហិតក្លិនដោយភាពសង្ស័យៗ មិនខ្វល់ថា ម្ចាស់អនុញ្ញាត ឬមិនអនុញ្ញាតឡើយ។

«គឺក្លិនផ្កាមួយប្រភេទនោះអី»

«លោកធុំក្លិនបែបហ្នឹងឬ?»



«ចុះនាងប្រើទឹកអប់អីដែរទៅ? វាស្រដៀងនឹងក្លិនម្ទេះ»

«ឈើតខាមែន ខ្ញុំ...ខ្ញុំមិនបានប្រើក្លិននេះទេណា វាជាក្លិនដែលខ្ញុំបានសុបិនឃើញ តើវាអាចមកជាប់ខ្លួនខ្ញុំបានដោយរបៀបណាទៅ?»

«នាងយល់សប្តិឃើញអី? សាកនិយាយប្រាប់ខ្ញុំបន្តិចទៅមើល»

រំពេចនោះ សុបិនដែលដក់ជាប់ក្នុងអារម្មណ៍របស់នាងក៏ត្រូវនិយាយរៀបចេញមកពីមាត់របស់នាងភ្លាមផងដែរ តែរឿងរ៉ាវពួកគេទាំងពីរប្រទាក់គ្នាទៅវិញទៅមក ហើយការគិតរបស់ពួកគេទាំងពីរក៏មិនសូវជាខុសគ្នាប៉ុន្មានដែរ។

«អំណាចមន្តគ្រាឬ?»

«ព្រះនាង ទេមីន ប្រហែលពិតជាចង់ឲ្យនាងបានដឹងពីអតីតជាតិហើយមើលទៅនោះ»

«អ៊ីចឹងបានជាខ្ញុំមានអារម្មណ៍ថា ខ្ញុំគឺជាព្រះនាង ទេមីន មែនទែន»

«ហើយនាងមានអារម្មណ៍ថា នាងស្រឡាញ់គូដណ្ដឹងនាងដែរទេ?»

សំឡេងគ្រលរនោះនិយាយឡើង រហូតដល់ថ្នាក់នាងមានអារម្មណ៍រង្គោះរង្គើ។ ពិតមែន នាងមានអារម្មណ៍ថា ស្និទ្ធស្នាល និងស្រឡាញ់គូដណ្ដឹងរបស់នាងដែលមានមុខមាត់ដូច ឈើតខាមែន នេះបេះបិទ ប្រៀបដូចមនុស្សតែមួយអ៊ីចឹង។ នេះដល់ពេលដែលនាងត្រូវជឿមែនទែនហើយមើលទៅនោះថា នាងនិង ឈើតខាមែន បានមកចាប់ជាតិថ្មី ហើយបានក្លាយជាគូព្រេងនឹងគ្នាក្នុងជាតិនេះផងដែរ។

«យ៉ាងម៉េចដែរ ខ្ញុំសួរថា នាងបានស្រឡាញ់គូដណ្ដឹងដែលនៅក្នុងសុបិននោះដែរទេ?»

«នៅក្នុងក្ដីសុបិននោះខ្ញុំមានអារម្មណ៍ថា ខ្ញុំបានស្រឡាញ់គូដណ្ដឹងខ្ញុំណាស់ ស្រឡាញ់ខ្លាំងដល់ថ្នាក់មិនធ្លាប់ស្រឡាញ់អ្នកណាដូចទ្រង់ពីមុនមកទាល់តែសោះឡើយ»

ចប់សំឡេងសារភាពស្នេហ៍នោះ ឈើតខាមែន ចាប់ផ្ដើមទាញរូបកាយនាងមកឱបនឹងដើមទ្រូង ហើយចំពោះគេវិញ តើនាងមានអារម្មណ៍យ៉ាងណា

ដែរទៅហ្ន!!!

«ហើយចុះនាងមានអារម្មណ៍យ៉ាងណាដែរចំពោះខ្ញុំ ?»

ស្រីស្រស់ដូចជាមានអារម្មណ៍ទាស់ចិត្តឡើងភ្លាម។ តើអ្នកណាគេមកប្រាប់ពីអារម្មណ៍ពិតនៅពេលកំពុងតែវិលវល់បែបនេះដែរទៅ ទោះបីជាពេលនេះនាងមានអារម្មណ៍ចាប់ចិត្តលើគេក៏ដោយចុះ។

«នាងមានអារម្មណ៍ស្រឡាញ់ខ្ញុំ ដូចស្រឡាញ់គូដណ្ដឹងក្នុងក្ដីសុបិនរបស់នាងដែរទេ ?»

យីស!! សំណួរនេះកាន់តែពិបាកឆ្លើយជាងមុនទៅទៀតណា តើគេសួរដើម្បីឲ្យសេតវិមានរបស់គេប្ដូរពណ៌ឬយ៉ាងណានៀក។ រំពេចនោះផ្ទៃមុខរបស់នាងប្រែជាក្រហមឆ្អាំងជំនួសចម្លើយព្រមទាំងគេចក្រសែភ្នែកមួយគូដែលកំពុងតែមើលមកកាន់នាងនោះផងដែរ។

កំលោះសង្ហាដឹងយ៉ាងច្បាស់ណាស់ថា ភាគីខាងស្រីក៏មានចិត្តលើគេដែរ បន្ទាប់មកគេក៏ឱនទៅថើបថ្ពាល់របស់នាង ដោយមិនមានការអនុញ្ញាតធ្វើឲ្យនាងខ្មាសអៀន។

«ខ្ញុំ...ខ្ញុំហេវហើយណា»

«ខ្ញុំក៏ហេវដូចគ្នាដែរ ព្រោះខ្ញុំនៅកំដរនាងពេញមួយថ្ងៃទៅហើយ មិនទាន់ទាំងបានញ៉ាំអីបន្តិចផង»

ឈឺស!!! គេនិយាយថា អង្គុយកំដរអីចឹងឬ? អង្គុយចាំឆ្មក់ឱកាសទេតើ! នាងគិតក្នុងចិត្ត ព្រោះថា វាច្រើនលើកច្រើនសាហើយនោះអី នៅពេលណាដែលនាងក្រោកដឹងខ្លួនពេលណា ត្រូវបានគេកំពុងតែបញ្ចេញអារម្មណ៍ស្នេហាដាក់នាងរាល់តែដង ទោះបីជាជ្រេញឫកគេយ៉ាងណាក៏ដោយចុះ ក៏នាងព្រមឲ្យគេត្រកងដើរទៅកាន់តុញ៉ាំអាហារតាមសម្រួលផងដែរ។

យ៉ុនហ៊ី លើកគ្រឿងប្រដាប់របស់ព្រះនាង ទេមីន យកមកតាំងហើយមើលរបស់ទាំងនោះដោយមិនធុញទ្រាន់បន្តិចណាឡើយ។

ពីរថ្ងៃមកនេះ មិនមានអំណាចអាថ៌កំបាំងអីមកគ្របដណ្ដប់នាងឡើយ



ធ្វើឲ្យនាងសប្បាយចិត្ត ដែលមិនបានបង្ហាញរាងកាយអាក្រាតមកឲ្យជាចំណីភ្នែកគេ។

«តើត្បូងនេះឬ ដែលគេហៅថា ថេសិយ ចេញម៉ូតជាកងដៃមួយដ៏ស្រស់ស្អាតតែម្ដង»

យ៉ុនហ៊ី រអ៊ូរទាំ ព្រមទាំងលើកយកកងដៃធ្វើពីមាសសុទ្ធ និងមានត្បូងទទឹមនោះមកមើល នាងពាក់លមើលដោយមានអារម្មណ៍សប្បាយចិត្តរកអ្វីប្រៀបពុំបាន។

ឈីតខាមែន បើកទ្វារសារមន្ទីរនោះចូលទៅ តែត្រូវញីភ្នែកម្ដងហើយម្ដងទៀត ព្រោះឃើញរូបព្រះនាង ទេមីន នៅជិតនឹងរូប យ៉ុនហ៊ី គេបានសូត្រមន្តតាមសម្ពីរបស់បិតាគេសាជាថ្មីរហូតដល់រូបព្រះនាង ទេមីន បានរលាយបាត់សូន្យទៅវិញ នៅសល់តែរាងកាយរបស់ស្រីស្រស់ដែលកំពុងផ្ទៀងផ្ទងមើលគ្រឿងប្រដាប់ទាំងឡាយនោះយ៉ាងមានក្ដីសុខ។ គេគិតថា ស្រីស្រស់ជាមនុស្សដែលខ្លាចខ្មោចជាទីបំផុត តែហេតុអីក៏នាងមកអង្គុយក្នុងសារមន្ទីរនេះតែម្នាក់ឯងអីចឹង នាងប្រហែលជាជាប់ចិត្តនឹងរបស់របរបស់នាងកាលពីជាតិមុនហើយមើលទៅនោះ។

«យ៉ុនហ៊ី ហេតុអីក៏នាងមិនព្រមចាំខ្ញុំសិន»

«អ!!! លោកទេ ? ខ្ញុំក្រោកលឿននោះណា ទើបមកទីនេះមុន»

កែវភ្នែករបស់គេសម្លឹងមើលទៅកាន់ដៃរបស់នាងដែលពាក់កងដៃមួយនោះដោយអារម្មណ៍ស្រស់ស្រាយសប្បាយចិត្តជាពន់ពេក មើលទៅពិតជាសក្ដិសមព្រមទាំងស្រស់ស្អាតចំពោះនាងតែម្ដងហើយនៀក។

«កងដៃមួយហ្នឹង ពិតជាសក្ដិសមជាមួយនាងខ្លាំងណាស់ណា នាងមានដឹងដែរទេ ?»

«លោកគិតបែបហ្នឹងឬ ?»

ស្រីស្រស់លើកកដៃមកមើលជាថ្មីម្ដងទៀត នាងហាក់បីដូចជាជាប់ចិត្តជិតអារម្មណ៍ចំពោះគ្រឿងប្រដាប់នេះខ្លាំងមែនទែនតែម្ដង ខុសស្រឡះកាលពី

លើកមុនដែលនាងមិនចាប់អារម្មណ៍វាទាល់តែសោះ។

«នាងចង់យកវាទៅពាក់ក៏បានដែរណា ខ្ញុំអនុញ្ញាត»

«មិន...មិនបានទេ ចុះបើពួកវាសុទ្ធតែជាឥទ្ធិពលនៃក្រសែចិត្ត មិនអីចឹង អី!»

កុំមកបោកឲ្យនាងពាក់វា ហើយឲ្យក្រសែចិត្តនោះមកគ្របដណ្ដប់នាងទៀតឲ្យសោះ គេប្រហែលជាចង់ឃើញនាងដោះខោអាវខ្លាំងណាស់ហើយ មើលទៅនោះ នាងអត់ទ្រាំមិនមើលទៅកាន់កំប្លោះសង្ហានោះដែលកំពុងតែញញឹមលាក់បាំងនាងមិនបាន។

«លោកញញឹមអីដែរទៅ ម៉េចខ្ញុំដឹងទាន់គំនិតលោកមែនដែរទេហ្នឹង!»

«ដល់ពេលនេះទៅហើយនាងនៅអៀនខ្ញុំទៀត?»

មើលគេនិយាយចុះ!! នេះគេគិតថា មុខរបស់នាងក្រាស់មែនទេហ្នឹង ហាស់!! គេទេវិញទេដែលមុខក្រាស់គ្មានកេរ្តិ៍ខ្មាសនោះ ភ្លេចខ្លួនពេលណាគេប្រព្រឹត្តសកម្មភាពមិនល្អមកលើនាងតែរហូតហ្នឹង។

«នេះខ្ញុំមិនមែនជាមនុស្សមុខក្រាស់នោះទេណា ដែលដោះខោអាវឲ្យលោកមើលបានរាល់ដងនោះ»

«ខ្ញុំមិនមែនចង់មានន័យថាបែបហ្នឹងឯណា»

«លោកចង់មានន័យថាយ៉ាងណាក៏ខ្ញុំមិនខ្វល់ដែរ តែខ្ញុំជ្រើសរើសមិនពាក់គ្រឿងប្រដាប់នេះដាច់ខាត»

«មិនពាក់ក៏បានដែរណា! ខ្ញុំគ្រាន់តែចង់ប្រាប់នាងថា នាងមិនអាចបំពានជោគវាសនាបាននោះឡើយ»

ឈើតខាមែន ចង់និយាយឲ្យនាងបានដឹងថា ទាំងនាង និងគេប្រាកដជាត្រូវប្រើជីវិតរួមគ្នាយ៉ាងពិតប្រាកដ ហើយហេតុអីនាងត្រូវគិតច្រើនធ្វើអីដែរទៅ។

«បំពានជោគវាសនា?»

«ក្រែងនាងក៏បានដឹងដែរតើសថា នាងត្រូវតែជាគូរបស់ខ្ញុំនោះ...»



ស្រីស្រស់ស្ដាប់គេនិយាយបន្ត

«នាងមានដឹងដែរទេថា អ្វីដែលខ្ញុំសម្ដែងចេញទៅនោះ វាចេញពីចិត្តពិតរបស់ខ្ញុំណា...» ដៃដ៏រឹងមាំរបស់គេទាញប្រាណរបស់ស្រីស្រស់ទៅឱបជាប់នឹងទ្រូង ដៃម្ខាងរបស់គេទាញចង្ការបស់នាងឡើង ហាក់បីដូចជាចង់បង្ខំឲ្យនាងមើលទៅកាន់កែវភ្នែក ដែលកំពុងតែបញ្ចេញមន្តស្នេហ៍ចំពោះនាងហើយមើលទៅនោះ។ សកម្មភាពនេះចេញពីចិត្តពិតរបស់គេ តែហេតុអីក៏គេមិនគិតខ្លះដែរទៅថា នាងចូលចិត្តឬក៏មិនចូលចិត្តនោះ... តែរាល់ពេលដែលគេបញ្ចេញរសជាតិស្នេហាដល់នាង នាងពេញចិត្តតែរហូតដែរតើស ហើយយយ!!

«ហើយខ្ញុំក៏បានដឹងថា នាងក៏មានចិត្តលើខ្ញុំដូចគ្នាដែរ...»

យ៉ុនហ៊ី ស្ដាប់ ឈើតខាមែន និយាយតែខ្លួនឯង ទោះបីវាជាការពិតដូចដែលគេនិយាយក៏ដោយចុះ តែគេមកនិយាយឲ្យនាងអៀនធ្វើអីដែរទៅទៀត ការនិយាយរបស់គេនោះ ធ្វើឲ្យស្រីស្រស់បានត្រឹមតែក្ដៅចិត្តភ្លាម ហើយណាមួយត្រូវត្រៀមលក្ខណៈទទួលនូវស្នាមថើបរបស់គេ ដែលកំពុងតែនឹងប្រថាប់មកលើមាត់របស់នាងនាពេលនេះផងដែរ។

«ឈើតខាមែន ខ្ញុំ...ខ្ញុំ...»

«ម៉េចដែរទៅ?

មែននោះណា តើនាងនឹងប្រាប់គេយ៉ាងណាដែរទៅ ដែលនៅសុខៗខួរក្បាលរបស់ស្រីស្រស់ឡើងវិលអស់ទៅហើយនោះ គិតអីលែងចេញទាំងអស់នៅពេលប្រមុះព្រមទាំងបបូរមាត់របស់គេ បានមកនៅលើផ្ទៃមុខរបស់នាងនោះអី។

«ខ្ញុំសុំពេល...ខ្ញុំមិនទាន់បានត្រៀមខ្លួនរួចជាស្រេចនោះទេណា...»

«ខ្ញុំយល់ថា វាលឿនពេកសម្រាប់ពួកយើង...តែពេលវេលាមិនមែនជាឧបសគ្គឯណាមិនអីចឹងឬ យ៉ុនហ៊ី!»

ហេតុអីក៏នាងត្រូវជឿលើគេដែរទៅ បើនាងខ្លាចចិត្តខ្លួនឯង ហើយក៏ខ្លាចអីៗ របស់គេនោះទេតើទោះបីជាគូព្រេងរបស់នាងក៏ដោយចុះ។ រំពេចនោះនាង

កំមានអារម្មណ៍ថា បបូរមាត់របស់គេបានមកប៉ះលើបបូរមាត់របស់នាងបាត់ទៅហើយ។ ដំបូងនាងដូចជាចង់បដិសេធចំពោះរសជាតិស្នេហានេះ តែពេលនេះបែរជាតបស្នងតើញយ៉ាងជក់ចិត្តជាខ្លាំង នាងពិតជាមានអារម្មណ៍ពុះកញ្ជ្រោលណាស់ចំពោះរសជាតិស្នេហ៍ដែលគេផ្តល់ឲ្យយ៉ាងយូរនេះ។

ហេតុអីក៏ពេញចិត្តនូវស្នាមថើបរបស់គេនោះមែនទែនតែម្តង? នាងមានក្តីសុខគ្រប់ពេល ដែលគេប្រគល់រសជាតិពាលពាលនោះមកកាន់នាង តែពេលនេះនៅក្នុងសារមន្ទីរទេតើស នាងគិត រូបដៃតូចឆ្មាររបស់នាងក៏ហាមប្រាមគេរហូតដល់បានសម្រេច។

«ឈឹតខាមែន លោកលែងខ្ញុំសិនទៅណា...»

ស្រីស្រស់ដកខ្លួនចេញ ទោះបីជាទាស់ចិត្តរបស់នាងក៏ដោយចុះ។ សំឡេងញ័រទទ្រើកនោះលាន់ឮចេញពីមាត់របស់ស្រីស្រស់។

«ខ្ញុំគិតថា វាមិនសក្តិសមនោះទេណា»

«ក្តីស្រឡាញ់ ភាពពេញចិត្ត មិនមែនស្ថិតនៅលើភាពសក្តិសម ឬមិនសក្តិសមនោះទេណា យ៉ុនហ៊ី!»

តណ្ហាក្រាស់ណាស់ហ្ន! អ៊ីចឹងបានជានាងលន្លង់លន្លោចរាល់ដងជាមួយគេនោះណា។ នាងមើលទៅកែវភ្នែកមួយគូដែលបញ្ចេញមន្តស្នេហ៍នោះ គេនៅមិនទាន់បញ្ឈប់អារម្មណ៍តណ្ហារបស់គេនៅឡើយទេ។

«ខ្ញុំ...ខ្ញុំហេវណាស់ ខ្ញុំចង់ចេញទៅរកអីញ៉ាំបន្តិច»

រាងស្តើងរបស់នាងដើរចេញទៅមិនខ្វល់អ្វីឡើយ។ បិះព្រមឲ្យខ្លួនគេបាត់ទៅហើយនៀក អ៊ីចឹងបានគេបង្ខំនាងឲ្យពាក់កងដៃសង្កត់វិញ្ញាណនាងនោះ! លើកហ្នឹងបើសិនជានាងព្រមពាក់ពិតជាអស់ខ្លួនដោយសារគេជាក់ជាមិនខានឡើយ។

ផ្ទៃមុខមុតមាំនោះអត់ទ្រាំមិនញញឹមចេញមកមិនបាន កែវភ្នែកមោះមុតរបស់គេ សម្លឹងទៅកាន់ស្រីស្រស់ដែលទើបតែដើរចេញទៅអំបាញ់មិញនោះ ព្រោះនាងស្អាតស៊ិចស៊ីនោះអី គ្រប់កន្លែងនៃរាងកាយរបស់នាងមិនត្រឹមតែ



ដើមទ្រូងប៉ុណ្ណោះទេ តើឲ្យគេទ្រាំខាំមាត់សង្កត់ចិត្តបានដោយរបៀបណាទៅពេលដែលនៅក្បែរនាងម្តងៗនោះ។

ខ្យល់បក់ជាយផាត់ទៅតាមកម្លាំងខ្យល់នាពេលរាត្រីយប់ងងឹត សំឡេងផ្គររន្ទះលាន់ឮទ្រហឹងអឺងកង ធ្វើឲ្យបរិយាកាសកាន់តែគួរឲ្យខ្លាចជាងមុនទៅទៀត សំឡេងសត្វចាបដែលអាស្រ័យនៅលើដើមឈើយំយ៉ាងទ្រហឹងហើយនាំគ្នាហើរទទះស្លាបចេញទៅ ប្រៀបដូចជាគេចអ្វីម្យ៉ាងដែលគួរឲ្យខ្លាចអីចឹង។

រូបរាងស្តើង ដែលគេងយ៉ាងលង់លក់នៅលើគ្រែបម្រាស់ខ្លួនចុះឡើងៗ ញើសហូររហាមនៅលើផ្ទៃមុខដ៏ស្រស់សោភានោះ។ ពេលនេះនាងកំពុងតែស្ថិតក្នុងរូបភាពអតីតជាតិ។

យ៉ុនហ៊ី ក្នុងរាងកាយជាព្រះនាង ទេមីន គុបតែងខ្លួនដោយគ្រឿងប្រដាប់ព្រមទាំងគ្រឿងសម្អាងទាំងឡាយ។ មានដៃដ៏មាំរបស់មនុស្សម្នាក់ឱបពីខាងក្រោយ គ្មាននរណាក្រៅពីគូដណ្តឹងរបស់ព្រះនាងបានឡើយ ហើយព្រះនាងក៏បែរទៅឱបទ្រង់ដូចគ្នាពោរពេញទៅដោយក្តីស្រឡាញ់។

«មើលចុះព្រះនាងម្ចាស់របស់ខ្ញុំស្រស់ស្អាតលុបព្រះច័ន្ទបាត់ទៅហើយហ្ន!!»

«ព្រះអង្គមកនេះដោយគោលបំណងតែមួយនេះទេឬ?»

«អ្នកណាថាទៅ! ខ្ញុំមកនេះដោយសារតែបេះដូងមិនអាចទ្រាំដោយគ្មានព្រះនាងនៅក្បែរខ្ញុំនោះទេតើ»

«នៅសល់ពេលមិនយូរប៉ុន្មាននោះទេណា នឹងដល់ថ្ងៃរៀបអភិសេករបស់យើងទាំងពីរហើយណាព្រះនាង»

ច្រមុះស្រួចមានខ្ពង់របស់ព្រះអង្គ បានឱនទៅថើបថ្ពាល់របស់ព្រះនាង

«ខ្ញុំត្រូវទ្រាំមួយដង្ហើមសិនទៅចុះ ទម្រាំតែដល់ថ្ងៃរៀបអភិសេករបស់យើងទាំងពីរ»

រំពេចនោះសំឡេងរួសរាយស្រស់ស្រាយបានចេញពីមាត់តូចស្តើងរបស់ព្រះនាង ទេមីន រួចបែរមកនិយាយដោយក្តីស្រឡាញ់

«បន្ទាប់ពីនោះមកខ្ញុំនឹងរស់នៅជាមួយទ្រង់រហូតដល់ថ្ងៃស្លាប់»

«ខ្ញុំក៏នឹងរស់នៅជាមួយព្រះនាងរហូតដល់ថ្ងៃស្លាប់ដូចគ្នាដែរ»

កែវភ្នែករបស់ពួកគេ សម្លឹងមើលទៅកាន់ព្រះច័ន្ទដោយមានក្ដីសុខជាពន់ពេក។ ពេលនេះព្រះនាងនៅក្នុងរង្វង់ដៃគូដណ្ដឹងរបស់ព្រះនាង ហើយស្ដាប់សំឡេងរបស់ទ្រង់។

«មុនថ្ងៃរៀបអភិសេក ខ្ញុំចង់ធ្វើរបស់អ្វីម៉្យាងសម្រាប់ប្រគល់ជូនព្រះនាងក្នុងថ្ងៃសំខាន់នោះ»

«ព្រះអង្គចង់មានន័យថាម៉េចទៅ ?»

«ការដែលខ្ញុំមកទីនេះក្នុងថ្ងៃនេះគឺមកជម្រាបដល់ព្រះនាងថា ថ្ងៃស្អែកនេះខ្ញុំនឹងចេញដំណើរពីព្រលឹមទៅកាន់ភ្នំកូនបីនោះណាព្រះនាង»

ផ្ទៃមុខដ៏ស្រស់ស្អាតរបស់ព្រះនាង មើលទៅកាន់ផ្ទៃមុខដ៏ស្រស់សង្ហារបស់គូដណ្ដឹងព្រមទាំងបញ្ចេញសំឡេងមិនយល់ស្របចេញមក។

«ព្រះអង្គមិនចាំបាច់ទៅទេណា ខ្ញុំមិនត្រូវការអ្វីក្រៅពីរូបព្រះអង្គទេ !»

«ព្រះនាង!! ខ្ញុំតាំងចិត្តទុកជាស្រេចទៅហើយថា ខ្ញុំនឹងធ្វើអ្វីមួយដើម្បីសម្ដែងពីក្ដីស្រឡាញ់ពេញចិត្តព្រះនាងតាមរយៈរបស់ទាំងឡាយនោះ»

«តែខ្ញុំដឹងច្បាស់ណាស់ថា ព្រះអង្គស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់ព្រះអង្គខ្លាំងដូចគ្នាដែរ»

«ដោយសារតែហេតុនេះហើយ បានជាខ្ញុំចង់ធ្វើអ្វីទាំងឡាយនេះដើម្បីព្រះនាងនោះណា»

«ខ្ញុំមិនយល់នោះទេ»

«នេះជាប្រពៃណី ខ្ញុំត្រូវប្រគល់របស់ដែលបញ្ជាក់ពីក្ដីស្រឡាញ់របស់ខ្ញុំជូនដល់ព្រះនាងនៅថ្ងៃរៀបអភិសេក»

«តែយើងបានត្រៀមគ្រឿងមាសប្រាក់កែវកងអស់ហើយតើសព្រះអង្គ»

ព្រះនាង អាចដឹងបានខ្លះចំពោះពិធីដែលខាងប្រុសត្រូវប្រគល់ឲ្យខាងស្រី តែសម្រាប់របស់មានតម្លៃផ្សេងៗ មិនសំខាន់ជាងក្ដីស្រឡាញ់ដែលគូដណ្ដឹ



ងព្រះនាងប្រគល់ជូនព្រះនាងឡើយ។

«ខ្ញុំអាចយល់បានចំពោះក្ដីស្រឡាញ់ដែលព្រះអង្គមានចំពោះខ្ញុំ ហើយខ្ញុំមិនត្រូវការអ្វីពីព្រះអង្គទៀតឡើយ»

«ព្រះនាងនឹងយល់ច្បាស់នៅថ្ងៃរៀបអភិសេក»

«តែខ្ញុំមិនចង់ឲ្យព្រះអង្គចាកចេញឆ្ងាយពីខ្ញុំឡើយណាព្រះអង្គ»

មាឌធំនោះទាញប្រាណរបស់ព្រះនាង ទេមិន ទៅឱបយ៉ាងណែនដើម្បីលួងចិត្ត ហើយគិតថា អ្វីដែលទ្រង់តាំងចិត្តនឹងធ្វើដើម្បីសម្ដែងនូវភាពស្មោះត្រង់ព្រមទាំងក្ដីស្រឡាញ់យ៉ាងធំធេងដល់ព្រះនាងដែលព្រះអង្គស្រឡាញ់ស្មើជីវិតនោះ ទោះយ៉ាងណាត្រូវធ្វើឲ្យបាន។

«ម្ចាស់បេះដូងរបស់ខ្ញុំនឹងនៅក្បែរខ្លួនខ្ញុំជារៀងរហូត»

«ខ្ញុំប្រហែលជាមិនអាចឃាត់ឃាំងព្រះអង្គបានទេមែនទេ»

«ហើយខ្ញុំ នឹងប្រញាប់ត្រឡប់មកវិញព្រមជាមួយនឹងរបស់សំខាន់មកប្រគល់ឲ្យព្រះនាង»

កែវភ្នែកមុះមុតនោះ សម្លឹងមើលទៅកាន់ព្រះចន្ទដែលកំពុងតែបញ្ចេញរស្មីយ៉ាងស្រស់ត្រកាល ដោយមិនដឹងទាល់តែសោះថា កែវភ្នែកមួយគូដ៏ស្រទន់កំពុងតែបញ្ចេញភាពបារម្ភ ហើយឱនមុខទៅនឹងដើមទ្រូងទ្រង់នោះ។

កែវភ្នែកដ៏លន្លង់លន្លោចនោះទន្ទឹងរង់ចាំផ្លូវគូដណ្ដឹងថា ពេលណាទើបព្រះអង្គត្រឡប់មកវិញ ព្រះនាងមានអារម្មណ៍ទុក្ខសោកជាខ្លាំងដោយបារម្ភលើគូដណ្ដឹងព្រះនាងខ្លាំងពេក។

សំឡេងតន្ត្រីមួយវង់ដ៏សែនពីរោះ ដែលព្រះនាងតែងតែកោតសរសើរពេលនេះលែងពីរោះហើយ បែរជាកាន់តែធ្វើឲ្យព្រះនាងបារម្ភលើរូបគូដណ្ដឹងព្រះនាងខ្លាំងឡើងតែម្ដង។

«ព្រះនាង ព្រះនាង នេះយប់ហើយណា ព្រះនាង!»

«យ៉ាងម៉េចដែរ ពួកឯងចង់ឲ្យយើងផ្ទំឬ ?»

«ក្រាបទូល! ក្រាបទូលព្រះនាង!!»

«យើងនៅរង់ចាំគូដណ្ដឹងរបស់យើង ព្រះអង្គអាចមកវិញនៅពេលនេះក៏ជាបានដែរ»

«ពុទ្ធោព្រះនាង!! ទោះបីជាយ៉ាងណាក៏ដោយក៏ទ្រង់នឹងយាងមកវិញជាក់ជាមិនខានឡើយក្រាបទូល»

«តែស្អែកនេះនឹងមានកម្មវិធីរៀបអភិសេកហើយណា...»

«ក្រាបទូលព្រះនាង ស្អែកនេះព្រះនាងនឹងបានជួបព្រះភក្ត្ររបស់ទ្រង់ហើយក្រាបទូល!»

ពាក្យសម្ដីទន់ភ្លន់លួងចិត្តរបស់ស្រីកំណាន់នោះធ្វើឲ្យព្រះនាងព្រមដើរទៅកាន់ព្រះដំណាក់ តែក្នុងចិត្តនៅតែព្រួយបារម្ភចំពោះគូដណ្ដឹងរបស់ព្រះនាងដដែល។

ព្រះនាង ទេមីន កំពុងតែឲ្យស្រីកំណាន់របស់ព្រះនាងតុបតែងកាយជូន ដោយប្រើឈុតពណ៌ក្រហមដាំ មានក្ដាប់ដោយខ្សែពណ៌មាសយ៉ាងស្រស់ត្រកាលតែម្ដង។ ព្រះនាងតុបតែងបែបនេះព្រោះតែជាពិធីអភិសេករបស់ព្រះនាងជាពិសេសតែម្ដង តែភ្នែកគិតតែពីក្រឡេកមើលទៅកាន់គូដណ្ដឹងដោយមិនខ្វល់ពីផ្កាជាច្រើនពណ៌ដែលគេរៀបចំសម្រាប់ព្រះនាងនោះឡើយ។

ផ្ទៃមុខព្រះនាងញញឹម នៅពេលក្រឡេកទៅឃើញគូដណ្ដឹងរបស់ទ្រង់កាន់ប្រអប់មាសដើរសំដៅមក ដោយសកម្មភាពខុសប្រក្រតី តែដោយសារភាពសប្បាយចិត្តនោះបានធ្វើឲ្យព្រះនាងភ្លេច។

«ព្រះអង្គ! ខ្ញុំនឹកព្រះអង្គខ្លាំងណាស់ ហេតុអីក៏ព្រះអង្គត្រឡប់មកវិញយឺតម្ល៉េះ!!!»

«តែខ្ញុំក៏បានមកវិញហើយ ព្រមជាមួយនឹងរបស់ដែលសំខាន់បំផុតសម្រាប់យកមកជូនព្រះនាងម្ចាស់ជាទីស្រឡាញ់របស់ខ្ញុំទៀត»

សំឡេងនិយាយចេញមកនោះ ពិតជាខំប្រឹងនិយាយណាស់។ ដៃដែលស្លេកស្លាំងរបស់ទ្រង់លូកទៅបើកប្រអប់មាសពន្លេចចេញពណ៌ចាំងព្រាកៗពីរបស់ដែលមាននៅក្នុងប្រអប់មួយនោះ។



«អូ!!! គ្រឿងប្រដាប់នោះពិតជាស្រស់ស្អាតមែនទែនណាព្រះអង្គ»

«គ្រឿងប្រដាប់ទាំងនេះគឺជាក្ដីស្រឡាញ់ទាំងអស់របស់ខ្ញុំ ខ្ញុំនឹងពាក់ជូនព្រះនាង»

ទ្រង់ពាក់គ្រឿងប្រដាប់ទាំងឡាយនោះ នៅលើខ្លួនរបស់ព្រះនាង ទេមីនរហូតគ្រប់ឈុត ហើយកម្មវិធីរៀបអភិសេកក៏បានចប់សព្វគ្រប់ផងដែរ។

ព្រះនាង មិនបានដឹងទាល់តែសោះថា ព្រះស្វាមីទ្រង់ខំប្រឹងតស៊ូយ៉ាងលំបាកវេទនាបំផុតដើម្បីឲ្យកម្មវិធីរៀបអភិសេកនោះបានចប់សព្វគ្រប់ទេ។ ការពិតព្រះអង្គបានឆ្លងជំងឺមួយយ៉ាងកាចសាហាវ។ ទ្រង់ និងព្រះនាងដើរទៅកាន់សួនច្បារមានផ្កាជាច្រើនប្រភេទឆ្លងទៅកាន់ព្រះដំណាក់ផ្ទាល់ខ្លួនរបស់ព្រះអង្គ ពេលនោះរាងកាយរបស់ព្រះស្វាមីព្រះនាងក៏បានដួលត្រាំងនៅចំពោះមុខព្រះនាងតែម្ដង។

«ព្រះអង្គ!!! តើមានអីកើតឡើងចំពោះព្រះស្វាមីរបស់ខ្ញុំ!!»

«ព្រះនាង!! ព្រះនាងជាទីស្រឡាញ់របស់ខ្ញុំ!!!»

ព្រះនាង ទេមីន ស្លុតចិត្តចំពោះហេតុការណ៍ដែលនឹកស្មានមិនដល់នេះ ព្រមទាំងឱបព្រះស្វាមីជាប់នឹងដើមទ្រូង ហើយក៏មិនភ្លេចហៅមនុស្សម្នាឲ្យចូលមកជួយព្រះនាងម្ចាស់ផងដែរ។

«គ្រូពេទ្យ!!!គ្រូពេទ្យ!!! អ្នកណាក៏បានដែរជួយយើងផងទៅ!!!»

រំពេចនោះពួកអ្នកបម្រើព្រមទាំងគ្រូពេទ្យនាំគ្នារត់ស្រចូលមក តែភ្នែកមួយគូដ៏ស្រទន់របស់ព្រះនាងកំពុងតែហូរទឹកភ្នែក ព្រះឱស្ឋសួរទៅកាន់គ្រូពេទ្យថាតើមានរឿងអីកើតឡើងចំពោះព្រះស្វាមី។

«លោកគ្រូពេទ្យ!! លោកគ្រូពេទ្យ!!! ព្រះស្វាមីរបស់យើង!! ព្រះស្វាមីរបស់យើង!!!»

«ព្រះនាង!! ព្រះនាងចូរត្រៀមព្រះទ័យទៅក្រាបទូល»

«គ្រូពេទ្យដឹងថាព្រះស្វាមីរបស់យើង...»

គ្រូពេទ្យដើរមកចាប់ជីពចររបស់ព្រះស្វាមីព្រះនាង ព្រមទាំងដើរថយមក

យ៉ាងឆ្ងាយព្រោះហួសពីសមត្ថភាពរបស់គ្រូពេទ្យ។ សំណួរចេញពីព្រះឱស្ឋព្រះនាងក៏ឮឡើង។

«យើងចង់ដឹងច្បាស់ពីព្រះស្វាមីរបស់យើង...»

«គឺបែបនេះណាព្រះនាង...» អ្នកដែលនិយាយឡើងនោះគឺស្រីបម្រើជំនិតរបស់ព្រះនាង ទេមីន។ តើស្អីគេដែរទៅគ្រូពេទ្យ នាង និងអ្នកទាំងអស់គ្នាដឹងគ្រប់គ្នាថា ព្រះស្វាមីរបស់យើងកើតអីនោះ!

**«តើមានអីកើតឡើងចំពោះព្រះស្វាមីរបស់យើង!!!»**

«ព្រះស្វាមីរបស់ព្រះនាង ឆ្លងជំងឺដ៏សាហាវបំផុតរហូតជ្រៀតចូលក្នុងសរសៃឈាម គ្រូពេទ្យបានធ្វើការថែរក្សាតាំងពីម្សិលមិញតាំងពីព្រះអង្គយាងមកដល់ម្ល៉េះព្រះនាងម្ចាស់»

«ហើយហេតុអីក៏មិនមានអ្នកណាប្រាប់យើងសោះអីចឹង!»

«ព្រះស្វាមីរបស់ព្រះនាងហាមមិនឲ្យអ្នកណាប្រាប់ព្រះនាងឡើយក្រាបទូល!»

«ហេតុអី!! ហេតុអីទៅ!!»

ព្រះនាងឱនទៅឱបកាយព្រះស្វាមី ដែលកំពុងតែដកដង្ហើមដាច់ៗនោះ ព្រមទាំងព្យាយាមឱនស្តាប់ពាក្យសម្តី របស់ព្រះស្វាមីនិយាយចេញមកទាំងវេទនា។

«ព្រះនាងម្ចាស់ជាទីស្រឡាញ់របស់ខ្ញុំ!! ខ្ញុំនឹងស្រឡាញ់ព្រះនាងម្ចាស់ជារៀងរហូត...!!»

«ទេ!! ព្រះអង្គត្រូវតែមិនកើតអីណាព្រះអង្គ!! គ្រូពេទ្យជួយលឿនឡើងទៅ!!!»

«យ៉ាប់ហើយព្រះនាង ដល់ពេលដែលខ្ញុំត្រូវចាកចោលព្រះនាងហើយព្រះនាង!!!»

«ទេ!!ទេ!!ព្រះអង្គចាកចោលខ្ញុំមិនបាននោះទេ!!ព្រះអង្គត្រូវតែនៅជាមួយខ្ញុំម្ចាស់ណាព្រះអង្គ»



«ត្រូវហើយ!! ក្តីស្រឡាញ់របស់ខ្ញុំនឹងនៅជាមួយព្រះនាងជារៀងរហូត»

ដៃទាំងពីរគ្មានកម្លាំងកំហែង លើកទៅចាប់ត្រង់បន្តោងខ្សែកនៅលើករបស់ព្រះនាង ទឹកមុខបញ្ចេញស្នាមញញឹមជាលើកចុងក្រោយមុននឹងផុតដង្ហើមចោលព្រះនាងទៅ។

សំឡេងស្រែកយំយ៉ាងខ្លាំងរបស់ព្រះនាង ទេមីន ដែលបានបាត់បង់មនុស្សជាទីស្រឡាញ់នោះជារូបភាពដ៏គួរឲ្យអាណោចអាធ័មណាស់។ ព្រះនាងនៅទន្ទឹងរង់ចាំព្រះស្វាមីពេញមួយយប់មិនឲ្យអ្នកណាប៉ះពាល់សោះឡើយ។

ក្រោយពីបាត់បង់មនុស្សជាទីស្រឡាញ់ទៅ ព្រះនាងគិតតែពីលាក់ខ្លួននៅក្នុងបន្ទប់មិននិយាយស្តីជាមួយអ្នកណា គិតតែពីមើលរៀងផ្ទួងគ្រឿងប្រដាប់គ្រប់ប្រភេទដែលព្រះស្វាមីរបស់ព្រះនាងបន្សល់ទុកឲ្យជាចំណាំដៃ ព្រះនាងគិតតែពីអង្វរអធិដ្ឋានលើគ្រឿងប្រដាប់ទាំងឡាយនោះថា ព្រះនាងនឹងតាមទៅមើលថែព្រះស្វាមីរបស់ព្រះនាងគ្រប់ៗជាតិ ហើយព្រះនាងក៏បានឆ្លាក់ជាពួអក្សរនៅលើស្បែកសត្វមួយប្រភេទមុននឹងព្រះនាងត្រាំចិត្តស្លាប់នៅទីបំផុត។

នៅលើគ្រែគេងទន់ល្មើយនោះ យ៉ុនហ៊ី កំពុងគេងយល់សប្តិទាក់ទងទៅនឹងអតីតជាតិរបស់នាង។ នាងបានយំសោកខ្សឹកខ្សួលអួលណែនជាពន់ពេករហូតដល់ថ្នាក់ស្រីបម្រើព្យាយាមផ្ទៀងត្រចៀកស្តាប់ ថាមានអីកើតឡើងចំពោះស្រីស្អាតដែលគេងនៅលើគ្រែនេះ។ នាងមើលទៅជុំវិញនោះដូចជាមិនមានអីខុសប្រក្រតីទេ ទើបនាងសម្រេចចិត្តដាស់ យ៉ុនហ៊ី។

«អ្នកនាង យ៉ុនហ៊ី!! អ្នកនាង យ៉ុនហ៊ី!!»

«ព្រះស្វាមីរបស់យើង!!! ព្រះស្វាមីរបស់យើង!!! ហឺៗ ព្រះស្វាមី!»

«អ្នកនាង!! អ្នកនាង!! អ្នកនាងយ៉ាងម៉េចទៅហើយ!»

«ព្រះស្វាមីរបស់យើង!! គឺព្រះស្វាមីរបស់យើងហឺៗៗៗ»

«អ្នកនាងមានស្វាមី! យីស!! ប្លែកមែនទែនទៀត»

ស្រីបម្រើអង្គុយពិចារណានូវពាក្យដែល យ៉ុនហ៊ី យំព្រមទាំងត្អូញត្អែរ ទឹកភ្នែកហូរស្ទើរតែមួយធុងធំ នាងអាចមិនស្រួលខ្លួនក៏ថាបានដែរ ទើបស្រីបម្រើ

នោះប្រញាប់លើកដៃស្ទាបក្បាល មិនមានក្តៅខ្លួនទេ ទើបនាងព្យាយាមដាស់យ៉ុនហ៊ី ជាថ្មីម្តងទៀត។

«**អ្នកនាង! អ្នកនាង!**»

«ហាស់...មានការអីមែនទេ ជូនី!!»

«អ្នកនាង យំធ្វើអីដែរទៅ!»

«គឺព្រះស្វាមីរបស់ខ្ញុំនោះណា...»

«ព្រះស្វាមីនៅឯណាដែរទៅចាស...!!»

យ៉ុនហ៊ី មើលទៅកាន់ស្រីបម្រើនោះ ព្រមទាំងតាំងសតិស្មារតីសាជាថ្មី ហើយដឹងភ្លាមតែម្តងថា នាងបានសុបិនឃើញអតីតជាតិរបស់នាង។ ដៃតូចស្រទន់របស់នាងលើកមកជូតទឹកភ្នែកចេញពីថ្ពាល់ ហេតុអីក៏នាងមានអារម្មណ៍សោកសៅដល់កម្រិតនេះដែរទៅហ្ន!

«ខ្ញុំយល់សប្តិអាក្រក់ហ្នឹងណា ឯងទៅគេងទៅ!!»

«យល់សប្តិអាក្រក់ទេ អីចឹងបានជាយំឮៗតែម្តង»

បើសិនជាស្រីបម្រើដូចជានាងសុបិនថា មានប្តីមិនដឹងជាល្អយ៉ាងណានោះទេ។ នាងមានអារម្មណ៍ថា អ្នកនាងមានអ្វីចម្លែកខុសពីមនុស្សស្រីដទៃ ហើយពេលនោះសំឡេងដែលចង់ដឹងពីការពិតក៏បានលាន់ឮឡើង។

«អ្នកនាងប្រាកដចិត្តហើយមែនទេថា អ្នកនាងសុបិនអាក្រក់នោះ!»

«ត្រូវហើយ! យើងសុបិនអាក្រក់!!»

យ៉ុនហ៊ី ងក់ក្បាលទទួល ហើយក៏ទម្រេតខ្លួនគេងដាក់ក្បាលនៅលើខ្នើយដែលជោគជាំទៅដោយទឹកភ្នែកនោះ។ កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះមិនអាចបិទភ្នែកឲ្យគេងលក់បាន ទោះបីវាជាការយល់សប្តិក៏ដោយចុះ តែអារម្មណ៍ភិតភ័យប្រហោងពោះនោះនៅតែមានក្នុងអារម្មណ៍របស់នាងនៅឡើយ។

នាងដើរទៅកាន់បន្ទប់គេងរបស់ ឈើតខាមែន យ៉ាងប្រញាប់ប្រញាល់ ហើយគោះទ្វាររង់ចាំការអនុញ្ញាតម្តងទៅពីរដង តែមិនមាន សំឡេងឆ្លើយតបទាល់តែសោះ។ នាងមានអារម្មណ៍ក្រោតក្រាត នាងចង់និយាយរៀបរាប់ពីក្តីសុបិនដែលនាងបានយល់សប្តិកាលពីយប់មិញនោះដល់គេ គឺមានតែគេម្នាក់ប៉ុណ្ណោះដែលនិយាយគ្នាដឹងរឿងចំពោះរឿងអាថ៌កំបាំងនេះ។ ដែលពោរពេញទៅដោយភាពអាថ៌កំបាំងនេះ។ នៅពេលនាងទ្រាំលែងបាន នាងក៏ធ្វើមធំបើកទ្វារចូលទៅ។



«ឈើតខាមែន! លោកទៅណាហើយ»

នាងក្រឡេកមើលទៅជុំវិញនោះ តែមិនឃើញសូម្បីស្រមោលរបស់គេ ហើយពេលនោះគំនិតរបស់នាងក៏នឹកឃើញអ្វីមួយឡើង។

«ឬក៏គេបាត់បង់ជីវិតព្រមគ្នាជាមួយនឹងព្រះស្វាមីរបស់ព្រះនាង ទេមិនហើយទេដឹង ព្រោះថា ចរិតឬកពា រូបសម្បត្តិដូចគ្នាបេះដាក់ដែរនោះណា»

សំឡេងរអ៊ូវបានលាន់ឮឡើងព្រមទាំងបែរភ្នែករកមើល ឈើត សាជាថ្មី ហើយគិតលួងចិត្តខ្លួនឯងថា ទេ! ប្រាកដជាមិនដូចអ្វីដែលគិតនោះឡើយ ព្រោះថា គេមិនមែនជាព្រះស្វាមីនាងឯណា។

«ឬក៏គេនៅក្នុងបន្ទប់ទឹក!»

នាងប្រញាប់រត់ចូលទៅក្នុងបន្ទប់ទឹកដោយមិនគិតអ្វីទាំងអស់ ហើយធ្វើមធំហ៊ានបើកទ្វារចូលទៅភ្លាម ធ្វើឲ្យស្រីស្រស់ស្ទើរតែខ្ទាតចេញមកក្រៅវិញ ព្រោះថា បានឃើញរូបអាក្រាតកាយរបស់គេនៅក្រោមទឹកផ្កាឈូកនោះ ដោយគេមិនភ្ញាក់កន្ត្រាក់ខ្លួនអីបន្តិចសោះឡើយ

«**អាយ!!!! អាសអាភាស!!!**»

«យីស!! យ៉ុនហ៊ី មានការអីដែរបានជាមកទាំងព្រលឹមបែបនេះនោះ!»

ឈើតខាមែន សម្លឹងមើលទៅកាន់ស្រីស្រស់ដែលប្រញាប់បែរខ្នងហើយយកដៃខ្ទប់ភ្នែកខ្លួនឯងនោះ គេងូតទឹកជុសសាប៊ូបណ្តើរនិយាយជាមួយនាងបណ្តើរ

«យ៉ុនហ៊ី! នាងបែរក្រោយអីចឹង និយាយគ្នាដឹងរឿងដែរអីហ្នឹង!!»

«ឆ្កួតមែន ហើយចុះហេតុអីក៏ចាំបាច់ស្រាតខោអាវធ្វើអីទៅ»

«យីស! ចុះខ្ញុំកំពុងតែងូតទឹកណា នាងចង់ឲ្យខ្ញុំពាក់ខោអាវងូតទឹកឬ!»

«អីចឹងលោកងូតឲ្យហើយចុះណា ខ្ញុំចេញទៅចាំនៅខាងក្រៅហើយ»

ផ្ទៃមុខរបស់បុរសសង្ហាញញឹមញញែមស្រស់ស្រាយ គេគ្រាន់តែលេងជាមួយនាងតែបន្តិចសោះ ណាមួយនាងបានចូលមកដល់កន្លែងគេទេ។

«ហាស់ ? ហាស់ ? ថាម៉េច ខ្ញុំស្តាប់មិនយល់ទេ ខ្ញុំមិនឮទេ នាងនិយាយសាថ្មីទៅមើល!!»

«ខ្ញុំប្រាប់ថា ខ្ញុំចេញទៅចាំនៅខាងក្រៅ!»

«ហាស់! ថាម៉េច!! នាងនិយាយអីគេ សំឡេងទឹកហូរឮពេក អត់ឮទេ»

មានអារម្មណ៍ក្តៅចិត្តមែនទែនតែម្តង នាងនិយាយឮៗដែរ តែហេតុអីក៏គេស្តាប់មិនឮដែរទៅ ត្រចៀកធ្ងន់ ឬយ៉ាងណាហ្នឹង ម៉េចក៏មិនទៅឆៀលអាចម៍ត្រចៀកចេញខ្លះទៅ។ ហើយពេលនោះនាងក៏បែរទៅរករាងកាយនោះដើម្បីនិយាយពីគោលបំណងរបស់នាងឲ្យគេឮច្បាស់ តែកែវភ្នែកនាងបានបែរទៅឃើញអ្វីដែលនៅពីខាងក្រោមរបស់កំលោះសង្ហាពេញៗភ្នែកតែម្តង។

**«អាយយយយ!! ម៉េចក៏មិនបិទ កើតភេតចិត្តចង់បង្ហាញគេឬ!!!»**

មិនបាច់និយាយឲ្យគេដឹងនោះទេ ឲ្យគេដោះខោអាវនៅក្នុងបន្ទប់ទឹកនេះ ហេតុតាមចិត្តគេចុះ។ រួចនាងក៏រត់ចេញមក ហើយដើរទៅកាន់សាលមន្ទីរនោះដោយអារម្មណ៍គ្រោតគ្រាត។

ផ្ទៃមុខខាងប្រុសអត់ទ្រាំមិនសើចមិនបានដែលគេបានធ្វើបាបស្រីស្រស់ម្នាក់នេះ ចុះបើនាងបើកទ្វារចូលមកដោយខ្លួនឯងសោះហ្នឹងណានៅមកនិយាយថា គេរោគចិត្តទៀត។ នាងប្រហែលជាមានរឿងអីហើយបានជាចូលមកដល់ក្នុងបន្ទប់គេបែបនេះនោះ ឈើតខាមែន ចាត់ចុះផ្លាស់ខ្លួនរបស់គេរួចរាល់ក៏ប្រញាប់តាមនាងទៅកាន់សាលមន្ទីរនោះភ្លាមដែរ។

យ៉ុនហ៊ី ឈរមើលទៅខាងក្រៅបង្អួច ព្រមទាំងនឹកដល់រឿងរ៉ាវដ៏សែនសោកសៅរបស់នាងដែលមាននៅក្នុងសុបិន រហូតដល់ភ្លេចខ្លួននិយាយអ៊ីៗចេញមក។

«គួរឲ្យអាណិតមែនទែន ព្រះនាងទេមីន!»

«អាណិតអ្នកណាគេដែរទៅ យ៉ុនហ៊ី!»



ដៃដ៏ព្រមទាំងរឹងមាំនោះ ឱបក្រសោបរាងដ៏តូចស្តើងរបស់នាងពីខាងក្រោយ យ៉ុនហ៊ី មានអារម្មណ៍ថា ការឱប និងទង្វើទាំងឡាយដែលគេធ្វើចំពោះនាងហាក់បីដូចជាទង្វើរបស់ព្រះស្វាមីរបស់ព្រះនាង ទេមីន នៅក្នុងសុបិនរបស់នាងតែម្តង ហើយទង្វើទាំងនេះឯងដែលធ្វើឲ្យនាងមានក្តីសុខរកនិយាយមិនត្រូវ នាងងើយមកមើលមុខបុរសសង្ហារួចនិយាយខ្សឹបៗថា៖

«កាលពីយប់មិញខ្ញុំយល់សប្តិទៀតហើយណា ឈើតខាមែន!!»

«នាងសាកនិយាយរៀបរាប់ឲ្យខ្ញុំស្តាប់បន្តិចមកថា វាយ៉ាងម៉េចខ្លះ ?»

«វាដូចការពិតគ្រប់យ៉ាងអីចឹង ដូចខ្ញុំកំពុងតែស្ថិតក្នុងហេតុការណ៍ពិតនោះដែរ»

«នាងក្នុងរូបកាយជាព្រះនាង ទេមីន មែនដែរទេ ?»

«ត្រូវហើយ!! ព្រះនាង ទេមីន និងព្រះស្វាមីព្រះនាងគួរឲ្យអាណិតណាស់»

ឈើតខាមែន អង្គុយស្តាប់ស្រីស្រស់រៀបរាប់ហេតុការណ៍ក្នុងក្តីសុបិនរបស់នាង វាហាក់ដូចជាទើបតែកើតឡើងថ្មីៗចំពោះនាង។ ចប់សំឡេងនិយាយទាំងអួលដើមករបស់នាង គេក៏ស្រវាឱបនាងព្រមទាំងនិយាយសម្លឹងលួងលោមចិត្ត។

«វាបានកន្លងផុតទៅហើយណា យ៉ុនហ៊ី»

«តែខ្ញុំហាក់បីដូចជាមានអារម្មណ៍អាណិតព្រះនាង ទេមីន និងព្រះស្វាមីព្រះនាងមែនទែន»

«ហើយជាតិនេះគឺនាង និងខ្ញុំនោះអី»

«ហើយចុះខ្ញុំត្រូវធ្វើយ៉ាងណាដែរទៅ ឈើត!»

«គ្រប់បញ្ហាមានផ្លូវដោះស្រាយ នាងជឿខ្ញុំចុះណា»

កែវភ្នែកមុះមុតរបស់គេ ដៃធំរបស់គេលើកចង្កានាងឡើងទៀតហើយ បានកំពុងតែបញ្ចេញមន្តស្នេហា យ៉ុនហ៊ី ប្រញាប់បង្វិលខ្លួនចេញពីរង្វង់ដៃរបស់គេភ្លាម ភ្លេចខ្លួនមិនបានទាល់តែសោះនៀក នាងគិត ហើយពេលនោះនាងក៏

ដើរទៅកាន់គ្រឿងប្រដាប់របស់ព្រះនាង ទេមីន។

«ខ្ញុំសុំធ្វើការសម្អាតលើគ្រឿងប្រដាប់របស់ព្រះនាង ទេមីន បន្តិចណា»

«បានតើស! ឲ្យខ្ញុំជួយនាងណា»

«ចាស មិនបាច់ក៏បានដែរ!»

«ហេតុអីដែរទៅ នាងមិនត្រូវការអ្នកជួយទេអី!»

«ចុះបើខ្ញុំខ្លាចលោកមិនធ្វើតួនាទីជាអ្នកជួយសម្អាតនោះអី»

តែនាងខ្លាចដៃដ៏រឹងរវាមរបស់គេឯណោះវិញទេ តិចឱបរឹត តិចក៏ចាប់ចង្កានាងឡើង ខ្លាចតែនាងភ្លេចខ្លួនប្រគល់ប្រាណឲ្យគេទាល់តែបាននោះអីដេញគេទៅឲ្យផុតពីនាងជាការប្រសើរបំផុត។

«នេះជាឈុតរៀបការរបស់ព្រះនាង ទេមីន ទេតើស»

ដៃដ៏តូចប្រឡឹងរបស់នាងក្រកងឈុតដែលមានពណ៌ក្រហមដាំ ព្រមទាំងមានឌិនពណ៌មាសដែលមើលទៅស្រស់ស្អាតណាស់ ហើយក៏លើកប្រដាប់ផុតនោះមកសម្អាតវាដោយអារម្មណ៍ស្រស់ស្រាយជាពន់ពេក។

«យ៉ុនហ៊ី តោះយើងទៅញ៉ាំអីទៅណា ខ្ញុំហេវហើយ»

«ចាស! ខ្ញុំនឹងទៅឥឡូវនេះហើយចាស»

រាងកាយដ៏ធំមាំនោះ ក៏មកត្រកងកាយនាងដើរតម្រង់ទៅកាន់តុអាហារដោយមិនបានសង្កេតថា មានស្រមោលមួយដើរតាម យ៉ុនហ៊ី មកជាមួយដែរទេ។

**យ៉ុនហ៊ី មានអារម្មណ៍ថា ហាក់បីដូចជាស្និទ្ធស្នាលជាមួយកំលោះសង្ហាម្នាក់នេះទ្វេដង ដូចជាពួកគេទាំងពីរជាគូព្រេងឆ្នាមករាប់ឆ្នាំមកហើយ តែងតែយកចិត្តយកថ្លើមគ្នាទៅវិញទៅមកយ៉ាងមានក្ដីសុខ ពួកគេទាំងពីរនាក់បាននាំគ្នាដើរត្រសងទៅកាន់សួនច្បារដែលមានផ្កាជាច្រើនប្រភេទ។**

«នាងដឹងដែរទេ ពីមុននៅទីនេះពិតជាស្ងប់ស្ងាត់ណាស់ រកនិយាយមិនត្រូវទេ»



គេនិយាយធ្វើមើលតែទីនេះ អឹកធឹកណាស់អីចឹង នាងសម្លឹងមើលទៅកាន់ជុំវិញ ព្រមទាំងគិតថា ទីនេះប្រហែលជាអឹកធឹកទៅដោយខ្មោច ឬក៏ជាអ្វីដែលនាងមិនអាចមើលឃើញហើយមើលទៅនោះ។

«ចុះក្រៅៗទីនេះមានភ្ញៀវមកទស្សនាសារមន្ទីរដែរមែនអីចឹងឬ?»

«ប្រហែលជាមិនអាចបានចូលគ្រប់គ្នា ឬក៏គ្រប់ឡានទេសចរណ៍នោះទេណា»

«ហេតុអីដែរទៅ!»

«គឺត្រូវមើលទៅលើភាពចាំបាច់ ឬមិនចាំបាច់ទៀត ដូចជាបើសិនជាមកដើម្បីសិក្សាពីសារមន្ទីរនឹងមានបញ្ជូនតំណាងមកសិក្សាជំនួស ជាពិសេសមិនអាចអនុញ្ញាតឲ្យថតរូប ឬថតវីឌីអូចេញទៅក្រៅជាសាធារណៈបានឡើយ»

«អីចឹងបានជារបស់របរគ្រប់យ៉ាងដែលមានតាំងនៅក្នុងសារមន្ទីរនេះវាបរិបូរណ៍ព្រមទាំងមិនមានខូចខាតអីបន្តិចសោះឡើយ»

«បើសិនជាអ្វីគ្រប់យ៉ាងបានពេញលេញហើយនោះ ខ្ញុំនឹងបើកសម្ភោធសារមន្ទីរនេះជាផ្លូវការតែម្ដងណា»

«បើកធ្វើអីដែរទៅ!»

«ចុះបើសារមន្ទីរនេះជារបស់នាងនោះអី ហើយក៏ត្រូវតែបន្តក្រកូលទៅដល់កូនៗរបស់យើងផងដែរណា»

យីស!! និយាយតែឯងថាតែឯងទៀតហើយនៀក នាងទៅប្រាប់គេតាំងពីពេលណាដែរទៅថា នាងនឹងធ្វើជាភរិយារបស់គេនោះ ហើយគេនៅគិតទៅដល់កូនចៅទៀត នាងបះបោមឲ្យឆ្អិតតែម្ដងនៅពេលនឹកឃើញដល់រឿងមុនមានកូននោះណា។

«នាងយល់ដូចខ្ញុំដែរទេ យ៉ុនហ៊ី?»

«យល់អីដែរទៅ?»

ចុះបើនាងគិតច្រើនណាស់នោះអី ជាពិសេសរឿងធ្វើឲ្យមានកូន នាងមិនស្របជាដាច់ខាត ចំណែកឯរឿងធ្វើជាភរិយាគេនោះទៀត នាងក៏មិនទាន់

បានយល់ព្រមនៅឡើយដែរ។

«ខ្ញុំសួរថា នាងយល់ព្រមដែរទេដែលខ្ញុំនឹងរៀបចំកម្មវិធីសម្ភោធជាផ្លូវការចំពោះសារមន្ទីរមួយនេះ»

«អំ!! រឿងនោះទេតើស បើកក៏បានដែរណា ទុកឲ្យកូនៗបានមើល»

«ហើយតើយើងនឹងមានកូនប៉ុន្មាននាក់ដែរទៅ?»

មើលចុះ! សំណួររបស់គេពិតជាជ្រៅៗមែនតែម្តង ហេតុអីក៏គេជាមនុស្សប្រុសដែលនិយាយហើយ ធ្វើឲ្យមនុស្សស្រីដូចជាខ្ញុំភ្លើតភ្លើនទៅជាមួយគេដែរទៅហ្ន៎!!! ហេតុអីក៏ស្រីរឹងមាំដូចជានាងបែរជាបណ្តោយឲ្យមនុស្សដូចជាគេនិយាយផ្តំត្រចៀកបានដល់ថ្នាក់នេះដែរទៅ។

«ខ្ញុំមិនមែនជាត្រីនោះទេណា ដែលចង់បានកូនភ្លាមៗនោះ»

«ព្រោះខ្ញុំដឹងថា នាងមិនមែនជាត្រីនោះណា បានជាខ្ញុំដាក់ផែនការមុននោះ»

នាងប្រហែលជាត្រូវគេផ្តាន់ហើយ យើញគេជំបូងនៅឯសេតវិមានរបស់ឈើត ស្មានតែជាមនុស្សរម្យទម តែមានឯណាព្រាននារីសោះ។ កែវភ្នែកគេតែងតែបញ្ចេញមន្តស្នេហ៍ជារឿយៗនៅពេលគេនៅជាមួយនាង ស្រីស្រស់ត្រូវចាញ់ក្រោយមួយជំហានទៀតនៅពេលដឹងថាទាល់ច្រកគេទៀតហើយនោះណា។

«ខ្ញុំទៅធ្វើរបាយការណ៍បន្តជាការប្រសើរជាងណា»

«បើអីចឹងខ្ញុំទុករឿងហ្នឹងជាកិច្ចការផ្ទះទៅចុះណា ថានាងពិតជាចង់បានកូនប៉ុន្មាននាក់»

កំលោះសង្ហា មើលតាមពីក្រោយស្រីស្រស់ដែលដើរចេញទៅយ៉ាងប្រញាប់ប្រញាល់ គេមិនបាននិយាយអីខុសឯណា ព្រោះថាទោះជាយ៉ាងណាក៏នាងនៅតែក្លាយជាគូគ្រងរបស់គេនៅថ្ងៃណាមួយមិនខាន។

**ក្រាកក!! ក្រាកក!!**

សំឡេងសត្វស្លាបយំនៅក្រោយសេតវិមាននាពេលយប់ងងឹតឈានមក



ដល់សាជាថ្មី មេឃឈើបក់បោកយ៉ាងខ្លាំង ទោះបីជានៅក្នុងបន្ទប់តែងមានម៉ាស៊ីនត្រជាក់ក៏ដោយចុះ តែនៅលើផ្ទៃមុខរបស់ស្រីស្រស់នាពេលនេះពោរពេញទៅដោយគ្រាប់ញើសធំៗ។

រាងស្តើងរបស់នាងប្រែចុះប្រែឡើង អារម្មណ៍រសាប់រសល់គេងមិនស្រណុក នាងឈានជើងចុះពីលើគ្រែដោយមិនមានស្មារតី ជើងស្រលូនរបស់នាងដើរនៅលើកម្រាលព្រំពណ៌ក្រហម សំឡេងទ្វារបើកចេញព្រមជាមួយនឹងកែវភ្នែកជំមុះមុតរបស់ ឈើតខាមែន គេមើលទៅកាន់មាត់ទ្វារ ដឹងភ្លាមតែម្តងថាអំណាចមន្តក្រាមការគេទៀតហើយ។

ហើយក៏ដូចនូវអ្វីដែលគេនិយាយនោះពិតមែន នៅពេលដែលគេបានឃើញរាងកាយ និងដំណើររបស់ស្រីស្រស់ចូលមក គេត្រៀមខ្លួនរួចជាស្រេចទៅហើយ។ នៅពេលគេឃើញស្រីស្រស់ដោះខោអាវ គេត្រូវតែជួយនាងឲ្យរួចផុតពីអំណាចមន្តក្រាដ៏សាហាវនេះឲ្យបាន រំពេចនោះសំឡេងមុតមាំក៏បានបន្លឺឡើង។

«ព្រះនាង ទេមីន សូមព្រះនាងមេត្តាទៅចុះព្រះនាង ដោះលែងនារីម្នាក់នេះឲ្យមានសេរីភាពទៅណាព្រះនាង»

ឈើតខាមែន មើលទៅកាន់កែវភ្នែកពណ៌ខៀវដែលសម្លឹងមកកាន់គេនោះព្រមទាំងបញ្ចេញក្រសែចិត្តមកកាន់គេដូចគ្នា នោះគឺបញ្ជាក់ពីអារម្មណ៍របស់ព្រះនាងដែលពិបាកក្នុងការសម្រេចចិត្តណាស់។

**«រាងកាយ ចិត្ត វិញ្ញាណរបស់នាងទាំងឡាយរួមចូលគ្នាតែមួយជាមួយនឹងយើង»**

«ទោះបីជានាងជាព្រះនាងកាលពីជាតិមុនក៏ដោយចុះ តែក្នុងជាតិនេះនាងមិនមែនជាព្រះនាងទៀតនោះឡើយ»

**«រាងកាយ ចិត្ត វិញ្ញាណរបស់នាងជារបស់យើង ហើយព្រះអង្គក៏ជាព្រះស្វាមីរបស់យើងដែរ»**

រាងកាយអាក្រាតទាំងលើទាំងក្រោមនោះដើរសំដៅមកកាន់គេ ដោយ

គ្មានអ្វីមកហាមប្រាមបានឡើយ តែភ្នែករបស់គេកំពុងតែសម្លឹងរកមើលថាតើចំណុចណាដែលអាចឲ្យក្រសែចិត្តនៃអំណាចអាថ៌កំបាំងរបស់ព្រះនាងទេមីនគ្របដណ្តប់លើរូបនាងបាន តែគេក៏មិនអាចរកឃើញនូវអ្វីដែលគេគិតនោះឡើយ រំពេចនោះសំឡេងមុតមាំរបស់គេក៏លាន់ឮឡើងភ្លាមផងដែរ។

«ព្រះនាង ទេមីន សូមមេត្តាស្តាប់ខ្ញុំម្ចាស់សិនចុះណាព្រះនាង ទោះបីជាខ្ញុំម្ចាស់ជាព្រះស្វាមីរបស់ព្រះនាងកាលពីជាតិមុន តែក្នុងពេលនេះយើងនៅភពពីរផ្សេងគ្នា ហើយព្រះនាង និងខ្ញុំម្ចាស់ក៏បានមកចាប់ជាតិថ្មីរៀងៗខ្លួនដូចគ្នាទៅហើយ ហើយក៏បានគូសវាសយើងទាំងពីរជាគូនឹងគ្នាក្នុងជាតិនេះទៀត ចូរព្រះនាងរលាយសាបសូន្យទៅតាមកាលវេលាទៅចុះណាព្រះនាង»

«រាងកាយ ចិត្ត វិញ្ញាណរបស់នាងជាមួយនឹងយើងត្រូវតែរួមគ្នា យើងរង់ចាំវេលានេះ រង់ចាំពេលវេលាដែលយើងនឹងចូលផ្សំដំណេកជាមួយព្រះស្វាមីរបស់យើងក្នុងនាមជាព្រះនាង ទេមីន មិនមែនក្នុងនាមជានាងម្នាក់នេះទេណា»

នៅពេលមិនបានតាមការអង្វរនោះ ឈើតខាមែន បានបិទភ្នែកព្រមទាំងសូត្រមន្តគាថាតាមដែលបិតាគេបន្សល់ទុកឲ្យគេនោះភ្លាម។ គេមានអារម្មណ៍ថា រាងស្តើងរបស់នាងបានចូលមកលូកលាន់បពោសអង្អែលរាងកាយរបស់គេយ៉ាងតក់ក្រហល់ មាលរាលតែម្តង តែគេក៏ពិបាកចិត្តមែនទែនដែលមន្តគាថារបស់គេនោះមិនបានផលដូចសព្វដង។ គេមានអារម្មណ៍ថាដូចជាដកដង្ហើមមិនចេញ ប្រហែលជាមកពីអំណាចមន្តគ្រាដែលកំពុងតែមកគ្របដណ្តប់នេះហើយមើលទៅនោះ ទោះជាយ៉ាងណាក៏គេនឹងមិនព្រមរួមភេទជាមួយមនុស្សស្រីដោយសារតែអំណាចមន្តគ្រាគ្របដណ្តប់នេះជាដាច់ខាត ព្រោះថាគេត្រូវការយ៉ុនហ៊ី មិនមែនជាព្រះនាង ទេមីន នោះឡើយ។

«កុំបង្ខំលើរូបកាយខ្ញុំអី ជាតិនេះខ្ញុំម្ចាស់មិនអាចស្រឡាញ់ព្រះនាង ទេមីនក្នុងជាតិមុនបាននោះឡើយ ក្រសែចិត្តរបស់ព្រះនាងចូររលាយទៅវិញចុះ»

ឈើតខាមែន តាំងចិត្តនិយាយយ៉ាងម៉ឺងម៉ាត់ ព្រមទាំងសូត្រមន្តគាថា



បណ្តើរ និយាយរៀបរាប់ប្រាប់ពីអារម្មណ៍ពិតបណ្តើរ។

«កុំបង្ខំខ្ញុំម្ចាស់អីព្រះនាង ខ្ញុំម្ចាស់មិនអាចនៅស្រឡាញ់ព្រះនាង ទេមីនកាលពីជាតិមុននោះបានឡើយ ក្រសែចិត្តរបស់ព្រះនាងចូររលាយទៅវិញទៅ»

រាងតូចច្រឡឹងរបស់នាងដូចជារាងទន់ខ្សោយទៅវិញជាលំដាប់ៗ គេចាប់ផ្តើមបើកភ្នែកយឺតៗ តែក៏ត្រូវស្លុតចិត្ត ស្លាប់ហើយ!! គែវភ្នែកដែលតែងតែមានពណ៌ខៀវនៅពេលព្រះនាងទេមីនចូលរូបនាងម្តងៗ ស្រាប់តែប្រែទៅជាពណ៌ក្រហមដូចភ្លើងឆេះ ទើបគេកាន់តែស្ទុះរាជារឿយៗមិនខ្វល់ពីក្រសែចិត្តរបស់ព្រះនាង ទេមីន នោះសោះឡើយ។

«ព្រះស្វាមីរបស់ខ្ញុំម្ចាស់ ព្រះអង្គមិនស្រឡាញ់ខ្ញុំម្ចាស់ទេ ព្រះអង្គមិនធ្វើតាមសន្យា ព្រះអង្គមិនព្រមធ្វើតាមសន្យា!!!»

ពេលចប់សំឡេងនិយាយដោយសារតែក្រសែចិត្តនោះ រាងកាយនននលគករបស់នាងបានខ្សោយទៅៗហើយដួល គេក៏ប្រញាប់ចូលទៅត្រកងបីនាងហើយលើកយកឈុតគេងរបស់នាងមកពាក់ឲ្យវិញ មុននឹងដាក់នាងឲ្យគេងនៅលើគ្រែរបស់គេ។ ក្រសែភ្នែករបស់គេមើលទៅឃើញផ្ទៃមុខដ៏សែនស្លេកស្លាំងរបស់នាងព្រមទាំងឃើញមានស្នាមពណ៌ក្រហម ដែលសរសេរនៅលើខ្នងដៃរបស់នាង រំពេចនោះគេដឹងតែម្តងថា ដោយសារតែស្លាកស្នាមមួយនេះហើយដែលអាចឲ្យអំណាចរបស់ព្រះនាង ទេមីន មកគ្រប់គ្រងលើរាងកាយនាងបាន។

សំឡេងខ្យល់បក់អាកាសធាតុរងាមានព្រិលធ្លាក់នៅលើទឹកដីនៃសមុទ្រខ្សាច់ អ្នកណាអាចដឹងបានទៅថា អាកាសធាតុប្រែប្រួលបែបនេះនោះ វាប្រហែលជាមានព័ត៌មានល្បីទូទាំងពិភពលោកហើយមើលទៅនោះ ដែលមានព្រិលធ្លាក់ក្នុងតំបន់សមុទ្រខ្សាច់បែបនេះនោះ ហើយតើអាចមានប៉ុន្មាននាក់ដែរទៅដែលជឿថា វាធ្លាក់ដោយសារតែអំណាចមន្តគ្រាដ៏អាថ៌កំបាំងមួយនេះនោះ។

នាងមានអារម្មណ៍ថា រងាញាក់ ឈើតខាមែន លូកដៃទៅបញ្ជាប្រដាប់បញ្ជាម៉ាស៊ីនត្រជាក់នោះឲ្យថយចុះ ហើយឱបកាយនាងកាន់តែខ្លាំងតាមដែល

អាចធ្វើទៅបានដើម្បីបង្កើនភាពកក់ក្ដៅ។ យ៉ុនហ៊ី មានអារម្មណ៍កក់ក្ដៅជាងមុន ព្រមទាំងកម្រើកកាយខិតចូលជិតដើមទ្រូងរបស់គេកាន់តែខ្លាំងជាងមុនទៅទៀត។ នាងក៏បានគិតថា តើវាមកពីប្រភពណាដែរទៅ ទើបដៃទន់ភ្លន់របស់នាងបានរាវប៉ះគ្រប់កន្លែងដើម្បីពិនិត្យ ហើយងើបមុខឡើងមើលផ្ទៃមុខមុតមាំនោះ មុននឹងតាំងសតិអារម្មណ៍បាន។ ពេលនេះតើនាងយល់សប្ដិ ឬក៏ជាការពិត? នាងជាព្រះនាង ទេមិន ឬជា យ៉ុនហ៊ី ហើយបុរសកំពុងតែតេងឱបនាងនោះគឺជា ឈើតខាមែន ឬជាព្រះស្វាមីរបស់ព្រះនាង? គ្រាន់តែគិតក៏វិលមុខដែរហើយ សំឡេងក៏បានបន្លឺឡើង

«នាងវង្វេងមែនដែរទេ?»

វង្វង់ដៃនោះឱបនាងកាន់តែខ្លាំងឡើង ដៃរបស់គេក៏លូកស្ទាបរាងកាយនាង ធ្វើឲ្យនាងដឹងតែម្ដងថា នេះគឺជា ឈើតខាមែន ពិតៗ មិនមែនជាព្រះស្វាមីព្រះនាងនោះឡើយ។ រំពេចនោះសំឡេងស្រួយស្រែសក៏បានលាន់ឮឡើងយ៉ាងទាស់ចិត្តតែម្ដង។

**«ឈើតខាមែន!!»**

«ស្អីគេដែរទៅ ហៅឮម្ល៉េះ នាងវង្វេងខ្លាំងឬបានជាហៅខ្ញុំឮរបៀបនេះ?»

«ខ្ញុំមកនៅទីនេះបានដោយរបៀបណាទៅ?»

ដល់ពេលដែលកំលោះសង្ហាត្រូវមានស្មារតីវិញម្ដងនៅពេលនាងសួរទៅកាន់គេបែបហ្នឹងនោះ។ នាងមិនដឹងខ្លួនទេឬថា រាងកាយនន្លគករបស់នាងនៅពេលនេះបានផុតអារម្មណ៍គេខ្លាំងប៉ុណ្ណានោះ ព្រោះមនុស្សប្រុស និង មនុស្សស្រីនៅលើគ្រែតែមួយជាមួយគ្នានោះ តើម៉េចនឹងអាចទប់ចិត្តបានទៅ

«បើខ្ញុំនិយាយនាងប្រាកដជាខ្លាចទៀតហ្នឹងឯងណា»

**«ខ្ញុ...ខ្លាចទៀតហើយឬ?»**

មិនមានសំឡេងឆ្លើយតបពីកំលោះសង្ហា នាងឱនពិនិត្យមើលទៅកាន់សម្លៀកបំពាក់នាង បានធូរចិត្តមែនទែនដែលនាងមានខោអាវជាប់ប្រាណមិនអាក្រាតដូចសព្វដង។



«ខ្ញុំមកទីនេះមិនមែនមកទាំងអាក្រាតកាយទេមែនទេ?»

ឈើតខាមែន ងក់ក្បាលទទួល មានពេលខ្លះការកុហកក៏បានធ្វើឲ្យបរិយាកាសប្រសើរឡើងបានខ្លះដែរ គេនឹងមិនប្រាប់នាងនោះទេថា នាងត្រូវបានអំណាចអាថ៌កំបាំងនោះនាំនាងមកទាំងអាក្រាតកាយ ធ្វើឲ្យគេមើលឃើញរូបរាងកាយទាំងមូលដ៏សែនស៊ិចស៊ីយ៉ាងពេញទំហឹងនោះទេ។

«តើមានអីកើតឡើងចំពោះខ្ញុំដែរទៅ លោកប្រាប់ខ្ញុំបន្តិចមក!»

«ដូចដែលខ្ញុំប្រាប់នាងហ្នឹងឯង ថានាងត្រូវអំណាចអាថ៌កំបាំងនោះនាំមកទីនេះ»

«នាំខ្ញុំមកធ្វើអីដែរទៅ ហើយមិនមានអីកើតឡើងចំពោះខ្ញុំលើសពីនេះទេមែនទេ?»

«ហើយចុះនាងចង់ឲ្យវាកើតឡើងអីចំពោះនាងឬ!»

សំឡេងខ្សឹបខ្សៀវៗឮនៅក្បែរត្រចៀករបស់នាង រំពេចនោះកំលោះសង្ហាក៏ទាញនាងមកជិតកាយរបស់គេ យ៉ុនហ៊ី មានអារម្មណ៍ថា មានដង្ហើមក្ដៅឧណ្ហៗនៅលើផ្ទៃមុខរបស់នាង ហើយអារម្មណ៍ហែលហាលកើតឡើងផងដែរ។

«ខ្ញុំ...ខ្ញុំចង់ត្រឡប់ទៅបន្ទប់ខ្ញុំវិញ»

តើគេម៉េចនឹងអាចបណ្ដោយឲ្យនាងទៅវិញដោយស្រួលៗដែរទៅ នាងត្រូវតែរួមជីវិតជាមួយគេបន្តទៅមុខទៀត ហើយគេក៏បានផ្ដល់ឱកាសឲ្យនាងច្រើនដងមកហើយដែរ ដល់ពេលដែលគេត្រូវធ្វើតាមចិត្តប្រាថ្នារបស់គេម្ដងហើយណា។

«កុំទៅវិញអីណា នៅជាមួយខ្ញុំទីនេះហើយណា»

អ្នកណាចង់នៅជាមួយលោកដែរទៅ ស្រីស្រស់រអ៊ូក្នុងចិត្ត ចុះបើនាងត្រូវបានគេឱបថើបអង្អែលដល់ថ្នាក់នេះហើយនោះណា តែនាងនៅតែខ្លាចចិត្តខ្លួនឯងដដែលហ្នឹង។

«តែខ្ញុំ...ខ្ញុំគិតថា ខ្ញុំត្រឡប់ទៅបន្ទប់របស់ខ្ញុំវិញវាល្អជាងណា»

«នាងត្រឡប់ទៅវិញមិនបានទេណា ព្រោះថាអំណាចអាថ៌កំបាំងនោះ

និងធ្វើបាបនាងមិនឈប់នោះឡើយ»

«លោកដឹងបានដោយរបៀបណាដែរទៅ បើខ្ញុំមិនមានក្រសែចិត្តផងហ្នឹងណា»

«គឺនៅត្រង់ដៃរបស់នាងហ្នឹងឯងណា!»

កែវភ្នែកមួយគូដ៏ស្រស់ស្អាតនោះ សម្លឹងមើលទៅយ័ន្តនៅលើខ្នងដៃរបស់នាង ហើយក៏ព្រមប្រថុយប្រថាននៅជាមួយគេ តែនាងក៏មិនសូវជាជឿជាក់លើគេប៉ុន្មានដែរហេតុធ្វើឲ្យនាងនិយាយមកដោយក្តីសង្ស័យ។

«រូបយ័ន្តដែលខ្ញុំសរសេរលេងនៅលើខ្នងដៃនោះក្លាយទៅជាក្រសែចិត្តបានដោយរបៀបណាដែរទៅ?»

«បានតើស គឺវាធ្វើឲ្យមានអំណាចអាថ៌កំបាំងនាំនាងមកកាន់ទីនេះបាននោះអី»

«តែអំណាចអាថ៌កំបាំងនោះវាទៅបាត់ហើយតើសមិនអីចឹងអី!»

«តែលើកនេះវានឹងអាចត្រឡប់មកវិញណា»

ទោះបីជាគេនិយាយពិតពាក់កណ្តាកកុហកពាក់កណ្តាល តែគោលបំណងរបស់គេគឺធ្វើយ៉ាងណាដើម្បីឲ្យបាននៅជាមួយនាង គេនិយាយព្រមទាំងធ្វើតាមអារម្មណ៍នៃបេះដូង។

«ដល់ពេលហើយណាដែលនាងត្រូវតែក្លាយជារបស់ខ្ញុំនោះណា»

ស្រីស្រស់មានអារម្មណ៍ស្លុតចិត្តចំពោះពាក្យសម្តីមួយម៉ាត់នោះណាស់តើគេយកច្បាប់ពីណាដែលអាចកំណត់ថា នាងត្រូវតែក្លាយជារបស់គេនៅពេលនេះដែរនោះ គេចង់ឲ្យនាងនៅទីនេះជាមួយគេក៏បានដែរ តែគេចង់ឲ្យនាងក្លាយជារបស់គេនោះពិតជាលឿនពេកទេដឹង រូបស្រីស្រស់សែនឆ្លាតដូចជានាងប្រឹងរិះរកវិធីក្នុងការយក្សាចខ្លួន។

«ខ្ញុំនៅមិនទាន់បានត្រៀមខ្លួននៅឡើយទេណា»

«បន្តិចទៀតនាងនឹងត្រៀមខ្លួនរួចជាស្រេចហើយណា»

«ខ្ញុំ...ខ្ញុំគិតថា នៅមិនទាន់ដល់ពេលទេណា»



«កុំណា កុំទៅគិតវាធ្វើអី!»

មានអារម្មណ៍ទាស់ចិត្តមែនទែនតែម្តង ដែលគេនិយាយមកធ្វើឲ្យនាងទាល់ច្រកបានគ្រប់ពេល តើនាងត្រូវដោះស្រាយស្ថានការណ៍នេះដោយវិធីណាដែរទៅ។

បបូរមាត់របស់គេប្រថាប់នៅលើបបូរមាត់ដ៏ស្តើងរបស់នាងភ្លាម ដោយនាងមិនទាន់ទាំងបានការពារអ្វីសោះនោះឡើយ ហើយគេក៏ចាប់ប្រាណនាងផ្តេកទៅលើពូកដ៏ទន់ល្មើយនោះ។ បុរសសង្ហាថើបយ៉ាងរោលរាលព្រមទាំងដោះសម្លៀកបំពាក់ដែលនៅលើប្រាណនាងចេញខ្ទេចគ្មានសេសសល់ ចំណែកឯរូបគេក៏បានដោះចេញគ្មានសល់ដូចគ្នាដែរ។ ពេលនេះពួកគេទាំងពីរស្រាតននលគកដូចគ្នា យ៉ុនហ៊ី ព្យាយាមច្រានប្រាណរឹងមាំនោះចេញពីលើប្រាណរបស់នាង តែហាក់បីដូចជាមិនបានផលទាល់តែសោះ ព្រោះថាអារម្មណ៍របស់នាងបានវិករជាមួយនិងអណ្តាតភាគីខាងប្រុស ដែលកំពុងតែវាយលុកចូលក្នុងមាត់របស់នាងយ៉ាងតក់ក្រហល់ និងគ្មានត្រាប្រណីនោះ។ គេបញ្ចេញស្នៀតឲ្យនាងស្នងអារម្មណ៍ជាមួយនិងសកម្មភាពទាំងឡាយ របស់គេក្នុងកាមតណ្ហាដ៏រោលរាលនោះ នាងមានអារម្មណ៍ថា ពេលនេះប្រាណរបស់គេសង្កត់មកលើប្រាណរបស់នាងកាន់តែខ្លាំងឡើង នៅទីបំផុតគេក៏បានធ្វើឲ្យនាងពេញចិត្តព្រមទាំងតបស្នងនូវសម្រែកតណ្ហាទាំងឡាយទៅកាន់គេវិញ ដោយភ្លេចខ្លួនផងដែរ ហើយរង់ចាំរសជាតិស្នេហ៍របស់គេជាបន្តបន្ទាប់យ៉ាងតក់ក្រហល់។ កែវភ្នែកទាំងពីររបស់បុរសសង្ហា មើលទៅកាន់ដើមទ្រូងទាំងគូដ៏ធំក្បុំក្បោះទ្រលុកទ្រលន់របស់នាងដោយមិនអាចហាមចិត្ត និងអារម្មណ៍បាននោះឡើយ ដៃទាំងសងខាងរបស់គេបានប្របាច់ព្រមទាំងញក់ញីទ្រូងនាងដោយតក់ក្រហល់ បបូរមាត់ដ៏មានជំនាញរបស់គេថើបនៅត្រង់ប្រឡោះដើមក ព្រមទាំងថើបរាលដាលរហូតមកដល់កំពូលភ្នំទាំងគូរបស់នាងទៀត។ មាត់ថើបឯដៃម្ខាងប្របាច់លើទ្រូងរបស់នាងថើបផង បឺតផង ជញ្ជក់ផង ធ្វើឲ្យនាងមានអារម្មណ៍ពុះកញ្ជ្រោលជាមួយគេកាន់តែខ្លាំង។

«អឺម!!! ឈើតខាមែន!!»

នាងហៅឈ្មោះគេនេះ ធ្វើឲ្យគេកាន់តែមានចំណង់កើនឡើងទ្វេដង អណ្ដាតដ៏រស់រវើករបស់គេ បឺតជញ្ជក់ទ្រូងទាំងគូរបស់នាងយ៉ាងឆ្ងាញ់មាត់ ព្រមជាមួយនឹងដៃដ៏រស់រវើករបស់គេច្របាច់ញក់ញី យ៉ាងញាប់ដៃនោះ ធ្វើឲ្យនាងតឹងទ្រូងទាំងទ្វេឡើងមកបញ្ជាក់ថានាងពិតជាមានអារម្មណ៍ណាស់ ធ្វើឲ្យគេបន្តអូសបបូរមាត់ព្រមទាំងអណ្ដាតរបស់គេទៅក្រោមដើមទ្រូង ដល់ក្បាលពោះរបស់នាង និងបានបង្អូសទៅកាប់ចំណុចសំខាន់ដែលនៅខាងក្រោមនោះផងដែរ។

ស្រីស្រស់ទើបតែបានទទួលរសជាតិស្នេហាដែលគេប្រគល់ឲ្យជាលើកដំបូង គេប្រគល់រសជាតិព្រមទាំងអារម្មណ៍តណ្ហាដល់នាងស្ទើរតែធ្វើឲ្យនាងដាច់ខ្យល់នៅនឹងកន្លែងតែម្ដង។ មាត់របស់គេបង្អូសទៅកាន់ក្លិនក្លែបនៃចំណុចពិសេសរបស់នាង ដៃរបស់គេក៏មិនព្រមនៅស្ងៀមដែរ គេលូកចូលទៅត្រង់ចំណុចពិសេសរបស់នាង ធ្វើឲ្យនាងស្ទើរតែស្លឈាម។

នាងកំពុងតែដាច់ខ្យល់ស្លាប់ឬយ៉ាងណាទេនៀក ហេតុអីក៏គេមានសមត្ថភាពធ្វើឲ្យនាងមានអារម្មណ៍ពុះកញ្ជ្រោល និងចង់ភ្លក់រសជាតិស្នេហារបស់គេបានខ្លាំងដល់ថ្នាក់នេះដែរទៅហ្ន៎! រំពេចនោះ នាងលើកជើងឲ្យគេបានជញ្ជក់ក្លែបកុលាបរបស់នាងយ៉ាងមិន ចៀនខ្មាស អ្នកណាទៅដឹង! អារម្មណ៍នាំទៅរកតណ្ហាពុះកញ្ជ្រោលទៅហើយនោះ ហើយនាងក៏មានអារម្មណ៍ថា មានអ្វីម៉្យាងសើកចូលទៅក្នុងក្លែបកុលាប របស់នាងរហូតដល់ឈឺផ្សាៗ។

«ឈឺត...ខ្ញុំ...ខ្ញុំឈឺ!!»

សំឡេងស្រែកថ្ងូររបស់នាង ធ្វើឲ្យកំលោះសង្ហាងើបមុខឡើងមើលមុខរបស់នាង ហើយដៃរបស់គេទាំងពីរក៏លូកមកច្របាច់សុដន់ទាំងសងខាងរបស់នាងដើម្បីរម្ងាប់អារម្មណ៍ឈឺផ្សានោះ។ រំពេចនោះមានអារម្មណ៍ថាប្រាណរបស់នាងនៅស្ងៀម នាងប្រហែលជាឈឺ ហើយចាប់ផ្ដើមភ័យខ្លាចហើយមើលទៅនោះ គេងើបកាយមកមើលមុខរបស់ស្រីស្រស់ ផ្ទៃមុខព្រមទាំងសកម្មភាពរបស់



នាងបញ្ជាក់ថា ពិតជាចង់សាកល្បងចំពោះរសជាតិប្លែកថ្មីនោះជាពន់ពេក ទើបខ្សឹបនៅក្បែរត្រចៀករបស់នាងថា៖

«នាងនឹងមានក្ដីសុខដែលនាងមិនអាចស្មានដល់ណា យ៉ុនហ៊ី!»

ឈើតខាមែន ឱនទៅថើបបបូរមាត់ដ៏ស្រស់ស្អាតរបស់នាងយ៉ាងទន់ភ្លន់ និងលួងលោមអារម្មណ៍មិនឲ្យនាងឈឺចាប់ បបូរមាត់នៅរកលដាលមកដល់ត្រង់ទួលទ្រូងទាំងគូដ៏ធំក្បុំក្បោះនោះ ហើយនាងក៏តបស្នងគេវិញផងដែរ នាងបានញែកជើងយ៉ាងធំ ដើម្បីឲ្យគេងាយស្រួលដាក់របស់គេចូលទៅ។ គេធ្វើសកម្មភាពនោះមួយៗ យឺតៗ ចាប់ផ្ដើមពីតិចទៅៗខ្លាំងទៅៗ យ៉ាងញាប់ៗ ធ្វើឲ្យនាងបានតបស្នងមកគេវិញយ៉ាងញាប់កាយដូចគ្នាដែរ។ គេធ្វើសកម្មភាពដកចុះដកឡើងនោះយ៉ាងយូរ ដល់ដំណាក់កាលចុងក្រោយ សំឡេងស្រែកថ្ងូររបស់ពួកគេទាំងពីរនាក់ក៏បានលាន់ឮឡើងព្រមៗគ្នា គឺពួកគេឈានដល់ចំណុចកំពូលរៀងៗខ្លួននោះណា។

ដំណាក់កាលចុងក្រោយ គឺឮស្ទើរតែដង្ហើមដកយ៉ាងត្រហេបត្រហបដាក់គ្នា គេគេងផ្ដួបនៅលើប្រាណត្រង់កណ្ដាលដើមទ្រូងរបស់នាង។

«ភរិយារបស់ខ្ញុំ!»

ឈើតខាមែន រអ៊ូៗ ព្រមទាំងថើបនៅលើផ្ទៃមុខដែលជោគទៅដោយញើស ហើយក៏បម្រាស់ខ្លួនទាញនាងមកដេកឱប កំលោះសង្ហាដូចជាគេបានឆ្លងកាត់មនុស្សស្រីមកជាច្រើននាក់ទៅហើយ តែមិនដែលមានពេលណាដែលមានក្ដីសុខខ្លាំងដូចពេលនេះឡើយ ព្រោះភរិយាថ្មីថ្មោងរបស់គេទាំងនៅក្រមុំបរិសុទ្ធ ទាំងមានកាយសិចស៊ីមិនអាចទប់អារម្មណ៍បានតែម្ដង តើនាងមានដឹងដែរទេហ្ន៎!! គេអត់ទ្រាំមិនឱនទៅថើបនាងជាថ្មីមិនបានដោយអារម្មណ៍ស្រឡាញ់ជាពន់ពេក។ ចំណែកឯរាងស្ដើងដែលនៅក្រោមដើមទ្រូងរបស់គេនោះមិនទាន់ប្រាកដចិត្តនៅឡើយថា ហេតុការណ៍ដែលកើតឡើងនោះជាសុបិនឬជាការពិតទេ តែអ្វីដែលនាងបានដឹងយ៉ាងច្បាស់នោះ គឺការប៉ះស្ទាបព្រមទាំងសកម្មភាពដែលគេបាន ធ្វើចំពោះនាងអំបាញ់មិញនេះជាការពិត

ហើយនាងក៏ហាក់ដូចជាមានអារម្មណ៍ផក់ចិត្តជឹតអារម្មណ៍ជាមួយសកម្មភាព ដែលគេបានផ្ដល់ដល់នាងនោះផងដែរ។

«យ៉ុនហ៊ី ក្ដីសុខគឺស្ថិតនៅលើយើងពីរនាក់នោះទេណា...ដឹងទេ!»

អ្នកណាមិនដឹងដែរទៅ តើគេមានដឹងដែរទេថា នាងអៀនគេខ្លាំងរហូតមិនហ៊ានមើលមុខគេសោះ នាងឮសំឡេងដែលគេរអ៊ូប្រាប់នោះផងដែរ។

«ខ្ញុំសប្បាយចិត្តណាស់ ដែលនាងមានក្ដីសុខ...»

រាងស្ដើងដែលនៅក្នុងរង្វង់ដៃឱបរបស់គេនោះ បានត្រឹមតែឱនមុខក្នុងដើមទ្រូងរបស់គេ ព្រមទាំងគិតថា អ្វីទៅដែលធ្វើឲ្យគេមានអារម្មណ៍បែបហ្នឹងនោះ! នាងមានអារម្មណ៍ពេញចិត្តចំពោះរសជាតិស្នេហារបស់គេ ប្រហែលជាគេដឹងច្បាស់ណាស់ហើយ នៅពេលនឹកឃើញដល់សកម្មភាពកន្លងមកនោះណា។ នាងពេលនេះមានអារម្មណ៍ថា ខកណាស់ដោយសារស្រែកខ្លាំងពេកអុយ!! ស្លាប់ហើយ នេះនាងធ្វើបានដល់ថ្នាក់ហ្នឹងឬ! កន្លងមកបានតែថាឲ្យមិត្តស្រីរបស់នាងគឺ ហាន់ណា ហើយហេតុអីក៏នាងក្លាយជាបែបហ្នឹងខ្លួនឯងទៅវិញ នាងគិត ព្រមទាំងគេងនៅក្នុងប្រអប់ដើមទ្រូងរបស់ស្វាមីនាងបណ្ដោយទៅ។

www.srolanhkhmer.com





...៤...

## ជីវិតបរិសុទ្ធ

នៅឯសេតវិមានដ៏ធំស្កឹមស្កៃរបស់ ឈើតអាអ៊ីត ភរិយាសែនស្រស់ស្អាតរបស់ម្ចាស់សេតវិមាននោះ បានលើកទូរស័ព្ទចុចចុះចុចឡើង មិនព្រមនៅស្ងៀមឡើយ។ នាងដើរចុះដើរឡើងៗរហូតស្វាមីដ៏ស្រស់សង្ហារបស់នាងអត់ទ្រាំមិនបានចំពោះសកម្មភាពរបស់ភរិយាគេនោះ ព្រោះវាខាតពេលសម្រាប់ពួកគេត្រូវធ្វើអីៗគ្នានោះណា។ រំពេចនោះសំឡេងមុតមាំក៏លាន់ឮឡើងដោយទ្រាំមើលតទៀតមិនបាន។

«ហាន់ណា បងគិតថា អូនគួរតែឈប់គិតរឿងរ៉ាវរបស់ យ៉ុនហ៊ី មួយរយៈទៅ»

«បងនិយាយរឿង យ៉ុនហ៊ី ខ្លះវាប្រសើរជាងណា»

«អូនគិតហើយមែនទែនថា គួរតែទុកវាចោលមួយរយៈនោះ!»

បើដូច្នោះ ជីវិតរបស់គេនឹងត្រឡប់មករកភាពស្រស់ស្រាយដូចលើកមុនវិញនោះណា។ រំពេចនោះស្វាមីក៏ចូលទៅឱបភរិយាយ៉ាងសប្បាយចិត្តជាពន់ពេក ព្រោះភរិយាគេឈប់ងប់ងុលនឹងការបុចទូរស័ព្ទទៅរកមិត្តស្រីរបស់នាងនោះណា។

«អ្នកណាថាដែរទៅ! អូនចង់ប្រាប់ថា ឲ្យបងជូនទៅរក យ៉ុនហ៊ី នៅឯសេតវិមានរបស់ ឈីតខាមែន នោះទេ»

«ហាស់!! ជាម៉េច!! វាធ្ងន់ធ្ងរជាងការដែលអូនបុចទូរស័ព្ទទៅទៀតណា»

«ចុះបើអូនបារម្ភពី យ៉ុនហ៊ី នោះណា មើលចុះទាក់ទងទៅមិនបានទាល់តែសោះហើយនៀក»

«តែផ្លូវដែលធ្វើដំណើរទៅកាន់សេតវិមានរបស់ ឈីតខាមែន ត្រូវខូចខាត អូនមានដឹងដែរទេ?»

«យើងនាំគ្នាជិះសេះទៅក៏បានដែរតើស មិនអ៊ីចឹង?»

«កាន់តែទៅហើយនៀក មិនមែនងាយស្រួលដូចអូននិយាយនោះទេណា»

ឈីត ហាក់ដូចជាពិបាកចិត្តចំពោះភរិយាដែលបារម្ភពីមិត្តស្រី នាងហួសហេតុពេកទៅហើយ នាំឲ្យគេខូចខាតផលប្រយោជន៍ផងដែរ ជាពិសេសសកម្មភាពលើគ្រែរបស់គេនោះណា។

«អូនដូចជាមានអារម្មណ៍ចម្លែកៗណាស់»

«ប្លែកអីដែរទៅ អូនប្រហែលជាគិតតែខ្លួនឯងពេកទេដឹង»

«តែការដែលអូនបានទាក់ទងទៅ យ៉ុនហ៊ី លើកចុងក្រោយនោះដូចជាមានអារម្មណ៍ថា នាងមានអ្វីចាំបាច់ត្រូវឲ្យជួយណា»

«ហឹស!!! បើសិនជាមានបញ្ហាអីនោះ ឈីតខាមែន ប្រហែលជារកវិធីផ្តល់ដំណឹងមកឲ្យយើងដឹងហើយណា»



«នេះបងកុំបានត្រឹមតែដកដង្ហើមធំទៅមើស! អូនកំពុងតែពិបាកចិត្ត»

«បុងនឹងថាអូនបារម្ភពី យ៉ុនហ៊ី តែតាមបង គិតថានាងប្រាកដជាមានសុវត្ថិភាពណា»

«តែអូនចង់ទៅមើលផ្ទាល់ភ្នែកនោះណាថា វាប្រាកដជាមានសុវត្ថិភាពពិតមែនឬក៏អត់»

ឈីត អត់ទ្រាំមិនគិតមិនបានទាល់តែសោះថា គេគឺជាអ្នកនិយាយរៀបរាប់រឿងរ៉ាវរបស់ ឈីតខាមែន ឲ្យនាងស្តាប់ ជាហេតុធ្វើឲ្យភរិយារបស់គេគិតច្រើនខ្វល់ខ្វាយមិនចេះចប់ គេប្រហែលជាត្រូវទទួលខុសត្រូវដែរហើយមើលទៅនោះ។

«អ៊ីចឹងក៏បានដែរណា! តែអូនត្រូវតែធ្វើតួនាទីជាភរិយាបងសិនណា!»

ចរិតឬកពាររបស់អ្នករកស៊ីតែប៉ុណ្ណឹងឯង ហាន់ណា គិត មិនថានាងចង់ឲ្យស្វាមីសង្សារបស់នាងធ្វើអ្វីមួយ គេតែងតែទាមទារសំណងពីនាងវិញគឺអារឿងលើគ្រែនោះឯងណា គេមិនភ្លេចវាម្តងណាឡើយ ស្វាមីរបស់នាងមិនដែលចាញ់ប្រៀបនាងចំពោះរឿងលើគ្រែនេះនោះឡើយ ថ្ងៃណាដែលនាងមិនបានឲ្យគេគេងជាមួយ ពេលក្រោយគេគិតទាំងដើមទាំងការតែម្តង នេះហើយជាគំនិតអ្នករកស៊ី។ ថែមទាំងមានពេលខ្លះគេគិតនាងទាំងដើមទាំងចុងព្រមទាំងលើស ដើមលើសចុងផងដែរ ហឹមមម! យ៉ាប់ណាស់ប្តីខ្ញុំ!!

«នែ ឈីត!!! ហេតុអីក៏បងមិនព្រមកាត់ចោលអារឿងលើគ្រែខ្លះទៅ!»

«តើរឿងនេះអាចបោះចោលបានដោយរបៀបណាទៅអូន?»

សំឡេងខ្សឹបខ្សៀវព្រមទាំងមានដង្ហើមក្តៅៗ នៅក្បែរត្រចៀកនាងផងដែរ ស្រីស្រស់មានអារម្មណ៍ថា អាអូនតូចរបស់ស្វាមីនាងបានឡើងធំទៅៗនៅត្រង់ប្រឡោះជើងទាំងពីររបស់នាង។ ដៃទាំងពីររបស់ស្វាមីប្រឡះខ្សែរអាវនាងទាំងក្នុង និងក្រៅ ព្រមទាំងដោះខោអាវរបស់គេចេញយ៉ាងងាយស្រួលតែម្តង រួចគេក៏ចាប់ផ្តើមសកម្មភាពលើគ្រែរបស់គេជាបន្តបន្ទាប់ដូចរាល់ដង។ គេធ្វើឲ្យនាងមានអារម្មណ៍ពុះកញ្ជ្រោលរហូតដល់ភ្លេចភ្លាំងរឿងរ៉ាវគង្វល់ផ្សេងៗ

នោះតែម្ដង។

នាពេលព្រឹកព្រលឹមអាកាសធាតុត្រជាក់ស្រិប រាងកាយនាងតេងប្រែចុះប្រែឡើងៗ-តេងលក់ក៏មិនជាលក់ ភ្ញាក់ក៏ដូចជាមិនភ្ញាក់ ចុងក្រោយនាងក៏ក្រោកឡើងអង្គុយនៅលើពូកដ៏ទន់ល្មើយនោះ កែវភ្នែករបស់នាងក្រឡេករកស្វាមីដែលគេបានសន្យាថា នឹងនាំនាងទៅរកមិត្តសម្លាញ់ ហើយនេះមិនដឹងជាគេបាត់ស្រមោលទៅណាទាំងព្រលឹមទៀត។

ហាន់ណា ដែលស្ថិតក្នុងឈុតហាត់ប្រាណបានរត់ជុំវិញសេតវិមានដ៏ធំនោះ កែវភ្នែកនាងសម្លឹងរកស្វាមីក្រែងលោគេកំពុងតែបញ្ជាការងារអ្វីមួយទៅកាន់កូនចៅ។ នាងក៏នឹកឃើញដល់ក្មេងប្រុស វ៉ាឈីត ដែលមានកូនផ្ទះដ៏ស្រស់ស្អាតមួយនៅពីក្រោយសេតវិមានដ៏ធំនេះផងដែរ ស្រីស្រស់ញញឹមហើយរត់ត្រឹកៗទៅកាន់ផ្ទះមួយនោះភ្លាម។

«ក្រោកហើយឬនៅទេទៀត វ៉ាឈីត»

នាងរអ៊ូរទាំម្នាក់ឯង ព្រមទាំងលើកដៃមើលនាឡិកា ហើយដកដង្ហើមយ៉ាងវែងៗដើម្បីឲ្យអារម្មណ៍ស្រស់ស្រាយ កែវភ្នែកសម្លឹងមើលទៅខាងក្នុងផ្ទះដ៏ស្រស់ស្អាតនោះមិនព្រមដាក់ភ្នែកទាល់តែសោះ ហើយក៏បានឃើញមនុស្សស្រីម្នាក់ញញឹមចេញមកសួរនាំរាក់ទាក់នាងដូចជាស្និទ្ធស្នាលអីចឹង។

«ឃឹស!!! អ្នកនាង ហាន់ណា រត់ហាត់ប្រាណមកដល់ទីនេះ?»

«មិនដឹងដែរ វ៉ានី នឹក វ៉ាឈិត ហ្នឹងណា ប្រហែលជាមិនទាន់ក្រោកទេដឹង!»

«នៅមិនទាន់ក្រោកទេ កាលពីយប់មិញគេរកញៀង គេងយប់ជ្រៅពេកហ្នឹងណាអ្នកនាង»

«អ!!! អីចឹងទេ!»

«អ្នកនាង អញ្ជើញចូលខាងក្នុងសិនទៅណាអ្នកនាង»

«អ! មិនបាច់ទេណា អរគុណច្រើនហើយ»

ហាន់ណា មើលទៅកាន់មនុស្សស្រីដែលនៅចំពោះមុខនាងនោះនាង



មានអារម្មណ៍អាណិតជាពន់ពេក ដែលស្វាមីរបស់នាងបានចាកចោលនាងទៅបន្សល់ទុកឲ្យនាងរស់នៅតែលតោលតែពីរនាក់ម្ដាយ និងកូនប្រុស តែក៏សំណាងល្អដែរដែលស្វាមីរបស់នាងបានទទួលពួកគេទាំងពីរនាក់ឲ្យនៅទីនេះ។

នាងមានអារម្មណ៍ខុសឡើងភ្លាម នៅពេលគ្រាមួយនាងបានយល់ច្រឡំលើមនុស្សស្រីដ៏គួរឲ្យអាណិតម្នាក់នេះថា នាងក៏ជាភរិយាម្នាក់ទៀតរបស់ស្វាមីរបស់នាង រហូតដល់ថ្នាក់នាងរត់គេចទៅស្រុកនាងវិញ តែក៏ដោយសារតែក្ដីស្រឡាញ់ស្មោះរបស់ស្វាមី ដែលគេខំព្យាយាមទៅតាមសម្រុះសម្រួលជាមួយនាងនៅឯស្រុកកូរ៉េនោះ រហូតដល់ដឹងការពិតថា មនុស្សស្រីដែលគួរឲ្យអាណិតឈរនៅចំពោះមុខនាងនាពេលនេះ គឺជាសាច់ញាតិរបស់ស្វាមីនាងនោះហ្នឹងណា ព្រោះប្ដីរបស់នាងបានស្លាប់បាត់បង់ជីវិតព្រោះតែទៅបំពេញការងារឲ្យឈីត ហើយ ឈីត ក៏មានទឹកចិត្តទទួលចិញ្ចឹមទាំងម្ដាយ និងកូនផងដែរ។

«វ៉ាឈីត ប្រហែលជាធំជាងមុនខ្លាំងហើយមើលទៅនោះ»

«ចាស! វ៉ាឈីត ធំជាងមុនច្រើនណាស់អ្នកនាង»

ហាន់ណា ញញឹមចំពោះពាក្យសម្ដីនោះ ហើយក៏ក្រឡេកភ្នែករកមើលស្វាមីរបស់នាងម្ដងទៀតមុននឹងបែរមកស្ដាប់មនុស្សស្រីនៅចំពោះមុខនាងនេះនិយាយបន្ត៖

«ហេតុអីក៏អ្នកនាងមិនយកកូនម្នាក់ឲ្យបង ឈីត ដែរទៅ?»

អ្នកណាមិនចង់មានដែរទៅ! នាង និងស្វាមីមិនបានការពារឯណា នេះដល់ថ្នាក់ នាងបើកភ្លើងខៀវឲ្យគេធ្វើសកម្មភាពលើគ្រែគ្រប់ពេលវេលាដោយមិនរាំងបន្តិចណាឡើយ ហើយកំហុសដែលនាំឲ្យនាងមិនមានកូនធ្លាក់មកលើស្វាមីនាងសាជាថ្មីម្ដងទៀត។

«អ្នកណាមិនចង់មានដែរទៅ វ៉ានី!»

«អ!! អីចឹងទេអ្នកនាង គង់តែមានខ្លួនឯងទេ គេហៅថាកូនច្រណែនហ្នឹងណាអ្នកនាង»

«កូនច្រណែន?»

«ចុះបើអ្នកនាង និងបង ឈិត អនុញ្ញាតឲ្យ វ៉ាឈិត ហៅអ្នកនាង និង បង ឈិត ជាប៉ាម៉ាក់នោះអីអ្នកនាង»

«អ!! ហើយកូនមែនទែនក៏ប្រណែន ហើយក៏ប្រញាប់មកកើតមែនដែរទេ?»

ពួកគេទាំងពីរនាក់អត់ទ្រាំមិនសើចមិនបានចំពោះពាក្យសម្ដីនោះ ចុះបើពាក្យបុរាណគេនិយាយបែបហ្នឹងមែននោះអី។

«អ្នកនាង នេះនិយាយរឿងពិបាកៗចិត្តឲ្យក្លាយជារឿងកំប្លែងបានទៀតហ្ន៎!!»

«តែនេះជិតមួយឆ្នាំទៅហើយណា មិនមានឃើញស្រមោលសោះហើយ»

កាន់តែនឹកកាន់តែឆ្ងល់ស្វាមីនាងដែលមិនអាចឲ្យនាងមានកូនដូចគេព្រោះនាងស្រឡាញ់ក្មេង ហើយគេក៏ស្រឡាញ់ក្មេងដូចគ្នាដែរនោះអី កាន់តែនឹកកាន់តែក្ដៅចិត្តភ្លាមតែម្ដង ស្របពេលដែលមិនឃើញស្រមោលស្វាមីនាងសោះនោះអី។ មើលទៅមនុស្សស្រីនៅចំពោះមុខនាងហាក់ដូចជាយល់ចិត្តនាងអីចឹងទើបនិយាយឡើង។

«រកមើលបង ឈិត មែនដែរទេអ្នកនាង?»

«ចាស! តាំងពីព្រឹកទៅហើយខ្ញុំមិនទាន់បានជួបមុខគេទាល់តែសោះហើយនៀក»

«កាលពីព្រឹកមិញ ខ្ញុំបានឃើញបង ឈិត ដើរទៅខាងក្រោយផ្ទះដើម្បីស្រូបកម្ដៅព្រះអាទិត្យហ្នឹងណាអ្នកនាង»

«អីចឹងបានជារកមិនឃើញ បើអីចឹងខ្ញុំរកទៅសិនហើយណា វ៉ានី»

«ចាស! អរគុណច្រើនហើយណាអ្នកនាងដែលបានមកលេងខ្ញុំ»

ហាន់ណា ញញឹមដាក់មនុស្សស្រីដែលនៅចំពោះមុខនាងព្រមទាំងដើរត្រឹកៗទៅវិញទៅខាងក្រោយផ្ទះត្រង់កន្លែងទទួលកម្ដៅព្រះអាទិត្យនោះ ហើយរំពេចនោះ ផ្ទៃមុខរបស់នាងក៏បញ្ចេញស្នាមញញឹមភ្លាមនៅពេលបានឃើញប្ដីខ្លួនកំពុងតែឱនមើលៗ ហើយបញ្ជាការងារដល់កូនចៅគេ។ រួចរាល់គេងាកមក



ឃើញនាងគេក៏ដើរសំដៅមករកភ្លាម។

«អូនមកទីនេះធ្វើអីដែរទៅ មេឃក្ដៅសឹងអី!»

«ចុះបើអូនមិនឃើញបងសោះនោះណា»

«បងឃើញអូនកំពុងគេងលក់ហ្នឹងណា បានជាមិនហ៊ានដាស់ មើលចុះគ្រាន់តែព្យុះភ្លៀងកាលពីថ្ងៃមុននោះបណ្ដាលឲ្យទំនប់ទឹកខូចខ្ទេចខ្ទីអស់ហើយទើបបងចេញមកបញ្ជាការងារកូនចៅជួសជុលជាថ្មីនោះណា»

«ហើយចុះបងនឹងនាំអូនទៅកាន់ សេតវិមាន របស់ ឈិតខាមែន ពេលណាដែរទៅ?»

ឈិត ដកដង្ហើមធំ គេមិនអាចពង្វាងអារម្មណ៍ភរិយាគេមិនបានទេឬយ៉ាងណាហ្នឹង គេដឹងច្បាស់ណាស់ថា ផ្លូវទៅកាន់សេតវិមានរបស់ ឈិតខាមែន គ្រោះថ្នាក់ណាស់ ផ្លូវថ្នល់ក៏ខូចជាច់ខ្ទេច។ រំពេចនោះសំឡេងដកដង្ហើមក៏បានលាន់ឮឡើងជាថ្មីម្ដងទៀត។

«អឺមមម!! គឺបែបនេះណា...គឺបងគិតថា ផ្លូវមិនទាន់ស្រួលបួលក្នុងការធ្វើដំណើរទៅនោះទេណា»

«តែកាលពីយប់មិញបងបានសន្យាជាមួយអូនហើយណាថា នឹងនាំទៅកាន់ផ្លូវដែលអាចធ្វើដំណើរទៅបាននោះអី»

«តែវាគ្រោះថ្នាក់ណាស់ណា»

«មិនដឹងទេ បងសន្យាជាមួយអូនហើយនោះអី ឬក៏បងបោកប្រាស់ដេកជាមួយអូន ហ្នឹ៎ៗ ហាស់?»

សំឡេងតវ៉ារបស់ភរិយា ធ្វើឲ្យ ឈិត អស់សំណើច ព្រមទាំងគិតថាភរិយារបស់គេពូកែខាងរកពាក្យមកនិយាយសមៗណាស់នោះណា។ ស្វាមីភរិយាគ្នាចាំបាច់បោកប្រាស់ដេកជាមួយធ្វើអីដែរទៅ។

«នេះបងសើចស្អីគេ អូនមិនកំប្លែងជាមួយបងនោះទេណា»

«ណ្ហើយចុះ ណ្ហើយចុះ បងនឹងនាំទៅក៏បានដែរ យើងនាំគ្នាចូលទៅខាងក្នុងសិនទៅណា នៅទីនេះក្ដៅខ្លាំងណាស់»

នេះគេចាំឲ្យមិត្តភក្តិរបស់នាងកើតអីសិន បានគេនាំនាងទៅ!! ហើយគេក៏បានសន្យាហើយដែរតើស រំពេចនោះសំឡេងស្រួយស្រែសក៏បានលាន់ឮឡើង។

«មិនបានទេណា យើងត្រូវតែនាំគ្នាទៅទីនោះថ្ងៃនេះឲ្យបាន តាមសន្យា»

«ពុទ្ធោ!!! ហេតុអីក៏អូនរឹងដល់ថ្នាក់នេះដែរទៅទៀត!!»

«បងកុំមកថាអូនរឹងឲ្យសោះណា បងទេជាអ្នកខុសសន្យាជាមួយអូននោះ ក្រែងបងក៏ដឹងដែរមិនថា ឈើតខាមែន ជាបុរសដែលហាមឃាត់នោះអី អូនត្រូវតែទៅទទួល យ៉ុនហ៊ី ត្រឡប់មកវិញវាប្រហែលជាមានបញ្ហាអ្វីម៉្យាងហើយ»

«បងសុំឲ្យកូនចៅរបស់ត្រួតពិនិត្យផ្លូវទៅសិនបានដែរទេ ចាំយើងនាំគ្នាទៅតាមក្រោយ»

«ទេ!!»

សំឡេងគោរពេញទៅដោយអំណាច បានឆាបឆួលចេញពីមាត់របស់ភាគីខាងស្រី ធ្វើឲ្យស្វាមីនាងរង្គោះរង្គើទៅដល់ឆ្អឹងខ្នងបានលាន់ឮឡើង។

«បើមិននាំ អូននឹងលែងធ្វើតួនាទីជាភរិយាបងទៀតហើយ ចាំមើលចុះ!»

«ហាស់!! ថាម៉េច អូននឹងលែងធ្វើតួនាទីជាភរិយាបង?»

«ត្រូវហើយ!!»

វាដូចជាហួសហេតុពេកហើយ ដែលភរិយារបស់គេហ៊ានលើកសម្ដីថាលែងធ្វើតួនាទីភរិយាមកគំរាមគេបែបនេះ។ បុរសសង្ហាដូចជាគេដែលតែងតែទទួលជោគជ័យមកគ្រប់យ៉ាង មើលការខុសត្រូវលើមនុស្សរាប់រយពាន់នាក់ គឺគ្រាន់តែភរិយាតែម្នាក់ប៉ុណ្ណោះ ធ្វើឲ្យគេមិនអាចគ្រប់គ្រងបាន! រំពេចនោះសំឡេងមុតមាំក៏លាន់ឮឡើង។

**«អីចឹងក៏បាន អីចឹងក៏បាន!!! បងនឹងនាំទៅ»**

គេមិនខ្លាចភរិយាគេនោះទេ តែគេស្រឡាញ់ភរិយាគេទៅវិញទេតើស។



ឡានមួយគ្រឿង ដែលចេញម៉ូតសម្រាប់ប្រើនៅក្នុងតំបន់សមុទ្រខ្សាច់ កំពុងតែបើកសំដៅទៅកាន់សេតវិមានរបស់ ឈើតខាមែន ទោះបីជា ឈើត មានជំនាញក្នុងការបើកឡានតាមផ្លូវសមុទ្រខ្សាច់នេះយ៉ាងណាក៏ដោយ តែដោយសារទើបតែខូចខាតដោយសារតែភ្លៀងធ្លាក់យ៉ាងខ្លាំងកាលពីថ្ងៃមុននោះ ធ្វើឲ្យលំបាកខ្លាំងបន្តិច ធ្វើឲ្យឡានជាប់ផុងនឹងដីខ្សាច់ដែលមានជម្រៅជ្រៅនោះច្រើនដងរហូតដល់ថ្នាក់ធ្វើឲ្យគេសម្រេចចិត្តឈប់ធ្វើដំណើរ។

«អូនឃើញហើយឬនៅថា ផ្លូវវាបានខូចខាតអស់ហើយដូចដែលបងនិយាយមែននោះណា»

«ចុះបងបើកអមៗទៅតាមណាដែលអាចទៅបានទៅ»

«តើឲ្យបើកអមៗទៅដោយរបៀបណាទៅ បើខ្សាច់នោះវាផុងទៅទាំងឡានទាំងមនុស្សអស់ទៅហើយណា»

«ចុះម៉េចក៏បងមិនព្រមទៅតាមផ្លូវផ្សេងដែរទៅ»

«បងដឹងម៉េចទៅថា ផ្លូវណាខ្សាច់វាស្រួប ឬមិនស្រួបនោះ?»

«គ្មានអីពិបាកនោះទេ បើវាស្រួប យើងនឹងឃើញវាស្រួបហើយ ហើយបើវាមិនស្រួបនោះយើងនឹងឃើញវាមិនស្រួប!»

«ហ៊ឹមមម!!! ហេតុអីក៏អូនជាមនុស្សរឹងបែបនេះហាស់ នៅតែរអ៊ូវនៅក្បែរត្រចៀកហ្នឹងឯង»

«នែ!! កុំមកថាអូនរឹងឲ្យសោះណា!»

មានអារម្មណ៍ថា ទាស់ចិត្តមែនទែនតែម្ដង ខំជួយបញ្ចេញគំនិតហើយនៅមកស្ដីឲ្យទៀត ចុះកាលពីលើកមុនវិញឃើញបើកដេញអាពួកជួញដូរមនុស្សឆ្លងដែនខុសច្បាប់នោះឡូយម្ល៉េះ មិនឃើញមានបញ្ហាអ្វីផងនោះណា។ មុខដ៏ស្រស់ស្អាតរបស់នាងចាប់ផ្ដើមក្រញូវភ្លាមតែម្ដង។

«អូនមិនបានរឹងឯណា គ្រាន់តែបារម្ភពីមិត្តភក្តិតែប៉ុណ្ណោះតើស»

«អីចឹងក៏បានដែរ អូនមិនរឹងទេណា»

«នែបង!! កុំមកពន្យ៉ះខ្ញុំមើស!!»

«បងនិយាយពន្យះអូនត្រង់ណាទៅ កុំមកនិយាយរាលដាលមើស ហេតុអីក៏អូនមួម៉ៅម្ល៉េះទៀត!!»

មែនហ្នឹងណា!! ហេតុអីក៏នាងមានអារម្មណ៍មួម៉ៅម្ល៉េះ? ដោយសារតែបារម្ភពីមិត្តភក្តិ និងការប្រកាន់គំនិតចង់ទៅជួបមិត្តនោះឬ? ហើយអាការៈចង់ក្អួតចង្អោរក៏ឈានចូលមកនៅចំពោះការបារម្ភពីស្វាមីរបស់នាង។

«អួកក!! អួកក!! អួកក!!»

«តើអូនកើតអីហ្នឹង! ពុលឡានមែនទេ?»

«អូនចង់ក្អួត !វិលមុខទៀតណា»

«អូនក្អួតចង្អោរបែបនេះ បងប្រហែលជានាំអូនត្រឡប់ទៅវិញហើយ!!»

«ទេ! ទេ អូនមិនកើតអីឯណា គឺគ្រាន់តែចង់ក្អួតតែប៉ុណ្ណោះតើស»

«នៅតមាត់ក្បែរត្រចៀកបងដដែលៗទៀតហើយណា»

«បងកំពុងតែថា អូនគ្មានហេតុផលទៀតហើយណា»

ឈើត ត្រវីក្បាលចំពោះពាក្យសម្តីរបស់ភរិយាកំពូលឱរបស់គេភ្លាម នាងតែងតែចង់យកឈ្នះគេរហូត តែនៅពេលបានឃើញទឹកមុខស្លេកស្លាំងរបស់ភរិយា គេអត់ទ្រាំមិនបារម្ភពីនាងមិនបាន។

«បងឃើញអូនមានអាការបែបនេះពីរបីថ្ងៃហើយណា អូនកំពុងតែខុសធម្មតាហើយណា!»

«ប្រហែលជាខ្វល់រឿង យ៉ុនហ៊ុ ទេដឹង»

«ចុះក្រែងអូនក៏បានឃើញហើយតើសថា ផ្លូវត្រូវកាត់ផ្តាច់ ហើយអូនក៏មិនស្រួលខ្លួនទៀត បងថាយើងនាំគ្នាទៅវិញសិនទៅណា ចាំបងនឹងរកវិធីមកទីនេះសាជាថ្មី»

ឈើត បញ្ជាឡានឲ្យត្រឡប់ទៅកាន់សេតវិមានគេវិញ ទោះបីជាមានការទាស់ចិត្តពីភរិយាស្រស់សោភារបស់គេខ្លាំងយ៉ាងណាក៏ដោយ គេមើលទៅមុខភរិយាដែលចង់ក្អួតបន្តិចអត់បន្តិច ហើយក៏បើកយឺតៗ ជួនណាឈប់ឡានឲ្យភរិយាគេក្អួតសិនផងដែរ។



«អួកកក!!»

«យ៉ាងម៉េចទៅហើយហ្នឹង!!»

«គឺនៅមានអារម្មណ៍ថា ចង់ក្អួតៗ វិលមុខដដែលហ្នឹងណា មិនដឹងយ៉ាងម៉េចដែរហ្នឹង!!!»

ជាធម្មតាមនុស្សដែលរឹងមាំ មនុស្សដែលចូលចិត្តការហាត់ប្រាណខ្លាំងដូចជានាងនេះ ហេតុអីក៏ក្លាយជាមនុស្សដែលមានពោគឈឺថ្កាត់បែបនេះទៅវិញ រំពេចនោះច្រមុះរបស់នាងក៏មានអារម្មណ៍ថា ស្អុយស្វាមីរបស់នាងដែលកំពុងតែរឹតមុខរឹតក្រោយឲ្យនាងតែម្តងហើយនៀក។

«ឈើត!! បងប្រើទឹកអប់អីគេហ្នឹងស្អុយម្ល៉េះ អួកកក!!!»

«ស្អីគេ! បងប្រើក្លិននេះមកយូរហើយ ហេតុអីក៏អូនទើបតែមកស្អុយវានៅពេលនេះទៅវិញ»

«មិនដឹងទេ! ចុះបើអូនស្អុយនោះណា បងទៅឲ្យឆ្ងាយបន្តិចទៅ អូនក្អួតឥឡូវហើយណា!!»

«ឲ្យបងទៅឲ្យឆ្ងាយដោយរបៀបណាដែរទៅ បើអូនកំពុងតែមិនសូវស្រួលខ្លួនហ្នឹងណា»

«អូនមិនមែនមិនស្រួលខ្លួនទេ គ្រាន់តែចង់ក្អួតព្រោះស្អុយក្លិនបងនោះណា!!»

រំពេចនោះកំហុសក៏ធ្លាក់មកលើស្វាមីរបស់នាងទៀតដដែល នាងមិនមែនគ្រាន់តែស្អុយក្លិនទឹកអប់របស់គេប៉ុណ្ណោះនោះទេ គឺនាងស្អុយអ្វីៗគ្រប់យ៉ាងដែលនៅក្បែរៗនាងនោះទៀតផង។

រំពេចនោះគេក៏នឹកឃើញភ្លាមថា ឬក៏ចាញ់កូន!! មែនហ្នឹងណាព្រោះថាប្រចាំខែរបស់នាងមិនមកប៉ុន្មានជាពីរបីខែហើយដែរ នេះនាងកំពុងតែមានកូនឬ? រំពេចនោះសំឡេងដែលសម្តែងភាពសប្បាយចិត្តបែរជាសំឡេងរបស់ស្វាមីនាងបញ្ចេញឡើងមុននាងទៅវិញ។

«អូនមានកូនមែនទេ? អូនចាញ់កូនមែនទេ?»

ទោះបីជាគេជាមនុស្សប្រុសក៏ដោយ តែគេក៏ដឹងខ្លះៗដែរចំពោះមនុស្សស្រីដែលមានអាការចាញ់កូនតាមសញ្ញាផ្សេងៗមួយចំនួន គេមានអារម្មណ៍សប្បាយចិត្តជាទីបំផុតដែលនឹងក្លាយជាឪពុកគេ។

«អូនកំពុងតែមានកូនឬ ឈិត!»

«ត្រូវហើយ ត្រូវហើយ!! អូនកំពុងតែមានកូន កូនរបស់យើងនោះអីហាន់ណា!!»

«បងដឹងដោយរបៀបណាទៅ បងធ្លាប់មានកូនឬ មានកូនជាមួយអ្នកណាគេ!!!»

«ហឺមមម!! កុំទម្លាក់កំហុសឲ្យបងបានទេ សម័យនេះទៅហើយអ្នកណាៗក៏គេរៀនចេះដឹងរឿងបែបនេះបានគ្រប់តែគ្នាហ្នឹងណា»

ឈិតទាញភរិយារបស់គេចូលមកឱបក្រសោបដោយអារម្មណ៍សប្បាយចិត្តជាខ្លាំង សមតាមបំណងគេហើយណា គេទន្ទឹងរង់ចាំពេលនេះជាយូរមកហើយ មិនឥតប្រយោជន៍ទេណាដែលគេខំប្រឹងធ្វើសកម្មភាពលើគ្រែញឹកញាប់នោះណា។ និយាយចប់បុរសសង្ហាក៏ប្រញាប់បើកឡានទៅកាន់សេតវិមានរបស់គេវិញ។

«បើកឡានឲ្យលឿនទៅមើស ឈិត បើកដូចអណ្ដើកភរអីចឹង»

«ចុះបើអូនកំពុងតែមានផ្ទៃពោះផងនោះណា ខ្លាចកូនយើងរន្ធត់!!»

«រន្ធត់អីគេទៅ បើកយឺតៗបែបនេះធ្វើឲ្យអូនអារម្មណ៍មិនល្អ ណាដឹងទេ!!»

មានអារម្មណ៍ទាស់ចិត្តមែនទែនតែម្ដង ជាធម្មតាប្ដីនាងចូលចិត្តណាស់ភាពលឿនរហូតដល់ថ្នាក់នាងហាមយ៉ាងណាក៏គេមិនស្ដាប់ដែរ តើគេគិតអីទៅ! ហើយសំឡេងដែលសម្ដែងពីអារម្មណ៍ពុះកញ្ជ្រោលរបស់គេដែលជាឪពុកក៏លាន់ឮឡើងភ្លាមតាមផ្លូវរហូតនោះ។

«ចាំបងហៅគ្រូពេទ្យប្រចាំត្រកូលរបស់យើង មកត្រួតពិនិត្យផ្ទៃពោះរបស់អូនណា!! អូនហាមហាត់ប្រាណក្នុងកំឡុងពេលមានផ្ទៃពោះបែបនេះណា



ត្រូវតែគេងឲ្យបានច្រើនបន្តិច...អ!! បងប្រហែលជាហៅជាងឲ្យមកធ្វើបន្ទប់ទារកឲ្យហើយណា ហើយចង់ញ៉ាំអីជាពិសេសដែរទេ បងនឹងចុចទៅប្រាប់ចុងភៅឲ្យធ្វើទុកឲ្យណា យ៉ាងម៉េចដែរ ចង់ញ៉ាំអីដែរ?»

«អូនមិនចង់ញ៉ាំអីទាំងអស់ណា គ្រាន់តែនិយាយចង់ក្អួតទៅហើយ»

«មិនបានទេណា ក្រៅពីញ៉ាំអាហារឲ្យគ្រប់គ្រាន់ហើយ អូនត្រូវតែធ្វើចិត្តឲ្យស្ងប់ផងដែរណា មើលតែអ្វីស្អាតៗ ល្អៗ អូនចូលចិត្តផ្កាមែនទេ ចាំបងកុម្ម៉ង់ផ្កាកុលាបមកដាំបន្ថែមបួនប្រាំឡានទៀតយ៉ាងម៉េចដែរ!»

ភរិយាដែលកំពុងតែមានផ្ទៃពោះថ្មីៗកើតមានអារម្មណ៍ពិបាកចិត្តចំពោះស្វាមីដែលគេអរពេកចំពោះការមានកូនជាលើកដំបូងនោះ ធ្វើឲ្យគេក្លាយជាមនុស្សដែលនិយាយច្រើនជាងនាងទៅវិញ។ នាងសម្រេចចិត្តកាច់ពួកឡានហើយបិទភ្នែកគេងវិញប្រសើរជាងការមើលឡានបើកភរដូចសត្វអណ្ដើកអីចឹងទេ ហឺមមម!!! យ៉ាងហោចណាស់ក៏អាចធ្វើឲ្យនាងមិនស្ទូវគិតរឿង យ៉ុនហ៊ីបានខ្លះដែរនោះណា។

ទោះបីជាមានភាពសប្បាយចិត្តខ្លាំងកើតឡើងក៏ដោយ នៅឯសេតវិមានរបស់បុរសម្នាក់ដែលនឹងក្លាយជាឪពុកក្មេង គេអត់ទ្រាំមើលភរិយាគេដែលមួយថ្ងៃៗគិតតែពីចុចទូរស័ព្ទមិនបានដែលនាងដឹងច្បាស់ទៅហើយថា មិនអាចទាក់ទង យ៉ុនហ៊ី បាននោះណា ហើយអ្វីដែលសំខាន់ គេពិតជាមិនចង់ឲ្យភរិយារបស់គេគិតច្រើននៅពេលនេះនោះអី ព្រោះនាងកំពុងតែមានផ្ទៃពោះ។ រំពេចនោះសំឡេងរបស់ប្ដីគេក៏បានលាន់ឮឡើង។

«ហាន់ណា កុំធ្វើមុខពិបាកចិត្ត គិតច្រើនបែបហ្នឹងទៅមើស!»

«ចុះបងគិតទៅមើស! ទាក់ទងទៅ យ៉ុនហ៊ី មិនបានទាល់តែសោះហើយទៀត!!»

«វាមិនមានអីនោះទេណា បើសិនជាមានអី ឈិតខាមែន ប្រហែលជាផ្ដល់ព័ត៌មានមកយើងហើយណា»

«បងចាំឲ្យវាកើតមានអីមុនឬយ៉ាងណាហ្នឹង!!!»

សំឡេងនិយាយឡើងយ៉ាងទាស់ចិត្ត នាងចង់ឲ្យគេបើកឡានទៅទីនោះ តែស្វាមីក្មេងក្លាងរបស់នាងបែរជារករឿងនេះអាងនោះមិនចេះចប់ កាលពីមុនវិញទៅចុះទឹកចូលភ្លើងឯណាក៏ទៅដែរមិនរុញរាទេ។ និយាយចប់ស្រីស្រស់ក៏ចាប់ផ្ដើមចុចទូរស័ព្ទបន្ត

«អូនកំពុងតែមានផ្ទៃពោះណា កុំក្ដៅក្រហាយទៅមើល តិចកូនកើតមកមុខក្រញ៉ូវទៅណា!!»

នាងមិនព្រមស្ដាប់សម្ដីទាំងឡាយនោះរបស់ស្វាមីនាងឡើយ នាងនៅតែព្យាយាមចុចទូរស័ព្ទមិនព្រមឈប់ឡើយ ព្រមទាំងគិតថា មិត្តភក្ដិរបស់នាងប្រាកដជាមានបញ្ហាអ្វីជាក់ជាមិនខានទេ នាងអាចកំពុងតែរង់ចាំជំនួយក៏ថាបានដែរណា ហើយសំឡេងដែលបារម្ភនោះក៏លាន់ឮឡើងជាថ្មី។

«អូនឈប់សិនបានដែរទេ ចាំបងបើកកម្មវិធីទូរទស្សន៍រឿងកំប្លែងៗឲ្យមើលណា»

«រឿងកំប្លែងអីគេដែរទៅ កំពុងតែបារម្ភមិត្តភក្ដិ អូនមិនមានអារម្មណ៍អីទៅមើលវានោះទេ!»

«តែបងចង់ឲ្យអូនរំសាយអារម្មណ៍ខ្លះនោះអី»

«ម៉េច!! អ្នកមានផ្ទៃពោះត្រូវតែសើចរហូតមែនដែរទេ!!!»

«បើធ្វើបែបហ្នឹងបានវាក៏ល្អហើយណា»

«ឈ៉ឺស!!! កូនអូនកើតមកសើចរហូត ក្លាយជាមនុស្សវិកលចរិតអីងាប់បណ្ដោយ»

«នែ!! ហេតុអីក៏អូនឌឺម្ល៉េះទេនៀក!!»

«ទៀតហើយណា! ទៀតហើយ!! បងថាអូនឌឺទៀតហើយ!!»

«អូ!! និយាយជាស់តឿនក៏មិនបានដែរ បងមិនដឹងជាធ្វើយ៉ាងម៉េចចំពោះអូនល្អទេនៀក!!»

ហាន់ណា មិនចាប់អារម្មណ៍លើស្វាមីរបស់នាងដែលបារម្ភលើរូបនាងហួសហេតុនោះឡើយ នាងបែរបៀងទៅឲ្យឆ្ងាយពីសំឡេងរបស់ស្វាមី ព្រមទាំង



គិតថា រូបគេនោះហើយជាអ្នកធ្វើឲ្យនាងខ្វល់ខ្វាយចិត្ត។

នៅពេលដែលមានស្មារតីឡើងវិញ ដៃមួយអត់ទ្រាំមិនអង្អែលពោះនាងព្រមទាំងបើបវាមិនបាន ដៃមួយចំហៀងទៀតក៏អត់ទ្រាំមិនចុចទូរស័ព្ទទៀតមិនបានដូចគ្នាដែរ នាងហាក់បីដូចជាមានអារម្មណ៍ឃ្លានឡើង ទើបដឹងថា តាំងពីព្រឹកមកនាងមិនបានញ៉ាំអីទាល់តែសោះឡើយ ស្រីស្រស់នឹកដល់កូនក្នុងផ្ទៃទើបរអ៊ូរទាំចេញមក។

«កូន!!! ម៉ាក់ចុចទូរស័ព្ទរកមីង យ៉ុនហ៊ី កូនសិនណា ចាំយើងនាំគ្នាទៅញ៉ាំអីណាកូន!!»

នាងបានចុចទូរស័ព្ទម្ដងទៀត ព្រមទាំងគិតថា បើសិនជានៅតែមិនចូលទៀត នេះជាលើកចុងក្រោយហើយណា មុននឹងនាងទៅរកអីមកញ៉ាំ ហើយរំពេចនោះនាងក៏សប្បាយចិត្តយ៉ាងខ្លាំង ហាក់ផងលោតផង នៅពេលដែលចុចចូលល្អម។

«យេៗ!!! **ចុចចូលហើយណា ឈីត!!!**»

«អូន!! អូន កុំហាក បងប្រាប់ថាកុំហកណា!!!»

ឈីត រត់ចូលមកត្រកងដោយអារម្មណ៍ហួងហែងភរិយា តើគេនឹងធ្វើយ៉ាងណាចំពោះភរិយាម្នាក់នេះដែរទៅហ្ន៎!!! នេះបើសិនជាគេអាចពពោះដោយខ្លួនគេបាន គេនឹងពពោះវាតែម្ដងហើយនៀក ឈីត គិតព្រមទាំងដកដង្ហើមធំៗ ហើយគេក៏នៅប្រុងប្រយ័ត្ននៅក្បែរៗ កាយភរិយាគេនោះឯង មិនព្រមឃ្លាតទៅណាឆ្ងាយឡើយ ស្ដាប់នាងនិយាយទូរស័ព្ទសំឡេងឡើងស្រួយខ្លោក។

«យ៉ុនហ៊ី!! ហេយៗ យ៉ុនហ៊ី!!!»

ហាន់ណា ស្រែកហៅឈ្មោះមិត្តភក្ដិនាងយ៉ាងសប្បាយចិត្ត មិនខុសគ្នាអីជាមួយនឹងអ្នកដែលលើកទូរស័ព្ទនោះឡើយ ទឹកដមសំឡេង សប្បាយចិត្តមិនខុសពី ហាន់ណា ដែរទេដែលសុខៗមិត្តនាងក៏ទាក់ទងមក។

[ហាន់ណា!! ឯងទេ!!! យើងសប្បាយចិត្តណាស់ណា ដែលឯងចុចមក]

«យើងបារម្ភពីឯងណាស់ឯងមានដឹងដែរទេ ហើយនេះឯងរួចរាល់ហើយមែនទេ»

យ៉ុនហ៊ី មានអារម្មណ៍ចម្លែកចិត្តមែនទែនដែលមិត្តភក្តិរបស់នាងដឹងថានាងបានក្លាយជារបស់ ឈីតខាមែន នោះណា។

[យើង!! យើង!!]

«ស្អីគេឯងដែរទៅ យ៉ុនហ៊ី ការងាររបាយការណ៍រួចហើយ ឯងត្រឡប់មកវិញមកណា»

[អ៎!! របាយការណ៍ទេឬ?]

«ត្រូវហើយណា ឬឯងបានទៅធ្វើអី ទើបបានជាមិនអាចទាក់ទងបានទាល់តែសោះនោះ ប្រាប់យើងភ្លាមមក!!»

[គឺ...គឺ...គឺយើង យើងមិនដឹងជាត្រូវនិយាយយ៉ាងម៉េចចំពោះឯងទៀត]

«ឯងត្រូវតែនិយាយតាមការពិតមកនោះអី ហើយពេលណាឯងត្រឡប់មកវិញដែរទៅ ធ្វើរបាយការណ៍រួចរាល់ហើយឯងត្រឡប់មកវិញភ្លាមមកណា»

យ៉ុនហ៊ី ខ្លួនឯងក៏ចង់និយាយពីគាក្យាជាមួយមិត្តសម្លាញ់របស់នាងដូចគ្នាដែរ ចំពោះអំណាចអាថ៌កំបាំងមួយនោះ ដែលមិនដឹងថា វានឹងអាចកើតមានអីទៀតចំពោះនាងនោះឡើយ។ តើនាងចាប់ផ្ដើមនិយាយយ៉ាងណាទើបល្អទៅបើនៅសុខៗ មិត្តនាងក៏ចុចមករកដោយមិនបានត្រៀមខ្លួនមុនសោះនោះអី ហើយនាងក៏ទើបតែបានឆ្លងកាត់ហេតុការណ៍ កាលពីយប់មិញនេះមកដែរ ខួរក្បាលនាងប្រាកដជាស្ពឹកជារឿងធម្មតានោះឯង។

[រឿងវាវែងឆ្ងាយណាស់ ហាន់ណា យើងពិតជាចង់ឲ្យឯងមករកយើងនៅឯសេតវិមានរបស់ ឈីតខាមែន មែនទែនទៀត]

«យើងព្យាយាមទៅកាន់ទីនោះដែរណា តែផ្លូវបានដាច់អស់រលីង ហើយពេលនេះមានព្រិលធ្លាក់ទៀតនោះណា ប្រហែលជាទៅរកឯងមិនបានទេណា ហើយឯងសុខសប្បាយតើសអី!!»



[យើងសុខតើស តែ...]

«តែស្អីគេទៀតទៅ/ក្រៅឯងសុខសប្បាយហើយតើស បើសិនជាឯងមានការអីចាំយប់នេះយើងចុចរកឯងម្ដងទៀតណា នែ!! ឯងដឹងដែរទេថាស្វាមីរបស់យើងសម្លឹងមើលមិនប៉ប្រិចភ្នែកសោះនោះ ចាំនិយាយគ្នាទៀតណាពួកម៉ាក»

សម្ដីចុងក្រោយនេះ នាងនិយាយជាមួយមិត្តនាងជាភាសារបស់នាង ព្រមទាំងយកដៃបាំងមាត់ទៀតផងហើយបែរទៅមើលមុខប្ដីមួយភ្លែតហើយក៏និយាយបន្ត៖

«ឈីត តាមយើងជាប់មិនព្រមទៅណាសោះហើយនៀក!!»

[ហាស់!!! នេះឯងចង់ប្រាប់យើងថា ឯង និងគេសម្ដែងសកម្មភាពលើគ្រែទាំងយប់ទាំងថ្ងៃអីចឹងឬ?]

«ឆ្កួតទេអី!! ឡប់!! ចាំយើងចុចទៅម្ដងទៀតណា ចាំទទួលខុសត្រូវយើងផងកុំភ្លេចឲ្យសោះណា!!»

[បាន បាន ចាំយើងលើកណា]

ហាន់ណា សើចសប្បាយចិត្តហាក់បីដូចជាក្ដីទុក្ខបានឆ្លងផុតយ៉ាងអីចឹងហើយបែរមកញញឹមដាក់ស្វាមីជាទីស្រឡាញ់របស់នាងដែលឈរនៅក្បែរនោះមិនព្រមដើរចេញទៅណាសោះ គេប្រហែលជាដឹងថាត្រូវភរិយានិយាយដើមហើយ។

«បងខ្ញុំឃ្លានណាស់នៀក!»

«តាំងពីព្រឹកមកអូនបានញ៉ាំអីខ្លះហើយនៅ?»

«នៅហ្នឹងណា!»

«អូយស្លាប់ហើយ!! បងឲ្យចុងភៅធ្វើម្ហូបឡើងច្រើននោះណា ហេតុអីក៏អូនមិនព្រមញ៉ាំដែរទៅហាស់!!»

«ចុះបើអូនមិនដឹងជាត្រូវញ៉ាំអាមួយណាមុននោះណា ម្ហូបច្រើនសឹងអី»

រំពេចនោះភរិយាឆ្លាតវៃដូចជានាងប្រញាប់បង្វែររឿង ដើម្បីកុំឲ្យស្វាមី

នាងខឹងភ្លាមតែម្តង។

«បងដឹងដែរទេថា យ៉ុនហ៊ី ពិតជាកាសិខ្លស់ណាស់ ចុះក្រែងបងប្រាប់អូនថាមនុស្សស្រីទាំងអស់ដែលនៅក្បែរ ឈិតខាមែន ត្រូវតែបញ្ចប់ជីវិតគ្រប់ៗគ្នានោះអី!!»

«ចុះបើវាពិតមែនហ្នឹងណា»

«យីស!!! អីចឹងមានន័យថា មិត្តភក្តិអូនពិតជាកាសិខ្លស់មែននោះណា បើអីចឹងក៏មិនព្រមប្រាប់ ធ្វើឲ្យអូនឯនេះបារម្ភស៊ឹងអីទៅហើយ!!»

ឈិត ចាប់ផ្តើមគិតឡើងភ្លាមតាមដែលភរិយាគេនិយាយ បើសិនជាបែបហ្នឹងពិតមែន ប្រាកដជាមានរឿងអីមួយដែលធ្វើឲ្យពីរនាក់នោះមានជោគជតាដូចគ្នាហើយមើលទៅនោះ។ ទោះបីជាមានអារម្មណ៍ចម្លែកចិត្ត តែគេក៏អត់ទ្រាំមិនសប្បាយចិត្តចំពោះរឿងនោះជំនួសភរិយាគេមិនបានដូចគ្នាដែរ។

«ល្អហើយដែលនាងមានសុវត្ថិភាពណា អូនក៏មិនត្រូវបារម្ភច្រើនអីទៀតនោះដែរណា!»

«អឺមមម!! ប្លែកមែនទែនដែលនៅសុខៗក៏អាចចុចទាក់ទងជាមួយ យ៉ុនហ៊ី បាន»

«ហើយចុះអូនចាំបាច់គិតឲ្យពិបាកទៀតធ្វើអីទៅ»

«ហាកកក ឈិត!! អូនមិនមែនជាមនុស្សខួរបង្គងនោះឯណា ដែលមិនចេះគិតអីទាល់តែសោះនោះ»

«ណ្ហើយចុះ!! ណ្ហើយចុះ!! យ៉ាងណាក៏យ៉ាងណាទៅ តែនៅពេលនេះអូនគួរតែញ៉ាំអាហារនេះឲ្យអស់ណាអូនសម្លាញ់»

«អស់ទាំងអស់នេះឬ?»

«ត្រូវហើយណា! បើមិនអីចឹងទេបងនឹងមិនព្រមឲ្យអូនងើបទៅណាជាដាច់ខាត»

ហាន់ណា សម្លឹងមើលមុខម៉ឹងម៉ាត់របស់ស្វាមីជាទីស្រឡាញ់របស់នាង នេះគេយល់ថា នាងជាទាសកររបស់គេឬយ៉ាងណានៀកដែលបង្ខំឲ្យនាងញ៉ាំ



អាហារឲ្យអស់ទាំងអស់នេះនោះ វាមិនតិចទេ គ្មាននរណាញ៉ាំវាអស់ទេ តែនៅពេលដែលនាងក្រឡេកទៅប៉ះកែវភ្នែកមុតនោះ ទើបនាងព្យាយាមលេបអាហារទាំងនោះចូលយ៉ាងញាប់មាត់។ រយៈពេលមួយថ្ងៃមួយយប់តើនាងញ៉ាំអាហារដែលនៅលើតុនេះអស់ឬអត់ទេនៀក ហឹមមម!!!

**ឈិតខាមែន លើកយកសៀវភៅចាស់ដែលនៅលើតុនោះឡើងមក។** សៀវភៅនេះជាតម្រារបស់បិតាគេកាលពីគាត់នៅមានជីវិតគេបើកចុះបើកឡើង ហើយព្យាយាមអានតួអក្សរ ដែលសរសេរជាភាសា អ៊ីស្លាម ដែលគេអាចយល់បានខ្លះៗដែរ តែគឺវាមិនបានជាជ្រៅជ្រះប៉ុន្មានឡើយ ព្រមទាំងនឹកដល់ផ្ទៃមុខរបស់ព្រះនាង ទេមីន ដែលមានកែវភ្នែកពណ៌ក្រហមមើលទៅគួរឲ្យខ្លាច ទើបមានអារម្មណ៍ខ្វល់ខ្វាយចិត្តភ្លាម ព្រមទាំងគិតថា វាបានបញ្ជាក់ពីហេតុការណ៍អាក្រក់ហើយមើលទៅនោះ គេត្រូវតែស្វែងរក ព្រមទាំងបញ្ឈប់សកម្មភាពអាក្រក់ៗដែលព្រះនាង ទេមីន ធ្វើមកលើ យ៉ុនហ៊ី ឲ្យទាល់តែបាន។ រំពេចនោះគេក៏ឈប់គិតនៅពេលសំឡេងគោះទ្វារបានលាន់ឮឡើង ព្រមជាមួយនឹងរាងស្តើងបានដើរចូលមក។

«គឺនាងទេ យ៉ុនហ៊ី»

«ហេតុអីក៏នៅក្នុងសារមន្ទីរត្រូវចាក់សោរជាប់អីចឹង!»

គេដាក់សៀវភៅមួយក្បាលនោះចុះព្រមទាំងក្រោកដើរទៅក្រសោបភរិយាថ្មីថ្មោងរបស់គេចូលមកខាងក្នុង ហើយក៏ផ្តើមជំទើបថ្ពាល់ដ៏ស្រស់ស្អាតរបស់នាងមួយខ្សឹត គេក៏អត់ទ្រាំមិនញញឹមមិនបាននៅពេលឃើញនាងមុខក្រហមដោយភាពអៀនខ្មាស។

«ខ្ញុំបានចាក់សោនោះណា ខ្ញុំក៏ភ្លេចប្រាប់នាងទៅ!»

«ហេតុអីក៏ចាំបាច់ចាក់វាធ្វើអីដែរទៅ?»

«ខ្ញុំដូចជាមានអារម្មណ៍ថា នឹងមានអីកើតឡើងបន្ទាប់ពីនេះនោះណា»

«វាទាក់ទងជាមួយនឹងព្រះនាង ទេមីន មែនដែរទេ?»

«ត្រូវហើយ ការដែលយើងនាំគ្នាចូលទៅប៉ះពាល់របស់របររបស់ព្រះនាង វាអាចនាំឲ្យក្រសែចិត្តរបស់ព្រះនាងរឹងមាំឡើងនោះអី»

«លោកគិតថា នឹងកើតមាននូវហេតុការណ៍អាក្រក់ឡើងឬ?»

«ញាណរបស់ខ្ញុំវាប្រាប់បែបហ្នឹងណា»

«បើពិតដូចលោកគិតមែន តើយើងគួរតែធ្វើយ៉ាងណាដែរទៅ?»

«មិនចាំបាច់ខ្លាចនោះទេណា យ៉ាងណាក៏ខ្ញុំមានផ្លូវដោះស្រាយដែរ»

ឈីតខាមែន ឱបប្រាណនាងយ៉ាងណែន ដៃរបស់គេអង្អែលសក់វែងរបស់នាង គេក៏កំពុងតែរកវិធីដោះស្រាយដែរ។ រំពេចនោះគេក៏ក្រាប្រាណនាងទៅកាន់តុដែលគេបានដាក់សៀវភៅនៅលើនោះផងដែរ។

«ខ្ញុំកំពុងតែស្វែងយល់ភាសាអ៊ីស្លាមហ្នឹងណា»

«ភាសាអ៊ីស្លាម! ប្រហែលជាខ្ញុំអាចជួយលោកបានច្រើនដែរណា»

«នាងចេះភាសាអ៊ីស្លាមនេះដែរ?»

«លោកភ្លេចហើយថា ភាសានេះកំពុងស្ថិតក្នុងលក្ខខណ្ឌមួយនៃការរៀនភាសាអារ៉ាប់របស់ខ្ញុំនោះណា»

«មែនហ្នឹងណា ខ្ញុំភ្លេចឲ្យឈឹងតែម្តងហើយនៀក!»

ពួកគេញញឹមដាក់គ្នា ព្រោះសប្បាយចិត្តនៅពេលដែលអាចធ្វើអ្វីរួមគ្នាបាន ឈីតខាមែន បើកសៀវភៅដែលគេគិតថា នឹងអាចឲ្យពួកគេរួចផុតពីអំណាចអាថ៌កំបាំងមួយនេះ ហើយចង្អុលទៅកាន់ប្រយោគមួយដែលគេបានគូសបន្ទាត់ពីខាងក្រោម។

«នាងសាកមើលទៅ ប្រយោគមួយនេះគេមានន័យថាយ៉ាងណាដែរទៅ?»

ស្រីស្រស់មើលទៅកាន់ប្រយោគមួយ ដែលមានគូសបន្ទាត់ពីខាងក្រោមនោះភ្លាម រួចប្រកបតួអក្សរព្រមទាំងបកប្រែមកជាអត្ថន័យថា៖

«បរិសុទ្ធ...កាន់សីល...ជីវិតដែលបរិសុទ្ធ...មនុស្សប្រុសស្រីដែលមានសិទ្ធិក្នុងមន្តគាថាអាថ៌កំបាំងនេះបាន...មានន័យថាយ៉ាងម៉េចដែរទៅ?»



«ខ្ញុំគិតថា ពាក្យថា កាន់សីល គឺជាបុគ្គលដែលកាន់សីលយ៉ាងខ្ជាប់ខ្ជួនក្នុងសាសនាណាមួយក៏បានដែរ គឺគេនោះអាចជួយយើងបានណា»

«ហើយចំណែកឯពាក្យថាកាន់សីលដែលលោកនិយាយនោះដូចគ្នានឹងពាក្យថា ជីវិតបរិសុទ្ធឬអត់ដែរទៅ»

«ជីវិតបរិសុទ្ធដែលខ្ញុំគិតនោះ គឺជាបុគ្គលមិនដែលធ្វើបាបអ្វីសោះ»

«តើពីរចំណុចនេះឬដែលអាចជួយយើងឲ្យរួចផុតពីអំណាចដ៏អាថ៌កំបាំងនេះបាននោះ?»

«ពេលនេះខ្ញុំគិតអ៊ីចឹង ចុះនាងវិញពេលអានវាហើយគិតថាយ៉ាងម៉េចដែរទៅ?»

«ខ្ញុំក៏គិតដូចលោកដែរនោះណា»

ទោះបីជាមានការគិតស្របគ្នាជាមួយគេយ៉ាងណាក៏ដោយចុះ តែអ្វីទាំងពីរចំណុចនេះនៅត្រង់ចំណុចណានៃពិភពលោកដែរទៅ នេះហើយជាអ្វីដែលនាងពិបាកចិត្តនោះណា។

«តើវាអាចមានដែរឬ អ្នកដែលកាន់សីលយ៉ាងខ្ជាប់ខ្ជួននោះត្រូវតែជាបុគ្គលដែលញ៉ាំតែបួសជាតិ ត្រូវតែប្រព្រឹត្តខ្លួនមិនឲ្យប៉ះពាល់ដល់អ្វីដែលមានជីវិតនៅលើលោក ហើយចុះជីវិតបរិសុទ្ធវិញនោះ?»

«មិនអីទេណា ខ្ញុំជឿជាក់ថា ប្រាកដជាមានពីរចំណុចនេះនៅលើលោកប្រាកដហើយណា»

«ចាស ពេលណាដែរទៅ! ហើយនៅទីណា!»

«ខ្ញុំក៏មិនដឹងដែរហ្នឹងណា គ្រាន់តែខ្ញុំគិតថា វាប្រាកដជាមាន យើងនឹងអាចជួបពីរចំណុចនេះនៅថ្ងៃណាមួយ»

យ៉ុនហ៊ី អត់ទ្រាំមិនគិតមិនបានថា ទេវតាលេងល្បែងអីធ្វើបាបនាងដែរទៅ នាងជាមនុស្សដែលខ្លាចពពួកខ្មោច ព្រាយបិសាចអីនោះខ្លាំងណាស់ តែបែរជាត្រូវមកប្រឈមមុខជាមួយនឹងអ្វីដែលនាងខ្លាចនេះ ដោយមិនអាចជៀសផុតបានសោះឡើយ។ ពេលនេះនាងមានអារម្មណ៍ថា ទទួលនូវការប៉ះដំទង់ខ្លាំង

ពីស្វាមីថ្មីថ្មោងដែលនៅក្បែរនាងនេះ ទើបនាងសម្រេចចិត្តអង្គុយស្តាប់គេបន្ត។

«ខ្ញុំគិតថា ប្រាកដជាអាចមានអ្នកណាម្នាក់ដែលនៅជុំវិញខ្លួនយើងនេះ អាចជួយយើងបានជាក់ជាមិនខានណា យ៉ុនហ៊ី ជាក្រសែចិត្តរបស់ព្រះនាង គ្រាន់តែជាអ្វីកំបាំងភ្នែកតែប៉ុណ្ណោះ ហើយបើគ្រាន់តែយើងមានចិត្តរឹងមាំអំណាចពិសពុលនេះនឹងមិនអាចធ្វើអ្វីយើងបាននោះឡើយ តែបើសិនជាយើងទន់ជ្រាយ វាប្រាកដជាមករុករានយើងបានជាក់ជាមិនខាន»

«ខ្ញុំនៅតែមិនយល់ដដែលហ្នឹងណា»

«ចាប់ពីពេលនេះតទៅយើងកុំនៅឆ្ងាយគ្នាជាដាច់ខាត ហើយនាងក៏នៅចាំសង្កេតថា មានអ្វីដែលចម្លែកៗល្អៗខ្លះដែលបានជួបប្រទះក្នុងរយៈពេលនេះ»

«អ្វីប្លែកៗក្នុងផ្លូវល្អដែលជួបឬ ?»

«ត្រូវហើយយើងត្រូវតែព្យាយាមសង្កេតណា វាអាចមាននៅក្បែរខ្លួនយើងដែលយើងមិនអាចគិតដល់»

យ៉ុនហ៊ី គិតបានភ្លាមថា រាងប្លែកៗដំបូងគេនោះគឺ ហាន់ណា អាចទាក់ទងមករកនាងបាន ដែលកាលពីលើកមុនៗនោះនាងព្យាយាមចុចដែរតែចុចមិនចូលសោះ។

«លោកថាវាប្លែកដែរទេ ថានៅស្រាប់តែៗ ហាន់ណា អាចទាក់ទងមកខ្ញុំបាន»

«វាប្លែកត្រង់ណាដែរទៅ ?»

«លោកភ្លេចហើយថា កាលពីលើកមុននោះខ្ញុំបានព្យាយាមចុចទៅរកហាន់ណា តែក្រសែចិត្តរបស់ព្រះនាង ទេមិន បានធ្វើបាបខ្ញុំស្ទើរតែក្លាយជាមនុស្សឆ្កួតហើយនោះអី»

«ហឹមមម!!! មែនហ្នឹងណា តើគួរធ្វើយ៉ាងណាបន្តទៀតទៅ»

«គឺថា ហាន់ណា អាចជួយយើងបាននោះណា»

«មិត្តភក្តិរបស់នាងកាន់សីលយ៉ាងខ្ជាប់ខ្ជួនឬ ?»



យ៉ុនហ៊ី ឈប់ស្ងៀមព្រមទាំងគិតឡើងភ្លាម មិត្តនាងនោះដែលអាចកាន់សីលខ្ជាប់ខ្ជួន គ្រាន់តែស្គាល់តាមមិនដឹងជាសូត្រត្រូវឬក៏អត់ផងនោះណា។ ហើយតាំងពីបានស្វាមីសង្ហាទាក់ទាញចិត្តផងនោះ មានអារម្មណ៍ថា នាងគិតតែពីរឿងកាមារម្មណ៍ផងនោះណា។

«យ៉ាងម៉េចដែរ មិត្តនាងកាន់សីលទេ ?»

«គឺចំណុចនេះហ្នឹងឯងណា ដែលខ្ញុំបារម្ភពីនាងនោះ»

ឈើតខាមែន ពិគ្រោះហេតុការណ៍ដែលកើតឡើងតាមដែលភរិយាគេនិយាយ ហើយក៏យល់ស្របជាមួយនឹងគំនិតនោះផងដែរ។

«តែវាក៏ប្លែកដូចដែលនាងនិយាយមែននោះណា ដែលនៅស្រាប់តែៗមិត្តនាងក៏អាចចុចទាក់ទងបាន»

«ឯណាមើល ខ្ញុំសុំមើលតម្រាភាសាអ៊ីស្លាមនោះបន្តិច ដើម្បីថាអាចមានគុណសម្បត្តិណាដែលអាចត្រូវជាមួយនឹងមិត្តភក្តិខ្ញុំខ្លះ»

យ៉ុនហ៊ី គិតថាវាអាចមានគុណសម្បត្តិអីផ្សេងៗដូចជា ភាពស្រស់ស្អាតជាតារា ស្វាមីសង្ហា ចរិតឆ្លូតតិចៗ ឬប្រភេទស៊ិចស៊ីខ្លាំង ហ្នឹងហើយជាគុណសម្បត្តិរបស់ ហាន់ណា នោះណា។

«ហឹមមម!! វាមានតែពីរចំណុចដែលលោកនិយាយនោះណា»

ចុងក្រោយ យ៉ុនហ៊ី ក៏អាចសរុបពីគុណសម្បត្តិរបស់មនុស្សដែលអាចឲ្យពួកគេរួចផុតពីបួងមន្តគ្រានោះបាន។ នៅពេលដែលកែវភ្នែកកំពុងតែអានតួអក្សរជាភាសាអ៊ីស្លាមនោះ នាងក៏បានទាក់ភ្នែកចំពោះប្រយោគមួយដែលគេសរសេរ។

«ឈើតខាមែន!! លោកមើលនេះទៅមើល!»

«ប្រយោគអីគេទៅ»

**"នុះនោះអីណា!! ក្រសែចិត្តរបស់អ៊ីស្លាម បានជួយជីវិតបរិសុទ្ធ ណែយឥទ្ធិពលអាថ៌កំបាំង"**

ឈើតខាមែន ចាំស្តាប់ស្រីស្រស់អានប្រយោគមួយប្រយោគ ដែលអាច

រំដោះចេញពីអំណាចអាថ៌កំបាំងនោះ គេខ្លួនឯងក៏អានប្រយោគនេះមករាប់ផងមិនអស់ទៅហើយតែនៅតែមិនអាចយល់ពីអត្ថន័យបានទាល់តែសោះ។

«នាងគិតយ៉ាងណាដែរ?»

«ក្រសែចិត្តរបស់អ៊ីស្លាមដែលមានឥទ្ធិពលអាថ៌កំបាំង ក្រសែចិត្តនោះវាទាក់ទងជាមួយនឹងគ្រឿងប្រដាប់ និងរបស់របរប្រើប្រាស់ របស់ព្រះនាង ទេមិនចំណែកឯជនជាតិអ៊ីស្លាមវិញនោះ...»

យ៉ុនហ៊ី ទន្ទេញប្រយោគនោះដដែលៗ ព្រមទាំងដើរចុះដើរឡើងគិតពីអត្ថន័យ ហើយពេលនោះនាងក៏បាននឹកឃើញនូវអ្វីម៉្យាងឡើង។

«ខ្ញុំនឹងឃើញហើយណា ឈីតខាមែន»

«នាងបាននឹកឃើញអីមែនដែរទេ?»

ឈីតខាមែន ដាក់ភ្នែកពីសៀវភៅមួយក្បាលនោះ កែវភ្នែករបស់គេក៏បានក្រឡេកឃើញស្រីស្រស់សប្បាយចិត្តជាខ្លាំង ចំពោះអ្វីដែលនាងបាននឹកឃើញនោះ គេគិតថានាងច្បាស់ជានឹកឃើញពីអ្វីមួយ។

«មនុស្សស្រីជនជាតិអ៊ីស្លាមតែលតោលម្នាក់នោះ ប្រាកដជាមានអីពាក់ព័ន្ធជាមួយនឹងរឿងរ៉ាវនេះប្រាកដហើយណា»

«មនុស្សស្រីដែលបានឲ្យខ្សែកព្រមទាំងបន្តោងមកនាងនោះឬ?»

«ចាស ត្រូវហើយណា បន្តោងនោះហើយគឺជាក្រសែចិត្ត អ៊ីស្លាមនោះគឺជាមនុស្សស្រីជនជាតិអ៊ីស្លាមតែលតោលម្នាក់នោះហ្នឹងឯងណា»

«សរុបទៅគឺយើងត្រូវតាមរកមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះ ព្រមទាំងតាមរកមនុស្សដែលកាន់សីលយ៉ាងខ្ជាប់ខ្ជួនដែលមានជីវិតបរិសុទ្ធនោះ?»

«ហឹមមម!!! សរុបទៅខ្ញុំនៅតែមិនសូវជាយល់ច្បាស់ដែរនោះណា»

«មិនអីនោះទេ យើងនាំគ្នាគិតបន្តិចម្ដងៗក៏បានដែរណា»

ឈីតខាមែន ទាញភរិយាថ្មីថ្មោងរបស់គេទៅឱប គេគិតថាអ្វីៗនឹងអាចដោះស្រាយបានជាក់ជាមិនខានទេ យ៉ាងហោចណាស់ក៏ថ្ងៃនេះគេអាចដឹងពីទិសដៅដែលអាចឲ្យពួកគេភ្លឺភ្នែកខ្លះៗដែរ។



«ឈីតខាមែន!!» សំឡេងរាបស្មើរបស់ភរិយាស្រីបានលាន់ឮឡើង ដែលការពិតទៅផ្ទៃមុខរបស់នាងនៅតែឱនក្នុងប្រអប់ដើមទ្រូងរបស់ស្វាមីនាងនៅឡើយនោះ។

«នាងមានអីបន្ថែមទៀត?»

«តើធ្វើយ៉ាងណាអាចឲ្យខ្ញុំបានជួបជាមួយ ហាន់ណា បានទៅ?»

«ផ្លូវវាដាច់ ហើយណាមួយកើតមានព្រិលធ្លាក់នៅសមុទ្រខ្សាច់នោះទៀតណា»

ផ្ទៃមុខដ៏ស្រស់សោភារបស់ យ៉ុនហ៊ី ងើបឡើងមើលទៅផ្ទៃមុខរបស់ឈីត ហើយពេលនោះសំឡេងសួរដើម្បីបញ្ជាក់ក៏ចេញពីមាត់នាងសាជាថ្មី។

«ហាស់!! នេះលោកថារឿងនេះវាចម្លែក?»

«ចុះនាងគិតបែបហ្នឹងអត់ចុះ?»

រឿងរ៉ាវទាំងឡាយនេះបើសិនជានាងយកទៅនិយាយប្រាប់ក្រុមមិត្តភក្តិនាងប្រាកដជាគ្មានអ្នកណាគេជឿជាដាច់ខាត តែអ្វីទាំងឡាយនេះជារឿងពិតដែលកើតឡើងចំពោះនាង យ៉ាងហោចណាស់ក៏មាន ឈីតខាមែន យល់ពីនាងព្រមទាំងរួមជតាកម្មជាមួយនាងនាពេលនេះផងដែរ។

«ទៅមិនបានក៏មិនអីដែរ តែយប់នេះនាងសាកល្បងនិយាយជាមួយមិត្តនាង ក្រែងលោអាចមានអ្វីរីកចម្រើនជាងមុនបានណា»

«លោកគិតបែបហ្នឹង?»

«ត្រូវហើយណា ខ្ញុំគិតថា វានឹងអាចមានផ្លូវដោះស្រាយជាក់ជាមិនខានឡើយ»

«ខ្ញុំសង្ឃឹមដូចលោកនិយាយទៅចុះណា»

«ខ្ញុំថា នាងប្រាកដជានឿយហត់ខ្លាំងហើយ! តោះយើងនាំគ្នាទៅសម្រាកសិនទៅណា»

យ៉ុនហ៊ី សម្លឹងមើលមុខ ឈីតខាមែន ដែលទើបតែក្លាយជាស្វាមីថ្មីថ្មោងរបស់នាង គេបានបញ្ចេញមន្តស្នេហ៍ដាក់នាងដែលឃើញយ៉ាងច្បាស់តែម្តង

នាងដឹងច្បាស់ថា បើសិនជានាងទៅសម្រាកដូចដែលគេនិយាយមែននោះ នាងប្រាកដជាហត់នឿយខ្លាំងជាងនៅទីនេះប្រាកដណាស់។

អារម្មណ៍របស់នាងប្រហែលជាទាយមិនខុសនោះទេណា ព្រោះថាពេលនេះកែវភ្នែកមោះមុតរបស់គេ ក៏កំពុងតែបញ្ចេញមន្តស្នេហ៍មិនមានការលាក់បាំងទាល់តែសោះ មិនត្រឹមតែប៉ុណ្ណោះគេលូកដៃមកអង្អែលប្រាណនាងបង្ហាមាត់និងដើមទ្រូងរហូតធ្វើឲ្យនាងស្ទើរតែហើបផុតពីដី។ រំពេចនោះគេក៏ឱបត្រកងនាងទៅកាន់បន្ទប់គេង។ ស្រីស្អាតដូចជានាងក៏ចង់ភ្លក់រសជាតិអ្វីដែលថ្មីដែរហ្នឹងណា ព្រោះកន្លងមកនោះដូចជាមិនទាន់គ្រប់គ្រាន់សម្រាប់នាងនៅឡើយ។

ហាន់ណា ដើរទៅកាន់បន្ទប់គេងនៅពេលឃើញស្វាមីរបស់នាងនៅអង្គុយក្នុងបន្ទប់ធ្វើការ ហើយនាងក៏លើកទូរស័ព្ទឡើងចុចទៅកាន់លេខមិត្តនាងតែម្តង តាំងចិត្តថា នឹងនិយាយឲ្យបែកពពុះមាត់ទៅព្រោះពេលនេះមិនមានស្វាមីមកអង្គុយចាំតាមដានសកម្មភាពនោះហ្នឹងណា។

«ហេតុអីក៏ចុចមិនចូលដូចមុនសោះអីចឹង!»

ហាន់ណា រអ៊ូរទាំតែម្នាក់ឯងនៅពេលដែលនាងចុចច្រើនដងហើយនៅតែមិនមានសេវាទាល់តែសោះ ទោះបីជានាងឈរនៅកន្លែងដែលនាងធ្លាប់ចុចចូលយ៉ាងណាក៏ដោយ ទើបធ្វើឲ្យអារម្មណ៍នាងក្តៅក្រហាយឡើងភ្លាម។

«ហាន់ណា បងយកទឹកដោះគោមកឲ្យញ៉ាំណា មកញ៉ាំសិនទៅណា កំពុងតែក្តៅខណ្ឌាវផង មកណា!»

រំពេចនោះ នាងក៏កើតមានអារម្មណ៍កាន់តែក្តៅក្រហាយជាងមុនទៅទៀតនៅពេលបានឮសំឡេងបារម្ភហួងហែងពីស្វាមី អូយ!!!! ហេតុអីក៏ស្វាមីរបស់នាងធ្វើការងារលឿនម្ល៉េះទេនៀក នាងនៅមិនទាន់បានចុចទូរស័ព្ទចូលផងនោះណា ហើយពេលនោះកំហុសក៏បានធ្លាក់មកលើស្វាមីរបស់នាងដោយគ្មានហេតុផលណាមកជួយសង្គ្រោះបានឡើយ។



«អឺមមមម!!! បងដាក់សេវាអីគេ អូនទាក់ទងទៅក្រៅមិនបានសោះហើយនៀក»

«ហាស់!!! ស្អីគេទៀតហើយហ្នឹង បងទើបតែទាក់ទងរឿងការងារស្ទើរតែពេញមួយថ្ងៃទៅប្រទេសក្រៅទៅហើយហ្នឹងណា»

«ចុះបើអូនទាក់ទងមិនបានមែននោះណានៀក បងសាកមើលទៅមើល»

«អូនទាក់ទងទៅអ្នកក្រៅ ឬក៏ទាក់ទងទៅមនុស្សក្រៅគពដែរទៅ!»

គេគ្រាន់តែលេងជាមួយភរិយាគេប៉ុណ្ណោះ តែភរិយាគេ មិនព្រមលេងជាមួយគេវិញសោះឡើយ។ រំពេចនោះគេក៏ត្រូវទ្រាំស្តាប់សំឡេងស្រួយស្រែសយ៉ាងឮរបស់នាងភ្លាម។

«នេះបងកំពុងថាឲ្យអូនឥតប្រយោជន៍មែនដែរទេ មួយថ្ងៃៗមិនព្រមធ្វើអីគិតតែពីចុចទូរស័ព្ទ និងរករឿងបងមែនដែរទេ?»

«មាន...មានណា អូនចេះនិយាយថាឲ្យខ្លួនឯងទៅកើតហ្ន!!!»

«ឈឺត!!»

«បងលលេងជាមួយអូនទេ កុំខឹងអីណា អូនកំពុងតែមានផ្ទៃពោះផងណា»

«ទៀតហើយណា នេះបងថាឲ្យខ្ញុំមិនចេះគិតទៀតហើយណា!»

«ហឺសសស!! បងនិយាយពីពេលណាដែរទៅ»

«មកពីបងដកដង្ហើមធំនោះណា មែនហ្នឹង!! ព្រោះខ្ញុំមានផ្ទៃពោះនោះអី!!»

នាងក៏មិនដឹងដូចគ្នាដែរថា ស្វាមីរបស់នាងបានធ្វើខុសត្រង់ណា នឹកមិនចេញដែរថា នាងក្តៅក្រហាយជាមួយស្វាមីរឿងអី តែអ្វីដែលនាងដឹងគឺ មានតែគេម្នាក់ប៉ុណ្ណោះ ដែលអាចឲ្យនាងបញ្ចេញកំហឹងបាន។

ស្វាមីសង្ហារបស់នាងអត់ទ្រាំមិនសើចមិនបានចំពោះពាក្យសម្តីនិយាយប្រហែលជាអាការរបស់មនុស្សមិនស្រួរជាតិតមុខតិតក្រោយរបស់ភរិយានោះ

មានផ្ទៃពោះទេដឹង ហើយអ្នកដែលធ្វើឲ្យភរិយាមានផ្ទៃពោះបែបនេះតើម៉េចហ្នឹង អាចប្រកាន់នាងបានដែរទៅ! សំឡេងដែលចង់និយាយលេងជាមួយភរិយាគេលាន់ឮឡើងម្តងទៀត។

«បងសុំដកដង្ហើមបន្តិចសិនណា!»

«ចុះបងមកសុំខ្ញុំធ្វើអីដែរទៅ»

«ចុះបើបងធ្វើឲ្យអូនមានកូន បងខុសតែរហូតហ្នឹងណា ខ្លាចអូនថាឲ្យបងលួចខ្យល់ដង្ហើមអូននោះអី»

«នែ!! ឈីត បងកំពុងតែធ្វើឲ្យខ្ញុំខឹងហើយណា! ខ្ញុំកំពុងតែទាក់ទងជាមួយ យ៉ុនហ៊ី បងមិនឃើញទេអី!»

យ៉ុនហ៊ី ទៀតហើយ! ឈីត គិតថា ហេតុអីក៏កើតមានរឿងបែបនេះឡើងយ៉ាងអីចឹង ទឹកដីរបស់ ឈីតខាមែន មិនគួរណាមានបញ្ហារឿងសេវានោះទេណា។

ឈីត ចាប់ផ្តើមគិតប្រាកដប្រជា តែអ្វីដែលគេត្រូវតែបារម្ភខ្លាំងបំផុតនៅពេលនេះគឺសុខភាពរបស់ភរិយាដែលកំពុងតែពពោះកូនក្នុងផ្ទៃរបស់នាង។

«អូនញ៉ាំទឹកដោះគោនេះហើយ ចូលគេងភ្លាមទៅណា»

«តែខ្ញុំបានណាត់ជាមួយ យ៉ុនហ៊ី ហើយថានឹងចុចរកគ្នានោះណា»

«តែ យ៉ុនហ៊ី នាងប្រហែលជាយល់ជាក់ជាមិនខាននោះទេណា ថាមានបញ្ហារឿងសេវា»

«តែខ្ញុំ...»

«គ្មានតែអីនោះទេ អូនត្រូវតែបារម្ភពីខ្លួនឯង និងកូនផងណា»

ដៃទន់ភ្លន់ លើកទៅអង្អែលពោះរបស់នាង មែនហ្នឹងណា!! នាងមិនមែនមានតែម្នាក់ឯងឯណា នាងនៅមានជីវិតម្នាក់ទៀតដែលត្រូវមើលថែ ហើយពេលនោះនាងក៏យល់ស្របជាមួយស្វាមី មុននឹងចុចទូរស័ព្ទម្តងទៀតទៅមិត្ត បើនៅតែមិនចូល នេះជាការចុចលើកចុងក្រោយហើយ។

«កូនម៉ាក់! ម៉ាក់ចុចរកមីង យ៉ុនហ៊ី កូនសិនណា ចាំយើងនាំគ្នាទៅគេង



ទាំងអស់គ្នាណាកូន»

ដៃមួយចំហៀងអង្អែលពោះដោយសេចក្តីស្រឡាញ់ ដៃមួយទៀតចុចទូរស័ព្ទរកមិត្តរបស់នាង ហើយនាងក៏មានអារម្មណ៍ចម្លែកចិត្ត តែក៏សប្បាយចិត្តដែរដែលបានចុចចូលនាងជាថ្មី។

«យេ!!! ខ្ញុំចុចចូលហើយណា ឈីត»

«ហាន់ណា កុំហកលោតបែបហ្នឹងទៅមើស! វានាំឲ្យប៉ះពាល់ដល់កូនយើងណា នេះ!!! បងមិនដឹងជាត្រូវធ្វើយ៉ាងណាជាមួយអូនទើបល្អទេទៀត... មិនចេះប្រយ័ត្នសោះហើយ!!»

ហាន់ណា មិនចាប់អារម្មណ៍លើសម្តីរអ៊ូរទាំរបស់ស្វាមីនាងទាល់តែសោះ អារម្មណ៍នាងកំពុងតែផ្តោតលើសំឡេងយ៉ាងស្រួយខ្លោក ដែលកំពុងតែបន្លឺឡើងនោះ ហើយអ្នកចុចចូលព្រមទាំងអ្នកទទួលក៏និយាយគ្នាយ៉ាងបែកផ្សៀង។

«យ៉ុនហ៊ី! យ៉ុនហ៊ី! សេវាស្រួលបួលហើយនៅ?»

[ច្បាស់ណាស់! ហាន់ណា យើងមានរឿងជាច្រើនត្រូវពិភាក្សាជាមួយឯងណា]

«និយាយមកណា! ឯងបានជួបអ្វីខ្លះ?»

យ៉ុនហ៊ី ហាក់ដូចជាមានអារម្មណ៍ប្លែកចិត្តថា ហេតុអីក៏មិត្តនាងដឹងថានាងកំពុងតែជួបនឹងបញ្ហាអ្វី បានជានាងសួរមកចំៗត្រូវគោលដៅរបស់នាងដែលចង់និយាយប្រាប់ពីអំណាចអាថ៌កំបាំងមួយនោះដែរអីចឹង។

[ហាន់ណា!! ហេតុអីក៏ឯងដូចជាដឹងហេតុការណ៍ដែលកើតឡើងចំពោះយើងដែរ?]

«យើងដឹងបានខ្លះៗពី ឈីត នោះអី ហើយឯងយ៉ាងម៉េចដែរហើយ?»

[គឺបែបនេះណា ឯងស្តាប់រឿងរ៉ាវដែលយើងរៀបរាប់ឲ្យយល់សិនទៅណា]

រឿងរ៉ាវដែលមានភាពអាថ៌កំបាំងនោះ យ៉ុនហ៊ី បានធ្វើការរៀបរាប់ឲ្យ

មិត្តនាងស្លាប់។ ហាន់ណា ទាំងខ្លាច ទាំងបារម្ភពីមិត្តនាង តែក៏មានអារម្មណ៍ធូរចិត្តបន្តិចនៅពេលដែលដឹងថា នៅមាន ឈីតខាមែន នៅក្បែរមិត្តរបស់នាង។ នាងបើកភ្នែកធំៗ នៅពេលនឹកឃើញដល់ការដោះសម្លៀកបំពាក់នៅចំពោះមុខ ឈីតខាមែន ដែលនាងស្ដាប់ យ៉ុនហ៊ី និយាយប្រាប់នោះ នាងព្រឺសម្បុរខ្លាចរ១ៗ។

«អូយ!!! ស្លាប់ហើយ!! យ៉ុនហ៊ី អីចឹងមានន័យថា ឈីតខាមែន បានឃើញរូបរាងរបស់ឯងអស់ហើយមើលទៅនោះ!!»

ជាងនោះទៅទៀតនោះណា នាងមិនទាន់ប្រាប់រឿងដែលនាងមានទំនាក់ទំនងជាមួយគេផង ប្រហែលជារង់ចាំឲ្យនាងខ្លួនឯងធ្វើចិត្តបានស្រួលបួលសិនក្នុងការដែលមានស្វាមីគ្រាន់តែមួយប៉ប្រិចភ្នែកនោះ។

«យ៉ុនហ៊ី! ឯងកំពុងស្ដាប់យើងឬអត់ហ្នឹងហាស់!»

[ស្ដាប់! ស្ដាប់តើស ពេញ្ញីយចុះណា រឿងហ្នឹងទុកវាមួយកន្លែងសិនចុះណា យើងពិតជាចង់សួរឯងក្នុងពេលនេះថា ឯងមានអ្វីដែលខុសប្លែកក្នុងផ្លូវល្អដែរទេ ហាន់ណា?]

«អ្វីដែលខុសប្រក្រតីក្នុងផ្លូវល្អនោះឬ? ស្អីគេដែរទៅ យ៉ុនហ៊ី!!»

[គឺដូចជាការដែលឯងកាន់សីល មិនសេពសន្ថវៈនោះអី...]

ហាន់ណា គិតនូវអ្វីដែលមិត្តនាងនិយាយ កាន់សីលឬ! នាងមិនដែលគិតទាល់តែសោះហើយ គឺគ្រាន់តែព្យាយាមកាន់សីលប្រាំ គិតល្អ ធ្វើល្អ និយាយល្អ គ្រាន់តែប៉ុណ្ណឹង នាងគិតថា ជីវិតរបស់នាងនឹងជួបអ្វីដែលល្អៗទៅហើយណា ហើយអាឿងតម្រូមតេទនោះ...ទោះបីជានាងតម តែស្វាមីរបស់នាងគេមិនតមជាមួយនាងនោះឡើយ។

«មិនមាននោះទេណា យ៉ុនហ៊ី គឺវាប្រក្រតីគ្រប់យ៉ាងតើស»

[ឯងមិនមានអីផ្លាស់ប្ដូរក្នុងជីវិតក្នុងកំឡុងពេលនេះទេអី?]

ហាន់ណា ឱនមើលដៃដែលនាងកំពុងតែអង្អែលពោះនោះហើយក៏ញញឹមចេញមក ព្រមទាំងប្រាប់ដំណឹងល្អដែលនាងកំពុងតែមានផ្ទៃពោះដល់មិត្តនាងដឹងភ្លាមផងដែរ។



«យ៉ុនហ៊ី យើងមានផ្ទៃពោះហើយណា ឯងដឹងទេ?»

**[ហាស់! ឯងមានផ្ទៃពោះ!!!]**

«ត្រូវហើយណា ឯងកំពុងតែក្លាយជាមីងគេហើយណា ឬឯងចង់ធ្វើជាអ៊ំក្មេងដែរទៅ!»

ការគិតផ្សេងពីនេះបានចេញមកភ្លាមមួយរំពេច យ៉ុនហ៊ី ញញឹមទាំងសប្បាយចិត្តចំពោះមិត្តនាងដែលក្លាយជាម្ដាយគេទៅហើយនោះណា ហើយម្យ៉ាងទៀតអាថ៌កំបាំងទាំងឡាយ ក៏ហាក់បីដូចជារកផ្លូវចេញឃើញបានខ្លះហើយដែរ ស្រីស្រស់ដូចជានាងអត់ទ្រាំមិនស្រក់ទឹកភ្នែកចេញមកមិនបាន។

«យ៉ុនហ៊ី! យ៉ុនហ៊ី! ឯងនៅស្ដាប់យើងឬក៏អត់ហ្នឹង!»

[ហាន់ណា! ការពិតគឺជាឯងទេ ដែលអាចជួយយើងបាននោះ]

«យ៉ុនហ៊ី! ឯងកើតអីហ្នឹង ហេតុអីក៏យំធ្វើអីទៅ?»

[ឯង និងកូនរបស់ឯង ដែលត្រូវជាក្មួយរបស់យើង នឹងអាចជួយឲ្យយើងរួចផុតពីបួងមន្តក្រាដែលជាអំណាចអាថ៌កំបាំងនេះបានហ្នឹងណា]

ហាន់ណា គិតដល់រឿងរ៉ាវដែលមិត្តនាងនិយាយពីជីវិតបរិសុទ្ធ ដែលអាចជួយឲ្យមិត្តនាងរួចផុតពីបួងមន្តក្រានេះបាន ផ្ទៃមុខរបស់ ហាន់ណា បានញញឹមឡើង។

«ឯងចង់មានន័យថា ជីវិតបរិសុទ្ធដែលឯងប្រាប់យើងនោះ គឺកូនរបស់យើងឬ!!»

[មែនហើយណា ជីវិតបរិសុទ្ធនោះគឺ កូននៅក្នុងផ្ទៃរបស់ឯងហ្នឹងណា គេមិនដែលបានធ្វើបាបអ្វីឡើយ យើងទើបតែនឹកឃើញទេទៀត!!!]

បើអីចឹងកូនរបស់នាង ក៏អាចជួយមនុស្សម្នាបានតាំងពីគេមិនទាន់កើតមកឬ ហេតុអីក៏គេបានឈាមបាំគេមកច្រើនម្ល៉េះហ្ន!! នាងនឹកដល់ស្វាមីរបស់នាងដែលតែងតែជួយមនុស្សម្នាមកជាច្រើននាក់ហើយនោះ ហើយកូនរបស់នាងក៏កំពុងតែដូចប៉ារបស់គេដូចគ្នាដែរ។

«តើយើងអាចជួយឯងដោយវិធីណាខ្លះដែរទៅ!»

«អ!! យើងសុំពេលទៅពិភាក្សាជាមួយ ឈីតខាមែន សិនណា!!»

«ពិភាក្សាជាមួយ ឈីតខាមែន សិន?»

ហេតុអីក៏ស្តាប់ទៅដូចជាប្លែកណាស់។ មើលទៅដូចនាងដែរហ្នឹងណា ដែលត្រូវពិភាក្សាជាមួយ ឈីត គ្រប់បញ្ហានោះអី។ ទោះបីជាប្លែកៗយ៉ាងណាក៏ដោយចុះ តែត្រចៀកនាងក៏នៅស្តាប់មិត្តនាងនិយាយដដែលហ្នឹងណា។

[យើងនិង ឈីតខាមែន នៅក្នុងបួងមន្តក្រាជាមួយគ្នានោះណា ឯងកុំភ្លេចមើស!]

«អ!!ធ្លាក់ក្នុងបួងមន្តក្រាជាមួយគ្នា!! បួងស្នេហាឬ យ៉ុនហ៊ី?»

[បួងមន្តក្រា ឯងថាឲ្យត្រូវបន្តិចទៅមើស]

តែស្តាប់មើលទៅដូចជាក្នុងបួងមន្តស្នេហាជាងនោះណា ទឹកដមសំឡេងរបស់មិត្តនាងដូចជារាងប្លែកៗយ៉ាងម៉េចមិនដឹងទេ ហាន់ណា គិត។

«បួងមន្តក្រាក៏បានដែរ ហើយចាំយើងទាក់ទងទៅណា យ៉ុនហ៊ី»

[អ! ពេលដែលឯងទាក់ទងមកយើង ឯងតាំងសតិគិតលើកូនឯងសិនណាមុននឹងចុចមកយើង ដើម្បីឲ្យងាយស្រួលក្នុងការទាក់ទង]

«អ!! មែនហ្នឹងណា ឯងមានដឹងដែរទេថា នៅពេលណាដែលយើងនឹកដល់កូនរបស់យើង យើងក៏ទាក់ទងទៅឯងបានយ៉ាងងាយតែម្តងណា»

រឿងរ៉ាវអាថ៌កំបាំងត្រូវបានរៀបរាប់ប្រាប់ដល់ស្វាមីរបស់នាងដោយមិនមានការលាក់បាំងអ្វីសោះឡើយ ឈីត គិតដល់រឿងរ៉ាវដែលអាថ៌កំបាំងនោះ ដែលមានការទាក់ទងជាមួយនឹងភរិយារបស់គេព្រមជាមួយនឹងកូនរបស់គេដែរ ដែលមិនដឹងអីសោះ។ ឈីត ទាញភរិយាគេទៅឱបដោយក្តីស្រឡាញ់ព្រមទាំងបារម្ភលើសុវត្ថិភាពរបស់នាង និងកូនក្នុងផ្ទៃ។

«បងបារម្ភកូនមែនដែរទេ ឈីត?»

«មិនមែនបែបហ្នឹងសុទ្ធសាធនោះទេណា បារម្ភពីកូននោះបងបារម្ភតាំងពីដឹងថា មានគេទៅហើយណា»



«ហើយហេតុអីក៏មើលទៅដូចជាពិបាកចិត្តម្ល៉េះ?»

ឈីត គិតថា ទោះបីជាគេជាមនុស្សដែលចូលចិត្តជួយដល់មនុស្សម្នាដែលមានទុក្ខសោកយ៉ាងណាក៏ដោយចុះ តែក្នុងពេលដែលគេជាមេគ្រួសារ គេគិតជាចង់ឲ្យភរិយាព្រមទាំងកូនក្នុងផ្ទៃមានក្តីសុខព្រមទាំងរួចផុតពីទុក្ខគ្រប់ប្រការ គេស៊ូទ្រាំទៅប្រឈមមុខនឹងគ្រោះថ្នាក់ដោយខ្លួនគេ វាប្រសើរជាងប្រថុយឲ្យប្រពន្ធ និងកូនទៅរងគ្រោះថ្នាក់ដែរណា។

ហាន់ណា ប្រហែលជាមនុស្សម្នាក់ដែលយល់ពីស្វាមីនាងបានល្អជាងអ្នកដទៃ នាងងើបមុខឡើងសម្លឹងទៅកាន់ប្តីរបស់នាង រួចនិយាយដោយសម្តីទន់ភ្លន់ ដើម្បីកាត់បន្ថយក្តីបារម្ភដែលប្តីនាងមានចំពោះនាង និងកូនបានខ្លះ។

«អូនដឹងថា បងពិតជាស្រឡាញ់ខ្ញុំ និងកូន តែអូនមិនបានទៅប្រយុទ្ធជាមួយអ្នកណាឯណា គ្រាន់តែប្រើការតាំងចិត្តដ៏ល្អរបស់ខ្ញុំ ព្រមជាមួយនឹងភាពដែលគេហៅថាជីវិតបរិសុទ្ធរបស់កូនយើង ជួយឲ្យពួកគេពីរនាក់រួចផុតពីអំណាចអាថ៌កំបាំងមួយតែប៉ុណ្ណោះតើស»

ឈីត ឱបភរិយាគេ មុននឹងនាងនិយាយឲ្យស្វាមីធូរស្រាលចិត្ត។

«អូនជឿជាក់ថា វិញ្ញាណរបស់ព្រះនាង ទេមីន ដែលមានអាយុកាលរាប់រយឆ្នាំហើយនោះ ប្រហែលជាវេទនាខ្លាំងណាស់ហើយមើលទៅ ណាមួយជីតរបស់ យ៉ុនហ៊ី ព្រមជាមួយនិង ឈីតខាមែន ពីរនាក់ទៀតនោះណា ពួកគេមិនដឹងជាវេទនាយ៉ាងណានោះទេ បើសិនជាអូន និងកូនអាចធ្វើឲ្យអ្វីៗប្រសើរឡើងបាននោះ មានន័យថា មនុស្សគ្រប់គ្នានឹងអាចរួចផុតពីទុក្ខសោកបាន បងកុំបារម្ភខ្ញុំ និងកូនដែលជួយមនុស្សគ្រប់គ្នានោះអីណា»

ឈីត ងក់ក្បាលទទួល គឺប្រហែលជាដូចដែលភរិយាគេនិយាយមែននោះណា ហើយគេក៏មានតួនាទីមើលថែប្រពន្ធ និងកូនឲ្យរស់ពីសមត្ថភាពដែរ។



## ...៥...

## ប្រឈមជីវិតក្នុងអំណាចអាថ៌កំបាំង

ប្រៀបបីដូចជាក្រសែចិត្តរបស់ព្រះនាង ទេមីន បានដឹងថានឹងមានអំណាចអ្វីមួយចូលមករំលាយអំណាចមន្តត្រារបស់ព្រះនាង។ រំពេចនោះក៏មានព្យុះភ្លៀងធ្លាក់យ៉ាងជោកជាំ ព្រមទាំងទ្វារត្រូវបានបក់បោកយ៉ាងខ្លាំងពេញទំហឹង ទាំងទ្វារទាំងបង្អួចរបើក និងបិទយ៉ាងគ្រាំងៗ។

«សំឡេងនោះ!! តើមានអីកើតឡើងទៀតហើយមែនទេ ឈីត?»

«អំណាចមន្តត្រា»

«ក្រសែចិត្តរបស់ព្រះនាង ទេមីន ទៀតហើយ?»

«ខ្ញុំគិតថា បែបហ្នឹងណា»

«តែខ្ញុំមិនមានក្រសែចិត្ត...ហើយ...ហើយ...»



ឈីតខាមែន មិនអាចរកពាក្យសម្ដីណា មកធ្វើការអធិប្បាយដែលអាចតបនឹងចម្លើយនាងបានឡើយ ដៃទាំងពីររបស់គេឱបក្រសោបស្រីស្រស់ដែលញ័រទទ្រើកដោយសារតែភាពភ័យខ្លាចព្យាយាមគិតថាអ្វីដែលកើតឡើងនោះគ្រាន់តែការបំភាន់ភ្នែកតែប៉ុណ្ណោះ អ្វីគ្រប់យ៉ាងត្រូវតែឆ្លងផុតទៅបានយ៉ាងល្អ គេតាំងសតិ ហើយស្រែកប្រាប់ដល់មនុស្សស្រីដែលឱបរួបគេជាប់ដោយភាពភ័យខ្លាចនោះ។

«តាំងសតិឲ្យបានរឹងមាំណា កុំខ្លាចចំពោះអំណាចបំភាន់ភ្នែកនោះឲ្យសោះ!!»

«តែវាគួរឲ្យខ្លាចខ្លាំងហ្នឹងណា ឈីត»

«បិទភ្នែកទៅណា ហើយតាំងសតិឲ្យរឹងមាំដូចដែលខ្ញុំធ្លាប់ប្រាប់នាងនោះណា នាងអាចនឹកឃើញដល់អ្វីក៏បានដែរដែលនាងជឿជាក់ណា នាងជឿខ្ញុំចុះណា!!»

«ចាស!! ខ្ញុំនឹងធ្វើតាមនូវអ្វីដែលលោកប្រាប់!»

ទោះបីជាគេស្រែកប្រាប់ស្រីស្រស់ដែលកំពុងតែនៅក្នុងរង្វង់ដៃរបស់គេយ៉ាងណាក៏ដោយ តែគេដូចជាចាប់ផ្ដើមដកដង្ហើមមិនចេញហើយ គេក៏សូត្រមន្តគាថាដែលលោកតាគេបន្សល់ទុកឲ្យនោះយ៉ាងមុតមាំ គេប្រាកដជាឆ្លងផុតនូវអំណាចទាំងឡាយនេះទាល់តែបាន។

ដៃរបស់គេបានទៅប្រទាក់ជាប់ជាមួយនឹងដៃរបស់ យ៉ុនហ៊ី ប្រមូលកម្លាំងចិត្តគ្នា ទោះបីជាគេដកដង្ហើមស្ទើរតែមិនចេញនោះក៏ដោយ តែគេក៏តាំងចិត្តសូត្រមន្តគាថានោះយ៉ាងមុតមាំបន្ត។

យ៉ុនហ៊ី វិញនឹកដល់គុណនៃមាតាបិតា អារក្សអ្នកតាចាំស្រុកចាំភូមិក្នុងជំនឿព្រះពុទ្ធសាសនា នាងចាប់ផ្ដើមសូត្រគាថាដែលនាងអាចចាំបាន ភាគច្រើននាងសុំក្ដីសុខពីទេវតា។

មួយសន្ទុះក្រោយមក សំឡេង និងខ្យល់ព្យុះដែលបានបក់បោកនោះក៏បានស្ងប់ស្ងាត់ទៅ យ៉ុនហ៊ី បើកភ្នែកព្រឹមៗ ហើយសម្លឹងមើលទៅកាន់មុខរបស់

ស្វាមីនាងដែលស្លាត់មាត់ទៅនោះ ហើយក៏ត្រូវស្លុតចិត្តជាខ្លាំងនៅពេលដែលបានឃើញឈាមចេញពីច្រមុះស្វាមីរបស់នាង។

«ឈឹតខាមែន!! លោកកើតអី!! លោកកើតអីហ្នឹងហាស់!!!»

ដៃទាំងពីររបស់នាង លូកទៅជូតឈាមដែលហូរចេញពីច្រមុះរបស់ស្វាមីទាំងអារម្មណ៍ភិតភ័យ នាងយំខ្សឹកខ្សួលអួលអាក់ព្រមទាំងនឹកគិតថាហេតុអីបានជាក្រសែចិត្តរបស់ព្រះនាង ទេមីន ធ្វើបាបស្វាមីរបស់នាងយ៉ាងធ្ងន់ធ្ងរបែបនេះទៅវិញ!

ឈឹតខាមែន ចាប់ផ្ដើមដកដង្ហើមមួយៗច្រើនដង តែវគ្គុកមើលទៅកាន់ភរិយារបស់គេដែលពេលនេះកំពុងតែយំខ្សឹកខ្សួល ហើយគេក៏ស្ទួរទៅកាន់ស្រីស្រស់ដោយក្ដីបារម្ភ។

«នាងមិនកើតអីមែនទេ?»

«ខ្ញុំមិនអីនោះទេណា តែលោក!! លោកហូរឈាមច្រើនណាស់!»

«ខ្ញុំមានកើតអីឯណា នាងកុំយំអីណា»

«បើមិនអីពិតមែន ហេតុអីក៏មានឈាមហូរមកបែបនេះ?»

«ដោយសារតែអំណាចអាថ៌កំបាំងមួយនោះ តែខ្ញុំពិតជាមិនកើតអីមែនណា នាងកុំបារម្ភអីណា»

«គឺព្រោះតែព្រះនាងស្រឡាញ់ព្រះស្វាមីរបស់ទ្រង់នោះណា មានន័យថាព្រះនាងស្រឡាញ់លោក តែហេតុអីក៏ព្រះនាងធ្វើបាបលោកធ្វើអីដែរទៅ?»

ឈឹតខាមែន ទាញប្រាណស្រីស្រស់មកឱបជាប់ទ្រូងរបស់គេ នាងប្រហែលជាបារម្ភគេខ្លាំងដូចដែលគេបារម្ភពីនាងហើយមើលទៅនោះ ដៃរបស់គេលូកមកអង្អែលសក់របស់នាងដោយការលួងលោម ព្រមទាំងនិយាយ។

«ប្រហែលជាមកពីខ្ញុំ បញ្ជូនក្រសែចិត្តទៅឲ្យព្រះនាង ទេមីន ហើយទេដឹងថា ខ្ញុំមិនបានស្រឡាញ់ព្រះនាងទេមីនក្នុងជាតិនេះនោះឡើយ ខ្ញុំព្យាយាមនិយាយឲ្យក្រសែចិត្តរបស់ព្រះនាងរលត់ទៅវិញនោះណា ដើម្បីឲ្យរួចផុតពីទុក្ខសោកទាំងឡាយ ព្រោះថាព្រះនាងព្រមទាំងព្រះស្វាមីរបស់ទ្រង់បានមកចាប់



ជាតិថ្មី ហើយក៏បានក្លាយជាគូគ្រងជាមួយគ្នាដូចដែលបានសន្យាទុកកាលពីជាតិមុននោះពិតមែន នោះគឺនាង និងខ្ញុំ»

«ការដែលលោកនិយាយនោះគឺជាការពិត ហេតុអីក៏ព្រះនាងចាំបាច់ខឹងធ្វើអីដែរទៅ»

«វាពិតជាអាថ៌កំបាំងខ្លាំងនោះណា»

«ហើយចុះអំណាចអាថ៌កំបាំងនោះមកវិញទៀតឬក៏អត់?»

ឈឹតខាមែន សញ្ជឹងគិត តើគេម៉េចនឹងអាចប្រាប់នាងបានទៅថាវានឹងអាចកើតមានអីឡើងទៀតនោះ តែអ្វីដែលគេដឹងគឺ ពេលនេះគេត្រូវបានអំណាចរបស់ព្រះនាង ទេមីន ធ្វើបាបខ្លាំងជាងលើកមុនៗទៅទៀតនោះណា ហើយលើកក្រោយទៀតវានឹងអាចខ្លាំងជាងលើកនេះទៀត តែគេបែរជាជ្រើសរើសនិយាយនូវអ្វីដែលជាការលើកទឹកចិត្តទៅវិញ គេធ្វើយ៉ាងណាឲ្យមនុស្សដែលគេស្រឡាញ់សប្បាយចិត្ត។

«ខ្ញុំគិតថា យើងនាំគ្នាមករកផ្លូវដោះស្រាយដើម្បីឲ្យរួចផុតពីអំណាចនេះទៅប្រសើរជាង មុនពេលដែលអំណាចនោះនឹងត្រឡប់មករកយើងជាថ្មី»

«មែនហ្នឹងណា! ខ្ញុំមិនទាន់បានប្រាប់ពីរឿងរ៉ាវរបស់ ហាន់ណា ផងនោះណា»

«ហាន់ណា មិត្តភក្ដិរបស់នាងឬ?»

«ចាស មែនហើយ នាងបានចុចមករកខ្ញុំកាលពីយប់មិញ ខ្ញុំបានឃើញលោកតាំងចិត្តអានសៀវភៅជាភាសាអ៊ីស្លាមនៅក្នុងបន្ទប់ ទើបខ្ញុំសម្រេចចិត្តគិតថា ចាំនិយាយប្រាប់លោកនាព្រឹកស្អែក»

ហើយពេលនោះ នាងក៏បាននិយាយរៀបរាប់ពីអ្វីៗទាំងឡាយពីមិត្តសម្លាញ់របស់នាង ព្រោះវាអាចជួយពួកគេឲ្យរួចផុតពីអំណាចអាថ៌កំបាំងនោះ។

«យើងកំពុងតែមានផ្លូវចេញរួចផុតពីបួងសួងមន្តស្រានោះបានហើយណា»

«ចាស!! ជាម៉េច!!»

«អ្នកនាង ហាន់ណា នឹងក្លាយជាបុគ្គលដែលអាចរំដោះយើងចេញពីបួងមន្តគ្រានេះបាន»

«ខ្ញុំមិនយល់ពីលោកនោះទេ តើលោកចង់ឲ្យ ហាន់ណា ធ្វើយ៉ាងណាដែរទៅ?»

«ដំណាក់កាលដំបូង ខ្ញុំចង់ឲ្យនាងទាក់ទងជាមួយមនុស្សស្រីដែលជាជនជាតិអ៊ីស្លាមតែលតោលម្នាក់នោះជាមុនសិន ហើយនោះនឹងអាចដឹងពីវិធីដោះស្រាយនេះបាន ក្នុងដំណាក់កាលក្រោយៗទៀត ដូចដែលពាក្យគេតែងតែនិយាយថាវាអាចមានមួយអាចមានពីរអាចមានបីនិងអាចមានជាបន្តបន្ទាប់គ្នារហូតទទួលបានជោគជ័យ»

សំឡេងអធិប្បាយយ៉ាងញាប់ព្រមទាំងហាត់ៗរបស់ ឈីត តែមើលទៅគេក៏មិនព្រមឈប់និយាយនោះដែរ គេគិតថា ពេលវេលាពិតជាមានតម្លៃណាស់ ឈីត អាចមានផលប៉ះពាល់ដល់អំណាចអាថ៌កំបាំងនោះក៏ថាបាន រួចគេព្យាយាមអធិប្បាយបន្ត៖

«នេះមានន័យថា យើងបានជាពុម្ពមកពីរបីបន្ថែមហើយណា នាងគិតបែបហ្នឹងដែរទេ?»

យ៉ុនហ៊ី គិតតាមអ្វីដែលគេនិយាយនោះភ្លាម ពិតមែនហ្នឹងណា ដូចដែលគេនិយាយនោះមែន គ្រាដំបូងត្រូវតែកម្ចាត់ក្រសែចិត្តទាំងឡាយដែលអាចទាក់ទងមកកាន់រូបនាងសិន ហើយបន្ទាប់មកទៀតគឺដោះស្រាយនូវប្រយោគក្នុងសៀវភៅជាភាសាអ៊ីស្លាមនោះ ហើយចុងក្រោយបំផុតនោះគឺក្មេងដែលនៅក្នុងពោះរបស់មិត្តនាងនោះអី។

«ចាស ខ្ញុំយល់ហើយណា មិត្តរបស់ខ្ញុំនឹងអាចជួយយើងបានដូចដែលលោកនិយាយជាក់ជាមិនខានឡើយ»

នាងចង់និយាយបន្ត តែនៅពេលនាងងើបមុខមើលទៅកាន់ផ្ទៃមុខរបស់ស្វាមីនាងស្រាប់តែឃើញទឹកមុខគេដូចជាស្លេកស្លាំង មិនមានកម្លាំងកំហែងនឹងនិយាយបន្តនាពេលនេះបានឡើយ រំពេចនោះសំឡេងនៃក្តីបារម្ភក៏ឮឡើង។



«លោកទៅសម្រាកសិនទៅណា»

«ខ្ញុំប្រាប់នាងហើយថា ខ្ញុំមិនកើតអីទេណា»

«តែខ្ញុំខ្លាច...ខ្លាចលោកកើតអីនោះណា»

យ៉ុនហ៊ី កំពុងតែរៀបនិយាយថា នាងខ្លាចស្វាមីថ្មីថ្មោងរបស់នាងកើតអីនោះណា តែហេតុអីទៅហ្នំ!! ដែលស្រីស្រស់បែរជានិយាយអ្វីដែលជាការបាត់បង់ទៅវិញ នាងមិនហ៊ានសូម្បីតែគិត តើឲ្យនិយាយពាក្យនោះចេញមកដោយរបៀបណាទៅ នៅទីបំផុតទឹកភ្នែកនោះក៏ហូរចេញមកស្រស់ៗតែម្តង។

«ស្អីគេហ្នឹង នាងខ្លាចស្ទើរស្លាប់ស្ទើររស់បែបនេះឬ?»

«លោកកុំនិយាយទៅមើស ហឺៗៗ»

«ខ្ញុំនឹងមិនកើតអីដូចជាតិមុនជាដាច់ខាតណា»

«លោកកុំនិយាយរឿងស្លាប់ទៅមើស ឈីត ខ្ញុំខ្លាច ខ្ញុំខ្លាចលោកទៅចោលខ្ញុំ»

ឈីតខាមែន អត់ទ្រាំមិនទាញករិយារបស់គេមកឱបយ៉ាងលួងលោមមិនបាន គេឃើញនាងជាមនុស្សស្រីដែលមានជំនឿជាក់លើខ្លួនឯងខ្ពស់ហ្នឹងណា រឹងមាំសឹងអី តែប្រែមកជាមនុស្សទន់ខ្សោយបែបនេះដោយរបៀបណាទៅឬក៏មកពីនាងស្រឡាញ់ និងបារម្ភពីគេខ្លាំងពេកទេដឹង។

«ហេតុអីក៏នាងក្លាយជាមនុស្សទន់ខ្សោយបែបនេះទៅកើត?»

តើនាងម៉េចនឹងដឹងទៅ បើពេលនេះនាងខ្លាច នាងខ្លាចបាត់បង់មនុស្សដែលនាងស្រឡាញ់នោះណា ព្រោះគេជាស្វាមីរបស់នាង មិនឲ្យនាងបារម្ភយ៉ាងម៉េចទៅ! យ៉ុនហ៊ី នឹកដល់មិត្តរបស់នាងដែលដឹងពីព័ត៌មានថាស្វាមីខ្លួនស្លាប់ នាងបានយំឡើងសន្លប់ នេះប្រហែលជាដូចតែគ្នានោះណា កាលនោះសំណាងដែរដែល ឈីត គេធ្វើជាស្លាប់លេងៗ។

តែពេលនេះគឺស្វាមីរបស់នាងអាចនឹងស្លាប់មែនទែន ដោយសារតែអំណាចអាថ៌កំបាំងនោះក៏ថាបានដែរ យ៉ុនហ៊ី បែរទៅមើលមុខស្វាមីនាងដែលកំពុងតែអស់កម្លាំងកំហែងនោះជាថ្មី រំពេចនោះទឹកភ្នែកក៏បានស្រក់ហូរចេញ

មកយ៉ាងជោគជាំ ធ្វើឲ្យ ឈឹត ត្រូវលួងលោមនាងសាជាថ្មី។

«យីស!!! កាន់តែយ៉ាប់ហើយទៀត បងប្រាប់ហើយតើសថា មិនអីនោះទេណា»

«តើបងអាចសន្យាបានដែរទេថា ប្រាកដជាមិនកើតអីមែននោះ!»

«សន្យាណា បងសន្យាថា នឹងមិនកើតអីនោះទេ ព្រោះជាបងត្រូវតែនៅមើលថែអូន»

«តែពេលនេះអូនសុំមើលថែបងសិនណា បងឈឺត្រង់ណាដែរទៅ?»

«បងមិនឈឺទេណា ដូចជាឈាមប្រឡាក់តិចៗហ្នឹងណា គេងតទៀតទៅណា»

គេសន្យាទៅកាន់ ភរិយារបស់គេទាំងមិនដឹងថាវាយ៉ាងម៉េចផងនោះណា។ គេក៏នឹកដល់ភ្នែកពណ៌ក្រហមដែលឆាបឆេះដូចភ្លើងរបស់ព្រះនាងទេមីន ប្រហែលជាត្រូវដោះស្រាយអំណាចអាថ៌កំបាំងនេះ ឲ្យបានលឿនជាទីបំផុតនោះណា។

**ហាន់ណា ស្តាប់នូវអ្វីដែលនាងត្រូវធ្វើចំពោះទង្វើដែលអាចជួយដល់**មិត្តភក្តិនាងបានយ៉ាងពេញចិត្តតែម្តង ក្រោយពេលបាននិយាយទូរស័ព្ទចរាល់ហើយនោះ នាងក្រឡេកភ្នែកមើលទៅកាន់ស្វាមីរបស់នាង ផ្ទៃមុខពោរពេញទៅដោយស្នាមញញឹម នៅពេលបានឃើញស្វាមីរបស់នាងរៀបចំតុអាហារនាពេលព្រឹកព្រលឹម។ រំពេចនោះ ឈឹត ក៏ងាកមកញញឹមដាក់នាងវិញនៅពេលគេឃើញនាងដើរចូលទៅរកគេ។

«អូនចូលមកនេះមកណា អាហារទាំងនេះសុទ្ធតែអូនចូលចិត្តទាំងអស់ណា បងចាំបានទើបធ្វើជូនអូនញ៉ាំនោះអី»

កែវភ្នែកមួយគូដែលមានមន្តស្នេហ៍នោះ ក្រឡេកភ្នែកមើលទៅកាន់អាហារជាច្រើនដែលរៀបនៅលើតុ ព្រមទាំងមានអាការចង់ក្អួតចេញមក។ ព្រឹកព្រលឹមបែបនេះអ្នកណាទៅញ៉ាំអាហារបែបនេះចូលនោះ សុទ្ធតែអាហារ



ដែលមានជាតិខ្លាញ់ព្រមទាំងបីរទាំងអស់នោះ។

«អឺម!!! អូនធុំក្លិនណាស់ណា ឈឹត»

«ស្អីគេហ្នឹង សាឡាត់សាច់មាន់នេះ បងឃើញអូនញ៉ាំញឹកសឹងអីឯស៊ុបអ៊ីតាលីនេះអូនក៏ញ៉ាំញឹកញាប់ដែរតើស ហើយបបរមូមមិត្តអូនក៏ចូលចិត្តវាខ្លាំងទៀតផង»

ហាន់ណា មិនអាចស្តាប់ស្វាមីរបស់នាងនិយាយរៀបរាប់ពីមុខម្ហូបបានចប់នោះឡើយ វាធ្វើឲ្យនាងកាន់តែចង់ក្អួតកាន់តែខ្លាំង ហើយក៏ត្រូវក្រោកចេញភ្លាមដោយអាការចង់ក្អួតចង្អោរ។

«បានហើយ...អូនមិនចង់ស្តាប់ទេណា មិនចង់ឃើញអាហារទាំងនេះនោះទេ កាន់តែបានឃើញកាន់តែចង់ក្អួត...អ្វកកក!!!»

«ចង់ក្អួតទៀតហើយ ហើយអូនចង់ញ៉ាំអីគេដែរទៅចុះ?»

«អូនរីន! អូនរីន!!»

«ចាស! អ្នកនាង»

«ខ្ញុំសុំរបស់ដែលអ្នកម៉ាក់ខ្ញុំផ្ញើមកពីភូមិបន្តិចមកណា»

«ហឹស!! ម៉ាក់អូនផ្ញើអីគេមកដែរទៅ មានសម្រាប់បងដែរទេ?»

ឈឹត ក្រឡេកភ្នែកទៅកាន់ក្រឡដែលមានផ្លែអំពិលត្រាំដែលអូន រីន បានយួរមកនោះ ព្រមទាំងស្រក់ទឹកមាត់តាមករិយាដែរ គេប្រញាប់លេបទឹកមាត់ចូលទៅវិញយ៉ាងលឿន នៅពេលបានឃើញករិយារបស់គេលើកយកអំពិលត្រាំដាក់ចូលមាត់ធ្វើព្រងើយនោះណា។

«នេះជាផ្លែអំពិលទេតើស តើអូនញ៉ាំវាចូលបានដោយរបៀបណាដែរទៅ»

«ហឺម!!! វាងគ្រាន់បើបន្តិច»

«នេះអូនមិនមានអារម្មណ៍ជូរខ្លះទេអីហ្នឹងហាស់!»

មិនមានចម្លើយឆ្លើយតបពីភរិយារបស់គេសោះឡើយ គឺនាងកំពុងតែតាំងចិត្តតាំងថ្លើមញ៉ាំយ៉ាងមានក្តីសុខនោះណា។ ឈឹត លូកដៃទៅចាប់យកអំពិលត្រាំនោះមួយចំណិតមកញ៉ាំសាកមើលដែរ។

«ហឺស!! ឆ្ងាញ់ដែរតើស»

ហើយពេលនោះ ពួកគេទាំងពីរនាក់ក៏នាំគ្នាយកអំពិលត្រាំនោះមកញ៉ាំយ៉ាងឆ្ងាញ់មាត់ ចំណែកឯអ្នកដែលដើរចេញពីក្រឡអំពិលត្រាំនោះគឺអូន រីន ស្រីបម្រើគេនោះឯង តែនាងក៏សួរមុនពេលចាកចេញទៅផងដែរ។

«លោក ឈីត ចាញ់កូនហ្នឹងគេដែរឬ?»

សម្ដីនេះធ្វើឲ្យភរិយាដែលកំពុងតែញ៉ាំយ៉ាងឆ្ងាញ់មាត់នោះបែរមកមើលស្វាមីរបស់នាងកំពុងតែដណ្ដើមនាងញ៉ាំដូចគេជាអ្នកមានកូនខ្លួនឯងអីចឹង។

«មែនហ្នឹងណា ឈីត បងញ៉ាំញាប់បែបហ្នឹងប្រយ័ត្នអស់ពីក្រឡណា»

«បើអូនចូលចិត្តយើងកុម្ម៉ង់មកថែមទៀតក៏បានដែរណា កុម្ម៉ង់មកឲ្យច្រើននោះអី»

«កុម្ម៉ង់ធ្វើអីច្រើនដែរទៅ?»

«ចុះបងញ៉ាំដែរនោះណា កុំឲ្យអូនរអ៊ូខ្លាចរអស់នោះអី»

ហឹម!!! មើលគេចុះធ្វើមើលតែចាញ់កូនជំនួសប្រពន្ធអីចឹង មិនអីទេណា!! ស្វាមីនាងប្រហែលជាស្រឡាញ់នាងខ្លាំងហើយមើលទៅនោះ គេខំជួយនាងចាញ់កូនដែរនោះណា។

នៅពេលដែលនាងដឹងថា អាការៈចាញ់កូននោះបានគ្រាន់បើជាងមុន នាងក៏នឹកឃើញរឿងសំខាន់ដែលត្រូវធ្វើដើម្បីជួយដល់មិត្តជិតស្និទ្ធរបស់នាង ហើយអ្នកដែលអាចជួយឲ្យនាងធ្វើការកិច្ចនោះបានសម្រេចជោគជ័យបាន គឺជាស្វាមីជាទីស្រឡាញ់របស់នាងហ្នឹងឯងណា។

«ឈីត ពេលយើងញ៉ាំអាហារពេលព្រឹកនេះរួចរាល់ហើយ បងជួយនាំអូនទៅកាន់វត្តអារាមមួយណា»

«តើអូនទៅធ្វើអីនៅទីនោះ?»

«ចាំអូននិយាយឲ្យស្ដាប់នៅក្នុងឡានណា»

«តែអូនប្រាកដថា ទៅរួចទេ?»

«រួចតើស!! ចុះបើទៅជាមួយបងនោះណា ទៅជាមួយបង អូនមិនខ្លាច



កើតអីទេណា»

ឈីត គិតថា ប្រហែលជាទៅទីនោះដោយសារតែរឿងរ៉ាវអាថ៌កំបាំងរបស់ យ៉ុនណា និង ឈីតខាមែន ហើយមើលទៅនោះ។ គេត្រូវតែតាមចិត្តភរិយាគេដូចមុនដដែលនោះណា ព្រោះថា អាការដែលជួយមនុស្សម្នានោះគេក៏ឧស្សាហ៍ធ្វើជាញឹកញាប់នោះណា ហើយ ឈីតខាមែន គឺជាមិត្តភក្ដិដែលជិតស្និទ្ធផងដែរនោះណា។

អ្វីគ្រប់យ៉ាង ត្រូវបានរាយរ៉ាប់ដល់ស្វាមីជាទីស្រឡាញ់របស់នាងដោយមិនមានការបិទបាំងសោះឡើយ ទោះបីជានាងដឹងថា ស្វាមីរបស់នាងជាមនុស្សសម័យថ្មីតែគេក៏តាំងចិត្តស្ដាប់រឿងរ៉ាវអាថ៌កំបាំងរបស់មិត្តនាងព្រមទាំងមិត្តស្វាមីនាងផងដែរ ព្រោះថា គេក៏ដឹងរឿងដែលទាក់ទងជាមួយ ឈីតខាមែន ខ្លះៗដែរនោះណា បើមិនដូច្នេះទេ នាងប្រាកដជាត្រូវហាមឃាត់ព្រោះគិតថាវាជារឿងឥតប្រយោជន៍មិនខាន។

នៅពេលឡានបានមកឈប់ចតនៅមុខចេតិយ៍មួយកន្លែងនោះ ឈីតចុះពីលើឡាននោះយ៉ាងលឿន។ គេនឹងធ្វើជាសសររឹងមាំសម្រាប់ទ្រភរិយាឲ្យឈានជើងចុះពីលើឡានដែលខ្ពស់នោះ រហូតចុះមកក្រោមជាការស្រេច។ ភ្នែកក្រឡេកមើលទៅកាន់បរិវេណជុំវិញចេតិយ៍មួយនោះ ដែលមិនមានមនុស្សមកកាន់សោះឡើយ អាចមកពីព្រឹកពេកឬក៏មានការប្រែប្រួលអីមួយក៏មិនដឹងនោះណា។

«តោះទៅ បងជាអ្នកនាំអូនទៅខាងក្នុងណា»

«តែមនុស្សស្រីជនជាតិអ៊ីស្លាមដែលតែលតោលនោះ នៅត្រង់ណានៃចេតិយ៍នេះដែរទៅ?»

«មិនអីទេណា ចាំបងទៅសួរព័ត៌មានបន្ថែមពីកូនចៅរបស់បងក៏បានដែរ អូននៅចាំទីនេះសិនណា!»

«កុំអីណា ឈីត»

«ហេតុអីទៅ! កុំឲ្យខាតពេលច្រើននោះណា»

«ឈើត!! បងកុំភ្លេចថា យើងកំពុងតែនៅក្នុងសភាពវិលវល់ណា»

ឈើត គិតទៅមែនហ្នឹងណា គេភ្លេចឲ្យឈឹងតែម្តង ចុះបើមនុស្សដូចជាគេរស់នៅជាមួយនឹងសម្ភារទំនើបថ្មីៗរហូតមកនោះណា តាំងពីកើតមកគេទើបតែបានជួបអ្វីដែលប្លែកគឺលើកនេះហ្នឹងឯងណា។

«ហើយចុះអូននឹងធ្វើយ៉ាងណាបន្តទៀតដែរទៅ?»

«ប្រហែលជាអូនដើរចូលទៅក្នុងចេតិយ៍នោះខ្លួនឯងហើយ អូនជឿជាក់ថា មិនយូរប៉ុន្មាននឹងបានជួបជាមួយមនុស្សស្រីជនជាតិអ៊ីស្លាមនោះជាមិនខាន»

ឈើត ក្រកងគរិយារបស់គេមិនឲ្យឃ្លាតទៅណាឆ្ងាយឡើយ ហើយក្អែកមើលទៅជុំវិញបរិវេណចេតិយ៍នោះផងដែរ។

ពួកគេទាំងពីរនាក់នាំគ្នារកមើលមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះរហូតទាល់តែមានអាការនឿយហត់ទើបឈប់សម្រាក ឈើត អត់ទ្រាំមិនបានម្តងរិយាដែលកំពុងតែមានផ្ទៃពោះនោះមិនបាន។

«តើទៅរួចដែរទេ នេះអូនបានដើរបីជុំមកហើយណា»

«រួចណា! យ៉ាងណាក៏ត្រូវតែរួចដែរ»

«អូនអង្គុយសម្រាកនៅទីនេះសិនណា ចាំបងចេញទៅយកទឹកមកឲ្យញ៉ាំ»

ហាន់ណា ងក់ក្បាលទទួល នាងមានអារម្មណ៍ពិបាកចិត្តមែនទែន ហេតុអីក៏មិនឃើញ សូម្បីតែស្រមោលរបស់មនុស្សស្រីជនជាតិអ៊ីស្លាមនោះអីចឹង រួចក៏នឹកឃើញអ្វីម្យ៉ាង ព្រមទាំងញញឹមចេញមក

«មែនហ្នឹងណា!! ខ្ញុំត្រូវតាំងចិត្តស្ងប់គិតពីកូនក្នុងផ្ទៃ ភ្លេចទៅកើតខ្ញុំ!»

នាងយកដៃទៅអង្អែលត្រង់ពោះរបស់នាង ហើយក៏និយាយខ្សឹបៗចេញមក ពេលនោះមានអារម្មណ៍ថា ខ្យល់បក់មកត្រជាក់ស្រិបតែម្តង តែមាត់របស់ស្រីស្រស់នៅតែនិយាយខ្សឹបបន្តះ

«កូន!! កូនជួយនាំផ្លូវម៉ាក់ទៅរកមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះ



បន្តិចទៅណាកូន!! យើងកំពុងតែជួយដល់មនុស្សដែលទទួលរងកម្មលំបាកវេទនាណាកូន!!»

រំពេចនោះសំឡេងតន្ត្រីលាន់ឮយ៉ាងរងំ ហាន់ណា ក្រោកឈរឡើង នាងក្រឡេកក្អែកមើលទៅកាន់ប្រភពសំឡេងនោះ ពេលនោះក៏ឃើញមនុស្សស្រីម្នាក់ដើរទៅខាងក្រោយចេតិយ៍នោះបាត់ នាងស្រែកហៅព្រមទាំងរត់តាម។

«ឈប់សិនណា ឈប់សិន»

នៅពេលរត់ចូលកាន់តែជិត នាងពិតជាសប្បាយចិត្តជាខ្លាំងដែលបានឃើញមុខមនុស្សស្រីនោះ ស្បែករបស់នាងរាងស្រគាំ សម្លៀកបំពាក់ស្រដៀងនឹងជនជាតិឥណ្ឌា ស្រដៀងប៉ាគីស្ថានដែលមានចងក្បាល នេះជាលក្ខណៈរបស់មនុស្សស្រីជនជាតិអ៊ីស្លាមនោះទេតើស។

«សុំទោសណា នាងគឺជាជនជាតិអ៊ីស្លាមមែនដែរទេ?»

«ជីវិតបរិសុទ្ធនាំឯងមកទីនេះហើយ»

ហាន់ណា លើកដៃអង្អែលពោះនាង ហើយញញឹមដាក់មនុស្សស្រីនោះ នាងមើលទៅកាន់មនុស្សស្រីដែលមានអំណាចអាថ៌កំបាំនោះ ដោយមិនមានការភិតភ័យអ្វីសោះឡើយ។

«ត្រូវហើយ!! ជីវិតបរិសុទ្ធរបស់កូនខ្ញុំ ចង់ជួយមនុស្សដែលកំពុងតែទទួលទុក្ខសោក ត្រូវអំណាចអាថ៌កំបាំងមួយគ្រប់គ្រង។ សូមមេត្តាជួយដល់ពួកយើងផងទៅ»

ហាន់ណា សម្លឹងមើលមនុស្សស្រីនោះដែលកំពុងតែសើចយ៉ាងក្អាក-ក្អាយព្រមទាំងនិយាយភាសាដែលនាងមិនសូវជាយល់ប៉ុន្មាននោះណា។

«ហាៗៗៗ ដល់ពេលដែលក្រសែចិត្តនឹងត្រូវរលត់ហើយ រាហូចាប់ច័ន្ទបានចាំងបិទងងឹតឈឹង ជីវិតបរិសុទ្ធនោះបានរំលាយមន្តគ្រានោះដោយភ្លើង»

«នៅពេលដែលរាហូចាប់ច័ន្ទបានចាំងបិទ ជីវិតបរិសុទ្ធនោះបានរំលាយមន្តគ្រាដោយភ្លើង»

ហាន់ណា ដឹងខ្លួនសាជាថ្មីនៅពេលមានសំឡេងមួយមកហៅនាង ព្រម

ទាំងប៉ះពីដៃមនុស្សម្នាក់ ដែលយកក្រណាត់ជូតនៅត្រង់មុខត្រង់ភ្នែករបស់នាង នាងចាប់ផ្ដើមបើកភ្នែកឡើងយ៉ាងងឿងឆ្ងល់ នឹកមិនចេញទាល់តែសោះថានាងបានបាត់ស្មារតីតាំងពីពេលណា។

«ហាន់ណា! ហាន់ណា! អូនកើតអីហ្នឹង»

«ឈើត!! ចុះមនុស្សស្រីជនជាតិអ៊ីស្លាមនោះ»

«មនុស្សស្រីជនជាតិអ៊ីស្លាម...ចុះព្រែងយើងកំពុងតែតាមរកនាងអី»

ឈើត ជូតមុខមាត់ខ្លួនប្រាណរបស់នាង ហើយគ្រាន់តែមួយភ្លែតប៉ុណ្ណោះ នាងក៏គេងលក់ទៅ ហៅយ៉ាងណាក៏មិនដឹងខ្លួនវិញដែរ ធ្វើឲ្យគេភ័យស្ទើរស្លាប់។

«ពុទ្ធោ!! អូនគិតច្រើនពេករហូតដល់ថ្នាក់ខ្យល់ចាប់ហើយ»

«អូននេះកើតខ្យល់?»

«ត្រូវហើយ បើបងហៅយ៉ាងណាក៏មិនដឹងខ្លួនសោះនោះ មិនបានទេ!! បងនឹងនាំត្រឡប់ទៅផ្ទះយើងវិញណា»

តើនាងយល់សប្តិតែម្នាក់ឯងទេឬ! តែវាហាក់ដូចជាការពិតមែនទែន ស្រីស្រស់ចាប់ផ្ដើមគិតសាជាថ្មី នាងមកទីនេះគឺដើម្បីរកមនុស្សស្រីជនជាតិអ៊ីស្លាមដែលជាជនអាថ៌កំបាំងមែនហ្នឹងណា! ព្រោះជារឿងអាថ៌កំបាំងនោះហើយទើបឲ្យនាងបានជួបនូវអ្វីដែលអាថ៌កំបាំងហ្នឹងណា។

«ឈើត!! អូនបានជួបមនុស្សស្រីជនជាតិអ៊ីស្លាមនោះហើយ»

«អូនបានជួបហើយ! នៅឯណាដែរទៅ បងគ្មានឃើញអ្នកណាផងហ្នឹង»

«មានតើស! អូនបាននិយាយជាមួយនាងផងដែរណា!»

ហាន់ណា អត់ទ្រាំមិនសើចចំពោះទឹកមុខស្វាមីនាងមិនបាន ដែលមនុស្សខួរក្បាលសម័យថ្មីដូចជាគេ ត្រូវមកជួបរឿងដែលមិនគួរឲ្យជឿបែបនេះនោះ។ រំពេចនោះសំឡេងស្រួយស្រែសក៏បានលាន់ឮឡើង។

«អូនជួបក្នុងសុបិននោះណា ឈើត»

«នេះកុំប្រាប់ឲ្យសោះថា ពេលដែលអូនគេងលង់លក់ហៅមិនភ្ញាក់នោះ



ព្រោះតែ...»

«ត្រូវហើយព្រោះអំណាចអាថ៌កំបាំងនោះ ធ្វើឲ្យអូនបានជួបជាមួយមនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះ កូនរបស់យើងជាអ្នកជួយអូន»

«ល្អើយចុះ! ល្អើយចុះ! បងយល់ហើយណា នេះបងអាចនាំអូនទៅផ្ទះវិញបានហើយមែនទេ?»

«តោះយើងនាំគ្នាទៅ អូនមានរឿងត្រូវពិភាក្សាជាមួយបងផងដែរណា»

នាងចាប់ផ្ដើមមានអាការៈចង់តែក្អួតចង្អោរយ៉ាងម៉េចមិនដឹងទេនៀក។ តើភរិយាគេដឹងដែរទេហ្ន៎! ថាគេស្ទើរតែដាច់ដង្ហើមនៅពេលបានឃើញនាងគេងស្ដូកស្ដឹងដាស់មិនព្រមដឹងខ្លួនបែបហ្នឹងនោះណា។ មកពីគេមិនមែនជាមនុស្សដែលឃើញតែប្រយោជន៍ផ្ទាល់ខ្លួន បានជាគេមិនហាមឃាត់ ហើយក៏មិនរាំងភរិយារបស់គេចូលទៅពាក់ព័ន្ធនឹងអំណាចអាថ៌កំបាំងនោះដែរ ដែលតាមចិត្តពិតគេពិតជាមិនចង់ឲ្យពាក់ព័ន្ធសោះឡើយ។

ឈើត បានត្រឹមតែសុំអង្វរភរិយារបស់គេឲ្យនាងគេងសម្រាកតែប៉ុណ្ណោះ ដោយគេមិនព្រមស្ដាប់ និងពិភាក្សាអ្វីៗទាំងអស់ គេមើលរាងកាយភរិយារបស់គេដែលកំពុងតែគេងលក់យ៉ាងស្ងប់ស្ងាត់ព្រមទាំងគិតថា ភរិយា និងកូនរបស់គេនឹងមិនអាចជួបនឹងអំណាចអាថ៌កំបាំងនោះទៀតឡើយ។

ឈើត ដាក់ភ្នែកពីការងារដែលកំពុងតែបំពេញ នៅពេលក្រឡេកទៅឃើញភរិយារបស់គេកំពុងតែដើរសំដៅចូលមក មានអារម្មណ៍ចម្លែកចិត្តចំពោះនាងមែនទែនតែម្ដងដែលកាលពីណាពីណីមកនាងមិនដែលចេះចូលមកក្នុងបន្ទប់ការងាររបស់គេម្ដងណាឡើយ ហើយតើថ្ងៃនេះមានអ្វីកើតឡើងបានជានាងមកទីនេះ។

«អូនក្រោកហើយ?»

«ហេតុអីក៏បងមិនព្រមដាស់អូន នេះវាល្ងាចហើយណា»

«ចុះបើបងឃើញអូនហត់នឿយពេញមួយថ្ងៃហើយនោះណា»

«តែអូនត្រូវតែទៅរក យ៉ុនហ៊ី ណា ឈើត»

«អូនចុចទៅនិយាយដូចកាលលើកមុនបានតើស ហេតុអីក៏ចាំបាច់ទៅរកធ្វើអីដែរទៅ?»

ផ្ទៃមុខស្រស់ស្អាតនោះក្រញូវក្រញាមនៅពេលត្រូវបានស្វាមីទាស់ចិត្ត តើចុចទៅនិយាយគ្នាយ៉ាងម៉េច បើនាងមិនទាន់យល់អត្ថន័យ ដែលមនុស្សស្រីជនជាតិអ៊ីស្លាមនោះនិយាយចេញមកមិនទាន់បានផង?

«មិនបានទេណា រឿងមួយនេះពិតជាសំខាន់ណាស់ យ៉ុនហ៊ី ព្រមទាំងឈើតខាមែន អាចទទួលគ្រោះថ្នាក់បានណា»

«តែផ្លូវធ្វើដំណើរទៅកាន់សេតវិមានរបស់ ឈើតខាមែន នៅមិនទាន់អាចឲ្យឡានទៅបានឡើយ»

«តែអូនត្រូវតែទៅ!»

ឈើត ក្រោកឡើងព្រមទាំងទាញភរិយាមកឱប គេពិតជាដឹងពីចរិតរឹងទទឹងរបស់ភរិយាបានល្អណាស់។ គេឃាមនាងមិនបាន មានតែជាគូនាទីរបស់គេទៀតហើយដែលត្រូវជួយនាង។

«ឯណា! មើលអូនសាកនិយាយរៀបរាប់ប្រាប់បងបន្តិចមកថា មនុស្សស្រីជនជាតិអ៊ីស្លាមនោះនិយាយអីខ្លះ?»

ផ្ទៃមុខស្រស់ស្អាតដែលជ្រកក្រោមដើមទ្រូងរបស់ស្វាមីបានសញ្ជឹងគិត ហើយងើបមុខឡើងមើលស្វាមីនាង ព្រមទាំងសំឡេងដែលមានភាពសង្ស័យក៏លាន់ឮឡើងចេញពីមាត់របស់នាង។

«ក្រសែចិត្តបានរលត់ទៅ នៅពេលដែលរាហូចាប់ច័ន្ទបានបាំងបិទងងឹតស្លុប វាមានន័យថាម៉េចទៅ?»

ចប់សំឡេងនោះ ធ្វើឲ្យអ្នកជំនួញជួញដូរធំដុំដែលមានភាពវៃឆ្លាតនោះ គិតដល់ថ្នាក់ស្ពឹកខួរក្បាលតែម្ដង។

«ក្រសែចិត្តវាទាក់ទងជាមួយនឹងឧបករណ៍វម្ខាប់ចិត្តនៅក្នុងបន្ទប់ពេទ្យមែនទេ?»

«នែ ឈើត! អូនជាអ្នកសួរណា នេះបងបែរជាមកសួរអូនទៅវិញ»



យ៉ាប់ហើយនៀក!!! ឈើត នៅស្ងៀមមួយសន្ទុះ មុននឹងនិយាយយកចិត្តភរិយាជាទីស្រឡាញ់។

«រាហូចាប់ច័ន្ទ គួរណាតែយកមកដាក់ជាឈ្មោះរបស់កូនយើងបានណា»

«ឆ្កួតទេអី! ឈ្មោះដូចតួល្ខោនបែបនេះនោះមិនដាក់ឲ្យកូនទេ»

ស្រីស្រស់មុខក្រញូវដែលស្វាមីរបស់នាងតែងតែទាស់ចិត្តនាងគ្រប់ពេលមនុស្សកំពុងតែប្រើការគិតផងមកនិយាយក្រៅរឿងបែបហ្នឹងទៅកើតដែរ!

«ទំ ឈើត! អូនសង្ស័យថា មកពិភាក្សាជាមួយបង តែបែរជាមិនដឹងរឿងអីសោះទៅវិញ»

«ហឹម!!! ចុះអូនមិនសួរបងពីតម្លៃអាត្រាលុយវិញទៅ ទាក់ទងនឹងការរកស៊ីបងជំនាញជាងណា»

«នេះបងនិឲ្យអូនខឹងទៀតហើយណា!»

«បងមិនបាននិទេណា ចុះបើបងមិនមែនជាអ្នកបួសឯណាទៅដឹងរឿងទាក់ទងជាមួយនឹងអំណាចអាថ៌កំបាំងអីនោះ»

មែនហើយ!! គេម៉េចហ្នឹងក្លាយជាអ្នកបួសបានទៅ បើមួយថ្ងៃគិតតែពីរឿងលើគ្រែមិនចេះចប់សោះ នេះដល់ថ្នាក់នាងមានផ្ទៃពោះគេនៅមិនចង់លើកលែងដែរណា។

ស្វាមីមើលទៅកាន់មុខក្រញូវរបស់ភរិយា ដែលអង្គុយស្ងៀម នាងកំពុងតែគិតអីដែរទៅហ្ន! តើគេអាចយកចិត្តភរិយាគេយ៉ាងណាទៀតដែរទៅ អស់ផ្លូវល្បួងចិត្តនាងហើយ។

«ណ្ហើយចុះ ណ្ហើយចុះ! អូនមានរឿងចង់ពិភាក្សាជាមួយបង និយាយមកណា»

«បងប្រាកដហើយឬថា នឹងអាចជួយអូនបាន?»

«សាកនិយាយមក!»

ស្រីស្រស់នឹកដល់ចំពោះពាក្យសម្ដីរបស់មនុស្សស្រីជនជាតិអ៊ីស្លាមនោះសាជាថ្មី ទោះបីមិនសូវប្រាកដចិត្តថា ស្វាមីរបស់នាងនឹងអាចជួយនាងបាន

ដូចដែលគេនិយាយនោះឬក៏អត់ក៏ដោយចុះ។

«ជីវិតបរិសុទ្ធ បញ្ចេញកម្លាំងគ្របដណ្ដប់អំណាចមន្តត្រា នោះបានដោយភ្លើង»

«ជីវិតបរិសុទ្ធនោះ គឺកូនរបស់យើងនោះអី»

«អូនដឹងតាំងពីយូរហើយណា អាពាក្យហ្នឹងនោះ»

ទាស់ចិត្តមែនទែននៀក ហេតុអីក៏គេចូលចិត្តធ្វើឲ្យនាងក្ដៅក្រហាយតែរហូតបែបនេះនៀក ?។

ស្វាមីសង្ហាព្យាយាមប្រែពាក្យដែលភរិយានិយាយមកប្រាប់គេនោះ ដើម្បីហាមឃាត់មិនឲ្យភរិយារបស់គេទៅសេតវិមានរបស់ ឈើតខាមែន បាន។

«ពាក្យបន្តទៅទៀត កម្លាំងរំលាយ...អីគេដែរទៅ ហាន់ណា ?»

«ជីវិតបរិសុទ្ធបញ្ចេញកម្លាំងរំលាយអំណាចមន្តត្រាបានដោយភ្លើង»

«វាប្រាកដជាទាក់ទងនឹងកម្លាំងថាមពលព្រះអាទិត្យ ប្រាកដជាមានអីទាក់ទងនឹងទំនប់ថាមពលព្រះអាទិត្យជាក់ជាមិនខានឡើយ»

ហើយរំពេចនោះសំឡេងស្រួយស្រែសក៏បានលាន់ឮឡើងភ្លាមផងដែរ។

«ឈើត !!»

តើគេនិយាយអីខុស! ឈើត បានមើលទៅកាន់ភរិយាដែលមើលទៅនាងដូចជាកំពុងរម្ងាប់អារម្មណ៍ខឹងដល់ទីបំផុតហើយ!!! ចំជាស្វាមីពិបាកមែនទែនតែម្ដងហើយនៀក ត្រូវតាមចិត្តនាងទៀតហើយមើលទៅនោះ។

«អូនកុំខឹងអីណា កំពុងតែមានផ្ទៃពោះណា»

«អូនខឹងគឺព្រោះតែបងហ្នឹងឯង !»

មិនបានដូចចិត្តទាល់តែសោះ ស្រីស្រស់គិត គ្រាន់តែនាំនាងទៅកាន់សេតវិមានរបស់ ឈើតខាមែន បន្តិចក៏មិនបានដែរ។ រំពេចនោះសំឡេងខឹងក៏បានលាន់ឮឡើង។

«អូនគ្រាន់តែចង់ឲ្យបងជូនទៅកាន់សេតវិមានរបស់ ឈើតខាមែន ប៉ុណ្ណឹងបងធ្វើមិនបានឬយ៉ាងណា ?»



«ណ្ហើយចុះ ណ្ហើយចុះ ! បងនឹងជូនអូនទៅក៏បានដែរ តែទាល់តែស្អែកណា»

«ហេតុអីក៏ទៅទាំងយប់នេះមិនបានដែរទៅ»

«បើសិនជាចង់ទៅមែនទែននោះ ត្រូវប្រើយន្តហោះផ្ទាល់ខ្លួនរបស់បងដូច្នេះត្រូវតែប្រាប់ឲ្យកូនចៅត្រៀមឲ្យរួចមុនចេញដំណើរណាដើម្បីសុវត្ថិភាពហើយពេលនេះព្រិលក៏កំពុងតែធ្លាក់ដែរ ទម្រាំតែដល់ស្អែកវានឹងអាចរលាយអស់»

គ្រាន់តែប៉ុណ្ណឹងអស់បញ្ហាទៅហើយ ព្រោះតាំងពីណាពីណាមកនាងមិនដែលចាញ់គេម្ដងណាឡើយ មិនថាជារឿងអ្វីក៏ដោយ ហេតុអីក៏គេនៅមិនដឹងទៀត នៅតែធ្វើឲ្យនាងខឹងជារឿយៗតែម្ដង ប្ដីសម្លាញ់ខ្ញុំអើយ!!

«បងសុំមើលព័ត៌មានសិនណា ចាំយើងនាំគ្នាទៅគេង»

«អូនទើបតែក្រោក ឲ្យគេងទៀតហើយ ?»

«បើអូនមិនទាន់ងងុយទេ យើងនាំគ្នាធ្វើអីផ្សេងក៏បានដែរតើស»

ថាហើយថា គេសរុបគ្រប់រឿងមកទម្លាក់លើរឿងលើគ្រែពិតមែន រឿងបែបហ្នឹងពូកែខាងនិយាយ និងប្រតិបត្តិណាស់។

«ធ្វើអី ក្រែងបងហាមអូននោះអីថា មិនឲ្យធ្វើអីដែលរង្គោះរង្គើដល់កូនក្នុងផ្ទៃនោះអី នេះបងនៅមក...»

«បងដឹងណាធ្វើក្បាច់បែបណាភាររង្គោះរង្គើ ក្បាច់បែបណាមិនរង្គោះរង្គើនោះ»

ឈើស!! ឃើញរង្គោះរង្គើគ្រប់តែក្បាច់នោះ នាងជ្រួញមុកស្វាមីរបស់នាងដែលគេធ្វើជាចាប់អារម្មណ៍លើព័ត៌មាន មុននឹងនាងងាកទៅមើលព័ត៌មានដែលកំពុងតែបញ្ចាំងនោះដែរ ធ្វើឲ្យនាងចាប់អារម្មណ៍វាភ្លាមដែរ។

«ព័ត៌មានអំពីសូរ្យគ្រាសឬ ?»

«ត្រូវហើយ ព្រឹកនេះហើយណា»

«បើអីចឹង អូននឹកឃើញហើយណា»

«នឹកឃើញ! នឹកឃើញអីដែរ?»

ឈិត មើលសកម្មភាពដែលភរិយារបស់គេសប្បាយចិត្តនោះព្រមទាំងគិតក្នុងចិត្ត។ ព្រឹត្តិការណ៍រាហូចាប់ច័ន្ទជាព្រឹត្តិការណ៍ធម្មជាតិមួយតែហេតុអីក៏ព្រឹត្តិការណ៍នេះបែរជាមានអាថ៌កំបាំងបែបនេះទៅវិញ។

បុរសសង្ហាដកដង្ហើម ព្រមទាំងសរុបសេចក្ដីដោយខ្លួនឯង ព្រោះវាជាហេតុការណ៍អាថ៌កំបាំងមិនទាន់មានដំណោះស្រាយដែលបានកើតឡើងពិតៗក្នុងគ្រួសាររបស់គេ ហើយចាប់ពីពេលនេះតទៅប្រហែលជាគេត្រូវជួយដល់ភរិយារបស់គេឲ្យនាងបានជួយមនុស្សរួចផុតពីទុក្ខ តាមបំណងប្រាថ្នារបស់នាង។

«អូនមានន័យថា ថ្ងៃស្អែកនេះនឹងមានហេតុការណ៍អីមួយកើតឡើងឬ?»

«មែនហើយ ហើយប្រាកដជាហេតុការណ៍ដែលកើតឡើងក្នុងផ្លូវល្អផងដែរណា»

ដៃទន់ភ្លន់របស់នាងអង្អែលពោះព្រមទាំងដកដង្ហើមធំ។ នាងមានជំនឿជាក់លើខ្លួនឯងភ្លាមថា ខ្លួននាង និងកូនប្រាកដជាអាចជួយមិត្តភក្តិបានជាក់ជាមិនខានឡើយ ដោយមិនខ្វីខ្វល់ពីកែវភ្នែកបារម្ភហួងហែងរបស់ស្វាមីនាងនោះឡើយ។

**នៅពេលពាក់កណ្ដាលយប់ងសេតវិមាន ដែលតាំងនៅលើផ្ទៃដីដ៏ធំ** ល្វឹងល្វើយមួយកន្លែងកំពុងតែធ្លាក់ក្នុងអំណាចអាថ៌កំបាំង របស់ព្រះនាងទេមីន។ ដោយសារតែកំហឹងទើបបានជាក្រសែចិត្តរបស់ព្រះនាងកើនឡើងរាប់រយពាន់ដង ធ្វើឲ្យដើមឈើនៅក្បែរសេតវិមាននោះបក់បោកជាខ្លាំងមួយទំហឹងនៃកំហឹងនោះតែម្ដង។

សត្វស្លាបមួយមានភ្នែកពណ៌ក្រហមឆ្អាំង ដោយសារតែអំណាចនៃកំហឹងរបស់ព្រះនាង។ រំពេចនោះទ្វារនៃសេតវិមានក៏របើកឮសូរគ្រាំងៗ។



ឈិតខាមែន ក្រោកឈរឡើងព្រមជាមួយនិងភរិយារបស់គេ ពួកគេទាំងពីរនាក់មើលមុខគ្នាបញ្ជាក់ថា ពួកគេដឹងច្បាស់ថា នឹងកើតមានហេតុការណ៍អីឡើងនោះ។ ក្នុងខួរក្បាលរបស់គេកំពុងតែគិតថា ត្រូវតែជួយដោះភរិយារបស់គេឲ្យរួចផុតពីអំណាចមន្តគាថាមួយនេះឲ្យបានដោយរបៀបណាទៅ។

«អូនមិនខ្លាចអំណាចនោះមែនទេ យ៉ុនហ៊ី?»

«ខ្ញុំ...ខ្ញុំមិនខ្លាចទេ តែខ្ញុំបារម្ភពីបងជាងណា»

យ៉ុនហ៊ី គិតថា នាងខ្លាចខ្មោចឡើងលែងខ្លាចទៅហើយ នាងមានអារម្មណ៍ដឹងច្បាស់ថា បើខ្លាចអីតែងបានជួយហ្នឹង ព្រោះនាងបានជួបខ្មោច និងអំណាចមន្តគាថាអាថ៌កំបាំងនោះស្ទើរតែរាល់ថ្ងៃនោះណា វាប្រហែលជាហួសភ័យខ្លាចហើយមើលទៅនោះ ពេលនេះនាងខ្លាចតែស្វាមីនឹងចាកចោលនាងទៅតែប៉ុណ្ណោះឯង។

«បងបានសន្យាជាមួយអូនហើយថា មិនចាកចោលអូនឡើយ»

«អូនកុំខ្លាចអីណា មិនថាមានអ្វីកើតឡើងក៏ដោយក៏បងមិនទុកអូនចោលតែម្នាក់ឯងជាដាច់ខាត»

រូបភាពដែលស្វាមីរបស់នាងបានហូរឈាមតាមច្រមុះនៅជិតជាមជាប់នឹងកែវភ្នែករបស់នាងនៅឡើយ ហេតុអីបានជាព្រះនាង ទេមីន ធ្វើបាបស្វាមីដែលមកចាប់ជាតិថ្មីរបស់ព្រះនាងទៅកើត។

«ហេតុអីក៏ព្រះនាងទេមីន មិនធ្វើបាបអូន?»

«ប្រហែលមកពីអូនគឺជា រាងកាយ និងចិត្តវិញ្ញាណរបស់ព្រះនាងហើយមើលទៅនោះ»

«ព្រះនាងស្រឡាញ់បងសឹងអី ហេតុអីក៏ព្រះនាងខឹងបងខ្លាំងបែបនេះធ្វើអីដែរទៅ?»

«គឺប្រហែលជាដូចអូននិយាយហ្នឹងណា មកពីបងបានទាស់ព្រះទ័យរបស់ព្រះនាងធ្វើឲ្យព្រះនាងក្រេវក្រោធ»

«អ្វីដែលបងនិយាយចេញមកវាជាការពិតថា បងជាមួយព្រះនាងបាន

រស់នៅពិភពផ្សេងគ្នាហើយណា»

ប្រហែលជាមិនមានពេលវេលាឯណា មកអង្គុយអធិប្បាយនោះឡើយគេហាក់ដូចជាមានអារម្មណ៍ថា ក្រសែចិត្តរបស់ព្រះនាងលាន់ឮមកកាន់តែខ្លាំងក្នុងសរសៃប្រសាទគេ។

**«ព្រះស្វាមីរបស់ខ្ញុំម្ចាស់ព្រះអង្គអស់ចិត្តស្រឡាញ់ខ្ញុំម្ចាស់មិនបានឡើយ ខ្ញុំម្ចាស់ត្រូវការព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ត្រូវយាងទៅនៅក្នុងភពរបស់ខ្ញុំម្ចាស់!»**

នៅពេលដែលក្រសែចិត្តរបស់ ឈើតខាមែន យល់ពីគោលបំណងរបស់ព្រះនាងទេមីន គេក៏ប្រញាប់បែរទៅប្រាប់គរិយារបស់គេមុននឹងតាំងសតិស្មារតីយ៉ាងមោះមុត។

«ចូរអូនធ្វើដូចកាលពីលើកមុនណា យល់ដែរទេ ត្រូវតែតាំងចិត្ត តាំងសមាធិនឹកដល់អ្វីដែលអូនជឿជាក់លើខ្លួនឯងនោះណា»

«ចាស ! អូនជឿបង តែបងវិញ...»

«បងប្រាប់អូនហើយថា មិនចាំបាច់បារម្ភពីបងនោះទេណា»

«ឈើតខាមែន! អូន...»

ហេតុអីក៏ស្រីស្រស់បែរជាមនុស្សទន់ជ្រាយបែបនេះទៅវិញ រំពេចនោះសំឡេងគ្រលរបស់ស្វាមីនាង បានលាន់ឮឡើងដាស់សតិអារម្មណ៍របស់នាងភ្លាម។

«អូនកុំគិតអ្វីច្រើនឲ្យសោះណា វាអាចធ្វើឲ្យចិត្តរបស់អូនប្រែទៅជាទន់ខ្សោយបាន»

«ចាស ចាស អូននឹងតាំងសមាធិឥឡូវនេះហើយណា»

ពួកគេទាំងពីរនាក់នាំគ្នាបិទភ្នែកតាំងសមាធិ ហើយរំពេចនោះការតាំងសមាធិរបស់គេក៏បានបំផ្លាញដោយសំឡេងគ្រលួចៗ នៃអំណាចរបស់ព្រះនាង ទេមីន ចូលក្នុងប្រព័ន្ធប្រសាទរបស់គេ ធ្វើឲ្យគេមិនអាចតាំងសមាធិសូត្រមន្តគាថាបានឡើយ។ ប្រុសសង្ហាហាក់បីដូចជាមានអារម្មណ៍ថា មានអំណាចអ្វីមួយមកសង្កត់រហូតដល់ផកដង្ហើមមិនរួច។



យ៉ុនហ៊ី មានអារម្មណ៍ថា មានភាពខុសប្រក្រតី គឺដៃរបស់ស្វាមីនាងដែលបានប្រទាក់គ្នាជាមួយដៃនាងនោះ ហាក់ដូចជាខុសប្លែកព្រមទាំងទាញចេញពីដៃនាងផងដែរ ទើបនាងបើកភ្នែកភ្លាម ហើយក៏ស្លុតចិត្តជាខ្លាំងនៅពេលឃើញស្វាមីរបស់នាងយកដៃខ្ទប់ក្បាលលក្ខណៈដូចជាឈឺចាប់យ៉ាងខ្លាំងនោះ។

«បង!! បងកើតអីគេ!!»

«បង...ដកដង្ហើមមិនចេញទេ»

មែនហ្អឹងណា! អំណាចអាថ៌កំបាំងនោះកំពុងតែធ្វើបាបស្វាមីរបស់នាងហើយ តើនាងម៉េចនឹងអាចព្រមបាត់បង់ស្វាមីនាងទៅដោយងាយៗនោះ។

«កុំធ្វើអីស្វាមីទូលបង្គំអីណាព្រះនាងទេមីន!!»

ដោយសារតែចិត្តមោះមុតក្នុងការតាំងស្មារតីការពារស្វាមី ធ្វើឲ្យនាងបានដឹងពីក្រសែចិត្តនៃព្រះនាង ទេមីន ថាទ្រង់មានគោលបំណងអ្វី។

**«ព្រះស្វាមីរបស់ខ្ញុំម្ចាស់ ព្រះអង្គអស់ចិត្តស្រឡាញ់ខ្ញុំម្ចាស់មិនបានឡើយ ខ្ញុំម្ចាស់ត្រូវការព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ត្រូវយាងទៅនៅក្នុងភពរបស់ខ្ញុំម្ចាស់!»**

ពេលនេះមនុស្សដែលខ្លាចខ្មោចបំផុត បែរជាគិតសាកល្បងប្រឡងជាមួយនឹងខ្មោច ដែលគិតចង់ធ្វើបាបពង្រាត់ស្វាមីជាទីស្រឡាញ់របស់នាងចេញ។ ហើយរំពេចនោះមានសំឡេងនិយាយជាច្រើនចេញមកពីមាត់របស់នាងដោយសារតែការបារម្ភ។

«ខ្ញុំនឹងមិនព្រមឲ្យក្រសែចិត្តរបស់ព្រះនាងមកធ្វើបាបមនុស្សដែលអូនស្រឡាញ់ដាដាច់ខាត យើងពីរនាក់គឺរស់នៅក្នុងភពរបស់យើង កុំមករញ៉េរញ៉ៃជាមួយយើងពីរនាក់ទៀតឲ្យសោះ»

«យ៉ុន...ហ៊ី...»

យ៉ុនហ៊ី បែរមកចាប់អារម្មណ៍លើស្វាមីរបស់នាងដែលយកដៃខ្ទប់ក្បាលជាប់ដោយសភាពទារុណទារាយ៉ាងខ្លាំង ឈាមក៏ហូរចេញពីច្រមុះរបស់គេជាបន្តបន្ទាប់ ហើយគេក៏ដួលសន្លប់នៅចំពោះមុខនាងតែម្តង។

«ឈើតខាមែន! ឈើតខាមែន! បងកុំកើតអីឲ្យសោះណា ក្រែងបងបាន

សន្យាជាមួយអូនហើយនោះអីថា នឹងមិនចាកចោលអូន!!!»

ភាពវឹកវរនោះបានស្ងប់ស្ងាត់ តែសំឡេងខ្សឹកខ្សួលយំបែរជាមកជំនួស ព្រម ជាមួយនឹងថ្ងៃថ្មីបានឈានមកដល់។ ព្រះអាទិត្យចាំងចែងស្មើ តែបែរជាធ្វើឲ្យអ្វី គ្រប់យ៉ាងក្នុងចិត្តរបស់ យ៉ុនហ៊ី បែរជាងងឹតសូន្យសុង។

ដៃទន់ភ្លន់របស់នាង ជូតទឹកភ្នែកព្រមទាំងទ្រូបមុខទៅលើមុខរបស់ ឈើតខាមែន ដែលគេងនៅលើពូកនោះដោយសភាពវេទនា នាងខ្លាចថា គេនឹង ចាកចោលនាង។

«មិនទេ!! ក្រែងបងសន្យាជាមួយអូនហើយមិនថា នឹងមិនចាកចោល អូននោះអី ហឺៗៗ»

សំឡេងយំយ៉ាងពេញទំហឹង នៅតែបន្តយំដដែលមិនអាចទប់ចិត្ត និង អារម្មណ៍បាន។ អារម្មណ៍សោកសៅខ្លូចចិត្តគ្មានអ្វីមកប្រៀបបាន ដូចដែលនាង បានសុបិនថា បានបាត់បង់ស្វាមីកាលពីអតីតជាតិនោះពិតមែន។

ចំណែកឯ ហាន់ណា វិញឈានជើងចុះពីលើយន្តហោះផ្ទាល់ខ្លួនរបស់ ស្វាមីនាង ដោយមិនខ្វីខ្វល់ពីសម្តីរបស់ស្វាមី ដែលបារម្ភពីនាងទាល់តែសោះ នាងឱបពោះហើយដើរចូលទៅក្នុងសេតវិមានរបស់ ឈើតខាមែន។ នាងដើរទៅ រកសំឡេងទ្រហោយំនោះ វាជាសំឡេងមិត្តសម្លាញ់របស់នាង ប្រហែលជាមិន យឺតពេលពេកសម្រាប់នាងចូលទៅជួយមិត្តសម្លាញ់របស់នោះទេណា។

«យ៉ុនហ៊ី! យ៉ុនហ៊ី! យើងមកហើយណា!»

យ៉ុនហ៊ី កំពុងតែយំសោកនៅលើទ្រូងរបស់ស្វាមីដែលមិនទាន់ដឹងខ្លួន នៅឡើយនោះ បានរត់ទៅឱបមិត្តយ៉ាងមានក្តីសង្ឃឹម។

«ហាន់ណា! ឈើតខាមែន!! ឯងជួយគេផងណា!!!»

ហាន់ណា មើលទៅកាន់មិត្តភក្តិនាងដែលពីមុនមកធ្លាប់តែរីករាយស្រស់ ស្រាយ តែពេលនេះនាងបែរជាយំសោកបោកខ្លួនប្រកបដោយទុក្ខពេញទំហឹង ទោះជានាងមិនដឹងលម្អិតយ៉ាងណាក៏ដោយ ក៏នាងអាចដឹងពីហេតុការណ៍ទាំង ឡាយនោះដែលមកពីអំណាចអាថ៌កំបាំងប្រាកដហើយ គឺនាងប្រហែលជាត្រូវ



ល្ងង់ចិត្តមិត្តហើយ។

«យ៉ុនហ៊ី! មិនអីទេណា ឯងជឿយើងចុះ ឈើត ប្រាកដជាមិនអីនោះទេ ណា»

«តែឈាមហូរច្រើនណាស់ ឯងសាកមើលទៅមើល!»

«គ្រាន់តែឈាមហូរដូចរលាត់ស្បែកនោះទេ ឯងកុំទៅស្លុតចិត្តពេកអី ណា»

ឈើត ទុកតួនាទីនោះឲ្យទៅភរិយារបស់គេ ចំណែកគេបានដើរចូលទៅ ស្ទាបជីបចររបស់ ឈើតខាមែន ដែលគេងសន្លប់នៅលើគ្រែមិនទាន់ដឹងខ្លួននោះ រំពេចនោះសំឡេងទន់ភ្លន់លក្ខណៈល្ងង់លោមបានលាន់ឮឡើងដូចគ្នាដែរ។

«ឈើតខាមែន គ្រាន់តែសន្លប់បាត់ស្មារតីតែប៉ុណ្ណោះទេណា»

ផ្ទៃមុខដែលទទឹកទៅដោយទឹកភ្នែកនោះក៏សប្បាយចិត្តបន្តិច តែនៅពេល នាងបាននឹកឃើញដល់ក្រសែចិត្តរបស់ព្រះនាង ទេមីន ដែលចង់នាំស្វាមីរបស់ គេទៅនៅជាមួយនោះធ្វើឲ្យទឹកដមសំឡេងដែលនៅតែអាក់អួលដោយក្តីបារម្ភ ពីស្វាមីនោះលាន់ឮឡើងបន្ត៖

«ត្រូវហើយ ហាន់ណា! ឈើតខាមែន អាចមិនទាន់កើតអីតែអំណាច ព្រមទាំងក្រសែចិត្តរបស់ព្រះនាង ទេមីន ប្រាកដជានាំយកគេទៅទៀតក៏ថាបាន ដែរណា»

«ឯងដឹងឬ?»

«យើងដឹង យើងអាចទាក់ទងនឹងក្រសែចិត្តរបស់ព្រះនាង ទេមីន បាន ឈើតខាមែន នៅមិនទាន់កើតអីពិតមែន ឯងត្រូវតែជួយគេឲ្យបានណា ហាន់ណា ឈើត លោកប្រាកដជាអាចជួយគេបាន»

ហាន់ណា លើកដៃទៅប៉ះពោះរបស់នាងមិនព្រមដាក់ចុះឡើយព្រមទាំង គិត ក្រសែចិត្តរបស់ព្រះនាង ទេមីន គឺគ្រាន់តែជាការបន្លំភ្នែក តែគ្រាន់តែចង់ បំផ្លាញផ្លូវចិត្តដ៏រឹងមាំ គឺត្រូវជួយព្រះនាងឲ្យរួចផុតពីទុក្ខដោយប្រើភាពបរិសុទ្ធ របស់កូនក្នុងផ្ទៃនាង ដើម្បីលាងពាក្យផ្តន្ទារបស់ព្រះនាង ទេមីន ឲ្យបាន។

«យើងនឹងទៅតាមដួងវិញ្ញាណរបស់ ឈឹតខាមែន ត្រឡប់មកវិញណា យ៉ុនហ៊ី!»

អ្នកដែលស្លុតចិត្តចំពោះការគិតរបស់នាងនោះគឺ ឈឹត គេស្រែកចេញមកយ៉ាងឮៗ នៅចំពោះភាពសោកសៅរបស់មិត្តនាង។

«ហាស់! អូននិយាយថាម៉េច?»

«ហេតុអីក៏ចាំបាច់ស្រែកឮៗធ្វើអីដែរទៅ ឈឹត?»

«ចុះអូននិយាយអីគេចុះ! នេះមិនមែនជាការសម្ដែងភាពយន្តនោះទេណា»

«បងកុំអាលបញ្ចេញគំនិតបានដែរទេ!»

«ចុះអូនធ្វើអ្វីដែលមិនគួរទៀតហើយនៀក»

«អាក!!! ឈឹត ម៉េចក៏និយាយអីចឹង អូនកំពុងតែគិតនៅឡើយណា ឈប់និយាយបានទេ»

«អូនចង់ធ្វើអី ប្រាប់បងមុនសិនណា វាអាចមានវិធីជាច្រើនទៀតដែលអាចជួយដល់ ឈឹតខាមែន បានណា»

មានអារម្មណ៍ថា ទាស់ចិត្តមែនទែនតែម្ដង បើអីចឹងមានតែរកវិធីចេញឆ្ងាយពីស្វាមីរបស់នាងហើយទើបបាន។ គេពិតជាបារម្ភហួងហែងលើនាងខ្លាំងហួសហេតុពេកហើយ។ រំពេចនោះ ហាន់ណា ក៏គិតរកវិធីចេញឆ្ងាយពីស្វាមីនាងមួយភ្លែតដើម្បីរកវិធីជួយមនុស្សរងគ្រោះឲ្យបាន ហើយសំឡេងដែលទើបតែស្ដីខ្លាំងៗដាក់ស្វាមីប្រែជាទន់ភ្លន់ល្ងងលោមវិញម្ដង។

«ឈឹត! អូនមិនបានធ្វើអ្វីឲ្យមានគ្រោះថ្នាក់ដល់ខ្លួន និងកូននោះទេណា តែបងត្រូវតែជួយអូនណា ឈឹត»

សម្ដីផ្អែមនិយាយចេញទៅនោះ ធ្វើឲ្យស្វាមីនាងមានអារម្មណ៍ត្រជាក់ចិត្តឡើងវិញខ្លះ ព្រោះតែតែងតែចិត្តទន់រាល់ដងដែលភរិយារបស់គេបាននិយាយពាក្យផ្អែមល្ហែមដាក់គេនោះ។

«តើអូនចង់ឲ្យបងជួយអីដល់នាងដែរទៅ?»



«អូន និង យ៉ុនហ៊ី នឹងទៅកាន់សារមន្ទីរណា បងជួយនៅទីនេះមើលថែ ឈឹតខាមែន ឲ្យផងណា»

«អ!!! បានតើស»

បានផលទៀតហើយ ហាន់ណា គិត ហើយក៏បានកេះមិត្តសម្លាញ់របស់នាងដែលកំពុងតែវិលវល់ចំពោះហេតុការណ៍ដែលកើតឡើងនោះ ឲ្យក្រោកដើរតាមពីក្រោយនាងទៅ ព្រោះនាងមានផែនការហើយក្នុងការជួយដល់អាយុជីវិតរបស់ ឈឹតខាមែន។

«យ៉ុនហ៊ីជួយនាំយើងទៅកាន់សារមន្ទីរបន្តិចមកណាមិនចាំបាច់បារម្ភពី ឈឹតខាមែន ទេណា ប្ដីយើងនៅជួយមើលថែគេហើយ»

«អឺបានតើស!! ឯងតាមយើងមកទីនេះមក»

ឈឹត មើលទៅកាន់មនុស្សស្រីពីរនាក់ដែលដើរផុតពីក្រសែភ្នែករបស់គេបាត់ទៅ ហើយក៏ហាក់បីដូចជាមានអារម្មណ៍ថា ដូចជាទើបតែភ្ញាក់ចេញពីក្ដីស្រមៃអីម៉្យាង ហាក់ដូចជាត្រូវបានសង្កត់ដោយវេទមន្ត។ តែបែរមកគិតសាជាថ្មីថា វាមិនមែនជាវេទមន្តឯណាទេ គ្រាន់តែចាញ់ល្បិចកលរបស់ភរិយាគេតែប៉ុណ្ណោះតើស ហើយគេក៏អត់ទ្រាំមិនស្រែកដាស់តឿននាងដោយក្ដីបារម្ភមិនបាន។

«អូនត្រូវតែប្រុងប្រយ័ត្នផងណា»

នេះឬដែលជាសារមន្ទីររបស់ព្រះនាង ទេមីន ហាន់ណា គិតក្នុងចិត្ត ទោះបីជាគិតថា របស់របរគ្រឿងប្រដាប់ហាក់បីដូចជាសង្កត់ដោយវេទមន្តអ្វីម៉្យាងក៏ដោយចុះ តែហេតុអីក៏វាមិនបានធ្វើឲ្យនាងមានភាពភ័យខ្លាចសោះអីចឹង ចុះបើនាងមិនខ្លាចអ្នកណា សូម្បីតែខ្មោចនោះណា កែវភ្នែកនាងមើលទៅកាន់មិត្តស្រីរបស់នាងហើយអត់ទ្រាំមិនបារម្ភមិនបាន។

«យ៉ុនហ៊ី ឯងរាងគ្រាន់បើជាងមុនដែរទេ?»

សំឡេងស្រួយស្រែសនោះ សួរទៅកាន់មិត្តភក្ដិនាង។

«ប្រសើរហើយនៅពេលដែលយើងឃើញឯងមកទីនេះឯងណា»

«ឯងតាំងចិត្តសិនទៅណា យើងនឹងនាំគ្នាទៅរក ឈើតខាមែនទាំងអស់គ្នាណា»

យ៉ុនហ៊ី មានអារម្មណ៍ជឿងឆ្ងល់ចំពោះពាក្យសម្ដីរបស់មិត្តនាងដែលពិតជាជឿជាក់ក្នុងការជួយដល់ស្វាមីរបស់នាង តើម៉េចនឹងអាចទៅរួចដែរទៅ តែវាមិនអីនោះទេណា ពេលនេះនាងត្រូវតែធ្វើយ៉ាងណាឲ្យស្វាមីនាងរួចផុតពីសភាពវេទនាទាំងឡាយនោះ ហើយក៏ត្រូវកម្ចាត់អំណាចនៃប្អូងមន្តក្រារបស់ព្រះនាងឲ្យបាន មិនថាដោយវិធីណាក៏ដោយចុះ។

«ឯងបានឮនូវអ្វីដែលយើងនិយាយដែរទេ? ឯងត្រូវតែតាំងសតិឲ្យរឹងមាំណា»

«បាន! យើងនឹងតាំងសតិ ហើយតើយើងគួរតែធ្វើយ៉ាងណាបន្តទៀតដែរទៅ?»

«អ្វីៗគ្រប់យ៉ាងហាក់ដូចជាមានការកំណត់ឲ្យយើងត្រូវតែធ្វើហើយណា យ៉ុនហ៊ី!!»

ហាន់ណា ព្យាយាមធ្វើការអធិប្បាយត្រួសៗឲ្យមិត្តនាងស្ដាប់ទាំងនាងនៅវិលវល់នៅឡើយ និយាយបែបងាយៗដើម្បីឲ្យលទ្ធផលដែលចេញមកនោះប្រសើរតាមដែលត្រូវការ។

«មិនចាំបាច់ឆ្ងល់ទេណា អ្វីៗគ្រប់យ៉ាងដែលយើងបានគិតចេញមកនោះវាត្រូវចំណុចខ្លាំងណាស់ អាចបណ្ដាលមកពីការតាំងចិត្តពិតប្រាកដ និងភាពរឹងមាំរបស់យើង ព្រមទាំងជីវិតបរិសុទ្ធរបស់កូនយើងនោះអី ឯងប្រហែលជាបានយល់ខ្លះហើយមែនទេ!»

«យើងយល់ ហើយយ៉ាងណាបន្តទៀតដែរទៅ?»

«យើងនឹងធ្វើតាម ដែលមនុស្សស្រីជនជាតិអ៊ីស្លាមតែលពោលនោះប្រាប់»

«ប្រាប់?»

«មែនហើយ! យើងក៏បានទម្លុះគន្លឹះនោះហើយណា»



«យ៉ាងណាដែរទៅ!! ឯងប្រាប់យើងមក!!»

ហាន់ណា តាំងអារម្មណ៍យ៉ាងមុតមាំដើម្បីឲ្យមិត្តស្រីនាងបានតាំងអារម្មណ៍ស្ដាប់ដូចគ្នាដែរ ក្រោយពេលដែលតាំងសតិមុតមាំរួចរាល់ហើយនោះសំឡេងអ្នកកម្ចាត់ខ្មោចក៏បានលាន់ឮឡើង។

«គឺបែបនេះណា បន្តិចទៀតនឹងកើតមានសូរ្យគ្រាស ហើយវាដល់ពេលដែលឯងនិង ឈើតខាមែន បានរួចផុតពីប្អូងមន្តក្រានោះហើយ»

«រួចផុតពីប្អូងមន្តក្រា តើរួចដោយរបៀបណាដែរទៅ?»

«ឯងសាកស្ដាប់សម្ដីរបស់មនុស្សស្រីជនជាតិអ៊ីស្លាមម្នាក់នោះនិយាយឯងនឹងបានយល់ជ្រៅជាងនេះបានណា»

**«ដល់ពេលដែលក្រសែចិត្តត្រូវបានរលត់ នៅពេលដែលរាហូចាប់ច័ន្ទបានបាំងបិទងងឹតសូន្យសុង ជីវិតបរិសុទ្ធនោះនឹងបានបញ្ចេញកម្លាំងរំលាយមន្តក្រាដោយភ្លើង»**

យ៉ុនហ៊ី បានស្ដាប់រួចគិតសាឡើងវិញនូវប្រយោគដែលមិត្តនាងនិយាយអាចមកពីនាងសិក្សាកាសាបាលីបែបនេះច្រើនក្នុងកំឡុងពេលនេះហើយបានជាអាចយល់វាបានដោយងាយបែបនេះនោះ។

«នោះមានន័យថាក្រសែចិត្តរបស់ព្រះនាង ទេមិន នឹងរលត់ទៅនៅពេលដែលមានព្រឹត្តិការណ៍សូរ្យគ្រាសឬ?»

«ត្រូវហើយ! យើងសប្បាយចិត្តណាស់ដែលឯងយល់បានលឿនបែបនេះនោះ»

«បន្ទាប់ពីនោះមកកូនរបស់ឯងនឹង...»

«វាពិតដូចដែលឯងគិតនោះណា កូនរបស់យើងគឺជាជីវិតបរិសុទ្ធដែលគេបញ្ជូនឲ្យមកជួយពួកយើងនោះអី»

កែវភ្នែកមួយគូរបស់ យ៉ុនហ៊ី បញ្ចេញភាពសប្បាយចិត្តជាខ្លាំង នាងក្លាយជាមនុស្សស្រីដែលមានជំនឿលើខ្លួនឯងខ្ពស់សាជាថ្មី នាងហាក់ទៅឱបមិត្តយ៉ាងសប្បាយចិត្តជាពន់ពេក។

«ហាន់ណា! យើងមានភាពជឿជាក់លើខ្លួនឯងវិញពេញទំហឹងតែម្តងហើយ តោះយើងនាំគ្នាចាប់ផ្តើមទៅ យើងបារម្ភពី ឈើតខាមែន ខ្លាំងណាស់»

«ល្អហើយណា ឯងលែងខ្លាចខ្មោចដូចលើកមុនហើយមែនដែរទេ?»

«មែនហើយ យើងត្រូវបានគេបន្លាចឡើងលែងខ្លាចទៅហើយណា»

«ឯងចាំទុកថា ក្រសែចិត្តរបស់ព្រះនាង ទេមីន តាមពិតទៅគ្រាន់តែជាការបន្លំភ្នែកយើងតែប៉ុណ្ណោះ»

«បាន! យើងនឹងចងចាំទុក ព្រោះថា ឈើតខាមែន ក៏បានប្រាប់យើងបែបហ្នឹងដែរ»

«បើអីចឹងយើងនាំគ្នាទៅជួយ ឈើតខាមែន ទៅណា ឯងត្រៀមរួចហើយមែនទេ?»

«រួចស្រេចហើយ យើស!!ហើយយើងនឹងទៅដោយរបៀបណាដែរទៅ?»

យ៉ុនហ៊ី មើលទៅកាន់មិត្តនាងដែលពេលនេះបានក្លាយជាមេខ្លោងបង្ក្រាបខ្មោច អាសសស!! មិនមែនទេ ធ្វើជាអ្នកនាំនាងទៅជួយ ឈើតខាមែន ដោយរបៀបណានោះ កុំប្រាប់ឲ្យសោះថា នាងនឹងប្រើយន្តហោះផ្ទាល់ខ្លួនរបស់ស្វាមីនាងទៅនោះ!

ហាន់ណា លើកដៃមកអង្អែលពោះរបស់នាង តាំងចិត្តរឹងមាំក្នុងការឲ្យកូនរបស់នាងផ្ទេរឥទ្ធិពលមកឲ្យ ដើម្បីឲ្យនាងមានឥទ្ធិពលអាចទៅជួយ ឈើតខាមែន បាន រំពេចនោះផ្ទៃមុខដ៏ស្រស់ស្អាតរបស់នាងក៏ញញឹមឡើង។

«គឺបែបនេះណា យើងមានជីវិតបរិសុទ្ធជួយនាំយើងទៅ ចំណែកឯងក៏ត្រូវបានក្រសែចិត្តជួយផងដែរ»

«ក្រសែចិត្តអីដែរទៅ! អូ!!! រឿងតូចតាចណាស់ ឯងមកនេះមកណា យើងមានឡើងពេញពោះតែម្តង»

នាងនឹកឃើញអ្វីម្យ៉ាង ក៏ទៅបើកទូលើកយកឈុតរៀបអភិសេករបស់ព្រះនាង ទេមីន ចេញមក។

«ហាស់! ស្អីគេហ្នឹង កំពុងតែស្ថិតក្នុងស្ថានការណ៍គិតភ័យផងនៅមាន



អារម្មណ៍មកលើកឈុតនោះមកស្លៀកទៀត»

«នេះហើយជាក្រសែចិត្តរបស់យើងនោះណា ឈុតរៀបអភិសេករបស់ព្រះនាងទេមីន»

«អ!! មែនឬ!! ពិតជាស្អាតមែនណា»

ហាន់ណា មើលទៅកាន់មិត្តភក្តិរបស់នាងដែលកំពុងតែស្លៀកឈុតអភិសេករបស់ព្រះនាងយ៉ាងល្អមខ្លួនតែម្តង ហើយនាងថែមទាំងទៅបើកទូយកគ្រឿងប្រដាប់នោះមកពាក់លើខ្លួនបន្ថែមទៀតផងដែរ។

«ហេយ!! ឯងប្រើក្រសែអីច្រើនពេកទេដឹងហ៊ីយ!!!»

«មិនទេណា គឺគ្រាន់តែខ្សែក មកុដ កងដៃ កងពាក់នៅត្រង់ជើងដៃ អ!!! នៅមានចិញ្ចៀន ហើយអ្វីដែលសំខាន់គឺបន្តោងខ្សែកដែលមានរូបសត្វទទះស្លាបនេះណា!»

«តែប៉ុណ្ណឹងរបស់ឯងនេះវាពេញខ្លួនទៅហើយណា»

ហាន់ណា សម្លឹងមើលទៅកាន់មិត្តរបស់នាងហើយបែរជាគិតថា នាងគឺជាព្រះនាង ទេមីន ជាជាងនោះណា អ!! មែនហើយមិត្តរបស់នាងគឺជាព្រះនាង ទេមីន មកចាប់ជាតិថ្មីនោះអី។

«តោះយើងនាំគ្នាទៅ យើងរួចរាល់ហើយ»

«អ!! រួចរាល់ហើយ យើងស្មានថា ឯងត្រូវផាត់មុខអីទៀតនោះណា»

«អ!! មែនហ្នឹងណា ឬក៏ត្រូវផាត់មុខសិនដែរទៅ?»

«ហេ!! កុំអី យើងគ្រាន់តែពន្យះឯងទេណា ឯងមិនដឹងទៀតវីយ៉ាងណាហ្នឹង!!»

«អ!! អីចឹងទេ!! តោះយើងនាំគ្នាទៅ»

យ៉ុនហ៊ី កៀកដៃមិត្តនាងចេញពីបន្ទប់នេះទៅ ព្រោះនាងចង់ទៅរកស្វាមីរបស់នាងនោះណា ហើយចុះទៅនៅធ្វើស្អីនៅក្នុងសារមន្ទីរនេះ!!

«ឯងចង់ទៅណា យ៉ុនហ៊ី!»

«យើស! ចុះក្រែងយើងនាំគ្នាទៅតាមដួងវិញ្ញាណរបស់ ឈើតខាមែន

នោះអី»

«ហឹមមម!!! ឯងនេះយ៉ាប់តែម្តងហើយនៀក តែយើងខ្ជិលថាឲ្យឯងណាស់ព្រោះឯងកំពុងតែស្ថិតក្នុងសភាពធ្ងន់ធ្ងរនោះណា»

«ចុះ! ចុះក្រែងឯងជាអ្នកប្រាប់យើងថានាំយើងទៅនោះ!»

«ទីនេះហើយដែលប្រសើរបំផុតនោះ ឯងគ្រាន់តែតាំងសមាធិ ឯងយល់ដែរទេ!»

«កុំប្រាប់ឲ្យសោះថា ឯង និងយើងនឹងដកព្រលឹងចេញទៅនោះ!»

«ត្រូវហើយ! គឺយើងមានន័យថា ដកព្រលឹងដើម្បីទៅតាមយកដួងព្រលឹងរបស់ ឈីកខាមែន ត្រឡប់មកវិញនោះណា»

យ៉ុនហ៊ី គិត ពិតមែននោះណា ទៅតាមដួងវិញ្ញាណ មិនមែនទៅតាមយកមនុស្សមែនទែនឯណា គឺប្រាកដជាត្រូវប្រើព្រលឹងទៅតាមហ្នឹងហើយទើបត្រូវ។ តែនាងជាមួយមិត្តនាងមិនធ្លាប់សិក្សាវិធីបែបនេះមកនោះទេ អ!! តែនាងមានក្រសែចិត្តជាគួរអង្គជំនួយ ហើយមិត្តនាងក៏មានជីវិតបរិសុទ្ធជាគួរអង្គជំនួយដែរ ប្រហែលជាទៅតាមព្រហ្មលិខិតហើយមើលទៅនោះ។

យ៉ុនហ៊ី មើលទៅកាន់មិត្តនាងកំពុងតែអង្គុយតាំងសមាធិយ៉ាងមោះមុតមើលទៅគួរឲ្យគោរពបូជា ទើបនាងដាក់គូទអង្គុយតាំងសមាធិនៅក្បែរៗនោះដែរ តែដើម្បីភាពជឿជាក់ទើបនាងហើបមាត់សួរទៅកាន់មិត្តនាងសាជាថ្មីម្តងទៀត។

«ហាន់ណា យើងជឿលើឯងណាថា ឯងនឹងអាចនាំយើងដុកព្រលឹងទៅរកគេបាន តែ...»

«អឹមមម!!! ហើយឯងនៅមានការសង្ស័យអីទៀត»

«តែឯងប្រាកដហើយថា ឯងពិតជានាំយើងត្រឡប់មកវិញបាននោះ យើងមិនចូលចិត្តធ្វើជាវិញ្ញាណតែលតោលនោះទេណា!!»

«នែ!! យើងមានជីវិតបរិសុទ្ធ ហើយឯងក៏មានក្រសែចិត្តដែលរឹងមាំមួយដែរ រឿងអីដែលថាត្រឡប់មកវិញមិនបាន»



ប្រហែលជាត្រូវផ្តល់ទំនុកចិត្ត ដល់មិត្តនាងឲ្យបានច្រើនជាងនេះហើយទើបបាន ហាន់ណា គិត ព្រោះថា វាទាក់ទងនឹងក្រសែចិត្តធំសាហាវមួយ បើសិនជាមានទំនុកចិត្តនោះលទ្ធផលនឹងបានល្អជាក់ជាមិនខានឡើយ។

«យើងបានប្រាប់ឯងហើយថា ក្រសែចិត្តរបស់ព្រះនាង ទេមិន គឺជាការខ្លាំងបន្តិចក្រែក បើចិត្តយើងរឹងមាំយើងនឹងអាចតទល់ជាមួយនឹងវាបានជាក់ជាមិនខាន ក្រែងឯងក៏បានដឹងដែរតើសមិនអីចឹង!»

«យល់ព្រម!! យល់ហើយ»

«ហើយម្យ៉ាងទៀតនោះណា មនុស្សធម្មតាមានតិចណាស់ដែលមានឱកាសបានធ្វើដូចយើងនោះណា ហើយលើកក្រោយៗទៀត យើងជឿជាក់ថាយើងនឹងអាចធ្វើបែបនេះបានទៀត ឯងជឿយើងទៅ ដូច្នេះត្រូវតែតាំងចិត្តឲ្យរឹងមាំ យល់ទេ?»

«យល់ព្រម! ហើយម៉េចទៀត យើងយល់ហើយណា បង្រៀនឡើងវែងឆ្ងាយតែម្តងហើយនៀក»

ពួកគេទាំងពីរនាក់មានកម្លាំងចិត្តពេញប្រៀបតែម្តង ហាន់ណា ពិតជាសប្បាយចិត្តជាពន់ពេកដែលនាងបានធ្វើឲ្យមិត្តដែលមានទុក្ខសោកបែរមកជាមានជីវិតជីវ៉ាសាជាថ្មីម្តងទៀត ហួសពីអ្វីដែលនាងគិតទុកទៅទៀត។

ពីរដួងវិញ្ញាណបានតាំងសមាធិយ៉ាងមុតមាំ ហើយបានប្លែងក្រសែចិត្តដកព្រលឹងចេញពីរាងកាយដើម្បីហោះហើរទៅរកដួងព្រលឹងរបស់ឈីតខាមែន ភាពអស្ចារ្យ បានកើតឡើងនៅពេលដួងវិញ្ញាណរបស់អ្នកទាំងពីរហោះហើរចេញពីរាងកាយដែលកំពុងតែតាំងសមាធិ ហោះហើរទៅរកដួងវិញ្ញាណមួយដួងដែលនៅលើផ្ទៃមេឃយ៉ាងល្វល្វើយធំធេង។



## ...៦...

## វិលោយបួងមន្តក្រា

នៅលើផ្ទៃមេឃខ្ពស់ស្រឡះដែលកំពុងតែមានព្រឹត្តិការណ៍ដ៏អស្ចារ្យមួយកើតឡើង នោះគឺដំណើរគោចររបស់ព្រះច័ន្ទមកបាំងពន្លឺព្រះអាទិត្យកុំឲ្យភ្លឺដល់កពផែនដី។ ហេតុការណ៍នេះធ្វើឲ្យផែនដីនៅក្រោមស្រមោលព្រះច័ន្ទមួយរយៈពេលខ្លី ដែលគេហៅម្យ៉ាងទៀតថា រាហូចាប់ច័ន្ទ។

ប្រហែលជាដល់ពេលដែលក្រសែបិត្តរបស់ព្រះនាង ទេមិន នឹងទន់ខ្សោយព្រោះតែអំណាចរាហូ ហើយនឹងរលាយដោយអំណាចនៃជីវិតបរិសុទ្ធផុតពីភាពទុក្ខសោករបស់ព្រះនាងមករាប់សិបឆ្នាំនោះហើយ។

សំឡេងសត្វចាបយំទ្រហឹងអឹងកងព្រមទាំងទទះស្លាបហោះចូលសំបុកអ្វីដែលនៅសល់នោះគឺព្រឹត្តិការណ៍អស្ចារ្យដែលកើតឡើងនោះតែប៉ុណ្ណោះ។



ឈីតខាមែន ឈរនៅចំព្រំពណ៌ស បែរឆ្វេងបែរស្ដាំដើម្បីរកផ្លូវចេញ តែយ៉ាងណា ក៏មិនអាចទៅរួចផុតពីមេឃដែលមានផ្ទៃយ៉ាងធំនោះទាល់តែសោះ កំលោះសង្ហាបញ្ចេញសំឡេងស្រែកហៅយ៉ាងឮៗដែលគ្មាននរណាឮ តែយ៉ាងណាក៏គេមិនព្រមលះបង់ក្ដីព្យាយាមដែរ គឺគេបានបញ្ចេញសំឡេងស្រែកហៅជាបន្តបន្ទាប់។

**«ទីនេះជាកន្លែងណា! មានអ្នកណាបានឮខ្ញុំដែរទេ!!»**

ឈីតខាមែន ដើរនៅលើផ្ទៃមេឃដែលមានពពកពណ៌សនោះដោយគ្មានគោលដៅច្បាស់លាស់ គេមិនអាចជួយខ្លួនឯងបានឡើយប្រៀបដូចជាគេបានជៀបជាប់នៅក្នុងពពកដែលមានផ្ទៃសក្បុសនោះ។

**«ទីនេះជាកន្លែងណា! មានអ្នកណាបានឮខ្ញុំដែរទេ!!»**

រំពេចនោះ ក្រសែភ្នែករបស់គេក៏បានក្រឡេកទៅឃើញមនុស្សស្រីមួយរូបដែលហាក់ដូចជាធ្លាប់ស្គាល់ឈរនៅចំពីមុខគេ ឈីតខាមែន ព្យាយាមបើកពពកពណ៌សនោះមើលឲ្យច្បាស់ថា ជាអ្នកណាគេ។

«យ៉ុនហ៊ី! នាងមែនដែរទេ!!»

**«ហាស់...ហាស់...ហាស់ តាមខ្ញុំម្ចាស់មកនៅទីនេះមក ព្រះស្វាមីរបស់ខ្ញុំម្ចាស់!!»**

ឈីតខាមែន ឈប់ភ្លាមនៅពេលមិនស្មុះជាប្រាកដចិត្តថា មនុស្សស្រីដែលដើរចូលមកនោះមិនមែនជាមនុស្សស្រីដែលគេស្រឡាញ់។

«ព្រះនាង ទេមិន មែនទេ ឬក៏ជា យ៉ុនហ៊ី នាងជាអ្នកណាឲ្យប្រាកដទៅ?»

«តាមខ្ញុំម្ចាស់មកទីនេះមកណាព្រះស្វាមីរបស់ខ្ញុំម្ចាស់»

«ទេ! ខ្ញុំមិនទៅនោះទេ នាងគឺជាក្រសែចិត្តរបស់ព្រះនាង ទេមីន»

«ហាស់...ហាស់...ហាស់! ត្រូវហើយព្រះស្វាមីរបស់ខ្ញុំម្ចាស់ ព្រះអង្គត្រូវតែទៅនៅក្នុងពិភពរបស់ខ្ញុំម្ចាស់»

«ព្រះនាង ទេមីន ការដែលខ្ញុំមានសភាពបែបនេះមកពីអំណាចរបស់

ព្រះនាងមែនទេ»

«ព្រោះថា ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ ព្រះអង្គទុរយស ព្រះអង្គក្បត់សន្យា»

«ព្រះនាង សូមមេត្តាដោះលែងខ្ញុំទៅណា ព្រោះថាយើងនៅពិភពផ្សេងគ្នាទៅហើយ មិនអាចស្រឡាញ់គ្នាបាននោះទេ»

«ព្រះស្វាមីរបស់ខ្ញុំម្ចាស់ ព្រះអង្គក្បត់សន្យា ព្រះអង្គក្បត់សន្យា»

ឈីតខាមែន មើលទៅស្រាប់តែឃើញកែវភ្នែករបស់ព្រះនាងប្រែជាក្រហមឆ្អៅ ដូចមានអីមកផ្លាស់ប្តូរព្រះនាងអីចឹង រាងកាយរបស់គេត្រូវបានស្រូបចូលដោយអំណាចអ្វីមួយឲ្យខិតចូលទៅជិតព្រះនាង ដោយមិនអាចមានអ្វីហាមឃាត់បាននោះឡើយ។

«នេះជាស្អីទៅ! ព្រះនាងចង់ធ្វើស្អីគេព្រះនាង!!»

«ខ្ញុំម្ចាស់កំពុងតែនាំព្រះអង្គទៅនៅក្នុងភពមួយជាមួយខ្ញុំម្ចាស់នោះអី»

ដៃរបស់ ឈីតខាមែន ទាំងពីរបានស្រវាតោងអ្វីម្យ៉ាង ព្រមទាំងស្រែកឲ្យគេជួយ តែក៏មិនអាចទប់ទល់ជាមួយនឹងកម្លាំងស្រូបរបស់ព្រះនាងបានទាល់តែសោះឡើយ។

វិញ្ញាណរបស់ ហាន់ណា បានដឹងពីសភាពការណ៍ដែលកំពុងតែកើតឡើងចំពោះ ឈីតខាមែន នាងក៏ស្ទុះទៅពាំងចំកណ្តាលរវាង ឈីតខាមែន និងក្រសែចិត្តរបស់ព្រះនាង ទេមីន នៅពេលជាមួយគ្នានោះដែរ យ៉ុនហ៊ី ក៏បានចូលទៅនិយាយជាមួយព្រះនាង ទេមីន។

«ព្រះនាង ខ្ញុំមិនព្រមឲ្យព្រះនាងនាំស្វាមីខ្ញុំទៅនោះទេ»

«ចុំ! ឯងក្លាយជាប្រពន្ធរបស់ ឈីតខាមែន តាំងពីពេលណាដែរទៅនៀក»

«កុំអាលសួរអីណា ខ្ញុំកំពុងតែស្ថិតក្នុងសភាពមិនស្ងប់ស្រួលនោះឯងមិនឃើញទេអី!»

យ៉ុនហ៊ី សម្លឹងមិនដាក់ភ្នែកទៅកាន់ព្រះនាងទេមីន។ ទោះបីជារូបរាងកាយនិងការតុបតែងខ្លួនដូចគ្នាក៏ដោយ តែរឿងដែលព្រះនាង ទេមីន មកដណ្តើមស្វាមីរបស់នាងនោះ នាងពិតជាមិនអាចយល់ព្រមបានឡើយ នាងគិតថាខ្មោច



នៅដោយខ្មោចទៅ យ៉ាងណាក៏មិនព្រមដែរ។

«ហឺស!! បាត់មាសឲ្យគេបាន តែមិនអាចឲ្យប្តីគេប្រើបានឡើយ»

«យ៉ុនហ៊ី! ព្រះនាងមិនដឹងអ្វីដែលឯងនិយាយនោះទេណា»

«យើស!! ហេតុអីទៅ»

«នោះជាក្រសែចិត្តឯងកាលពីជាតិមុន»

«ហ៊ឹមមម!! បើយើងមានអារម្មណ៍ថា ទ្រង់គឺជាមនុស្សដែលមកដណ្តើមស្វាមីយើង»

«ម៉េចដែលគេហៅថា អាថ៌កំបាំង ឬរូបភាពកំបាំងភ្នែកនោះ!»

«អឹម!! មែនហ្នឹងណា ហើយយើងគួរតែធ្វើយ៉ាងណាទៅចុះ!»

«មិនអីនោះទេណា ឯងនៅឲ្យស្ងៀមទៅ ចាំយើងជាអ្នកចាត់ការឲ្យ ហើយតាំងចិត្តធ្វើសមាធិតាមដែលយើងប្រាប់ទៅបានហើយណា!»

«អីចឹងក៏បានដែរ យើងនឹងជឿជាក់លើឯង តែឲ្យប្រាកដថា យើងនឹងបានស្វាមីយើងមកវិញណា»

«ប្រាកដជាបានជាក់ជាមិនខានឡើយ ឯងនេះលឿនណាស់ ភ្លេចខ្លួនតែមួយភ្លែតសោះមានប្តីបាត់ទៅហើយ»

«កុំអាលរិះគន់បានដែរទេ តើឯងនឹងជួយស្វាមីយើងបានដោយវិធីណាដែរទៅ យើងធ្វើតាមឯង»

ទោះបីជារឿងឆ្ងល់ និងវិលវល់ខ្លាំងយ៉ាងណាក៏ដោយចុះ តែយ៉ាងណានាងក៏ជឿជាក់លើមិត្តដែរ ទើប យ៉ុនហ៊ី បានត្រឹមតែតាំងសមាធិព្រមទាំងធ្វើចិត្តឲ្យស្ងប់ មានអារម្មណ៍ថា ព្រួសឿយឡើងវិញនៅពេលបានជួបនឹងដួងវិញ្ញាណរបស់ស្វាមីវិញនោះណា។

ហាន់ណា លើកដៃអង្អែលពោះរបស់នាង ហើយធ្វើការតាំងចិត្តអធិដ្ឋានឲ្យចិត្តស្ងប់ ឲ្យបុណ្យបារមីនៃអំពើល្អរបស់នាងបានជួយនាង សូមឲ្យព្រះនាងបានយល់ មិនរារាំងស្វាមីហើយដោះលែងគេឲ្យមានសេរីភាពវិញផងចុះ សាធុ!

បើសិនជាអ្នកគឺជាក្រសែចិត្ត និងដួងវិញ្ញាណរបស់ព្រះនាងទេមីនពិតមែន

ពួកយើងកំពុងតែជួយឲ្យព្រះនាងបានរួចផុតពីទុក្ខសោកទាំងឡាយ។ សម្រាប់ជាតិនេះព្រះនាងក៏បានកើតមកជាគូហ្នឹងគ្នាដែរ សូមដួងវិញ្ញាណរបស់ព្រះនាងរំសាយទៅតាមកាលវេលាទៅចុះព្រះនាង។

ចប់ពាក្យសម្តីរបស់ ហាន់ណា ពីរនាក់មិត្តភក្តិនោះក៏បានបិទភ្នែកតាំងសមាធិនិយាយដដែលៗ រំពេចនោះក្រសែចិត្តរបស់ព្រះនាង ទេមិន ប្រែក្លាយទៅជាភ្លើងមួយដុំយ៉ាងធំ ហើយស្ទុះសំដៅមករកពួកគេទាំងបីនាក់ តែក៏កើតមានពន្លឺពណ៌ខៀវមកគ្រប់គ្រងចិត្តវិញ្ញាណរបស់ពួកគេទាំងបី ហើយដុំភ្លើងមួយដុំធំនោះក៏បានបាត់សោត់ទៅ។

ហាន់ណា ដឹងថា ក្រសែចិត្តរបស់ព្រះនាងទេមិនបានថយកម្លាំងចុះ ទើបប្រើក្រសែចិត្តរបស់នាងនិយាយជាមួយមិត្តភក្តិ។

«យ៉ុនហ៊ី យើងអាចនាំដួងវិញ្ញាណរបស់ ឈីតខាមែន ត្រឡប់ទៅវិញបានហើយណា»

«ហេតុអីក៏ ឈីតខាមែន មើលទៅដូចជាវិញ្ញាណហោះហើរម្លេះ»

«ឈីតខាមែន នៅក្នុងអំណាចមន្តក្រាគ្របដណ្តប់ជាប់នៅឡើយនោះណា ប្រហែលជាមិនទាំងដឹងផងថា ពួកយើងមកជួយគេនោះណា»

ពពកសស្ទុះបានមកផ្តុំនៅកន្លែងដែល ឈីតខាមែន ដេកនៅនោះ

«ពុទ្ធោ! ប្តីខ្ញុំ!!»

«តោះយើងនាំគ្នាទៅណា យ៉ុនហ៊ី កុំយឺតយ៉ាវអី»

ពីរនាក់មិត្តភក្តិនោះបាននាំយក ឈីតខាមែន ដើរចុះមកតាមដងផ្លូវដែលមានពណ៌ស។ នៅពេលមកដល់កន្លែងមួយ មានអារម្មណ៍ថា ស្វាមីនាងត្រូវ បានកម្លាំងមួយទាញមួយទំហឹង ចំណែកឯពួកគេពីរនាក់ក៏បានដឹងខ្លួនថា ព្រលឹងពួកនាងចូលមកក្នុងខ្លួន ដែលកំពុងតែអង្គុយតាំងសមាធិនៅក្នុងសារមន្ទីរនោះវិញហើយណា។ ពួកនាងទាំងពីរនាក់បែរមើលមុខគ្នានូវភាពអស្ចារ្យដែលអាចឲ្យពួកនាងត្រឡប់ចូលក្នុងរាងកាយដើមវិញបាននោះណា។

«ឃើញទេ យ៉ុនហ៊ី!! គឺយើងធ្វើបានសម្រេចហើយណា»



«មែនហ្នឹងណា ហាន់ណា! ឯងពិតជាធ្វើបានពិតមែន»

«មិនមែនយើងតែម្នាក់ឯងនោះទេ គឺមានកូនយើងម្នាក់ទៀតណា»

«មែនហ្នឹងណា កូនឯងជាគូយរបស់យើងនោះអី»

យ៉ុនហ៊ី ឱបមិត្តភក្តិសម្លាញ់របស់នាងដោយភាពសប្បាយចិត្តជាពន់ពេក ការប្រតិបត្តិរបស់ពួកគេបានឆ្លងផុតទៅដោយរលូនហើយ រំពេចនោះនាងក៏បាននឹកដល់ស្វាមីនាង ប្រហែលជាពេលនេះដួងចិត្តវិញ្ញាណរបស់គេត្រឡប់ចូលរាងកាយគេវិញហើយមើលទៅនោះ។

«ហាន់ណា យើងទៅរក ឈីតខាមែន សិនណា»

«តោះយើងទៅ»

ពួកនាងទាំងពីរនាក់កាន់ដៃគ្នាមកកាន់បន្ទប់របស់ ឈីតខាមែន។ នៅពេលដែលទ្វារបន្ទប់បានបើក មិនបានដូចអ្វីដែល យ៉ុនហ៊ី គិតសោះ។ រាងកាយរបស់គេនៅតែដេកស្តូកស្តឹងនៅលើគ្រែដដែល។

«ហាន់ណា ហេតុអីក៏នៅតែបែបហ្នឹង!»

«មែនហ្នឹងណា ហេតុអីក៏នៅបែបហ្នឹង»

«ឬក៏ដួងវិញ្ញាណរបស់ ឈីតខាមែន ត្រឡប់មកវិញលែងបានហើយ!»

«កុំអាលស្លុតចិត្តណា យ៉ុនហ៊ី គេប្រាកដជាត្រឡប់មកវិញបាន»

ហាន់ណា ក្រឡេកភ្នែកមើលទៅកាន់ស្វាមីរបស់នាងដែលនៅចាំមើល ឈីតខាមែន នៅពេលដែលនាងមិននៅ។ នាងចង់សួរគេពីពេលមុននេះមានភាពខុសប្រក្រតីអ្វីកើតឡើងដែរទេ តែមិនឃើញសូម្បីតែស្រមោល មានអារម្មណ៍សង្ស័យថា តើគេទៅណាដែរទៅ។ រំពេចនោះនាងក៏ឈប់គិតពីស្វាមីរបស់នាងក៏លើកដៃអង្អែលពោះព្រមទាំងតាំងសមាធិអធិដ្ឋាន។ នាងដឹងថាដួងវិញ្ញាណរបស់ ឈីតខាមែន ត្រឡប់ចូលមករាងកាយគេមិនទាន់បានទេ ព្រោះមានភាពទាស់ខុស និងការរាំងពីអំណាចមន្តក្រារបស់ព្រះនាង នាងព្យាយាមគិតថាតើគួរធ្វើយ៉ាងណាទើបល្អ ទើបនាងគិតសាជាថ្មីលើប្រយោគដែលមនុស្សស្រីជនជាតិអ៊ីស្លាមនោះនិយាយម្តងទៀត។

«ដល់ពេលដែលក្រសែចិត្តត្រូវលត់ នៅពេលដែលមាន់ព្រឹត្តិការណ៍រាហូចាប់ច័ន្ទបានមកបាំងបិទជីវិតបរិសុទ្ធនឹងជួយដោះមន្តក្រានោះបានដោយភ្លើង»

«ហាន់ណា ឯងនិយាយពាក្យនេះសាជាថ្មីនោះមានន័យថា ការដែលយើងធ្វើនោះមិនសម្បូរបែបមែនដែរទេ?»

«មែនហើយ យ៉ុនហ៊ី មន្តក្រា!»

«មន្តក្រា! យ៉ាងណាដែរទៅ?»

«ឯងសាកគិតទៅមើលថា អ្វីជាមន្តក្រា យើងនឹងនាំគ្នារំលាយមន្តក្រានោះ»

ពួកគេទាំងពីរនាក់នាំគ្នាសញ្ជឹងគិតក្នុងភាពស្ងៀមស្ងាត់នោះ ហាន់ណាយកដៃទៅអង្អែលពោះដូចលើកមុនៗដែរ តែនៅតែមិនអាចគិតឃើញទាល់តែសោះ ព្រមទាំងគិតថា ព្រឹត្តិការណ៍រាហូចាប់ច័ន្ទបានរលាយបាត់ហើយនោះមានន័យថា មិនអាចជួយ ឈឹតខាមែន ឲ្យត្រឡប់ចូលក្នុងរាងកាយគេបានឡើយ។

«យ៉ុនហ៊ី ឯងសាកគិតទៅមើលថា នៅមានអ្វីដែលជាវេទមន្តរបស់ព្រះនាងទេមីនបានទៀតដែរទៅ?»

«ស្បែកសត្វ! ស្បែកសត្វណា»

«ស្បែកសត្វអីគេ ចិត្តត្រជាក់សិនណា និយាយឲ្យដឹងរឿងសិន»

ជាអាការសប្បាយចិត្តជាខ្លាំងរបស់អ្នកទាំងពីរ ដែលអាចរកចំណុចជួយមនុស្សបាន រំពេចនោះ យ៉ុនហ៊ី ក៏ព្យាយាមនិយាយពន្យល់ឡើងភ្លាម។

«គឺជាស្បែកសត្វដែលព្រះនាងទេមីនបានសរសេរពាក្យអធិដ្ឋាននៅលើនោះ មុនពេលទ្រង់សុគត»

ផ្ទៃមុខស្រស់ស្អាតនោះ ញញឹមយ៉ាងស្រស់ស្រាយសប្បាយចិត្តនឹកឃើញវិធីសាស្ត្រចុងក្រោយ ដែលអាចជួយប្ដីសម្លាញ់របស់នាងឲ្យរួចផុតពីបួងមន្តក្រាបាន។

«មែនហើយណា! ប្រាកដជាមួយហ្នឹងមែនហើយ ហើយវានៅឯណាដែរ



ទៅ យ៉ុនហ៊ី?»

«មែនហ្នឹង! នៅឯណាដែរទៅ ព្រោះថា ឈឹតខាមែន ជាអ្នកទុកវានោះណា»

ហាន់ណា មើលទៅកាន់ព្រះអាទិត្យដែលលិចពណ៌ក្រហមចេញមករាហូកំពុងតែលេបច័ន្ទបាត់នោះណា បើអ៊ីចឹង ឈឹតខាមែន នឹងមិនអាចវិលត្រឡប់មកកាន់រាងកាយគេបានជាក់ជាមិនខានឡើយ នាងគិតព្រមទាំងអត់ទ្រាំមិនបារម្ភមិនបានចំពោះបញ្ហានេះ។

«យ៉ុនហ៊ី! ម៉េចដែរ នឹកឃើញហើយឬនៅថា ឈឹតខាមែន ទុកស្បែកសត្វនោះនៅទីណា?»

«នៅក្នុងសៀវភៅជាភាសាអ៊ីស្លាមណា»

«ហើយចុះសៀវភៅនោះទុកនៅឯណា ឯងប្រាប់ឲ្យលឿនឡើងមកណា»

«កាលពីម្សិលមិញយើងឃើញគេដាក់នៅលើក្បាលគ្រែគេងនោះណា»

ស្រីស្រស់ទាំងពីរសម្លឹងទៅកាន់ទិសដៅតែមួយគឺនៅលើក្បាលគ្រែគេង តែមិនឃើញសូម្បីតែស្រមោលរបស់សៀវភៅភាសាអ៊ីស្លាមនោះទាល់តែសោះ ហើយចុះវាទៅណាបាត់ទៅនៀក!!

ហាន់ណា មើលទៅកាន់មុខរបស់មិត្តនាងដែលពេលនេះទឹកភ្នែកកំពុងតែស្រក់ហូរមកនោះណា ហើយនាងក៏ដូចគ្នាដែរនៅពេលដែលគិតដល់ថា ឈឹតខាមែន នឹងមិនអាចត្រឡប់ចូលរាងកាយរបស់គេវិញបាន រំពេចនោះសំឡេងដែលនាងធ្លាប់ឮក៏បានលាន់ឮឡើង។

«យើស! ហាន់ណា យ៉ុនហ៊ី!! ពួកនាងត្រឡប់មកវិញហើយ?»

«**ឈឹត**!!»

«**ឈឹតអាអឹត**!!»

«ត្រូវហើយ! គឺខ្ញុំហ្នឹងឯងណា មិញនេះខ្ញុំបានដើរទៅរកមើលពួកនាងនៅក្នុងសារមន្ទីរនោះ ស្រាប់តែឃើញពួកនាងកំពុងតែអង្គុយតាំងសមាធិ ទើបខ្ញុំមិនហ៊ានរំខាននោះណា»

ហាន់ណា មើលទៅកាន់ស្វាមីដែលធ្វើឫកធម្មតាៗ មិនរង្គោះរង្គើអ្វីសោះនោះ គេមិនដឹងទេឬយ៉ាងណាហ្នឹងថា ការដែលខ្ញុំធ្វើបែបនេះគឺដើម្បីជួយសង្គ្រោះដល់មនុស្សដែលមានទុក្ខសោកនោះ តែអត់ទ្រាំមិនសូរមិនបាន។

«ហើយចុះបងទើបមកពីណាដែរ ?»

«បងទៅមើលរាហូចាប់ច័ន្ទនោះណាហើយក៏បានយកសៀវភៅមួយនេះទៅអានជាប់ដៃជាមួយដែរ ខ្យល់នៅខាងក្រៅត្រជាក់ដែរណា»

ស្រីស្រស់ទាំងពីរនាក់ក្រលេកភ្នែកមើលទៅកាន់សៀវភៅដែលនៅនឹងដៃរបស់ ឈើត ដូចណាត់គ្នាអីចឹង ដើមហេតុដែលធ្វើឲ្យពួកនាងស្លុតចិត្តគឺស្វាមីរបស់នាងនេះហ្នឹងឯង ភ្លាមនោះពួកនាងក៏ឧទានចេញមកព្រមៗគ្នាតែម្តង។

«**សៀវភៅ**!!»

**រំពេច**នោះសំឡេងរបស់ស្រីស្រស់ ដែលកំពុងតែទាស់ចិត្តស្វាមីនាងនោះក៏លាន់ឮឡើងភ្លាម។

«ឈើត យកសៀវភៅមកនេះឲ្យលឿនភ្លាមណា»

«អូននឹងអានវាមែនទេ វាជាភាសាអ៊ីស្លាមណា បងខានអានវាជាយូរមកហើយនោះណា»

«នែ!! ឈើត បងឲ្យសៀវភៅនោះមកខ្ញុំឲ្យលឿនឡើងទៅណា»

«បាន បាន បងថា អូនអានវាខ្លះក៏ល្អម្យ៉ាងដែរណា អូននឹងក្លាយជាមនុស្សដែលនិយាយដឹងរឿងខ្លះនោះអី»

មិនបានដូចចិត្តទាល់តែសោះហើយនៀក នាងមិនមានអារម្មណ៍ឯណាមកស្តាប់ពាក្យសម្តីនិយាយលេងរបស់ស្វាមីនាងនោះឡើយ នាងប្រញាប់ដើរទៅយកសៀវភៅចេញពីដៃស្វាមីរបស់នាង ដែលមិនដឹងអីទាល់តែសោះនោះ ភ្លាម តែការពិតទៅគេមិនដឹងរឿងមែននោះណា គេប្រហែលជាគិតថា នាងតាំងសមាធិលេងៗនោះណា ប្រហែលជាគេមិនគិតដល់ថ្នាក់ថា នាងអាចដកដួងវិញ្ញាណអីចេញពីរាងកាយនោះឡើយ បើសិនជាគេដឹងគេមិនព្រមឲ្យនាងមកធ្វើអីប្លែកៗបែបនេះទេមើលទៅ!



យ៉ុនហ៊ី បើកសៀវភៅមួយក្បាលនោះស្ទើរតែគ្រប់ទំព័រ តែមិនឃើញស្បែកសត្វដែលនាងធ្លាប់ឃើញនោះឡើយ ហាន់ណា បានងើយមើលទៅកាន់រាហូចាប់ច័ន្ទនោះម្តងទៀត វារៀបលិចបាត់ទៅហើយនោះណា ធ្វើឲ្យកាន់តែអាចមើលឃើញពណ៌ក្រហមកាន់តែខ្លាំងឡើងៗ។

«មិនមានមែនទេ យ៉ុនហ៊ី! ឯងប្រាកដហើយថា ឈើតខាមែន ទុកនៅក្នុងនេះពិតមែននោះ ?»

«ប្រាកដចិត្តហើយ»

«ស្លាប់ហើយ តើគួរតែធ្វើយ៉ាងណាដែរទៅទៀត»

ឈើត មើលទៅកាន់ស្រីស្រស់ទាំងពីរដូចជាមិនប្រក្រតីទាល់តែសោះ ហើយមើលទៅពួកនាងហាក់បីដូចជាវិលវល់ក្នុងការរកអ្វីម្យ៉ាងនៅក្នុងសៀវភៅមួយក្បាលនោះ ប្រហែលជាពួកនាងកំពុងតែរកបន្ទះស្បែកសត្វដែលមានសរសេរជាតួអក្សរភាសាអ៊ីស្លាមហើយមើលទៅនោះ ព្រោះគេបានឃើញវារបូតជ្រុះចេញមកនោះណា ទើបគេរើសវាដាក់ក្នុងហោប៉ៅ។ រំពេចនោះសំឡេងគ្រលររបស់ស្វាមីនាងក៏លាន់ឮឡើងភ្លាមផងដែរ។

«ពួកនាងទាំងពីរនាក់កំពុងតែរកអាមួយនេះមែនដែរទេ ?»

នាងទាំងពីរនាក់ដាក់ភ្នែកចេញពីសៀវភៅ ហើយបែរមកមើលស្បែកសត្វដែលសរសេរជាភាសាអ៊ីស្លាមដែលកាន់នៅនឹងដៃរបស់ ឈើត មុននឹងឧទានចេញមកផ្ទួនៗគ្នាសាជាថ្មីម្តងទៀត។

«ស្បែកសត្វ!!»

«ត្រូវហើយ! ហើយនេះពួកនាងនាំគ្នាលេងស្អីគេហ្នឹងហាស់ ហើយចុះរឿងដែលពួកនាងទៅជួយ ឈើតខាមែន នោះយ៉ាងម៉េចទៅហើយ!! ពួកនាងបានដឹងដែរទេថា រាហូចាប់ច័ន្ទនោះជិតលិចវិញបាត់ហើយណា»

មើលស្វាមីនាងនិយាយទៅមើស នោះត្រូវតែជាពាក្យដែលនាងត្រូវសួរគេវិញនោះទេណា មិនមែនជាអ្វីដែលគេមកសួរថាឲ្យនាងនោះឡើយ ចុះបើនាងរវល់តែរកវិធីជួយដល់ ឈើតខាមែន នៅឡើយនោះណា។ គេមិនដឹងខ្យល់អី

ទេ ឬយ៉ាងណាហ្នឹង! រំពេចនោះសំឡេងនិយាយទាំងក្រិតធ្មេញក៏បានលាន់ឮឡើងចេញពីមាត់របស់ភរិយាស្រីស្រស់របស់គេនោះ។

«ឈើត ផ្ញើសិនចុះ!!»

«ស្អីគេដែរទៅ! ស្បែកសត្វនេះឬផ្ញើទុកនឹងបងនោះ?»

«ស្បែកសត្វនោះយកវាមកឲ្យខ្ញុំ!! ហើយបងផ្ញើសិនចុះ ចាំចាត់ការតាមក្រោយ»

«ស្អីគេទៀតហើយហ្នឹង ហាន់ណា?»

ហឹមមម!! ស្វាមីរបស់នាងពូកែតែម្ដងអាខាងរករឿងមកឲ្យនាងទាស់ចិត្ត។ នាងមានអារម្មណ៍ក្ដៅក្រហាយ លូកដៃទៅយកស្បែកសត្វពីដៃស្វាមីមុននឹងបែរទៅពិភាក្សាជាមួយនឹងមិត្តស្រីរបស់នាង នាងមិនខ្វីខ្វល់ពីស្វាមីដែលកំពុងតែឈរងឿងឆ្ងល់ក្បែរៗនាងនោះឡើយ។

«នេះគឺជាតួអង្គជំនួយចុងក្រោយ ដែលឯងធ្លាប់ប្រាប់យើងនោះអី យ៉ុនហ៊ី»

«តើយើងត្រូវតែធ្វើយ៉ាងណាបន្តទៀតដែរទៅ?»

ហាន់ណា តាំងអារម្មណ៍យ៉ាងមុតមាំ នាងយកដៃទៅអង្អែលពោះរបស់នាងដូចរាល់ដង ព្រមទាំងនិយាយពាក្យដែលមនុស្សស្រីជនជាតិអ៊ីស្លាមតែលពេលនោះប្រាប់ដល់នាង ដែលនាងចាំជាប់ក្នុងខួរតែម្ដង។

**«ដល់ពេលដែលក្រសែចិត្តត្រូវបានរលត់ នៅពេលដែលរាហុចាប់ចន្ទបានចាំងបិទងងឹតសូន្យសុង ជីវិតបរិសុទ្ធនោះនឹងបានបញ្ចេញកម្លាំងរំលាយមន្តត្រាដោយភ្លើង»**

«រាហុលេបចន្ទហើយ ហើយជីវិតបរិសុទ្ធក៏បានរំលាយមន្តត្រាបានដោយភ្លើង»

«ហាន់ណា! នេះមានន័យថា...»

«ត្រូវហើយវាដូចដែលឯងគិតហ្នឹងឯងណា ឯងប្រញាប់ដុតស្បែកសត្វមួយផ្ទាំងនេះភ្លាមទៅណា ជាការបំផ្លាញមន្តត្រា»



«ដុតស្បែកសត្វមួយផ្ទាំងនេះឬ ហាន់ណា! យើងគ្រិសម្បុរអស់ហើយណា»

យ៉ុនហ៊ី ស្ទូបញាក់ នៅពេលដែលប្រាកដចិត្តច្បាស់ហើយនោះ ពួកនាងក៏បែរមកខាង ឈើត វិញ ធ្វើឲ្យ ឈើត ដែលឈរងឿងឆ្ងល់នោះកាន់តែងឿងឆ្ងល់ជាងមុនទៅទៀត នេះពួកនាងចង់ធ្វើស្អីគេហ្នឹង គេក៏មើលទៅកាន់ពួកនាងទាំងពីរនាក់មិនព្រមព្រិចភ្នែកដូចគ្នាដែរ។

«ដែកកេះណា ឈើត!»

«នេះអូនគិតថា បងលួចទៅជក់បារីឬ បានជាសួររកដែកកេះបែបនេះ»

«អូនគ្រាន់តែចង់ឲ្យបងជួយរកឈើគូស ឬក៏ដែកកេះឲ្យខ្ញុំបន្តិចតែប៉ុណ្ណោះ»

«អ!! បានតើស រឿងប៉ុណ្ណឹងសោះនោះណា»

ស្វាមីរបស់នាងកំពុងតែទាស់ចិត្តនាង ដែលកំពុងតែប្រតិបត្តិការណ៍ជួយដល់មនុស្សម្នាទៀតហើយ នាងមើលទៅកាន់រាងកាយដ៏ខ្ពស់ស្រឡះនោះដើរចេញទៅ ហើយក៏បានដើរមកវិញព្រមជាមួយនឹងឈើគូស និងទៀនមួយដើមមកជាមួយទៀតផងណា។

«យ៉ុនហ៊ី! យើងត្រូវនាំគ្នាតាំងសមាធិម្ដងទៀតណា»

«បាន! ឯងប្រញាប់ធ្វើវាឲ្យលឿនឡើងទៅណា ប្រយ័ត្នយឺតពេល»

«បានតើស! យើងនឹងចាត់ការឲ្យណា»

ពីរនាក់មិត្តភក្ដិបានតាំងសមាធិម្ដងទៀតដោយភាពមោះមុត និងព្យាយាមដើម្បីជួយ ឈើតខាមែន ឲ្យត្រឡប់ចូលរាងកាយគេវិញ។ ពេលដែលស្បែកសត្វនោះត្រូវបានដុត ផ្សែងពណ៌ខ្មៅក៏ប្រមូលផ្ដុំគ្នាហោះចេញទៅក្រៅបាត់ទៅ។

ឈើត ស្ទើរតែមិនជឿភ្នែករបស់គេទាល់តែសោះ ថាផ្សែងដែលបានហោះផ្ដុំគ្នាទៅនោះត្រូវបានកម្លាំងអ្វីមួយស្រូបទៅមួយទំហឹងនោះ នេះជាស្អីគេទេនៀក! ហើយគេក៏ដុតស្បែកសត្វនោះរហូតទាល់តែអស់សល់តែផេះ។ ដួងវិញ្ញាណរបស់ ឈើតខាមែន ត្រូវបានអំណាចអ្វីមួយអូសគេឲ្យទៅតាមផ្លូវរបស់វា

តែគេទៅមិនបានដោយមានអំណាចខ្លាំងជាងអំណាចមួយនោះចូលមករាំងគេមិនឲ្យទៅបានឡើយ ហើយរំពេចនោះកែវភ្នែករបស់គេក៏ឃើញដួងវិញ្ញាណរបស់ព្រះនាងទេមិនបានរសាយទៅយ៉ាងសន្សឹមៗ មុននឹងគេមានអារម្មណ៍ថាដូចជាមានអ្វីមួយទាញគេឲ្យធ្លាក់ពីលើទីខ្ពស់មួយអ៊ីចឹង។

សំឡេងក្អកនៅលើគ្រែធ្វើឲ្យស្រីស្រស់ទាំងពីរបើកភ្នែកឡើង ផ្ទៃមេឃប្រែជាស្រស់ថ្លាដូចដើមវិញ រាហូចាប់ចន្ទនោះបានរសាត់ទៅវិញបាត់ រាងកាយដែលដេកស្ដូកស្ដឹងចាប់ផ្ដើមកម្រើក ព្រមទាំងព្យាយាមបើកភ្នែកឡើងយ៉ាងយឺតៗ ហើយអ្វីដែលគេបានឮដំបូងបង្អស់គឺសំឡេងហៅឈ្មោះរបស់គេពីមនុស្សស្រីដែលគេស្រឡាញ់។

«ឈីតខាមែន! ឈីតខាមែន!!»

«យ៉ុនហ៊ី!...»

«បងដឹងខ្លួនហើយ! បងដឹងខ្លួនពិតមែនហើយ ឈីត!!»

ដៃរបស់គេលូកចាប់ចង្ការបស់នាងដែលឱនទ្រុបមុខទៅលើដើមទ្រូងរបស់គេនោះមកមើលឲ្យឃើញច្បាស់ ដៃរបស់គេជូតទឹកភ្នែកដែលហូរចេញនៅលើថ្ពាល់នាង ស្រីស្រស់នឹកសប្បាយចិត្តជាពន់ពេកដែលគេរួចពីគ្រោះភ័យហើយ ហើយគេក៏ក្រសោបឱបស្រីស្រស់មកនែបនិត្យនឹងដើមទ្រូងរបស់គេម្ដងទៀត។ ស្រីស្រស់ទ្រុបនៅលើដើមទ្រូងដ៏ធំរបស់គេនោះដោយភាពសប្បាយចិត្ត ទឹកភ្នែករបស់នាងហូរព្រោះតែរំភើបពេក រហូតដល់ជោគអាវមនុស្សប្រុសដែលដេកនៅលើគ្រែ។

«កុំយំទៅមីសអូន»

«អូនខ្លាចណាស់មានដឹងដែរទេ អូនខ្លាច ខ្លាចបងមិនត្រឡប់មកវិញ»

«ចុះបងបានសន្យារួចហើយតើស ថាមិនទៅណាចោលអូនជាដាច់ខាតនោះ»

«ចាស! អូនជឿហើយ ចាប់ពីពេលនេះតទៅយើងឈប់ខ្លាចបួងមន្តគ្រាទៀតហើយណា វាលែងមានអំណាចអីមកព្រាត់ប្រាស់យើងទៀតឡើយ»



កែវភ្នែករបស់ ឈីត ក្រឡេកទៅស្រោប់តែឃើញ ឈិត និងភរិយារបស់គេឈរញញឹមនៅក្បែរនោះដែរ ហើយព្រមទាំងបានយល់នូវរឿងរ៉ាវគ្រប់យ៉ាងព្រោះតែពីរនាក់ប្ដីប្រពន្ធនោះចូលមកជួយដល់ពួកគេ។

«អរគុណហើយណា ឈិតអាអ៊ីត អ្នកនាង ហាន់ណា ផងដែរ»

«ដោយក្ដីរីករាយចាស ព្រោះអាចធ្វើឲ្យលោកព្រមទាំងមិត្តភក្ដិខ្ញុំមានក្ដីសុខរួចផុតពីបួងមន្តគ្រានោះណា»

«មិនគួរឲ្យជឿទាល់តែសោះថាកូនរបស់ ហាន់ណា និង ឈិត អាចជួយដល់មនុស្សដែលមានទុក្ខសោកបានតាំងពីមិនទាន់កើតបែបនេះសោះ»

ឈិត ញញឹម ដៃគេស្រវាឱបភរិយាព្រមទាំងអង្អែលកូនក្នុងពោះ រួចស្ដាប់ ឈីតខាមែន និយាយកោតសរសើរយ៉ាងមានមោទនភាព

«ប្រហែលជាឈាម ឈិត ដែលចូលចិត្តជួយមនុស្សម្នាមានទុក្ខសោកនោះខ្លាំងហើយមើលទៅ បានជាបង្កើតកូនបានខ្លាំងបែបនេះនោះណា»

«ហ៊ឹមមម!!! ដូចជាសរសើរពេកហើយចាស!»

«យ៉ាងណាក៏ដោយចុះក៏ខ្ញុំសុំអរគុណចំពោះក្រុមគ្រួសារ ឈិត ណាស់ដែលបានជួយពួកខ្ញុំពីរនាក់ឲ្យរួចផុតពីបួងមន្តគ្រាបានបែបនេះ»

«ដោយក្ដីរីករាយណា ឈិត!»

ឈិត និយាយហាក់បីដូចជាយល់ចិត្តមនុស្សប្រុសដូចគ្នា កែវភ្នែកមើលទៅកាន់ ឈីតខាមែន ដែលប្រហែលជាត្រូវការភាពផ្ទាល់ខ្លួនជាមួយមនុស្សដែលគេស្រឡាញ់នោះអី ហើយក៏ប្រហែលជាត្រូវការលួងចិត្តស្រីស្រស់ យ៉ុនហ៊ី ដែរ ទើបគេក៏ទុកឱកាសនោះលាត្រឡប់ទៅសេតវិមានគៅវិញតែម្ដងទៅ។

«បើអ្វីៗរួចរាល់ហើយ ខ្ញុំពីរនាក់សុំត្រឡប់ទៅវិញសិនហើយណា»

«ទៅវិញហើយឬ ឈិត អូនមិនទាន់និយាយជាមួយ យ៉ុនហ៊ី ចប់ផងហ្នឹង»

«ចាំមកសាថ្មីក៏បានដែរតើស!»

«តែ...តែអូនចង់និយាយឥឡូវនេះណា»

«មិនមានតែនោះទេ អូននិយាយជាមួយបងក៏បានដែរតើស»

ឈើត បង្ខំភរិយាគេដែលមិនដឹងខ្យល់អីទាល់តែសោះនោះ ថាពួកគេពីរនាក់ត្រូវការភាពផ្ទាល់ខ្លួន ហើយចំពោះគេក៏ត្រូវការភាពផ្ទាល់ខ្លួនហ្នឹងគេដែរនោះណា នៅទីបំផុតគេត្រូវទ្រាំស្តាប់សំឡេងរអ៊ូរទាំរបស់ភរិយាគេជាថ្មី។

«ហើយបងប្រញាប់ទៅណាហ្នឹង យន្តហោះនោះប្រើពេលមិនដល់គន្លះម៉ោងផងហ្នឹង»

«អូនមិនយល់ចិត្តពួកគេទាំងពីរនាក់នោះផងទេអីហ្នឹង!»

«នេះបងចង់មានន័យថា ខ្ញុំគឺជាឆ្កឹងទទឹងកពួកគេទាំងពីរនាក់?»

«ត្រូវហើយ!! យើងបានជួយពួកគេឲ្យរួចផុតពីគ្រោះថ្នាក់ហើយ យើងបែរមកគិតរឿងរបស់យើងវិញម្តងទៅណាប្រពន្ធសម្លាញ់»

រឿងរបស់យើង? មែនហ្នឹងណា កាលដែលនាងបានដកដួងវិញ្ញាណចេញនោះគេបានដើរទៅណាបាត់ គេបានណាត់ស្រីណាផ្សេងជួបទេដឹង! ភ្លេចខ្លួនមិនបានទាល់តែសោះហើយនៀក។ រំពេចនោះសំឡេងរករឿងក៏លាន់ឮឡើងចេញពីមាត់របស់ភរិយាពូកែខាងឌឺរឹងទទឹងរបស់ ឈើត ភ្លាម។

«ឈើត! ពេលដែលខ្ញុំកំពុងតែតាំងសមាធិ បងបានទៅលបលួចជួបអ្នកណាមែនដែរទេ ប្រាប់ខ្ញុំភ្លាម!»

«ហាក!! ស្អីគេអូនហ្នឹង? នេះអូននៅមិនទាន់ភ្លេចទៀត?»

«ភ្លេចម៉េចនឹងបានទៅ ខ្ញុំប្រាប់បងហើយតើសថា ខ្ញុំនឹងគិតបញ្ជីជាមួយបងតាមក្រោយនោះ»

«ហឹមមម!! នេះអូនពូកែខាងទម្លាក់កំហុសលើបងតែរហូតនៀក»

«មិនដឹងទេ! នេះបងគិតថា ខ្ញុំដកដួងវិញ្ញាណចេញហើយ បងមានសិទ្ធិទៅណាមកណាធ្វើអីជាមួយអ្នកណាក៏បានឬ?»

«ហាស់!! ថាម៉េចហ្នឹង! នេះអូនបានដកដួងវិញ្ញាណដែរ?»

ឈើត ឈប់ដើរភ្លាមនៅពេលដែលគេបានឮសម្តីរបស់ភរិយារបស់គេ គេស្មានថា នាងគ្រាន់តែតាំងចិត្តអង្គុយសមាធិធម្មតាៗ គិតថាភរិយាគេចេះគិត



ឈប់រឹងទទឹង ចិត្តស្ងប់បានខ្លះ តែនេះភរិយារបស់គេដល់ថ្នាក់ដកដួងវិញ្ញាណចេញទៀត។

«ទ្រ!! បងសួរថា អូនដកដួងវិញ្ញាណឬ?»

«អូយ!! ស្តាប់ហើយ នេះខ្ញុំប្រាប់បងបែបហ្នឹង?»

«នេះអូនឈប់និយាយធ្វើមិនដឹងមិនឮបានហើយណា អូនបានធ្វើអីខ្លះអូនមានដឹងដែរទេ?»

ធ្វើម៉េចទៅនាងតាំងចិត្តបិទបាំងគេមិនឲ្យដឹង ព្រោះស្វាមីនាងហួងហែងពីនាង និងកូនគេសឹងអីហ្នឹងណាតែនាងបានត្រឡប់មកវិញបានហើយដែរតើសនាងមើលទៅកាន់កែវភ្នែកកាចរបស់ស្វាមី ព្រមទាំងនិយាយលួងលោមប្តីដោយសម្តីទន់ភ្លន់ ផ្អែមល្ហែមជាទីបំផុត ព្រោះវាជាអាវុធរបស់នាងដែលតែងតែប្រើជាមួយស្វាមីនាងនោះណា។

«តែអូនក៏បានត្រឡប់មកវិញហើយណា ឈើត អូនម៉េចនឹងអាចទៅចោលប្តីសម្លាញ់បានដែរទៅ មិនឃើញអីផងនោះណានៀក!! បងឃើញដែរទេ ហើយក៏បានជួយ ឈើតខាមែន ត្រឡប់មកវិញដោយសុវត្ថិភាពផងដែរ»

«អូនដឹងដែរទេ បើសិនជាអូន និងកូនត្រឡប់មកវិញមិនបាន តើឲ្យបងធ្វើម៉េចទៅ?»

«អូនដឹង! ថាបងបារម្ភអូន និងកូន តែទោះបីជាយ៉ាងណាក៏ដោយអូននិងកូនបានជួយមនុស្សរួចផុតពីទុក្ខសោកបាន បងកុំខឹងអីណា ឈើត!!»

ចុះបើនៅក្នុងជីវិតរបស់គេគឺមានតែភរិយា និងកូនដែលជាវត្ថុដ៏មានតម្លៃកាត់ថ្លៃមិនបាននោះណា និយាយចប់គេក៏កើតមានអារម្មណ៍ព្រឺសម្បុរឡើងភ្លាមតែម្តង បើសិនជានាងមានអីកើតឡើងនោះតើគេនឹងអាចមានជីវិតរស់នៅបានដោយរបៀបណាទៅ។ គេក៏ទាញដៃភរិយាមកឱបជាប់ប្រាណ ព្រមទាំងសម្តីទន់ភ្លន់បានចេញពីមាត់របស់គេភ្លាម។

«អូនសន្យាជាមួយបងណាថា នឹងមិនធ្វើអ្វីដែលប្លែកៗបែបនេះទៀតនោះ»

«ប្រហែលជាមានតែម្តងក្នុងឆាកជីវិតហ្នឹងឯងណា ឈិត ព្រោះជាទេវតាបានកំណត់បែបនេះនោះណា»

សំឡេងស្រួយស្រួសបាននិយាយឡើង ព្រមទាំងសើចយ៉ាងក្អាកក្អាយចំពោះភាពបារម្ភហួងហែងរបស់ស្វាមីនាង។ គេអត់ទ្រាំមិននិយាយតាមការពិតមិនបាន។

«ឲ្យរាពិតដូចដែលអូននិយាយចុះណា ចាប់ពីពេលនេះទៅបងប្រហែលជាត្រូវមើលថែអូនឲ្យម៉ត់ចត់ជាងនេះហើយទើបបាន»

«ហាស់!! កន្លងមកនៅមិនទាន់ម៉ត់ចត់ទៀតមែនទេ ឈិត?»

«កន្លងមកបងយោគយល់ចំពោះអូនច្រើនណាស់ ដល់ថ្នាក់ដកដួងវិញ្ញាណចេញពីខ្លួននៅមិនប្រាប់បងមួយម៉ាត់ផងហ្នឹងណា»

ករិយារបស់គេអត់ទ្រាំមិនគិតមិនបាន គេប្រាប់ថា គេមើលថែនាងដោយយោគយល់ពេកឬ កន្លងមកនាងមិនបានសូម្បីតែឈានជើងចេញពីគេផងនោះណា ហើយទម្រាំតែគេមើលថែនាងយ៉ាងម៉ត់ចត់វិញនោះ តើនាងអាចកម្រើកជើងបានឬអត់ហ្ន៎!!

«អ៎!! សរុបមកបងបានទៅណាដែរ នៅពេលដែលអូនដកដួងវិញ្ញាណនោះ ឈិត?»

«ទៀតហើយ រឿងនេះនៅមិនទាន់ចប់ទៀតឬ? ចុះក្រែងបងប្រាប់ហើយថា បងចេញទៅមើលរាហូចាប់ច័ន្ទនោះអ!!ហើយបានអានសៀវភៅដែលមានភាសាអ៊ិស្លាមនោះផងដែរ បងបានប្រាប់ហើយតើស»

ស្វាមីរបស់នាងបានបង្អូសសំឡេងឡើងវែង ហាក់នឿយចំពោះនាងដែលពូកែខាងរករឿង តែគេក៏បានព្យាយាមអធិប្បាយតាមការពិតយ៉ាងលម្អិតម្តងដែរនោះណា។

«មិនដឹងទេ!! ចាប់ពីពេលនេះតទៅ អូនក៏មិនព្រមឲ្យបងបាត់ពីក្រសែភ្នែកដូចគ្នាដែរ»

«បាន បាន! មើលនោះណាអាកាសធាតុល្អណាស់ យើងប្រញាប់នាំគ្នា



ទៅផ្ទះយើងវិញទៅណា»

វាជាប្រតិកម្ម ដែលនាងមិនព្រមចុះចាញ់គេនោះ ព្រោះស្វាមីរបស់នាងជាមនុស្សសង្ហាទាក់ទាញចិត្តស្រីៗគ្រប់គ្នា ចាប់ពីពេលនេះតទៅកុំសង្ឃឹមឲ្យសោះថា នឹងរួចពីកែវភ្នែករបស់នាងបាននោះ។ ទោះបីជាមានការប្រកែកគ្នាយ៉ាងណាក៏ដោយ ក៏គូស្វាមីភរិយាបានឱបគ្នាដើរទៅកាន់យន្តហោះផ្ទាល់ខ្លួនរបស់គេទៅកាន់សេតវិមានគេវិញផងដែរ។



## ...៧...

### ថ្ងៃថ្មីដែលសុខដុមរម្យនា

ពេលដែលរឿងរ៉ាវអាក្រក់ៗបានកន្លងផុតទៅ ស្រីស្រស់ដែលធ្លើជាក់លើខ្លួនឯងខ្ពស់អត់ទ្រាំមិននឹកដល់រឿងអាក្រក់ដែលទាក់ទងនឹងអំណាចអាថ៌កំបាំងកើតឡើងក្នុងជីវិតពិតរបស់នាងនោះមិនបានឡើយ។ ម្យ៉ាងស្វាមីដែលនាងបានមកដោយមិនបានត្រៀមខ្លួននោះទៀត នាងនៅតែងឿងឆ្ងល់មិនទាន់បាត់នៅឡើយ។ ពេលដែលកំពុងតែគិតនោះក៏មានអារម្មណ៍ថាដៃរបស់អ្នកណាម្នាក់បានមកឱបពីក្រោយត្រង់ចង្កេះរបស់នាង ព្រមទាំងរឹតយ៉ាងណែនថែមទៀតផង។

«កំពុងតែធ្វើរបាយការណ៍មែនដែរទេអូន ?»

«ចាស! ធ្វើរបាយការណ៍ទើបតែហើយនេះឯង!»



«ហើយចុះកំពុងតែគិតអីដែរទៅ ?»

«ធ្វើរបាយការណ៍គឺគិតពីរបាយការណ៍ហ្នឹងឯង»

នាងនិយាយតាមការពិតពាក់កណ្ដាល តើនាងម៉េចនឹងអាចប្រាប់គេបានទៅថា នាងកំពុងតែគិតពីរឿងរបស់ស្វាមីថ្មីថ្មោងរបស់នាងនោះណា។

«មើលចុះធ្វើរបាយការណ៍យ៉ាងណាទៅ សៀវភៅកត់ត្រាក៏នៅតុមួយនោះចំណែកឯអូនបែរជាមកនៅទីនេះទៅវិញ»

«ចុះក្រែងអូនប្រាប់បងហើយថា ទើបតែធ្វើរួចនោះអី ហើយក៏កំពុងតែគិត...អឺ...គិត...»

«គិតរឿងរបស់យើងពីរនាក់មែនដែរទេ!»

ត្រូវហើយ! ទោះបីជានាងនៅឆ្ងល់ការដែលនាងទើបតែបានស្វាមីមកដោយមិនបានត្រៀមខ្លួនត្រៀមប្រាណយ៉ាងណាក៏ដោយចុះ ប្រហែលជាខ្មោចឡហើយមើលទៅនោះ តើចំពោះគេវិញគេមានអារម្មណ៍យ៉ាងណាដែរទៅចំពោះរឿងរ៉ាវដែលកើតឡើងនោះ។

«ហើយចុះបងវិញគិតយ៉ាងម៉េចដែរទៅ ?»

«ហេតុអីក៏ចាំបាច់គិតធ្វើអីដែរទៅ!»

នេះគេមិនគិតអីទេឬ មានប្រពន្ធទាំងមូលនោះណា ឬក៏មនុស្សប្រុសគ្រប់គ្នាសុទ្ធតែបែបនេះគ្រប់គ្នានោះ ពេលមិនទាន់បានជាភរិយាវិញ និយាយរៀបរាប់យ៉ាងវែងឆ្ងាយពីអ្វីដែលល្អៗ ធ្វើយ៉ាងណាឲ្យយើងជឿចិត្តគេ ពេលបានមកហើយមិនចាំបាច់គិតអីឬ ហើយរំពេចនោះសំឡេងគ្រលរក៏បានលាន់ឮឡើងភ្លាម។

«តើអូនគិតអីច្រើនម្ល៉េះ ?»

អ្នកណាមិនគិតបានដែរទៅ កូនមានម៉ែមានឪណា អ្នកណាមិនចេះគិតដូច ឈើគខាមែន ដែរទៅ កាន់តែស្ដាប់ពាក្យសម្ដីរបស់គេកាន់តែក្ដៅចិត្តតែម្ដងរំពេចនោះផ្ទៃមុខស្រស់ស្អាតរបស់នាងក៏បែរជាក្រញូវឡើង។

«បងមិនគិតជារឿងរបស់បង តែខ្ញុំគិតម៉េចដែរ ?»

ផ្ទៃមុខរបស់គេនៅក្រកក្រង់ដើមក និងកញ្ចឹងកសខ្ចីរបស់នាង រង្វង់ដៃរបស់គេកាន់តែឱបខ្លាំងជាងមុនទៅទៀតព្រមទាំងគិតថានាងមិនដឹងជាត្រូវគិតអ្វីច្រើននោះទេ ព្រោះថានាង និងគេក្លាយជារបស់គ្នានិងគ្នាទាំងកាយ និងចិត្តទៅហើយនោះ។

«មនុស្សប្រុសមនុស្សស្រីដែលស្រឡាញ់គ្នា ហើយមានអីៗនឹងគ្នា ហើយក៏រៀបការនឹងគ្នា គ្រាន់តែប៉ុណ្ណឹងវារួចបាត់ទៅហើយ មិនមានអីត្រូវគិតនោះទេ»

«នេះឬ ដែលថា មិនចាំបាច់គិតច្រើននោះ?»

«បងបានត្រៀមរឿងរៀបការរបស់យើងរួចរាល់ហើយ អូនគ្រាន់តែរង់ចាំធ្វើជាកូនក្រមុំរបស់បងតែប៉ុណ្ណោះទៅបានហើយណា»

«នេះបងបានត្រៀមការរៀបការរួចរាល់ហើយ?»

«ត្រូវហើយណា! វាដល់ពេលដែលបងត្រូវធ្វើខ្លួនដូចមនុស្សធម្មតានឹងគេម្តងហើយ មិនចាំបាច់លាក់បាំងខ្លួនឯងអីទៀតនោះឡើយ ហើយអ្វីដែលសំខាន់បងមានភរិយាដ៏ស្រស់ស្អាត ព្រមទាំងគួរឲ្យស្រឡាញ់ម្នាក់ទៅហើយនោះណា មិនឲ្យបើកចំហដោយរបៀបណាទៅ!»

នាងបែរមកកើយទ្រូងរបស់ស្វាមីនាងយ៉ាងមានក្តីសុខ ទោះបីជានាងបានស្វាមីដែលទើបតែស្គាល់គ្នាមិនបានមួយខែផងនោះក៏ដោយចុះ តែពេលនេះអារម្មណ៍របស់នាងហាក់ដូចជាបានស្គាល់គេរាប់រយឆ្នាំមុនអីចឹង។ត្រូវហើយណា ព្រោះនាង និងគេធ្លាប់ស្និទ្ធស្នាលគ្នាតាំងពីជាតិមុនៗមកនោះអី មិនឲ្យមានអារម្មណ៍ថា ស្និទ្ធស្នាលគ្នាបានយ៉ាងណាទៅ! ការឱបក្រសោបរបស់ស្វាមីដូចជាជ្រាលជ្រៅទៅៗហើយ យ៉ុនហ៊ី ក្រឡេកមើលទៅឆ្វេងស្តាំដោយអាការៈអៀនខ្មាសថា ខ្លាចមានអ្នកណាឃើញ ទើបនាងប្រញាប់បញ្ឈប់ទង្វើរបស់គេនោះភ្លាមតែម្តង ព្រោះនាងមិនចង់សម្តែងល្បែងស្នេហានៅកណ្តាលវាលបែបនេះទេ បើសិនជានៅក្នុងបន្ទប់គេងវិញនោះ ស្រីស្រស់អាចត្រៀមខ្លួនក្នុងការរង់ចាំត្រូកសេជាតិស្នេហ៍របស់គេជានិច្ច ចុះបើនាងជាក្មេងរៀននោះណា ហើយថែមទាំងខំប្រឹងដើម្បីរៀនបាននិទ្ទេសល្អផងដែរ។



«លែងអូនសិនទៅណា! អូនសុំរៀបចំសម្ភារធ្វើរបាយការណ៍នេះទុកសិនបានទេ!»

ទោះបីជាគេទ្រេតត្រតក្នុងការដោះលែងភរិយារបស់គេយ៉ាងណាក៏ដោយក៏គេបានដឹងដែរថា ការដែលនាងនិយាយនោះគ្រាន់តែជាលេសអាងតែប៉ុណ្ណោះ ភរិយារបស់គេចង់ចូលទៅក្នុងបន្ទប់ដែលមិនមានមនុស្សណាឃើញឯងណោះទេ គិតចប់គេក៏ប្រញាប់ជួយរៀបអីវ៉ាន់ភរិយារបស់គេទុក ព្រោះថា គេក៏ត្រូវការចូលទៅក្នុងបន្ទប់ដែលមិនមានមនុស្សម្នាឃើញដូចគ្នាដែរ។

«បានតើស! បងជួយអូនណា»

នាងញញឹមចំពោះពាក្យសម្តី ព្រមទាំងការបញ្ចេញមន្តស្នេហ៍នោះ ពួកគេទាំងពីរនាក់ នាំគ្នារៀបចំសម្ភារចូលទៅក្នុងសេតវិមានវិញយ៉ាងប្រញាប់ប្រញាល់ព្រោះពេលនេះនាងបានស្រឡាញ់ពេញចិត្តចំពោះកែវភ្នែក ដែលមានមន្តស្នេហ៍នោះហើយ វាជាសញ្ញាបញ្ជាក់ពីការដែលនាងនឹងបានទទួលក្តីសុខពីមនុស្សប្រុសដែលនាងស្រឡាញ់។

នៅឯមហាវិទ្យាល័យក្រុង ខៃរ៉ូ នៅក្នុងបន្ទប់រៀនមុខវិជ្ជាបុរាណវិទ្យាមានភាពស្ងប់ស្ងាត់ណាស់ សិស្សទាំងឡាយតាំងភ្លឹកចំពោះការឡើងបកស្រាយសារណាដែលស្រីស្រស់ យ៉ុនហ៊ី បានធ្វើទាក់ទងនឹងគ្រឿងប្រដាប់ដែលជាទ្រព្យសម្បត្តិបន្សល់ទុករបស់ព្រះនាងទេមីន។

លោកគ្រូសាស្ត្រាចារ្យ ក៏ធ្លាក់ក្នុងភាពតាំងភ្លឹកដូចសិស្សដទៃទៀតនោះដែរ កែវភ្នែកម្នាស់មើលទៅកាន់ស្រីស្រស់ដែលកំពុងតែនិយាយរៀបរាប់ពីព្រឹត្តិការណ៍ និងរបាយការណ៍ដែលទាក់ទងនឹងព្រះនាង ទេមីន យ៉ាងក្បោះក្បាយហាក់បីដូចនាងគឺជាព្រះនាង ទេមីន អីចឹង រហូតធ្វើឲ្យការការពារសារណានោះបានចប់សព្វគ្រប់។ សិស្សនិស្សិតទាំងឡាយស្ថិតក្នុងអារម្មណ៍សោកសៅនៅពេលដែលនាងបាននិយាយរៀបរាប់រឿងរ៉ាវពិតរបស់ព្រះនាង ទេមីន និងព្រះស្វាមីរបស់ព្រះនាងមួយខណៈពេល រំពេចនោះសំឡេងទះដៃក៏លាន់ឮយ៉ាងទ្រហឹងអឺងកង ព្រមទាំងមាននិស្សិតមួយចំនួនធំចូលមកសាកសួររឿងរ៉ាវដែល

នាងបានដឹង ហាក់បីដូចជាពួកគេចង់ស្ដាប់តាគបន្តអីចឹង។

«យ៉ុនហ៊ី សរុបមកព្រះនាង ទេមិន នោះបានមកចាប់ជាតិថ្មីមែនដែរទេ?»

«ព្រះស្វាមីរបស់ព្រះនាងក៏មកចាប់ជាតិថ្មីដែរមែនទេ?»

«យ៉ុនហ៊ី! យ៉ុនហ៊ី!»

នាងខ្លួនឯងក៏ពិតជាចង់រៀបរាប់រឿងរ៉ាវរបស់ព្រះនាង ទេមិន ដែលមកចាប់ជាតិថ្មីជានាង និងព្រះស្វាមីដែលមកចាប់ជាតិថ្មីនោះដូចគ្នាដែរ។ តែភ្នែកនាងមើលទៅកាន់មិត្តរួមថ្នាក់ដែលមើលមកដោយភាពកោតសរសើរ។

«យ៉ាងម៉េចទៀតដែរទៅ យ៉ុនហ៊ី?»

«ខ្ញុំបានធ្វើតាមបរិបទនៃសារណាដែលលោកគ្រូបានដាក់ឲ្យហើយណា តែឥឡូវវាបានចប់សព្វគ្រប់ហើយ»

ហើយរំពេចនោះ សំឡេងអ៊ូមួយក៏លាន់ឮឡើងក្នុងចំណោមហ្វូងមិត្តភក្ដិរួមថ្នាក់របស់នាង ដែលកំពុងតែមានអារម្មណ៍ចង់តាមដាននោះអីព្រោះវាហាក់ដូចជាមិនទាន់ចប់ បើសិនជាវាចប់រឿងនោះពិតមែនតួប្រុស និងតួស្រីប្រាកដជាបានក្ដីសុខរម្យនាជាមួយគ្នាជាក់ជាមិនខានឡើយ។

«អូ!! ពិតជាអាណិតព្រះនាង ទេមិន ខ្លាំងណាស់ ដល់ថ្នាក់ព្រះនាងបានរៀបការរួចទៅហើយនៅមិនទាន់បានសមបំណងទៀតហ្នឹងណា»

«មែនហើយ! ព្រះនាងប្រហែលជាស្រឡាញ់ព្រះស្វាមីព្រះនាងខ្លាំងណាស់ហើយមើលទៅនោះ បានជាព្រះនាងតាំងចិត្តអធិដ្ឋាន ព្រមទាំងស្លាប់តាមព្រះស្វាមីទៅតាមក្រោយនោះណា យើងថាព្រះនាង ប្រាកដជាបានមកចាប់ជាតិថ្មីជាក់ជាមិនខានទេ យល់បែបហ្នឹងដូចខ្ញុំដែរទេពួកយើង?»

«អឺមមម!!មែនហ្នឹងណាហើយតើអ្នកណាទៅដែលកើតមកជាព្រះនាង ទេមិន និងព្រះស្វាមីរបស់ព្រះនាងក្នុងជាតិនេះទៅ ឬក៏...»

គ្រប់ក្រសែភ្នែកទាំងអស់សម្លឹងចាប់ចងមកកាន់ម្ចាស់របាយការណ៍ដែលបានធ្វើការរាយការណ៍យ៉ាងក្បោះក្បាយឥតខ្ចោះហាក់ដូចជានាងគឺជាព្រះនាង ទេមិនខ្លួនឯងអីចឹង រំពេចនោះក៏មានផ្ទុះសំឡេងនិយាយចេញមកដូចៗគ្នាព្រម



ទាំងដំណាលៗគ្នាទៀតផង

«យ៉ុនហ៊ី!!»

«ត្រូវហើយ ប្រាកដជា យ៉ុនហ៊ី ប្រាកដហើយ!!»

ប្រហែលជាត្រូវដល់ពេលដែលនាងត្រូវនិយាយហើយមើលទៅនោះ នាងត្រូវរៀបរាប់ប្រាប់ដល់អ្នកទាំងអស់គ្នាថា នាងគឺជាព្រះនាងទេមិនបានមកចាប់ជាតិថ្មី ព្រោះថាវានឹងអាចមានសំណួរសួរមកទៀតជាក់ជាមិនខាន មិនទាន់ទាំងបានសរុបសេចក្ដីចប់សព្វគ្រប់ផងសំឡេងមិត្តភក្ដិបានលាន់ឮឡើងជាបន្ទុះ

«យើងនឹកឃើញហើយ យ៉ុនហ៊ី ការដែលឯងរស់តែងប់ងល់ជាមួយនឹងឈិតខាមែន ម្ចាស់សេតវិមានដ៏ធំស្កឹមស្កៃ ព្រមទាំងជាម្ចាស់សារមន្ទីរ និងគ្រឿងប្រដាប់របស់ព្រះនាងទេមិនទៀតនោះ គេនោះហើយដែលជាព្រះស្វាមីមកចាប់ជាតិថ្មីរបស់ព្រះនាងទេមិននោះណា មែនដែរទេ យ៉ុនហ៊ី?»

«ហ៊ឹមមម!!! មែនហ្នឹងណា យ៉ុនហ៊ី តើមានព្រឹត្តិការណ៍ដែលគួរឲ្យស្ញប់ស្ញែងណាខ្លះដែរទៅ?»

គេនាំគ្នានិយាយពីស្ដី កាន់តែយ៉ាប់ទៅៗហើយណា យ៉ុនហ៊ី ចាប់ផ្ដើមខ្វល់ខ្វាយ រំពេចនោះសំឡេងស្រស់ស្រាយក៏បន្លឺឡើងភ្លាមដើម្បីបញ្ចប់សេចក្ដី

«ពួកឯងប្រហែលជាឆ្ងល់ក់រង្វេងចំពោះរឿងរ៉ាវដែលខ្ញុំនិយាយប្រាប់ពេកហើយទេដឹង ខ្ញុំគ្រាន់តែ...»

«គ្រាន់តែអីដែរទៅ យ៉ុនហ៊ី?»

តើនាងគួរតែកុហកពួកគេបន្តទៀតយ៉ាងណាដែរទៅហ្ន៎! ចុះបើនាងនឹងរៀបការជាមួយនឹង ឈិតខាមែន ហើយនោះណា តើនាងគួរខ្មាសអៀនអីទៀតដែរទៅ បើបណ្ដាមិត្តភក្ដិរបស់នាងនាំគ្នាគិតតែខ្លួនឯងហើយវាក៏ជាការពិតផងនោះណា។

ទោះបីជានាងនិយាយរៀបរាប់ ឬមិននិយាយក៏ដោយចុះ តែមនុស្សម្នាគ្រប់គ្នាក៏ជឿថា នាងគឺជាព្រះនាងទេមិនមកចាប់ជាតិថ្មីដែរ ចំណែកឯព្រះស្វាមីរបស់នាងគឺជា ឈិតខាមែន នោះ។ បើបែបហ្នឹងហើយនោះនាងមិនព្រមឲ្យវា

ទៅតាមហ្នឹងទៅ វាចប់រឿងទៅហើយ មិនដឹងជាមករករឿងកុហកអីដល់ណា ទៀតនោះទេ ព្រោះរឿងរ៉ាវដែលកើតឡើងចំពោះនាងគឺជាការពិតនោះណា។ ភ្លាមនោះសំឡេងដែលស្ងប់ស្ងែងក្រោកអរជាមួយនាងក៏លាន់ឮឡើង។

«គឺគ្រាន់តែយល់ព្រមរៀបការជាមួយ ឈើតខាមែន នោះឯងណា»

ភ្លាមនោះសំឡេងក៏លាន់ឮឡើងនៅក្នុងថ្នាក់រៀនរបស់នាងជាបន្តទៀត ជាមួយនិងសំឡេងសម្ដែងយោបល់ផ្សេងជាច្រើនទៀត។

«ឃើញទេ យ៉ុនហ៊ី យើងថាហើយមិនចេះខុសនោះទេណា របស់របរព្រម ទាំងគ្រឿងប្រដាប់ប្រើប្រាស់ទាំងឡាយរបស់ព្រះនាង ទេមីន កាលពីជាតិមុន ប្រាកដជាធ្លាក់មកជាកម្មសិទ្ធិរបស់ព្រះនាងទេមីនដែលមកចាប់ជាតិថ្មីនោះឯង ណា»

«ត្រូវហើយណា យើងក៏យល់បែបហ្នឹងដែរ តើមានរឿងអីកើតឡើងខ្លះ ដែរទៅ បានជាឯងសម្រេចចិត្តរៀបការជាមួយ ឈើតខាមែន នោះ?»

អូ!!! កាន់តែយ៉ាប់ហើយនៀក សំណួរនេះហ្នឹងឯងដែលនាងពិតជាខ្លាច ជាងគេនោះណា អ្នកណាទៅហ៊ានប្រាប់គេឯងទៅថា នាងបានក្លាយជារបស់ ឈើតខាមែន នោះហើយណា វាជារឿងដែលគួរនិយាយដែរទេ!

«យ៉ាងម៉េចដែរ យ៉ុនហ៊ី! ស្គាល់គ្នាមិនបានប៉ុន្មានផង យល់ព្រមរៀបការ ជាមួយគេបាត់ទៅហើយហ្នឹង តើមានរឿងអីមិនស្រួលកើតឡើងទេដឹងហ្នឹង? វាយ៉ាងណាខ្លះដែរទៅ និយាយប្រាប់ពួកយើងខ្លះមក ទោះបីនាងគឺជាគូព្រេង របស់ ឈើតខាមែន តាំងពីជាតិមុនមកក៏ដោយចុះ»

យ៉ុនហ៊ី ត្រូវបានក្រុមមិត្តភក្តិនិយាយឲ្យទាល់ច្រក មើលទៅលោកគ្រូ ដែលជាមនុស្សចាស់ជាងគេក៏និយាយឡើង រសាយភាពរញ៉េរញ៉ៃក្នុងថ្នាក់នោះ ភ្លាម៖

«ល្មើយចុះ! ពួកយើងគ្រប់គ្នាប្រហែលជាបានដឹងពីដំណើររឿងនៃគ្រឿង ប្រដាប់នេះហើយណា លោកគ្រូថាយើងនាំគ្នាស្ដាប់រឿងរ៉ាវរបស់ ក្លារមល្បួស របស់ស្ដេច ហ្សារ៉ូ ម្ដងយ៉ាងម៉េចដែរ!! អ្នកណាដែលស្រាវជ្រាវចំណាងជើង



ទាក់ទងជាមួយនឹងអត្ថបទនេះនិយាយរៀបរាប់ជាបន្តបន្ទាប់មកណា»

«អូ! លោកគ្រូហ្នឹ!! និយាយបង្វែរឡើងតាមមិនទាន់តែម្ដងហើយនៀក»

ហឹមមម!! វាងគួរទ្រូងបន្តិច យ៉ុនហ៊ី ដកដង្ហើមធំព្រមទាំងមើលទៅកាន់ ឯកសារដែលលោកគ្រូបានត្រួតពិនិត្យហើយនោះ ដែលមានទាំងស៊ីញ៉េព្រមទាំង ពិន្ទុមកជាមួយ ដែលជាហេតុធ្វើឲ្យនាងញញឹមបិទមាត់មិនជិត យ៉ាងមានមោទន ភាពព្រោះនាងបានពិន្ទុខ្ពស់នោះណា ពិតជាហេងមែនទែនតែម្ដងការងារនេះ ក្រៅពីបានលទ្ធផលល្អហើយ ថែមទាំងបានស្វាមីមួយដ៏ប្រពៃផងដែរណា គួរ ឲ្យស្ងប់ស្ងែងមែនទែន!

**នៅឯសេតវិមានដ៏សែនធំល្វឹងល្វើយរបស់ ឈើត នៅតែមានភាពស្រស់** ស្រាយដោយសារតែការយកចិត្តយកថ្លើមរបស់ស្វាមី ព្រោះភរិយាគេនឹងអឺ មិនឲ្យគេតាមយកចិត្តយកថ្លើមបានយ៉ាងម៉េចទៅ។ កែវភ្នែកមើលទៅកាន់ ភរិយាដែលដើរចុះពីជណ្ដើរមក ព្រមទាំងនិយាយទូរស័ព្ទនៅពេលដើរនោះទៀត ទើបបុរសមាឌធំក៏ដើរទៅជួយគ្រានាងយ៉ាងកក់ក្ដៅតែម្ដង។

«ឯងបានកំណត់ថ្ងៃរៀបការហើយមែនដែរទេ យ៉ុនហ៊ី យល់ព្រម ចាំ យើងប្រាប់ ឈើត ឲ្យណា ចាស! មិនអីទេណា!! អឺ!! ប៉ុណ្ណឹងហើយណា»

«ប្រយ័ត្នតិចទៅណាអូន ពេលចុះជណ្ដើរកុំនិយាយទូរស័ព្ទមើល»

«អូយ!!»

និយាយមិនទាន់ទាំងចប់ពីមាត់ផង នាងក៏បានជាន់ភ្លាត់ជណ្ដើរដែលនៅ សល់តែពីរកាំចុងក្រោយនោះ ដៃដ៏មាំរបស់ ឈើត ទ្រនាងជាប់ ធ្វើឲ្យគេស្ទើរតែ ស្លះបេះដូង។ ភ្លាមនោះសំឡេងមុតមាំក៏លាន់ឮឡើងខ្ទរពេញសេតវិមាន។

«ប្រយ័ត្នបន្តិចទៅមើល!! តើបងគួរតែធ្វើយ៉ាងណាល្អចំពោះអូនទៅ នៀក ជណ្ដើរដើររាល់តែថ្ងៃនៅជាន់ខុសទៀត!!!»

ចំណែកឯភរិយាដែលកំពុងតែស្លុតចិត្តនោះ ធ្វើឲ្យនាងកាន់តែស្លុតចិត្ត ចំពោះការប្រើសម្ដីឮៗរបស់ស្វាមីនាង ហើយនាងបែរទម្លាក់កំហុសឲ្យស្វាមីរបស់

នាងធ្វើព្រងើយទៅវិញថា មកពីគេស្រែកស្តីឲ្យនាង បានជានាងស្លុត ជំនួសកំហុសដើរជាន់ខុសជណ្តើរ។

«ហេតុអីក៏ចាំបាច់និយាយឮៗធ្វើអីដែរទៅ ឈើត ខ្ញុំនេះភ័យសឹងអី!»

«ហើយចុះហេតុអីក៏អូនមិនព្រមប្រយ័ត្នដែរទៅ»

«អ្នកណាប្រាប់បងដែរទៅថា ខ្ញុំមិនប្រយ័ត្ននោះ?»

«នែ៎!! បងឃើញនឹងភ្នែកផ្ទាល់តែម្តងណា ថាអូនដើរនិយាយទូរស័ព្ទភ្នែកមិនមើលជណ្តើរនោះ»

«តែខ្ញុំភ័យនឹងសម្តីរបស់បងជាងនោះណា មើលចុះខ្ញុំភ្លេចទៅថារកប្រាប់អីដល់បងទៀតណា»

ហាន់ណា រៀបរៀងការគិតនោះឡើងវិញថា នាងនឹងប្រាប់អ្វីដល់ស្វាមីរបស់នាង ហឹម!! នឹកមិនឃើញទាល់តែសោះហើយនៀក នាងបានអាននៅក្នុងតម្រាថា មនុស្សស្រីដែលមានផ្ទៃពោះភ្លេចខ្លាំងច្រើន តែសម្រាប់នាងវិញតាមធម្មតានាងក៏ឆាប់ភ្លេចស្រាប់ហើយនោះណា បែបនេះនាងមិនក្លាយជាមនុស្សដែលភ្លេចខ្លាំងទេអី! ភ្លាមនោះសំឡេងស្វាមីដែលបារម្ភពីនាងក៏លាន់ឮឡើង។

«ហាន់ណា អូនយ៉ាងណាហើយហ្នឹង»

«បង! កុំអាលមករំខានសមាធិខ្ញុំអីបានទេ ខ្ញុំកំពុងតែនឹកថា ខ្ញុំចង់ប្រាប់អីដល់បងនោះណា»

ផ្ទៃមុខស្រស់ស្អាតនោះបានគិតថា នឹងប្រាប់អីដល់ស្វាមី តែនឹកមិនចេញទាល់តែសោះ នេះនាងក្លាយជាមនុស្សឡប់ទេដឹង ហើយស្វាមីនាងក៏ចាប់ផ្តើមនិយាយសាជាថ្មី។

«រឿង យ៉ុនហ៊ី ដែលត្រូវរៀបការនោះមែនទេ!»

«មែនហើយ! មែនហើយ! នាងនឹងរៀបការ ហើយហេតុអីក៏បងដឹងដែរទៅ?»

«ហឹមមម! ចុះបើអូនដើរនិយាយទូរស័ព្ទសំឡេងឡើងឮៗនោះអី អ្នកណាមិនដឹងដែរទៅ?»

«ស្តាយណាស់ដែលយើងមិនបានមានកម្មវិធីនោះណា»

«ចុះបើអូនមិនព្រមរៀបការតែខ្លួនឯងសោះហ្នឹងណា»

ឈើត ទាញភរិយាគេមកឱប ទោះបីជាមិនបានរៀបចំកម្មវិធីរៀបការដែលភរិយារបស់គេមិនព្រមតាមចិត្តក៏ដោយចុះ តែគេក៏បានចុះសន្ធិសញ្ញាសែតរួចរាល់ហើយថា គេបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនឹងមនុស្សស្រីម្នាក់នេះ។

«អូនចង់រៀបការមែនដែរទេ?»

«មិនអីទេណា អូនភ្លេចអារម្មណ៍នោះជាយូរមកហើយ»

«បើអីចឹងយើងរៀបចំកម្មវិធីគម្រប់មួយឆ្នាំជាមួយគ្នាតែម្តងទៅ»

«គម្រប់ខួបមួយឆ្នាំ! ពេលនោះខ្ញុំពោះឡើងប៉ោងប្រាំពីរទៅប្រាំបីខែបាត់ទៅហើយ អត់ទេ ពោះធំបែបនេះខ្ញុំមិនធ្វើពិធីវិញប្រសើរជាង»

ស្វាមីកំលោះមិនព្រមអស់ក្តីព្យាយាមក្នុងការយកចិត្តយកថ្លើមភរិយាគេឡើយ ព្រោះជាតួនាទីរបស់គេដែលធ្វើឲ្យភរិយាគេមានក្តីសុខនោះណា។

«បើអីចឹងយើងនឹងរៀបចំកម្មវិធីទទួលសមាជិកថ្មីល្អទេ?»

«នេះបងនឹងនាំប្រពន្ធចុងមកក្នុងផ្ទះឬ?»

«ស្តីគេទៀតហើយ! អូនទម្លាក់កំហុសមកលើបងទៀតហើយណា បងមានន័យថាកូនរបស់យើងពីរនាក់នោះណា»

«រួចខ្លួន! កុំសូម្បីតែគិតឲ្យសោះណា»

«អូនកុំនិយាយរករឿងទៅបានហើយ»

«ឈើត!! ចាំបងទៅចាប់ជាតិថ្មីទៅ កុំឲ្យខ្ញុំរកចំណុចខ្សោយឃើញណា»

ឈើត អត់ទ្រាំមិនសើចចំពោះពាក្យសម្តីដែលភរិយាគេនិយាយចេញមកមិនបាន ព្រោះគេគ្រាន់តែលេងជាមួយនាងសោះនោះណា។ តាំងពីនាងមានផ្ទៃពោះមកហាក់បីដូចជាមានសាច់មានឈាម ភ្លឺថ្លាជាងមុន គេមិនចង់សូម្បីតែក្រឡេកភ្នែកមើលស្រីណាផ្សេងសោះឡើយ។

«បងនិយាយលេងតើស! បងថាយើងនាំគ្នាទៅសម្រាកនៅខាងលើវិញទៅប្រសើរជាងណា»

«ខ្ញុំទើបតែចុះមកសោះ បងចង់ឲ្យខ្ញុំឡើងទៅវិញទៀតហើយឬ?»

ហើយនាងក៏នឹកឃើញភ្លាម នៅពេលដែលឃើញកែវភ្នែករបស់ស្វាមីដែលនាងទាយមិនចេះខុសនោះ គេចង់ប្រតិបត្តិការលើគ្រែទាំងថ្ងៃថែសបែបនេះឬ!

«ខ្ញុំដឹងណា ថាបងត្រូវឡើងទៅលើធ្វើអីនោះ»

«ណា! អូនមិនដឹងអីទាល់តែសោះ បងគ្រាន់តែចង់គដៃគជើងកូនរបស់យើងតែប៉ុណ្ណោះ»

ហឹមម!! លើកហេតុផលមកនិយាយដដែលៗជាលេសតែប៉ុណ្ណោះ ទោះបីជារឿងឥតប្រយោជន៍ក៏គេលើកយកមកជាលេសបានដែរ។

«នែ៎ ឈើត! បងចង់ឲ្យកូនយើងមានដៃមួយរយជើងមួយរយឬ! ខ្ញុំឃើញបងធ្វើបែបនេះជាងមួយខែមកហើយ»

នាងចាំបានល្អដែរហ្នឹង ចុះព្រែងនិយាយថា មនុស្សស្រីមានផ្ទៃពោះមិនសូវចងចាំអីនោះ បើអ៊ីចឹងរកលេសផ្សេងវិញ!

«អ៊ីចឹងម៉ាស្សាខ្លួនក៏បានដែរ»

«បងប្រាកដហើយថា គ្រាន់តែម៉ាស្សាខ្លួនពិតមែននោះ!»

«ហឹស!! ហេតុអីក៏អូនពូកែរកខាងជំទាស់ចិត្តបងតែរហូតអ៊ីចឹង?»

«ល្មើយចុះ! ចាត់ទុកថា ខ្ញុំម៉ាស្សាខ្លួនមុន រួចហើយចាំម៉ាស្សាអីផ្សេងតាមក្រោយក៏បានដែរ»

ត្រូវតែយល់ព្រមហើយ នាងមិនយល់ព្រមយ៉ាងម៉េចហ្នឹងកើតទៅបើស្វាមីរបស់នាងគេជាអ្នកជំនួញ ខួរក្បាលគេឆ្លាតសឹងអីនោះណា។ ហើយបន្ទាប់មកនាងក៏ព្រមឲ្យស្វាមីគ្រកងទៅកាន់បន្ទប់គេងនៅខាងលើភ្លាម នាងក៏ពិតជាត្រូវការឲ្យស្វាមីនាងម៉ាស្សាទាំងខាងមុខ និងខាងក្រោយដូចគ្នានោះណា ម្យ៉ាងទៀតវាអាចបន្ថែមក្តីនៃបនិត្យព្រមទាំងក្តីស្រឡាញ់ឲ្យគ្នាទៅវិញទៅមកដែរមិនអ៊ីចឹង!



សេតវិមានដែលតែងតែគួរឲ្យខ្លាច ពេលនេះបែរជាមានជីវិតជីវ៉ាជាងមុនពោរពេញដោយក្តីស្រឡាញ់ល្អកល្អើនតែម្តង ឈើតខាមែន ឱបកវិយារបស់គេយ៉ាងណែនជាប់នឹងដើមទ្រូង ផ្ទៃមុខរបស់គេមានក្តីសុខក្រោយពីគេទាំងពីរបានរួចផុតពីអំណាចមន្តស្រា ហើយថែមទាំងបានកវិយាដ៏ស្រស់ស្អាតព្រមទាំងគួរឲ្យស្រឡាញ់ទៀតផង ផ្ទុយស្រឡះពីកវិយារបស់គេដែលនៅគិតពីនេះពីនោះមិនចេះចប់នោះអី ថារឿងរ៉ាវដែលកើតឡើងទាំងប៉ុន្មានគឺជាការស្រមៃ ឬជាការពិតដែរទៅ ដែលនាងបានប្តីមកនៃបនិត្យដោយមិនបានតាំងចិត្តបែបនេះនោះណា ទោះបីជានាងព្យាយាមគិតថា វាជារឿងពិតយ៉ាងណាក៏ដោយចុះ។

«អូនកំពុងតែគិតអីដែរទៅ?»

នាងបែរមកចាប់អារម្មណ៍លើស្វាមីសង្ហា ដែលកំពុងតែលើកចង្កានាងសួរពេលគេចាប់ចង្កាមើលមុខនាងចំៗពេលណា ធ្វើឲ្យអារម្មណ៍នាងមិនដឹងជាហោះហើរទៅឯណាបាត់នោះឡើយ ព្រោះកែវភ្នែកគេមានមន្តស្នេហ៍ណាស់។

«អូនគិតរឿងរៀបការរបស់យើងមែនទេ?»

«អឹម!! អូនគិតច្រើនរឿងណាស់ បូកទាំងរឿងរៀបការនោះដែរ»

«មានរឿងផ្សេងឲ្យគិតដែរ?»

«គឺមាន តែរឿងរបស់យើងពីរនាក់នោះណា ព្រោះសុទ្ធតែជារឿងដែលគួរឲ្យគិតទាំងអស់នោះណា»

ប្រអប់ដៃរបស់គេឱបរឹតលើប្រាណកវិយាគេកាន់តែខ្លាំងជាងមុន ព្រមទាំងគិតថា រូបគេវិញបានត្រៀមចិត្តត្រៀមកាយរាប់ឆ្នាំមកហើយ នៅមិនអាចទ្រាំចិត្តមិនរំភើបចំពោះរឿងរ៉ាវដ៏សែនអាថ៌កំបាំងនេះមិនបានទាល់តែសោះ ចុះទម្រាំតែកវិយារបស់គេដែលនៅសុខៗបែរជាមកជួបបញ្ហាចម្លែកៗបែបនេះនោះ។

«តែពេលនេះយើងកំពុងតែមានក្តីសុខជាមួយគ្នាមែនទេ?»

«ចាស! ត្រូវហើយណា អូនមានក្តីសុខដែលបានស្រឡាញ់បង»

តែនាងស្រីស្រស់ រលមុខទៅក្នុងប្រអប់ដៃរបស់ស្វាមីជាទីស្រឡាញ់ មិនអាចទ្រាំបក្នុងប្រអប់ទ្រូងគេបានយូរឡើយ ព្រោះថា ដៃរបស់គេបានលូកលាន់

លើរាងកាយរបស់នាងធ្វើឲ្យនាងមិនអាចនៅស្ងៀម។ គេមិនហត់ខ្លះទេអី តែស្រីស្រស់ក៏ងើបមុខឡើងឲ្យគេថើបលូកលាន់ដោយចិត្តប៉ងប្រាថ្នាដូចគ្នាដែរ ព្រោះនាងក៏មិនទាន់ហត់នឿយដែរនោះអី។

មាត់ផ្ទឹបលើគ្នា កែវភ្នែកមួយគូសម្លឹងគ្នាទៅវិញទៅមក ស្រីស្រស់ដូចជាអាចដឹងបានភ្លាមតែម្តងដោយសារតែបទពិសោធកន្លងមកថា ដល់ពេលដែលត្រូវភ្លក់រសជាតិស្នេហ៍នោះសាជាថ្មីហើយ ទោះបីជាយ៉ាងណាក៏នាងពិតជាចូលចិត្តរៀនល្បែងនេះពីស្វាមីថ្មីថ្មោងរបស់នាងដូចគ្នាដែរ។

«បងក៏មានក្តីសុខដែលបានស្រឡាញ់អូនដូចគ្នាដែរ»

សំឡេងត្រហេបត្រហបលាន់ឮនៅក្បែរៗត្រចៀករបស់នាង ព្រមទាំងបន្តមកជាមួយនូវបបូរមាត់ថើបមកលើមាត់នាងយ៉ាងពុះកញ្ជ្រោល គ្រាន់តែស្វាមីចាប់ផ្តើមតែបន្តិច ភរិយាក៏ចាប់ផ្តើមមិនខ្វីខ្វាសនរណាសោះឡើយនាង ប្រតិបត្តិដូចចិត្តប្រាថ្នា។

ស្វាមីរបស់នាងថើបគ្រប់ចន្លោះកន្លោះកន្លៀតព្រង់ដើមករបស់នាង ដៃទាំងសងខាងរបស់នាងបានលូកចូលទៅក្នុងអាវរបស់គេ ហើយអង្អែលចុះឡើងនៅលើផែនទ្រូងដ៏ធំរបស់គេ។ មើលទៅគេដូចជាដឹងចិត្តនាងអីចឹង គេក៏ដោះអាវចេញភ្លាម ដោយមាត់របស់គេមិនព្រមដកចេញពីរាងកាយរបស់ភរិយាឡើយ ដៃរបស់គេក៏មិនព្រមនៅស្ងៀមដូចគ្នាដែរ គេជួយដោះអាវរបស់នាងចេញទាំងក្នុង និងក្រៅ ភ្លាមនោះមាត់របស់គេក៏បឺតជញ្ជក់កំពូលភ្នំរបស់នាងយ៉ាងតក់ក្រហល់។

គេកោតសរសើរភរិយារបស់គេដែលបានតបស្នងមកគេវិញយ៉ាងស្ទាត់ជំនាញដូចគ្នា គេធ្វើសកម្មភាពលើគ្រែយ៉ាងសកម្ម គេដកចុះដកឡើង ហើយស្រីស្រស់ក៏តបស្នងគេវិញយ៉ាងអស់ក្បាច់ដូចស្វាមីនាងដែរ។

“អូនពិតជាប្រពៃណាស់ អូនដឹងដែរទេ ?”

គេបន្តសកម្មភាពនោះយ៉ាងកក្រើកគ្រែអារម្មណ៍មិនដឹងជាទៅដល់ឋានសួគ៌ឯណានោះឡើយ។ ភ្លាមនោះគេចាប់នាងប្តូរក្បាច់យ៉ាងជំនាញ គេចាប់នាង



ទៅចុងគ្រែ ហើយក៏បន្តសកម្មភាពនោះយ៉ាងញាប់ដៃញាប់ជើង រហូតដល់មានសំឡេងស្រែកថ្ងូរចេញពីភរិយារបស់គេ។

«អូននឹងពេញចិត្តវា»

ស្រីស្រស់ត្រូវតែជឿស្វាមី ព្រោះថាពេលនេះនាងកំពុងតែចង់រៀនសូត្រពីសកម្មភាពលើគ្រែជាមួយមនុស្សប្រុសដែលនាងស្រឡាញ់ស្មើជីវិតជាងភាពអៀនខ្មាសនោះណា នាងមានអារម្មណ៍ថា ប្លែកថ្មីនៅពេលដែលគេបានបង្រៀនក្បាច់ថ្មីៗដល់នាង ពិតជាជក់ចិត្តមែនទែនតែម្តងចំពោះសកម្មភាពលើគ្រែដែលគេផ្តល់ឲ្យនាងបែបនេះ គេនៅតែបន្តសកម្មភាពនោះជារឿយៗ។

«អូ!! ភរិយាបងពិតជាអស្ចារ្យមែនទែនតែម្តង អូនទាំងស្អាតទាំងសិចស៊ីមានដឹងខ្លួនដែរទេ ?»

ឈឹតខាមែន ថើបទាំងអស់នៃរាងកាយរបស់នាង ព្រមទាំងល្បួងលោមដែលពេលនេះកំពុងតែត្រហេបត្រហបនៅខាងក្រោមទ្រូងរបស់ស្វាមី។

«បងពិតជាសប្បាយចិត្តណាស់ដែលអូនមានក្តីសុខ»

មើលនោះ គេនៅតែនិយាយពីសកម្មភាពលើគ្រែរបស់គេឲ្យនាងខ្មាសអៀនដល់ណាទៀត មិនដឹងទេថា នាងកំពុងតែខ្មាសមិនដឹងយកមុខទៅទុកនៅកន្លែងណាទេ ក្រៅពីមានក្តីសុខហើយថែមទាំងហត់ខ្លាំងទៀតផងណា នេះគេបានស៊ីកម្លាំងញើសឈាមនាងឬយ៉ាងណាទៀត! ដែលគេប្រគល់តួនាទីឲ្យនាងជាអ្នកធ្វើនោះ តែគេក៏ជាអ្នកធ្វើនាងច្រើនដងហើយនោះដែរ នាងជាភរិយាត្រូវតែជួយស្វាមីហើយទើបបាន នាងគិត ហើយក៏ទ្រុបមុខនៅក្រោមទ្រូងរបស់ស្វាមីយ៉ាងមានក្តីសុខ។

**ចេតិយ៍របស់ត្រកូល អ៊ីមភ័មបាហាម កំពុងតែបាន ឈឹតខាមែន ជាអ្នក**ទទួលស្នងត្រកូលព្រមជាមួយនិងភរិយារបស់គេ ពួកគេទាំងពីរនាក់កាន់ធូប-ទៀន ព្រមទាំងផ្កាដែលជាគ្រឿងសម្រាប់ធ្វើបុណ្យដាក់ទានដាក់ពីមុខចេតិយ៍។

«មិនគួរឲ្យជឿទាល់តែសោះថា បុព្វបុរសរបស់បងបានមកស្តូបរួមចេតិយ៍

ជាមួយគ្នានៅទីនេះសោះ»

«ត្រកូលដើមរបស់បងនោះវង្វេងឆ្ងាយអន្លាយណាស់បានយកមកប្រមូលចេតិយ៍ជាមួយគ្នានៅទីនេះ តែតាមដែលបងដឹងខ្លះៗមក គឺចេតិយ៍មួយនេះបានផ្ទុកឆ្អឹងរបស់ព្រះនាង ទេមីន និងព្រះស្វាមីរបស់ព្រះនាងជាលើកដំបូង មិនមានព្រះសពរបស់ក្សត្រអង្គណាឡើយ»

«រូបភាពនោះគឺជាបុព្វបុរសរបស់បងមែនទេ ?»

«ត្រូវហើយ ! កាលសម័យនោះគេបានប្រើរូបភាពជាគំនូរមិនមានចម្លងពិតនោះឡើយ»

«បងជាមួយនិងខ្ញុំ អាស !! មិនមែនទេព្រះនាង ទេមីន និងព្រះស្វាមីរបស់ព្រះនាងនៅត្រង់ណាដែរទៅ ?»

«ខាងនេះណា បងនឹងនាំអូនទៅគោរព»

គោរពខ្លួនឯងឬ ! នាងគិតក្នុងចិត្ត ហើយដៃរឹងមាំរបស់ស្វាមីបានកៀកកនាងទៅកាន់ចេតិយ៍មួយទៀតដែលនៅខាងក្នុងបន្តិចដោយនាងមិនមានអារម្មណ៍ខ្លាចចំពោះផ្នូរនៅតាមផ្លូវយ៉ាងហូរហែនោះទាល់តែសោះ។

«នេះនោះអី មឈូសរបស់ព្រះនាង ទេមីន»

«ហេតុអីក៏មកនៅខាងក្រៅមិននៅជាមួយនឹងចេតិយ៍គេដែរទេ ?»

«លោកតារបស់បង បានផ្តល់វិចិត្រកររមកជីកមឈូសដើម្បីយកគ្រឿងប្រដាប់ដែលកប់ទុកក្នុងមឈូសរបស់ព្រះនាង ក្រោយពីនោះមកយើងក៏បានគ្រឿងប្រដាប់យ៉ាងហូរហែមកដាក់ក្នុងសារមន្ទីរដូចដែលបានឃើញនេះ»

យ៉ុនហ៊ី ឈរមើលទៅកាន់មឈូសរបស់ព្រះនាងទេមីនដែលធ្វើឡើងពីមាសសុទ្ធគួរឲ្យទាក់ទាញ ព្រោះនាងគឺជាសិស្សបុរាណវិទ្យានោះអី ហើយមឈូសនោះក៏ជារបស់នាង អាសសស ! មិនមែនទេ គឺជាមឈូសរបស់ព្រះនាង ទេមីនកាលពីជាតិមុននោះណា។

«មើលរូបចុះ ដូចជាព្រះនាងទេមីនអីចឹង»

«ត្រូវហើយពិតជាស្រស់ស្អាតណាស់ ចំណែកឯមួយនេះគឺជារបស់ព្រះ



ស្វាមីរបស់ព្រះនាង»

ឈើតខាមែន ប្រញាប់និយាយហើយចង្អុលទៅកាន់មឈូសដែលនៅក្បែរមឈូសរបស់ព្រះនាង ទេមីន។

«ជារបស់បងមែនទេ ?»

«បងមិនទាន់ស្លាប់ តើជារបស់បងយ៉ាងម៉េចទៅ ?»

«អ៎ ! ជារបស់បងកាលពីជាតិមុននោះអី»

ឈើតខាមែន ញញឹមចំពោះពាក្យសម្តីរបស់ភរិយាគេ គឺពិតដូចដែលគេនិយាយមែននោះណា គេពិតជាសប្បាយចិត្តណាស់ដែលនាងលែងខ្លាចខ្មោចព្រមទាំងរឿងអាថ៌កំបាំងអីតទៅទៀតនោះ វាហាក់ដូចជាផ្ទុយស្រឡះពីថ្ងៃដែលគេជួបនាងលើកដំបូង។ នៅពេលនោះគេក៏នឹកឃើញអាការខ្លាចខ្មោចរបស់ភរិយាគេ ស្នាមញញឹមក៏លេចចេញលើមុខរបស់គេ។

«បងសើចអីគេ ?»

«គឺសើចអូនហ្នឹងឯងដែលខ្លាចខ្មោច»

«ម៉េចក៏សើច ? មិនល្អទេឬដែលអូនលែងខ្លាចនោះ !»

«ចុះបើមិនមានអ្នកណាមកឲ្យបងឱបនោះណា»

«នេះបងនិយាយលេងជាមួយអូនទៀតហើយ !»

មែនហ្នឹងណា ប្រហែលជាអាការខ្លាចខ្មោចនោះអាក្រក់មើលណាស់ហើយគេមកលលេងជាមួយនាងធ្វើអីដែរទៅ គួរឲ្យខ្មាសណាស់ រំពេចនោះផ្ទៃមុខស្រស់ស្អាតនោះបែរជាក្រញូវឡើងភ្លាម។

«អូនមិនកំប្លែងជាមួយបងនោះទេ ដែលយករឿងគួរឲ្យខ្មាសអៀនរបស់គេមកលលេងនោះ»

«អ្នកណាថាដែរទៅ បងថាគួរឲ្យស្រឡាញ់ណាស់ ពេលអូនខ្លាចខ្មោចនោះ»

ត្រូវហើយពេលដែលនាងខ្លាចខ្មោចពេលណា នាងត្រូវស្រាតខោអាវហើយឲ្យគេលួកស្ទាបបានគ្រប់ពេលនោះណា គេមិនចូលចិត្តយ៉ាងម៉េចទៅ !

«អត់ទេ ! អូនមិនចង់និយាយជាមួយបងទៀតនោះឡើយ អូននឹងទៅ

សារមន្ទីរព្រះនាងទេមីនវិញ»

«អូនមើលវារាល់ថ្ងៃមិនធុញខ្លះទេអី ?»

«បើបងធុញមិនបាច់ទៅនោះទេ អូនទៅម្នាក់ឯងក៏បានដែរ»

«អ្នកណាថា បងធុញដែរទៅ បងនឹងទៅកំដរណា»

«ព្រោះអូនលែងខ្លាចខ្មោចហើយនោះណា មិនចាំបាច់បងទៅកំដរទេ»

«បងចង់នៅជិតភរិយានោះណា»

ឈីតខាមែន មិនខ្វីខ្វល់ពីពាក្យសម្ដីរបស់ភរិយាគេឡើយ គេឱបត្រកងភរិយារបស់គេដើរទៅកាន់សារមន្ទីររបស់ព្រះនាងទេមីនភ្លាម។

ផ្នែកខាងក្នុងសារមន្ទីរដែលធ្លាប់ជាមានរឿងរហូតនោះ ពេលនេះបែរជាមានភាពស្រស់ស្រាយសម្រាប់ស្វាមីភរិយាថ្មីថ្មោងទុករំឭកពីអនុស្សាវរីយ៍ចាស់ដែលគួរឲ្យខ្លាចរន្ធត់នោះ។

ឈីតខាមែន ឱបភរិយាដែលកំពុងតែស្ងួងអារម្មណ៍ជាមួយនឹងគ្រឿងប្រដាប់របស់ព្រះនាង ទេមីន ដៃទាំងពីររបស់នាងក៏ឱបដៃស្វាមីវិញយ៉ាង ស្និទ្ធស្នាលព្រមទាំងផ្អែមល្ហែមដែរ។ ដៃម្ខាងលើកខ្សែកមានបន្តោងរូបសត្វស្លាបត្រដាងស្លាបជារាងបេះដូង មកឱបនឹងដើមទ្រូង រួចនិយាយ។

«គ្រឿងប្រដាប់ទាំងនេះគឺបងជាអ្នកធ្វើជូនអូនកាលពីជាតិមុន អូននឹងថែរក្សាថ្នាក់ថ្នមវាឲ្យល្អតែម្ដង»

«បងនឹងមើលថែ និងថ្នាក់ថ្នមអូនឲ្យល្អដូចគ្នាដែរណា»

ពួកគេទាំងពីរនាក់មើលមុខគ្នា ញញឹមដាក់គ្នាយ៉ាងមានក្ដីសុខ ម្នាក់ៗយល់ចិត្តយល់ថ្លើមគ្នា ព្រមទាំងគិតថា ការដែលបានស្គាល់គ្នារយៈពេលខ្លីមិនមែនជាឧបសគ្គមករារាំងស្នេហាមិនឲ្យកើតមានឡើងចំពោះស្នេហាយើងទាំងពីរបានឡើយ ព្រោះថាគេ និងនាងបានក្លាយជាគូនឹងគ្នាតាំងពីជាតិមុនមកម្ល៉េះ ហើយនឹងរួមរស់ជាមួយគ្នារៀងរហូត។

21-11-2015

( ចប់ )



www.srolanhkhmer.com